ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ការស្ថាបនាមជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍
- លិខិតផ្ញើជូន ខៀវ សំផន

[illegible]

លេខ៥០ ខែ កុម្ភៈ ឆ្នាំ២០០៤

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៥០ ខែកុម្ភៈ ឆ្នាំ២០០៤


## មាតិកា


◆ សំបុត្រៈ ការស្ដាបនាមជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍......... ១

**ផ្នែកឯកសារ**

◆ ដូ ដេត ហៅ ស៊ី លេខាភូមិភាគបស្ចិម.................................. ៤

◆ របាយការណ៍ពាណិជ្ជកម្មក្រៅប្រទេសឆ្នាំ១៩៧៥ ....................... ៨

◆ បញ្ជីឈ្មោះជនរងគ្រោះនៅមន្ទីរ ស-២១ ................................. ៩

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ នេះមិនមែនជាកម្មពៀរ.................................................... ១១

◆ ជឿថាជាការពិត............................................................. ១៥

◆ រស់ដើម្បីកូន................................................................. ១៧

◆ ប្រធានាធិបតី ជីមមី ខាធ័រៈ សិទ្ធិមនុស្ស និង កម្ពុជា............. ២០

◆ គួនាទីសិល្បៈនៅក្នុងដំណើរការផ្សះផ្សាជាតិនៅកម្ពុជា............. ៣១

**ផ្នែកច្បាប់**

◆ ឧក្រិដ្ឋកម្មនិងការរំលោភសិទ្ធិមនុស្សនៅឆេចឆ្នី........................ ៤៧

**វេទិកាពិភាក្សាសាធារណៈ**

◆ ដំណោះស្រាយក្រោយជម្លោះនៅប្រទេសសេរ៉ាឡេអូន............ ៥០

**ទំព័រស្វែងរកគ្រួសារ**

◆ លិខិតផ្ញើជូន ខៀវ សំផន ..............................................៥៦

◆ កូនអត់ឪ........................................................................៥៨

◆ ភ្លើងគំនុំដែលមិនអាចបំភ្លេចបាន.......................................៦០



ញ៉ៀប ហូ


វិចិត្រករៈ ប៊ូ ម៉េង (អតីតអ្នកទោសនៅមន្ទីរ ស-២១)


**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតក្របមុខដោយ ហេង ស៊ីនិត

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និង សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នេរលេខនេះ** យិន នាន, ប៉ាង ពីរីន, គីម សុដានី, ហឿ សេធុល, ឆេង រ៉េង, អៀ ម៉េងទ្រី, ប្រាក់ ទុន្នី, ហ៊ុយ វណ្ណៈ, ខេនតុន ក្លៃម័រ, អូឡិច អូឡុហ្
**អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, ផាត រចនា **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងៈ** ស្វួ ប៊ុនស៊ូ **អ្នកបកប្រែៈ** អេង កុកថាយ
**និពន្ធនាយកខុទ្ទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

*សំបុត្រៈ*

# ការស្ថាបនាមជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍

មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវតែស្វែងរកខ្លួនឯងអំពីតួនាទីរបស់ខ្លួនចំពោះអនាគតប្រទេសកម្ពុជា ប្រសិនបើតុលាការខ្មែរក្រហមមិនមានដំណើរការទេនោះ ។ តើការខំប្រឹងប្រែងប្រមូលឯកសារអស់រយៈពេលជាច្រើនឆ្នាំមកនេះនឹងក្លាយទៅជាអត់ន័យឬយ៉ាងដូចម្តេច? នៅក្នុងប្រទេសមួយដែលប្រើប្រាស់រូបថតទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យតែពីរបីសន្លឹកនៅក្នុងសៀវភៅប្រវត្តិវិទ្យាសម្រាប់ថ្នាក់វិទ្យាល័យ ហើយជាប្រទេសដែលក្មេងជំនាន់ក្រោយមិនអាចជឿថាមានមនុស្សរាប់លាននាក់បានស្លាប់បាត់បង់ជីវិតនៅក្នុងសម័យនោះ តើការចងចាំអំពើប្រល័យពូជសាសន៍កម្ពុជានឹងអាចឋិតថេរបានរយៈកាលមួយឬពីរជំនាន់ដែរឬទេ? តើការធ្វើដំណើរឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យដែលកម្ពុជាកំពុងធ្វើ នឹងបន្តដោយគ្មានមជ្ឈមណ្ឌលឯកសារកម្ពុជានិងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតដែលកំពុងដើរតួស្រដៀងទៅនឹងគណៈកម្មការស្វែងរកការពិត បានដែរឬទេ?



គំនូរព្រាងអគារមជ្ឈមណ្ឌលឯកសារកម្ពុជាលើកទី២

ទោះបីជាមានការពិបាកក្នុងការទស្សន៍ទាយអំពីដំណើរនៃព្រឹត្តិការណ៍ឲ្យបានច្បាស់លាស់ក៏ដោយ ក៏យើងយល់ថា ចម្លើយទៅនឹងសំណួរនីមួយៗខាងលើគឺទំនងជា «ទេ» ។ ដូច្នេះយើងបានសម្រេចចិត្តថា មជ្ឈមណ្ឌលឯកសារកម្ពុជាចាំបាច់ត្រូវតែស្វែងរកការគាំទ្រចំពោះការបង្កើតមជ្ឈមណ្ឌលអចិន្ត្រៃយ៍មួយ ។ មជ្ឈមណ្ឌលនេះនឹងបន្តពង្រីកតួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងការប្រមូលនិងចែកចាយឯកសារ ជំរុញដល់ដំណើរការប្រទាក់ក្រឡាគ្នានៃការផ្សះផ្សានិងការកសាងសង្គមប្រជាធិបតេយ្យ ផ្តល់នូវការប្រឹក្សាយោបល់ និងជាឧទាហរណ៍សម្រាប់ប្រទេសផ្សេងទៀតដែលបានឆ្លងកាត់ការរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរដូចគ្នា ។

បេសកកម្មមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅពេលអនាគតគឺបន្តការងារប្រមូលនិងចងក្រងឯកសារទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឯកសារដែលយើងបានប្រមូលកន្លងមក ហើយនឹងបន្តប្រមូល នឹងក្លាយទៅជាឃ្លាំងពត៌មានដ៏មានតម្លៃសម្រាប់បញ្ញាជន និងសំខាន់ជាងនេះគឺសម្រាប់អនាគតប្រវត្តិវិទូកម្ពុជា ។ តាមរយៈការប្រើប្រាស់ជំនាញឯកទេសខាងប្រវត្តិសាស្ត្រខ្មែរក្រហមជាមូលដ្ឋាន យើងមានតួនាទីក្នុងការអភិវឌ្ឍខ្លួនឲ្យទៅជាអង្គភាពដ៏ទូលំទូលាយមួយដែលគ្របដណ្តប់ទៅលើសកម្មភាពស្រាវជ្រាវកម្មវិធីសម្រាប់ការអប់រំ ការដើរតួជាសារមន្ទីរ និងការហ្វឹកហ្វឺនដល់អ្នកដែលមានវិជ្ជាជីវៈនៃ

*សង្គមស៊ីវិល អ្នកសិក្សាស្រាវជ្រាវវ័យក្មេង និងសិស្សានុសិស្ស ។ មជ្ឈមណ្ឌលអចិន្ត្រៃយ៍របស់យើងនឹងក្លាយទៅជាមណ្ឌលនៃការអប់រំកូនខ្មែរជំនាន់ក្រោយថែមទៀត ។*

*បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាភស្តុតាងបញ្ជាក់អំពីអ្វីដែលអាចធ្វើបាន ដើម្បីធានាថាប្រជាជនកម្ពុជាមិនបដិសេធនិងមិនបំភ្លេចប្រវត្តិសាស្ត្ររបស់ខ្លួនឡើយ ។ បុគ្គលិកទាំងអស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានអាយុជាមធ្យម២៥ឆ្នាំ បានចាប់ផ្តើមចូលបម្រើការងារជាអ្នកស្ម័គ្រចិត្ត ។ ក្រោយពីបានសិក្សាអំពីប្រវត្តិរបបកម្ពុជាប្រជាធិបតេយ្យ ស្តាប់ការរៀបរាប់របស់អ្នកនៅរស់ពីរបបនេះ ហើយបំពេញការងារនៅក្នុងមជ្ឈដ្ឋានមួយដែលជំរុញឲ្យមានការត្រិះរិះពិចារណា និងការស៊ើបអង្កេតប្រកបដោយគោលដៅច្បាស់លាស់ យើងបានសង្កេតឃើញពន្លកចំណេះវិជ្ជាដុះឡើងនៅក្នុងខ្លួនបុគ្គលិកម្នាក់ៗ ។ បុគ្គលិករបស់យើងបានលះបង់ជាលក្ខណៈបុគ្គលជាច្រើនចំណុច ដូចជាការចំណាយពេលទៅបម្រើការងារឆ្ងាយពីគ្រួសារ ល័ក្ខខ័ណ្ឌការងារលំបាកនៅតាមតំបន់ដាច់ស្រយាល និងការលះបង់មិនជ្រើសយកការងារនៅក្នុងអង្គភាពផ្សេងដែលមានប្រាក់បៀវត្សរ៍ខ្ពស់ជាង ។ បុគ្គលិកយើងបានលះបង់បែបនេះក្នុងគោលបំណងចងក្រងជាឯកសារប្រវត្តិសាស្ត្រនូវអ្វីដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយធានាថាប្រវត្តិសាស្ត្រនេះនៅតែមានភាពរស់រវើកជានិច្ចនៅក្នុងការចងចាំរបស់ប្រជាជនខ្មែរជំនាន់ក្រោយ ។*

*នៅក្នុងឆ្នាំ២០០៣កន្លងទៅ បុគ្គលិកចំនួនបួនរូបបានទទួលអាហារូបករណ៍ទៅសិក្សានៅឯបរទេសខាងផ្នែកសន្តិភាពនិងការផ្សះផ្សា ច្បាប់សិទ្ធិមនុស្ស និង ទេសចរណ៍និងសារមន្ទីរ ។ បុគ្គលិកមួយរូបទៀតកំពុងតែសិក្សាយកសញ្ញាប័ត្រថ្នាក់បរិញ្ញាប័ត្រនៅក្នុងប្រទេស ។ កាលពីឆ្នាំមុន បុគ្គលិករូបនេះបានចេញផ្សាយសៀវភៅទីមួយរបស់ខ្លួនដែលកំពុងតែត្រូវបានប្រើប្រាស់ជាឯកសារយោងនៅតាមថ្នាក់រៀននៅមហាវិទ្យាល័យផ្សេងៗនៅសហរដ្ឋអាមេរិកនិងប្រទេសម៉ាឡេស៊ី ។ យើងជឿជាក់ថា យើងប្រាកដជាអាចបណ្តុះឲ្យមានសន្ទុះសិក្សាដូចគ្នាដល់កូនខ្មែរជំនាន់ក្រោយទៀត ។ គឺកូនខ្មែរប្រុសស្រីទាំងនេះហើយដែលជាអ្នករក្សាអណ្តាតភ្លើងនៃការចងចាំមិនឲ្យរលត់ និងធ្វើកិច្ចការដើម្បីធានាថាអំពើប្រល័យពូជសាសន៍នឹងមិនកើតឡើងជាថ្មីម្តងទៀតនៅក្នុងប្រទេសកម្ពុជា ។*

*មានភស្តុតាងបញ្ជាក់ថា កិច្ចប្រឹងប្រែងរបស់យើងឲ្យមានការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា កំពុងតែចេញផ្លែផ្កា ។ នៅក្នុងប្រទេសមួយដែលអ្នកភូមិជងរបងជាមួយអាចជាអតីតខ្មែរក្រហមដែលធ្លាប់បានធ្វើទារុណកម្មឬសម្លាប់សមាជិកគ្រួសាររបស់ប្រជាជនរស់នៅជិតខាង ការផ្សះផ្សាមិនមែនជាការណ៍ដែលងាយនឹងសម្រេចបានឡើយ ។ តាមរយៈការងារតាមមូលដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្ហាញថា កម្មាភិបាលខ្មែរក្រហមមានការភិតភ័យនិងធ្លាប់រងទុក្ខវេទនាដូចជនរងគ្រោះដែរ ហើយបច្ចុប្បន្នកំពុងតែមានវិប្បដិសារីចំពោះទង្វើរបស់ខ្លួន ។ ប្រជាជនកម្ពុជាកំពុងតែចាប់ផ្តើមសង្កេតឃើញនូវចំណុចរួមមួយរបស់មនុស្សជាតិដែលបង្រួបបង្រួមជនរងគ្រោះជាមួយអតីតជនដៃដល់ ។ មនុស្សជាច្រើនលែងមើលឃើញកម្មាភិបាលថ្នាក់ទាបជាជនកំណាចទៀតហើយ ហើយកំពុងតែធ្វើដំណើរតាមវិធីមួយឆ្ពោះទៅរកភាពអត់ឱន ។*

*ជាក់ស្តែង បុរសម្នាក់ឈ្មោះ អ៊ិន ហៀង រស់នៅខេត្តស្វាយរៀង បានផ្ញើលិខិតមួយមកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលក្នុងលិខិតនោះបានសរសេរថា “ខ្ញុំមានកិត្តិយសជម្រាបជូនលោកនាយកថា បុរសឈ្មោះ ទិត្យ យុត គឺជាគណៈឃុំអង់តាសូរនៅក្នុងរបបខ្មែរក្រហម... ។ ថ្វីដ្បិតតែគាត់មានតំណែងចាត់តាំងឡើងដោយរបបនេះមែន តែគាត់ពុំត្រូវបានប្រជាជនស្អប់ទេ ។ គាត់តែងតែបានការពារប្រជាជន ហើយពុំសូវគោរពអង្គការចាត់តាំង ដោយសារតែមានមនោសញ្ចេតនាជាមួយប្រជាជនច្រើន...” ។*

*លិខិតមួយទៀតដែលផ្ញើមកពីប្រជាជននៅក្នុងភូមិមួយក្នុងខេត្តតាកែវ ក្រោយពីទស្សនាវដ្តីស្វែងរកការពិតបានចេញផ្សាយប្រវត្តិរូបរបស់ គឹម ទន ដែលជាអតីតអ្នកសួរចម្លើយមួយរូបនៅគុកទួលស្លែង ។ អ្នកភូមិទាំងនោះបានភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយបានដឹងថា គឹម ទន ដែលធ្លាប់រស់នៅក្នុងភូមិជាមួយគ្នា និងជាប្រជាពលរដ្ឋស្លូតត្រង់មួយរូប គឺជាជនដៃដល់ម្នាក់នៅក្នុងរបប*

កម្ពុជាប្រជាធិបតេយ្យ ។ អ្នកភូមិបានថ្លែងអំណរគុណចំពោះទស្សនាវដ្តីស្វែងរកការពិត សម្រាប់ការផ្សព្វផ្សាយការពិតដែលជាជំនួយដល់គាត់ក្នុងការធ្វើដំណើរឆ្ពោះទៅរកការយល់ដឹងកាន់តែច្បាស់អំពីរបបខ្មែរក្រហម និងក្នុងការធ្វើឲ្យអស់ចិត្តនិងការផ្សះផ្សា ។

លើសពីនេះ តាមរយៈការជួយទ្រទ្រង់សិទ្ធិមនុស្សនិងការទទួលខុសត្រូវរបស់យើង មជ្ឈមណ្ឌលឯកសារកម្ពុជាបានក្លាយទៅជាអង្គភាពនាំមុខក្នុងការកសាងប្រជាធិបតេយ្យភាពនៅក្នុងប្រទេសកម្ពុជា ។ កម្មវិធីអប់រំ ទស្សនាវដ្តីប្រចាំខែ ការបកប្រែសៀវភៅនិងការបោះពុម្ពផ្សាយ វគ្គហ្វឹកហ្វឺនផ្នែកច្បាប់ និងសម្ភាសន៍ជាច្រើនពាន់ករណីដែលយើងបានធ្វើជារៀងរាល់ឆ្នាំបានផ្តល់លទ្ធភាពឲ្យយើងជួយជំរុញឲ្យមានការទទួលខុសត្រូវខាងផ្នែកនយោបាយនិងការគ្រប់គ្រងរដ្ឋតាមបែបប្រជាធិបតេយ្យយ៉ាងមានប្រសិទ្ធភាព ។ គម្រោងការថ្មីមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានឈ្មោះថា "គម្រោងការឯកសារមានជីវិត" នឹងនាំប្រជាជនកម្ពុជានៅតាមជនបទរាប់រយនាក់ឲ្យចូលរួមនៅក្នុងដំណើរការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហម ហើយនឹងផ្តល់ដល់អ្នកទាំងអស់នូវសំឡេងមួយនៅក្នុងដំណើរការកសាងប្រទេសរបស់ខ្លួន ។ តាមរយៈការធ្វើដូចនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា អ្នកចូលរួមទាំងនោះនិងអ្នកស្រុកអ្នកភូមិផ្សេងទៀតដែលទទួលការណែនាំបន្តពីអ្នកចូលរួមដោយផ្ទាល់ នឹងចាប់ផ្តើមកសាងលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជាពីក្រោមឡើងលើ ។ម្យ៉ាងវិញទៀត តាមរយៈ"បន្ទប់ព័ត៌មានសាធារណៈ"ថ្មីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា យើងនឹងទាក់ទាញសាធារណជនឲ្យចូលរួមនៅក្នុងការពិភាក្សាបែបស្ថាបនាអំពីសិទ្ធិមនុស្សនិងរដ្ឋបាលបែបប្រជាធិបតេយ្យដែលមានការទទួលខុសត្រូវ ។

ការក្លាយខ្លួនជាមជ្ឈមណ្ឌលអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា មិនត្រឹមតែមានសារប្រយោជន៍ចំពោះប្រទេសកម្ពុជាប៉ុណ្ណោះទេ មជ្ឈមណ្ឌលអចិន្ត្រៃយ៍នេះនឹងក្លាយទៅជាគំរូមួយសម្រាប់ការជំរុញឲ្យមានការទទួលខុសត្រូវនៅក្នុងរបបនយោបាយសម័យអន្តរកាលឬកំពុងរីកលូតលាស់នៃប្រទេសជាច្រើន ។ បច្ចុប្បន្នយើងកំពុងតែផ្តល់ប្រឹក្សាអំពីកិច្ចខិតខំប្រឹងប្រែងប្រមូលឯកសារនៅអឺរ៉ុបខាងកើត ភូមា អ៊ីរ៉ាក់ និងប្រទេសដទៃទៀត ។ ក្នុងខណៈដែលសកម្មភាពនិងកេរ្តិ៍ឈ្មោះរបស់យើងកំពុងរីកដុះដាល យើងនៅតែបន្តទាមទារឲ្យមានការណែនាំបន្ថែម ។ មជ្ឈមណ្ឌលអចិន្ត្រៃយ៍នឹងអាចផ្តល់ប្រយោជន៍ដល់មនុស្សទាំងអស់ដែលព្យាយាមធ្វើដំណើរទៅមុខឲ្យផុតពីការរំលោភបំពានផ្នែកសិទ្ធិមនុស្សពីអតីតកាល ឆ្ពោះទៅកាន់ប្រជាធិបតេយ្យភាពក្នុងសង្គមកាន់តែរឹងមាំនៅក្នុងអនាគតកាលដែលគាត់តែងដោយវិធាននៃច្បាប់ ។

ការបង្កើតប្រព័ន្ធប្រមូលនិងចងក្រងឯកសារដែលមានប្រសិទ្ធភាពនិងតម្លាភាព នឹងមានសារសំខាន់ចំពោះប្រទេសដែលបានទទួលរងការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ។ ប្រព័ន្ធបែបនេះនឹងជួយអាជ្ញាធររដ្ឋនៅក្នុងការបង្កើតតុលាការពិសេស និងនាំមកនូវការកាត់សេចក្តីដែលបំពេញតាមបទដ្ឋានអន្តរជាតិនៃច្បាប់ ។ ប្រព័ន្ធនេះនឹងផ្តល់សិទ្ធិឲ្យពលរដ្ឋសាមញ្ញតវ៉ា និងរួមចំណែកនៅក្នុងដំណើរការថ្មីនៃការពិភាក្សាបែបប្រជាធិបតេយ្យ ។ ការចងក្រងឯកសារដ៏សមស្របនឹងក្លាយជាមូលដ្ឋានសម្រាប់ការសរសេរនិងផ្សព្វផ្សាយប្រវត្តិសាស្ត្រដ៏ត្រឹមត្រូវ ។ ដូចដែលយើងបានឃើញនៅក្នុងប្រទេសកម្ពុជា សង្គមមួយដែលធ្លាប់ឆ្លងកាត់សង្គ្រាមរ៉ាំរ៉ៃមិនអាចគេចផុតពីស្រមោលនៃអតីតកាលរបស់ខ្លួនបានទេ លុះត្រាតែសង្គមនោះយល់ឲ្យបានច្បាស់អំពីមូលហេតុដែលនាំឲ្យមានភាពអន្ធកាល ។ បទពិសោធន៍ការងារនៅក្នុងប្រទេសកម្ពុជាបានប្រាប់យើងថា ការងារស្វែងរកការពិតនិងការទទួលខុសត្រូវ អាចក្លាយទៅជាបេសកកម្មគ្រឹះនៃការអភិវឌ្ឍសង្គមស៊ីវិល ។

តាមរយៈការស្ថាបនាឡើងវិញនូវព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដ៏ត្រឹមត្រូវ ការប្រឹងប្រែងទាមទាររកយុត្តិធម៌ដែលជាឱសថព្យាបាលដ៏សមស្រប និងការធ្វើការជារៀងរាល់ថ្ងៃដើម្បីសម្រេចឲ្យបាននូវសន្តិភាពនិងការផ្សះផ្សា មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលបំណងក្លាយខ្លួនជាគ្រឹះស្ថានដែលមនុស្សគ្រប់រូបអាចពឹងពាក់នៅក្នុងការធ្វើដំណើរទៅកាន់អនាគតកាន់តែរុងរឿង ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ជូ ជេត ហៅ ស៊ី លេខាភូមិភាគបស្ចិម

ជូ ជេត ហៅ ស៊ី គឺជាលេខាភូមិភាគបស្ចិមរបស់កម្ពុជាប្រជាធិបតេយ្យ ដែលត្រូវចាប់ខ្លួនឃុំឃាំងនៅមន្ទីរ ស-២១ នៅឆ្នាំ១៩៧៨ ។

ជូ ជេត មានឈ្មោះបដិវត្តន៍ ស៊ី ឪពុកឈ្មោះ យូ ជូ ម្តាយឈ្មោះ អ៊ិន ប៊ូ ។ ជេត មានតែពីរនាក់នឹងបងប្រុសឈ្មោះ ជូ ជា ដែលបានស្លាប់តាំងពីអាយុ២០ឆ្នាំ ។ ប្រពន្ធរបស់ ជេត ឈ្មោះ ណេន ឈ្មោះបដិវត្តន៍ លី ក្នុងរបបខ្មែរក្រហមមាននាទីជាលេខាស្រុកខដុក្ក តំបន់៣២ ភូមិភាគបស្ចិម ។

ជេត ចូលរៀននៅអាយុ៧ឆ្នាំ នៅវត្តបន្ទាយថ្មី ស្រុកព្រៃឈរ ខេត្តកំពង់ចាម ក្នុងសំណាក់លោកគ្រូ ណុន ។ អាយុ ១៥ឆ្នាំ ជេត បួសនេន ។ នៅឆ្នាំ១៩៣៨ ជេត ចេញទៅរៀនបាលីជាមួយអាចារ្យ កាន់ ឯល នៅវត្តរការកោង ។ ឆ្នាំ១៩៤០ ជេត រៀនថ្នាក់ទី៣ សាលាបាលីជាន់ខ្ពស់នៅវត្តកែវព្រះភ្លើង ភ្នំពេញ ។ ដោយសារនៅទីក្រុងភ្នំពេញមានការទម្លាក់គ្រាប់បែក ជេត ក៏ទៅរស់នៅស្រុកបារាយណ៍ ខេត្តកំពង់ធំ នៅឆ្នាំ១៩៤១ ហើយបានប្រឡងជាប់សាលាបារីវង់នៅទីនោះ ។ មួយរយៈក្រោយមក ជេត វិលមកភ្នំពេញដើម្បីប្រឡងចូលសាលាបាលីជាន់ខ្ពស់ ប៉ុន្តែប្រឡងមិនជាប់ក៏វិលទៅបង្រៀននៅកំពង់ធំវិញ ។ ឆ្នាំ១៩៤៩ ជេត ទៅខេត្តតាកែវរៀនបន្តផងនិងបង្រៀនព្រះសង្ឃផង ។ ឆ្នាំ១៩៥០ ជេត វិលមកសឹកនៅស្រុកកំណើត ។ បន្ទាប់ពីដើរលេងពីកន្លែងមួយទៅកន្លែងមួយ នៅខែមេសា ជេត បានចូលជាមួយទ័ព ចៅ យិន ហើយធ្វើដំណើរទៅប្រទេសវៀតណាមរៀននយោបាយជាមួយអាចារ្យហែមចៀវ ។

មួយឆ្នាំក្រោយមក គឺនៅថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៥១ ជេត បានចូលជាសមាជិកបក្សកុម្មុយនិស្តឥណ្ឌូចិន តាមរយៈយួនពីរនាក់គឺឈ្មោះ ទី ហុង និង កឹង ហើយត្រឡប់មកប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៥២ ។ ជេត រៀបការនៅឆ្នាំ១៩៥៤ ។

នៅខែកក្កដា ឆ្នាំ១៩៥៤ ជេត ធ្វើជាគណៈកម្មការចម្រុះប្រចាំខេត្តស្វាយរៀងជាមួយ ជ័យ សួន, កែវ មាស, ជី គឹមអាន, ស៊ាន អាន... និងស័ក្តិ៥យួនឈ្មោះ ថាញ់ ស៊ើន ។ ខែមេសា ឆ្នាំ១៩៥៥ ជេត វិលមកភ្នំពេញវិញ ធ្វើការនៅកាសែតប្រជាជនជាមួយ ប៉ែន យុត្តិ ។ កាសែតចេញផ្សាយបានតែមួយលេខគត់ នៅខែឧសភា រាជការចាប់ ជី គឹមអាន ដាក់គុក បុគ្គលិកកាសែតក៏ឆ្លេឆ្លាបាត់លំនឹង ចំណែក ជូ ជេត អស់សង្ឃឹម ឈប់ធ្វើអ្វីទាំងអស់ គិតតែដើរលេង ។ បន្ទាប់ពីថ្ងៃបោះឆ្នោតសកលតាមកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវនៅខែសីហាឆ្នាំ១៩៥៥ ប៉ែន យុត្តិ បង្កើតកាសែតថ្មីមួយទៀតឈ្មោះ ប្រជាជាតិ ហើយកាសែតថ្មីពីរទៀតក៏បានចាប់កំណើត គឺកាសែតឯកភាព និងមិត្តភាព ។ កាសែតឯកភាពមានចាងហ្វាងឈ្មោះ សឹម ជីងហាយ ។ ចុងឆ្នាំ១៩៥៦ រដ្ឋាភិបាលបានបិទដំណើរការកាសែតចម្រើនទាំង៤ ។

ឆ្នាំ១៩៥៨ ជេត បានចូលជាសមាជិកអង្គការ សេ.អ៊ី.អា តាមរយៈ ថាច់, ឆួន និង យ៉ា ហើយទទួលបានប្រាក់ខែ៤០០០ រៀល ។

បន្ទាប់ពីជ័យជម្នះទូទាំងប្រទេសរបស់បក្សកុម្មុយនិស្តកម្ពុជា ជេត បានបន្តទាក់ទងជាមួយ ទី កាម ដើម្បីបន្តការវាយដណ្តើមអំណាចពីបក្សកុម្មុយនិស្តកម្ពុជាតាមគម្រោងដែលខ្លួនបានរៀបចំធ្វើជាយូរមកហើយ ។ ក្រៅពី ទឹកាម, ជូ ជេត បានទាក់ទងប្រជុំការងារជាមួយថ្នាក់ដឹកនាំវៀតណាមដទៃទៀតដូចជា ធន់, ហាយសូ, ម៉ាយឡាំ, ទ្រឿង ជិញ, ដាំ វ៉ាន់ដុង, ឡេ យន់, យ៉ ផ្សៀនយ៉ាប់, ផៀន គាក់យុង, ង្វៀង ឌិកធន់, កុកមិញ ក្នុងផែនការវៀតណាមវាយលុកចូលប្រទេសកម្ពុជាដោយកម្លាំងយោធាដើម្បីដណ្តើមកម្ពុជាដាក់ជាសហព័ន្ធឥណ្ឌូចិន ។

ចាប់ពីឆ្នាំ១៩៧៥ ជូ ជេត បានធ្វើដំណើរគ្រប់ទីកន្លែងទូទាំងប្រទេសដើម្បីទាក់ទងការងាររក្សត់ ស្នើសម្ភារប្រើប្រាស់ និងពិនិត្យមើលសភាពការណ៍ទូទាំងប្រទេស ។ ឧទាហរណ៍ នៅខែមិថុនា ឆ្នាំ១៩៧៥ ជេត បានធ្វើដំណើរទៅខេត្តបាត់ដំបងដើម្បីសុំត្រាក់ទ័រ ម៉ាស៊ីនភ្លើង និងរបស់របរប្រើប្រាស់ខ្លះពី ញឹម (រស់

ញឹម លេខាភូមិភាគពាយ័ព្យ) និងឆ្លៀតពេលនោះពិនិត្យស្ថានភាពធ្វើស្រែនៅខេត្តកំពង់ឆ្នាំង ។ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ដេត បានធ្វើដំណើរទៅកោះកុងដើម្បីទៅមើលក្រុងខេមរភូមិន្ទ និងជួបប្រជុំជាមួយកងទ័ពវៀតណាមរៀបចំផែនការធ្វើរដ្ឋប្រហារផ្តួលរំលំរដ្ឋអំណាច ។ ក្រៅពីនោះ ដេត ក៏បានធ្វើដំណើរទៅទីកន្លែងជាច្រើនទៀតដូចជា ខេត្តកំពង់ចាម កំពង់ស្ពឺ តំបន់២៥ និងកោះកុងជាដើម ។

ខែកុម្ភៈ ឆ្នាំ១៩៧៦ មហាសន្និបាតមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជាលើកទី៤បានបើកនៅភ្នំពេញ ។ ការប្រជុំលើកនេះយកចិត្តទុកដាក់ជាសំខាន់ទៅលើការរៀបចំសង្គមនិយមនៅកម្ពុជា ឆ្លងលក្ខន្តិកៈថ្មីរបស់បក្ស និងគោលការណ៍ជាមូលដ្ឋាននៃបដិវត្តន៍សង្គមនិយម ។

ខែមីនា ឆ្នាំ១៩៧៦ ដេត បានទទួលផែនការរដ្ឋប្រហារមួយពី សោ ភឹម ។ ទទួលបានផែនការនេះនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៦ ដេត បានចាត់តាំងឲ្យ ធុច និង យ៉ា រៀបចំរដ្ឋប្រហារមួយដែលមានលក្ខណៈទូទាំងប្រទេស ។ រដ្ឋប្រហារនេះគឺធ្វើឡើងដោយមិនបាច់មានការបង្ហូរឈាមទូទាំងប្រទេសទេ គឺ÷

១) ចាត់តាំងយុវជនឲ្យត្រៀមបាញ់បង់ទី១និងទី២ក្នុងឱកាសមិទ្ទីងខួបឆ្នាំទី១នៃជ័យជម្នះ ។ ការងារនេះប្រគល់ឲ្យកងទ័ពរបស់ អឿន ជាអ្នកធ្វើ ។ ២) ចាត់ចុងភៅដាក់ថ្នាំបំពុលបងទី១និងទី២ ។ ៣) ចាត់តាំងយុវជននៅក្នុងជួរ ចក្រី បោកគ្រាប់បែកចូលវាំងដើម្បីបង្កឲ្យមានការភ្ញាក់ផ្អើល ។ ៤) គ្រប់កងកម្លាំងតាមមូលដ្ឋាននិងអគ្គភាពមន្ទីរយោធា ត្រូវប្រុងប្រៀបរង់ចាំទទួលជ័យជម្នះដោយសញ្ញាស៊ីរ៉ែនតាមវិទ្យុ ។

ថ្ងៃទី១៤ កន្លងផុតទៅ រហូតដល់ថ្ងៃទី១៧ក៏នៅតែមិនឮសញ្ញាណាមួយអំពីរដ្ឋប្រហារនៅភ្នំពេញ ។ បន្ទាប់ពីនោះមានពាក្យចចាមអារ៉ាមថា នៅថ្ងៃមិទ្ទីង កងសន្តិសុខចាប់បានយុទ្ធជនម្នាក់ស្ពាយកាំភ្លើងអាកាមួយដើមនិងកាទុសៀគ្រាប់ពេញខ្លួនដើរចូលទៅកន្លែងប្រារព្ធមិទ្ទីង ។ យុទ្ធជននោះនៅក្នុងកងពលរបស់ភាគឧត្តរ ។ ដេត ដឹងថាផែនការបានបរាជ័យហើយ ។

ខែឧសភា ឆ្នាំ១៩៧៦ ដេត ចូលដេកពេទ្យ ព-១៧ អស់រយៈពេលជាងកន្លះខែដោយសារតែជំងឺប្រមាត់ ។ នៅទីនោះដេត បានជួប សុទ្ធ ហើយបានដឹងថា ធុច, យ៉ា និង អឿន ត្រូវអង្គការចាប់ខ្លួន ។ សុទ្ធ ខ្លួនឯងក៏បារម្ភចំពោះសុវត្ថិភាពរបស់ខ្លួនជាខ្លាំង ។ បន្ទាប់ពីចំណាយពេលកន្លះខែនៅក្នុងមន្ទីរពេទ្យ ដេត បានទទួលការអនុញ្ញាតពីអង្គការឲ្យទៅព្យាបាលនៅប្រទេសចិន ។ នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៧៦ ដេត ចេញដំណើរទៅទីក្រុងប៉េកាំងជាមួយយុវជនពេទ្យម្នាក់ឈ្មោះ ប៊ូរ៉ាត ។ បន្ទាប់ពីពិនិត្យអាការរោគនៅប៉េកាំង ដេត ទៅព្យាបាលនៅខេត្តក័ងតុង ។ នៅប៉េកាំង ដេត បានជួបនឹង ភឹម ដែលបានទៅទីនោះតាំងពីដើមខែឧសភា ឆ្នាំ១៩៧៦ ។ ឆ្លងតាមការពិភាក្សារវាងអ្នកទាំងពីរ ភឹម នឹងរៀបចំផែនការបន្តទៀតដើម្បីធ្វើរដ្ឋប្រហារនៅឆ្នាំក្រោយៗទៀត ។ ភឹម និយាយថា មូលហេតុដែលបរាជ័យលើកមុនគឺដោយសារ ធុច និង យ៉ា ធ្វើការទាំងប្រថុយប្រថាន ។

ដេត វិលមកប្រទេសកម្ពុជាវិញនៅខែសីហា ឆ្នាំ១៩៧៦ ប៉ុន្តែជំងឺរបស់គាត់ពុំទាន់ជាសះស្បើយនៅឡើយទេ គាត់ត្រូវបន្តការព្យាបាលនៅពេទ្យ ព-១៧ ។ ក្រៅពីជំងឺប្រមាត់ ដេត ថែមទាំងមានជំងឺសរសៃប្រសាទនិងលើសឈាមទៀត ។ ខែមករា ឆ្នាំ១៩៧៧ រោគប្រមាត់របស់ ដេត ឈឺកាន់តែខ្លាំងឡើងៗ ។ ដេត មិនអាចចេញដើរតាមមូលដ្ឋានបានទៀតឡើយ គាត់សម្រាកនៅតែក្នុងមន្ទីរប៉ុណ្ណោះ ។ បន្ទាប់ពីចូលរួមសន្និបាតភាគរយៈពេល៣ថ្ងៃនៅខេត្តកំពង់ឆ្នាំង នៅខែកុម្ភៈ ឆ្នាំ១៩៧៧ ក្រោមអធិបតីភាពរបស់បងទី១ ដេត ចូលសម្រាកក្នុងមន្ទីរពេទ្យរហូត ។ ដេត បានសរសេរលិខិតស្នើសុំពេទ្យចិនមកពិនិត្យដល់ផ្ទះ ប៉ុន្តែគណៈ៨៧០ បានបដិសេធហើយនិយាយថា បើចង់ពិនិត្យត្រូវមកពិនិត្យនៅផ្ទះពេទ្យ ។ ដោយឈឺខ្លាំងពេកទ្រាំមិនបាន ដេត ក៏យល់ព្រមឲ្យពេទ្យវះកាត់នៅថ្ងៃទី៣ ខែមីនា ឆ្នាំ១៩៧៧ ហើយចំណាយពេលសម្រាកព្យាបាលក្នុងមន្ទីរពេទ្យរយៈពេល ២០ ថ្ងៃ ។

ដើមឆ្នាំ១៩៧៧ កម្លាំងខ្មែរដែលមកពីហាណូយជ្រួលច្របល់ចង់បះបោរឡើង ។ ដេត បានស្នើសុំឲ្យ ប៉ាល់ ដោះស្រាយបញ្ហានេះ ។ ប៉ាល់ សម្រេចថា ត្រូវដកមេធំៗចេញ ហើយរង់ចាំមើលប្រតិកម្មរបស់ថ្នាក់ក្រោម ។ ឈ្មោះ ឌុន ចង់កសម្លាប់ខ្លួនដោយដឹងថាមេធំៗដែលដកទៅនោះគឺត្រូវសម្លាប់ចោលអស់

ហើយ ។ កម្លាំងខាងហាណូយមិនស្ងប់ នៅតែបន្តជ្រួលច្របល់ រហូតដល់ត្រូវកម្ទេចអស់៨០នាក់ ។ បន្ទាប់ពីសភាពការណ៍ រពើតរពើងនេះ សន្តិសុខត្រូវបានពង្រឹងកាន់តែខ្លាំងជាងមុន ។ នៅតាមផ្លូវ គ្រប់រថយន្តទាំងអស់ត្រូវឆែកឆេរ ការធ្វើដំណើរ ត្រូវមានលិខិតអនុញ្ញាត បើមិនដូច្នោះទេនឹងត្រូវចាប់ឃុំខ្លួនសួរ ចម្លើយ ។ ជាក់ស្តែង មិត្ត សារុន លេខាតំបន់៣១ ត្រូវឃុំខ្លួន អស់មួយយប់និងឲ្យធ្វើដំណើរវិលត្រឡប់វិញ ព្រោះតែលិខិតគ្មានលេខ គ្មានត្រានិងហត្ថលេខាត្រឹមត្រូវ ។ ដេត បានយករឿងនេះជម្រាប ដល់បងទី២ (នួន ជា) ហើយសភាពការណ៍ក៏បានធូរស្រាលវិញ ។

ថ្ងៃមួយ ដេត បានទទួលលិខិតអញ្ជើញទៅទន្លេបិទដើម្បី ប្រជុំអំពីផែនការប្រចាំឆ្នាំ១៩៧៧ ។ អង្គប្រជុំចូលរួមដោយ ភឹម, ភួង, ញឹម, វី, ជា, ឃី ។ អង្គប្រជុំបានលើក៤ចំណុច ដែលត្រូវធ្វើដើម្បីសម្រេចផែនការដណ្តើមអំណាចគឺ ផ្នែកយោធា កងទ័ពវៀតណាមជួយវាយពីផ្លូវជាតិលេខ៧ ស្នួល ក្រចេះ ស្នាច់ តំបន់ស្វាយរៀង ព្រៃវែង តំបន់២៥ កោះអណ្តែត និងលក ។ នៅក្នុងប្រទេស កងទ័ពកម្ពុជាមានភារកិច្ចនាំកងទ័ពវៀតណាម វាយសម្រុក ។ កងទ័ពដែលនៅសមរភូមិក្រោយត្រូវក្រោកឡើង អុកឡុកតាមភូមិនិងសហករណ៍ ។ កងទ័ពជើងទឹកត្រូវត្រៀម វាយបំផ្លាញកំពង់ផែរបស់សេនាធិការ ។ កងទ័ពខាងពាយ័ព្យត្រូវ ទាក់ទងកម្លាំងរបស់អ៊ិនតាំប៊្ងថៃ ដើម្បីវាយលុកចូលឲ្យដល់ខេត្ត កំពង់ឆ្នាំង ។ កងទ័ពខាងព្រះវិហារត្រូវទាក់ទងនឹងកម្លាំងខ្មែរស ប្ងថៃ វាយចូលមកខាងកំពង់ធំ ។ ខាងផ្នែកសេដ្ឋកិច្ចត្រូវបំផ្លាញ ស្រូវអង្ករ ដំឡូង ពោត សណ្តែក បន្លែបង្ការគ្រប់ប្រភេទ គ្រឿង ម៉ាស៊ីន ខោអាវ ថ្នាំពេទ្យ ចានឆ្នាំង ។ល ។ ខាងនយោបាយក៏ត្រូវ ផ្លាស់ប្តូរកម្លាំងគ្រប់គ្រង ។

ចូលដល់ខែមេសា ឆ្នាំ១៩៧៧ សភាពការណ៍នៅតែស្ងាត់ ស្ងៀប ឥតមានសញ្ញាអ្វីមួយដែលបង្ហាញថានឹងមានការអនុវត្ត ផែនការរដ្ឋប្រហារឆ្នាំ១៩៧៧ឡើយ ។ ដេត បានសរសេរ សំបុត្រសួរ ភឹម អំពីរឿងនេះ ។ ភឹម ឆ្លើយតបវិញថា ធ្វើមិន ទាន់ទេ ព្រោះខាងកងទ័ពវៀតណាមមកមិនទាន់គ្រប់ ។

ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧ មានព្រឹត្តការណ៍ភ្ញាក់ ផ្អើលមួយកើតឡើងនៅក្នុងតំបន់៣២នៅមន្ទីរឃុំឃាំង ម-៩៩ ដែលមានទីតាំងនៅឃុំតាសាល ស្រុក២៧ កំពង់ស្ពឺខាងជើង ។ កងការពារម្នាក់បានបាញ់និងចាប់កម្មាភិបាលនៅក្នុងមន្ទីរដាក់ខ្នោះ ហើយដោះលែងអ្នកទោសចេញពីគុក ។ ជាលទ្ធផលគឺ អ្នកទោស ជាង២០០នាក់រត់រួចដោយដណ្តើមយកកាំភ្លើងបាន១៦ដើម កម្មាភិបាលម្នាក់និងយុទ្ធជន៤នាក់ស្លាប់ ។ ថ្នាក់លើបានបន្ទោស ចាប ណាម ដែលរងរបួសក្នុងហេតុការណ៍ ។ ដេត បានព្យាយាម ទម្លាក់កំហុសនេះលើ ប៉ាល់ ដែលជាលេខាតំបន់ អំពីការមិន ទទួលខុសត្រូវ ។ សមមិត្ត ហែម (ខៀវ សំផន) និងបងទី២ (នួនជា) បានចុះមកដោះស្រាយដោយផ្ទាល់ ។

ដេត បាននិយាយថា ខ្លួនបានធ្វើកំហុសក្នុងឱកាសទស្សនកិច្ច របស់គណៈប្រតិភូចិនឈ្មោះ ចិន យុងគុយ ហៅ តាចាយ នៅក្នុង ខែកញ្ញា ឆ្នាំ១៩៧៧ ។ ដេត បានចូលរួមនៅក្នុងឱកាសជូន ដំណើរទស្សនកិច្ចនោះនិងបានធ្វើអំពីខុសឆ្គងជាច្រើនដែលខុស នឹងបែបបទពិធីការ ។

ចាប់ពីខែធ្នូឆ្នាំ១៩៧៧ដល់ដើមឆ្នាំ១៩៧៨ មានការ ប្រយុទ្ធគ្នាយ៉ាងតឹងតែងជាច្រើនលើកច្រើនសានៅតាមព្រំដែន កម្ពុជាវៀតណាម ។ ពេលខ្លះ កងទ័ពវៀតណាមវាយលុយចូល ទឹកដីកម្ពុជារហូតដល់៣០គីឡូម៉ែត្រ ។ ប្រយុទ្ធគ្នាលើកក្រោយៗ ខាងវៀតណាមប្រើសុទ្ធតែកាំភ្លើងធំបាញ់ផ្លោងពីចម្ងាយ ។ ជម្លោះ នេះបន្តរហូតដល់ពាក់កណ្តាលខែ១ ឆ្នាំ១៩៧៨ ទើបស្ងប់ស្ងាត់ ។

វិធីមួយទៀតក្នុងការកម្ទេចថ្នាក់ដឹកនាំ គឺដាក់ថ្នាំបំពុល តាមរយៈម្ហូបអាហារ នំបង្អែម ផ្លែឈើ ប៉ុន្តែតែងតែបរាជ័យ ជានិច្ច ព្រោះបងទី១និងទី២តែងតែមានការប្រយ័ត្នប្រយែងក្នុង ការហូបចុក ។ ឧទាហរណ៍ នៅក្នុងវគ្គរៀនសូត្ររយៈពេល៣ថ្ងៃ នៅខេត្តកំពង់ស្ពឺនៅខែកក្កដា ឆ្នាំ១៩៧៧ ដែលចូលរួមដោយ បងទី១ (ប៉ុល ពត) ដេត បានប្រើថ្នាំបំពុលដាក់នៅក្នុងនំគមបំណង យកទៅឲ្យបងទី១ទទួលទាន ប៉ុន្តែមិនបានសម្រេច ដោយសារបង ទី១មិនបានទទួលទាននំនោះ ។ ម្តងទៀត នៅក្នុងសន្និបាតឆ្លង ផែនការរបស់ភាគក្រោមអធិបតីភាពបងទី១ដដែល នៅលង្វែក ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨ ដេត បានត្រៀមផែនការបំពុលបងទី១ តាមរយៈអាហារទៀត ប៉ុន្តែលើកនេះក៏បរាជ័យ ដោយសារមាន កងការពារតាមពិនិត្យមើលយ៉ាងម៉ត់ចត់ ។

*មិនមានការបញ្ជាក់ច្បាស់ថា ជូ ជេត ត្រូវចាប់ខ្លួននៅពេលណាទេ ប៉ុន្តែតាមការពិពណ៌នានៅក្នុងចម្លើយសារភាព យើងសន្និដ្ឋានថា ជូ ជេត ត្រូវចាប់ខ្លួននៅថ្ងៃទី២៦ ខែមីនា ឆ្នាំ ១៩៧៨ បញ្ជូនមកឃុំឃាំងនៅមន្ទីរ ស-២១ និងសួរចម្លើយជាច្រើនលើកច្រើនសា ។ ចម្លើយសារភាពរបស់ ជូ ជេត មានចំនួន៤២៧ទំព័រ មានសភាពលម្អិតប៉ុន្តែកាលបរិច្ឆេទនីមួយៗមិនច្បាស់លាស់ ។ នៅទីបញ្ចប់នៃចម្លើយសារភាព ជេត បានសរសេរសេចក្តីអង្វរករមួយសុំការលើកលែងទោសពីថ្នាក់ដឹកនាំបក្សកុម្មុយនិស្តកម្ពុជា ។ សេចក្តីអង្វរករនោះមានដូចតទៅ÷*

*បក្សកុម្មុយនិស្តកម្ពុជាជាទីគោរពស្នេហា!*

*ថ្ងៃនេះ ក្រោយពីពេលដែលសរសេរសេចក្តីរាយការណ៍ចប់ កាន់តែឃើញច្បាស់នូវទោសកំហុសរបស់ខ្លួនផ្ទាល់ដែលបានប្រព្រឹត្តខុសចំពោះបក្សប្រជាជនយ៉ាងធំសម្បើម ។ ថ្ងៃនេះខ្ញុំបានត្រួតពិនិត្យនូវជីវទស្សនៈរបស់ខ្ញុំក្រោមការណែនាំរបស់បក្ស ខ្ញុំឃើញថាៈ*

*ការរស់នៅរបស់ខ្ញុំតាំងពីដឹងក្តីមករហូតដល់អាយុ៥២ឆ្នាំគឺគ្មានផលប្រយោជន៍អ្វីបន្តិចសោះចំពោះបក្ស ប្រជាជន ប្រទេសជាតិ ។*

◆ *គិតទាំងនៅវត្តនិងបួសជាង១០ឆ្នាំឥតបានការអ្វីក្រៅពីទទួលយកគំនិតនិយមរបស់សាសនា ។*

◆ *គិតតាំងពីឆ្នាំ១៩៥០មករហូតដល់១៩៧៨នេះដែលសន្មតថាធ្វើបដិវត្តន៍នោះ ថ្ងៃនេះឃើញតែបំរើចក្រពត្តិ-បរទេសជាភ្នាក់ងារសេអ៊ីអា ខ្ញុំកញ្ឆះយួនលេបទឹកដី និងបំរើរបបសក្តិភូមិនាយទុន ។ល ។ទៅវិញ ។*

◆ *ដូចនេះ ៥២ឆ្នាំកន្លងមកជា៥០ឆ្នាំដែលខ្ញុំរស់នៅឥតបានការអ្វីបន្តិចចំពោះជាតិ ប្រជាជន ប្រទេស ។ ផ្ទុយមកវិញមានតែប្រព្រឹត្តទោសកំហុសចំពោះជាតិ ប្រជាជន ប្រទេសជាតិយ៉ាងច្រើនអនេកប្បការរកទីបំផុតគ្មាន ។ មូលហេតុដែលនាំឱយខ្ញុំដើរផ្លូវខុសនេះមកពីធាតុនៃវណ្ណៈដើមរបស់ខ្លួនខ្ញុំគឺជាធាតុក្រ អាវ៉ាសែ បាតផ្សារ សប្បាយហ៊ឺហា ស្រាស្រីញី ។ល ។ ទន្ទឹមនេះ សត្យានុម័តវាអូសទាញខ្ញុំ ដូចជាគំនិតនិយមរបស់ពុទ្ធសាសនា ចក្រពត្តិនិយម អាណានិគមនិយម (យួន) ជាដើម ។*

*បក្សកុម្មុយនិស្តកម្ពុជាជាទីគោរពស្នេហា!*

*ថ្ងៃនេះខ្ញុំបានឃើញនូវទោសកំហុសរបស់ខ្លួនខ្ញុំហើយក្នុងរយៈកាលនៃជីវិតរបស់ខ្លួន ។ ខ្ញុំមានការសោកស្តាយរកអ្វីមកប្រៀបពុំបានក្នុងឋានៈខ្លួនជាជនជាតិកម្ពុជាម្នាក់ ។ បើតាមទំងន់នៃទោសកំហុសនេះ ខ្ញុំត្រូវតែទទួលខុសត្រូវចំពោះមុខបក្សប្រជាជនយ៉ាងធ្ងន់សម្បើម ។ តែក្នុងពេលឱកាសនេះខ្ញុំសូមលំអោនកាយគោរពអង្គការបក្សកុម្មុយនិស្តកម្ពុជា តែសុំទុកតែអាយុជីវិតរបស់ខ្លួនផង ដើម្បីខ្ញុំបានឃើញនូវអនាគតដ៏រុងរឿងត្រចះត្រចង់ក្រោមពន្លឺដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជា ឬក៏សុំអនុញ្ញាតឲ្យខ្ញុំបានបម្រើភារកិច្ចអ្វីមួយ សូម្បីភារកិច្ចតូចក៏ដោយក្នុងក្របខណ្ឌដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាដ៏បរិសុទ្ធ ។*

*សំណូមពរជាពិសេសរបស់ខ្ញុំគឺ ក្រោយពេលឃើញកំហុសរបស់ខ្លួនហើយ ចង់កសាងខ្លួនឲ្យបានល្អក្នុងរយៈកាលដែលមានជីវិតរស់នៅដ៏ខ្លីខាងមុខ បម្រើបក្ស ប្រទេសជាតិ ឱយសមឋានៈជាពលរដ្ឋកម្ពុជាមួយរូប ។*

*ដូចនេះ ចាប់តាំងពីពេលនេះទៅ ខ្ញុំសុំប្តេជ្ញាចំពោះបក្សកុម្មុយនិស្តកម្ពុជាថាៈ*

◆ *ខ្ញុំសុំប្តេជ្ញាលះបង់នឹងក្បត់នូវបក្សពលករកម្ពុជាដែលមានបងភឹមដឹកនាំរហូតសព្វថ្ងៃចេញពីខ្លួន ហើយលែងទទួលស្គាល់និងទទួលការដឹកនាំតទៅទៀត ។*

◆ *សុំប្តេជ្ញាក្បត់នឹងក្រុមសេ.អ៊ី.អាដែលចេះតែបន្តខ្សែរយៈរហូតមក ។*

◆ *ប្តេជ្ញាលែងទទួលស្គាល់កម្លាំងក្បត់ទាំងអស់ដែលបានសហការជាមួយគ្នាប្រឆាំងនឹងបក្សកុម្មុយនិស្តកម្ពុជាកន្លងមក ។*

◆ *សុំស្មោះត្រង់នឹងបក្សកុម្មុយនិស្តកម្ពុជា រាយការណ៍ជូនបក្សនូវកម្លាំងក្បត់ទាំងអស់នេះក្រែងមានភ្លេចភ្លាំងខ្លះ សុំស្រាវជ្រាវនិងរាយការណ៍ជូនជាបន្តបន្ទាប់ទៅទៀត ។*

*នេះជាសេចក្តីសារភាពនូវទោសកំហុសរបស់ខ្ញុំចំពោះបក្សកុម្មុយនិស្តកម្ពុជា សុំបក្សកុម្មុយនិស្តកម្ពុជាអនុគ្រោះនូវសេចក្តីសារភាពនេះឱយបានតាមការស្នើរបស់ខ្ញុំ ។...*

*ថ្ងៃ២០ ខែ៥ ១៩៧៨ ជូ ជេត ហៅ ស៊ី ។*

**សាន់ កល្យាណ**

# របាយការណ៍ពាណិជ្ជកម្មក្រៅប្រទេសក្នុងឆ្នាំ១៩៧៥

របបកម្ពុជាប្រជាធិបតេយ្យបានស្ថាបនាប្រទេសដោយចាប់ផ្តើមពីចំណុចសូន្យ ពោលគឺកម្ទេចចោលអ្វីៗទាំងអស់ដែលជាសំណល់ពីរបបមុនៗ ការិយាល័យរដ្ឋបាល សាលារៀន ផ្សារលក់ទំនិញ ប្រាក់កាស...ត្រូវបានបំបិទចោលទាំងស្រុងៗ អ្វីៗទាំងអស់ដែលជាកម្មសិទ្ធិឯកជនត្រូវកាត់ផ្តាច់ៗ ដោយសារតែយល់ឃើញថាកម្មសិទ្ធិឯកជនជាដើមហេតុនៃវិសមភាពនិងអំពើពុករលួយនៅក្នុងសង្គម ខ្មែរក្រហមបានបង្កើតសហករណ៍ប្រមូលផ្តុំប្រជាជនឲ្យរស់នៅរួម ធ្វើការរួម និងហូបរួមៗ ការធ្វើពាណិជ្ជកម្មមានតែផ្លូវរដ្ឋ ហើយក៏មិនមានភាពទូលំទូលាយដូចពីរបបមុនដែរៗ មានតែប្រទេសមួយចំនួននៅអាស៊ីប៉ុណ្ណោះដែលកម្ពុជាប្រជាធិបតេយ្យជ្រើសរើសធ្វើជាដៃគូពាណិជ្ជកម្មមានប្រទេសចិន កូរ៉េ ហុងកុង យូហ្គោស្លាវី ថៃ និងវៀតណាមៗ ដោយឡែក នៅក្នុងឆ្នាំ១៩៧៥ ប្រទេសដែលធ្វើជាដៃគូពាណិជ្ជកម្មជាមួយកម្ពុជាប្រជាធិបតេយ្យមានតែពីរប៉ុណ្ណោះ គឺប្រទេសចិននិងកូរ៉េៗ ក្នុងចំណោមប្រទេសជាដៃគូពាណិជ្ជកម្មទាំងអស់ សាធារណរដ្ឋប្រជាមានិតចិនមានទំនាក់ទំនងជាមួយកម្ពុជាប្រជាធិបតេយ្យស្និតល្អបំផុតទាំងក្នុងវិស័យពាណិជ្ជកម្ម សេដ្ឋកិច្ចនិងនយោបាយៗ

យោងតាមរបាយការណ៍ពាណិជ្ជកម្មឆ្នាំ១៩៧៥របស់កម្ពុជាប្រជាធិតេយ្យ បានបង្ហាញថា នៅក្នុងឆ្នាំ១៩៧៥ ខាងភាគីកម្ពុជាបានលក់ទំនិញទៅឲ្យប្រទេសចិនចំនួនពីរលើកៗ លើកទី១នាំចេញកៅស៊ូឆៅចំនួន៧៥០តោន ម្រេចខ្មៅចំនួន១៩៦តោននិង៧៥៦គីឡូក្រាម និងគ្រាប់ស្វែងចំនួន៣៩តោននិង១៥០គីឡូក្រាមៗ លើកទីពីរនាំចេញកៅស៊ូឆ្អិននិងកៅស៊ូឆៅប្រភេទលេខ១និងលេខ២ចំនួន១៦២៨តោននិង៧១០គីឡូក្រាម ដូងទុំចំនួន១១៣តោននិង២២៨គីឡូក្រាម និងឈើមូលចំនួន១៣៦០ដើមៗ ទន្ទឹមនឹងនេះ កម្ពុជាក៏បានទិញចូលមកវិញនូវផលិតផលច្រើនសន្ធឹកសន្ធាប់ពីប្រទេសចិនវិញ ដែលភាគច្រើនគឺអង្ករអំបិល ក្រណាត់ ថ្នាំពេទ្យ ឧបករណ៍ធ្វើស្រែ ថ្នាំសម្លាប់សត្វល្អិតសម្ភារប្រើប្រាស់នៅក្នុងរោងចក្រកាត់ដេរ គ្រឿងបន្លាស់រថភ្លើងនិងប្រេងឥន្ធនៈ សរុបទាំងអស់ចំនួន៦៨.៨៨៨.៧៥៦តោនៗ

ក្រៅពីទិញនិងលក់ទំនិញជាមួយប្រទេសចិន កម្ពុជាប្រជាធិបតេយ្យបានទិញផលិតផលរបស់ប្រទេសកូរ៉េចំនួន២លើកមានក្រណាត់ ថ្នាំពេទ្យ ត្រាក់ទ័រ សម្ភារអគ្គិសនី និងឧបករណ៍ធ្វើកសិកម្មៗ លើកទីមួយដឹកតាមកប៉ាល់ឈ្មោះ រ៉ុងក្រាដូ មានចំនួន៤០០៨៣គីឡូក្រាម មកដល់កំពង់ផែកំពង់សោមថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៧៥ និងលើកទីពីរដឹកតាមកប៉ាល់ រ៉ុងរ៉ាគូចូលមកដល់ផែកំពង់សោមថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៥ មានចំនួន១១១២០៨គីឡូក្រាមៗ

ទន្ទឹមនឹងទំនាក់ទំនងពាណិជ្ជកម្មផ្លូវរវាងប្រទេសចិននិងកូរ៉េ កម្ពុជាប្រជាធិបតេយ្យក៏បានទទួលជំនួយមួយចំនួនពីប្រទេសទាំងពីរដែរៗ របាយការណ៍របស់ពាណិជ្ជកម្មរដ្ឋដែលចុះបញ្ជីត្រឹមថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៧៥ កត់ត្រាថា ពាណិជ្ជកម្មរដ្ឋបានទទួលការឧបត្ថម្ភជាក្រណាត់ចំនួន១៨.៩៧០.០៣០ម៉ែត្រ ពីប្រទេសចំនួនបីគឺ ចិន កូរ៉េ និងវៀតណាមៗ ក្នុងតារាងរបាយការណ៍លម្អិតបញ្ជាក់ថា ប្រទេសចិនបានផ្តល់ជំនួយជាក្រណាត់ជាឌិបខ្មៅ ឈុនទីវខ្មៅ និងក្រណាត់ចម្រុះ ចំនួន៣២០៩៥៨៧យ៉ាត្រូវជា២.៨៨៨.៦២៨ម៉ែត្រៗ ប្រទេសកូរ៉េបានឧបត្ថម្ភជាក្រណាត់ជាឌិបខ្មៅនិងក្រណាត់កាគីពណ៌អាចម៍សេះចំនួន៦២១ដុំស្មើនឹង១៩៨.១៩៣ម៉ែត្រ និងប្រទេសវៀតណាមឧបត្ថម្ភជាក្រណាត់ចំនួន៥០៩៩ដុំស្មើនឹង១៤.៩៩៣.៦៥៩ម៉ែត្រៗ

ដូច្នេះ ទំនិញដែលកម្ពុជាប្រជាធិបតេយ្យបានទិញក្នុងឆ្នាំ១៩៧៥ សុទ្ធតែជាផលិតផលចាំបាច់សម្រាប់ប្រើក្នុងវិស័យកសិកម្មនិងឧស្សាហកម្មៗ

**លី សុផល**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១១៩១ | ហែម សុខុន | កូន ហែម ដៃ | អគ្គិសនីទី៣ | ៣០-១០-៧៦ | ៣១-១០-៧៦ | |
| ១១៩២ | ដឹម ដៀក | កូន ដឹម ងីហេង | អគ្គិសនិទី៣ | ៣០-១០-៧៦ | ៣១-១០-៧៦ | |
| ១១៩៣ | ដឹម ព្រួ | កូន ដឹម ងីហេង | អគ្គិសនីទី៧ | ៣០-១០-៧៦ | ៣១-១០-៧៦ | |
| ១១៩៤ | អ៊ូ សារិន | កូន អ៊ូ សារិន | អគ្គិសនីទី៧ | ៣០-១០-៧៦ | ៣១-១០-៧៦ | |
| ១១៩៥ | ទៀង សំបូរ | កម្មករ | រទេះភ្លើង | ៦-៩-៧៦ | ៣១-១០-៧៦ | ឃើស្លាប់ |
| ១១៩៦ | ម៉ក់ សារ៉ន | សក្តិ១ | តាឡី | ៣១-៨-៧៦ | ៣១-១០-៧៦ | ឃើស្លាប់ |
| ១១៩៧ | ស ផល្លា ហៅ ភាក់ | មេក្រុម | ថាមពល | ១១-៨-៧៦ | ១-១១-៧៦ | ឃើស្លាប់ |
| ១១៩៨ | រ៉ូន ថន ហៅ ថាំង | ប្រជាជន | តំបន់៣២ | ៦-៧-៧៦ | ២-១១-៧៦ | ឃើស្លាប់ |
| ១១៩៩ | អ៊ុង ដុយ ហៅ ប្រាំមួយ | សក្តិ១ | តាឡី | ៣០-៨-៧៦ | ៤-១១-៧៦ | ឃើស្លាប់ |
| ១២០០ | យូ អ៊ី ហៅ ពល | កងរយ | កងពល៣១០ | ១០-៧-៧៦ | ៤-១១-៧៦ | ឃើស្លាប់ |
| ១២០១ | ឃឹម ផាត់ ហៅ ឃុន | យុទ្ធជន | ពាណិជ្ជកម្ម | ១០-៧-៧៦ | ៤-១១-៧៦ | ឃើស្លាប់ |
| ១២០២ | សន សារិន ហៅ ចិត្រ | មេពួក | កងពល៣១០ | ១០-៧-៧៦ | ៤-១១-៧៦ | ឃើស្លាប់ |
| ១២០៣ | ឃើវ ហួត ហៅ ហ៊ាន់ | យុទ្ធជន | កងពល១៦៤ | ១៥-៦-៧៦ | ៦-១១-៧៦ | ឃើស្លាប់ |
| ១២០៤ | អ៊ិត ឃឹម ហៅ យ៉ែម | កងហា | កងពល៣១០ | ១០-៧-៧៦ | ៦-១១-៧៦ | ឃើស្លាប់ |
| ១២០៥ | គឹម លីង ហៅ លន់ | កងហា | ថាមពល | ១១-៨-៧៦ | ៧-១១-៧៦ | ឃើស្លាប់ |
| ១២០៦ | ឡុង សារ៉េន ហៅ សារ៉េត | ជំនួយវរសេនាធំ | កងពល១៧០ | ១៧-៩-៧៦ | ៨-១១-៧៦ | ឃើស្លាប់ |
| ១២០៧ | សេក គឹមជា (ស្រី) | ប្រពន្ធ យិន ឡោម | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២០៨ | អ៊ឹម ស៊ុក (ស្រី) | ម្តាយ វង សឿន | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២០៩ | វង សឿន (ស្រី) | ប្រពន្ធ គីម សាដូ | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២១០ | ស ស៊ឹម (ស្រី) | ម្តាយ សាង សំបាត់ | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២១១ | សាង សំបាត់ (ស្រី) | ប្រពន្ធ ញ៉ក់ សារុន | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២១២ | ឃុន សុកអ៊ឹម (ស្រី) | ប្រពន្ធ អ៊ុំ សារ៉ាវុធ | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២១៣ | កៀត សាតសំនារី (ស្រី) | ប្រពន្ធ ពេជ សារ៉េត | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២១៤ | ដឹម ណារី (ស្រី) | ប្រពន្ធ ព្រាប ឌឹម | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២១៥ | និល វ៉ាន់ស៊ី (ស្រី) | ប្រពន្ធ ដួង ដាវុធ | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២១៦ | លឹម ហ៊ុន (ស្រី) | ប្រពន្ធ ស៊ុក សឿន | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២១៧ | តាន់ គឹមហៀង (ស្រី) | ប្រពន្ធ មួង យូតិច | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២១៨ | តាន់ គឹមថា (ស្រី) | ប្អូន តាន់ គឹមហៀង | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២១៩ | ស៊ឹន ថន (ស្រី) | ប្រពន្ធ ចក់ អ៊ុន | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |

| | | | | | | |
|---|---|---|---|---|---|---|
| ១២២០ | កៅ សូភី (ស្រី) | ប្រពន្ធ ទិត គង់ | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២២១ | ពត សុផន (ស្រី) | ប្រពន្ធ អ៊ូម ផន | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២២២ | វ៉ា ដេលីឡា (ស្រី) | ប្អូនថ្លៃ តឹក តូ | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២២៣ | អោម យិនដូនី (ស្រី) | ប្រពន្ធ ជឹម ឡាង | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២២៤ | ដេត គីមណារី (ស្រី) | ប្រពន្ធ អ៊ុច ម៉ុងហ៊ា | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២២៥ | ភូ យ៉ែម (ស្រី) | ប្រពន្ធ វ៉ាល់ សប៉ុន | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២២៦ | ទា ឈុនកេង (ស្រី) | ប្រពន្ធ ម៉ៅ សុផានី | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២២៧ | អ៊ឹង សោនណារី (ស្រី) | ប្រពន្ធ កែ ហុកបៀន | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២២៨ | ជា ឡុង (ស្រី) | ប្រពន្ធ ហោ ឌូរេន | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២២៩ | ហោ ស៊ុនណារ៉េត (ស្រី) | កូន ជា ឡុង | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២៣០ | អ្វង យ៉ន (ស្រី) | ប្រពន្ធ សុក តិចឌិ | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២៣១ | ស៊ុម វត្ថនា (ស្រី) | ប្រពន្ធ ទៀវ កូសិត | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២៣២ | គីម ស្រ៊ីន (ស្រី) | ប្រពន្ធ ហ៊ីង ចុង | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២៣៣ | សែម ចាន់ (ស្រី) | យុទ្ធនារី | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២៣៤ | គង់ វ៉ាន់ថា (ស្រី) | ប្រពន្ធ សំ ហម | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២៣៥ | គង់ វ៉ាន់ថន (ស្រី) | ប្អូន គង់ វ៉ាន់ថា | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២៣៦ | ម៉ិច សំបូរ (ស្រី) | ប្រជាជន | ស-២១យ | ៨-១១-៧៦ | ៩-១១-៧៦ | |
| ១២៣៧ | ស្ងួត ហ៊ិល ហៅ ស្រៀក | យុទ្ធជន | កងពលទី៣ | ១-៩-៧៦ | ៩-១១-៧៦ | ឈឺស្លាប់ |
| ១២៣៨ | សុក ណាំង | យុទ្ធជន | តំបន់១៥ | ១-៩-៧៦ | ៩-១១-៧៦ | ឈឺស្លាប់ |
| ១២៣៩ | ចាន់ ថា | យុទ្ធជន | អគ្គិសនីទី១ | ៤-៨-៧៦ | ១១-១១-៧៦ | ឈឺស្លាប់ |
| ១២៤០ | ជា ឡូ | មេក្រុម | ស-២១យ | ៩-១១-៧៦ | ១១-១១-៧៦ | |
| ១២៤១ | ស្រី ដៀន | យុទ្ធជន | ស-២១យ | ៩-១១-៧៦ | ១១-១១-៧៦ | |
| ១២៤២ | ជា លី | យុទ្ធជន | ស-២១យ | ៩-១១-៧៦ | ១១-១១-៧៦ | |
| ១២៤៣ | ហៃ ឡេង | យុទ្ធជន | ស-២១យ | ៩-១១-៧៦ | ១១-១១-៧៦ | |
| ១២៤៤ | ម៉ុត ម៉ាន់ ហៅ សារិត | យុទ្ធជន | ស-២១យ | ៩-១១-៧៦ | ១១-១១-៧៦ | |
| ១២៤៥ | ឈុំ ឈន | យុទ្ធជន | ស-២១យ | ៩-១១-៧៦ | ១១-១១-៧៦ | |
| ១២៤៦ | ម៉ៅ ទី | យុទ្ធជន | ស-២១យ | ៩-១១-៧៦ | ១១-១១-៧៦ | |
| ១២៤៧ | សោម រស់រដា | យុទ្ធជន | ស-២១យ | ៩-១១-៧៦ | ១១-១១-៧៦ | |
| ១២៤៨ | អេង ស្រេង ហៅ វុន | យុទ្ធជន | ស-២១យ | ៩-១១-៧៦ | ១១-១១-៧៦ | |
| ១២៤៩ | យុត ផន (ស្រី) | ប្រពន្ធ សឿ សុត | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ | |
| ១២៥០ | ម៉ា វីង (ស្រី) | ប្រពន្ធ ម៉ា សួស | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ | |
| ១២៥១ | ពេញ ឆុន (ស្រី) | ប្រពន្ធ ចាន់ ស៊ីណាត | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ | |
| ១២៥២ | លួន គីមភួន (ស្រី) | ប្អូន បួ មិទ្ធរ | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ | |
| ១២៥៣ | ឈៀង ឆេងអវ (ស្រី) | ប្រពន្ធ អ៊ា ពុធ | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ | |
| ១២៥៤ | បួ បូរិទ្ធ (ស្រី) | ប្អូន បួ មិទ្ធរ | ស-២១យ | ១៤-១១-៧៦ | ១៥-១១-៧៦ | **(នៅមានត)** |

# នេះមិនមែនជាកម្មពៀរ

ជនរងគ្រោះវ័យចំណាស់បានចូលរួមកាន់តែច្រើនឡើងក្នុងការចែករំលែករឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមឲ្យដល់ក្មេងជំនាន់ក្រោយ ។ នៅក្រោមផ្ទះដំបូលក្បឿងជញ្ជាំងស្លឹក លោកយាយ គុជ វ៉ាន អាយុ៧៧ឆ្នាំ អង្គុយបុកម្លូបណ្តើរ រៀបរាប់រឿងរ៉ាវរបស់គាត់ប្រាប់ខ្ញុំបណ្តើរ ដោយមានចៅស្រីពីរនាក់នៅក្បែរផង ។ ជារៀងរាល់ថ្ងៃ យាយនៅផ្ទះថែទាំចៅៗក្នុងខណៈដែលកូនស្រីនិងកូនប្រសាររបស់យាយចេញទៅប្រកបការងារនៅឯវាលស្រែ ។


យាយ គុជ វ៉ាន

យាយវ៉ាន កើតឆ្នាំថោះ ឪពុករបស់យាយឈ្មោះ គុជ ជាអតីតជំទប់ទី១ឃុំប្រសូត្រ ។ យាយមានបងប្អូន៦នាក់ ប្រុសតែម្នាក់គត់គឺបងធំបង្អស់ ។ ខ្លួនយាយជាកូនទី៥ ។ យាយបាននិយាយថា “តាំងពីខ្ញុំធំដឹងក្តីមក ខ្ញុំឃើញតែឪពុកខ្ញុំដើរប្រមូលពន្ធនិងដោះស្រាយពាក្យបណ្តឹងរបស់ប្រជាជននៅក្នុងឃុំ ហើយជួបជុំគ្នាផឹកស្រារាល់ថ្ងៃ ។ ជីវភាពគ្រួសារខ្ញុំគ្រាន់បើដែរ មិនពិបាកទេ ។ ឪពុកខ្ញុំមានដីច្រើនណាស់ ប៉ុន្តែគាត់មិនសូវរវីរវល់ទេ តែម៉ែខ្ញុំនិងបងប្អូនខ្ញុំទេដែលទៅកាប់គាស់ធ្វើស្រែ ។” ក្នុងចំណោមបងប្អូនទាំងអស់របស់យាយ មានតែបងប្រុសទីមួយប៉ុណ្ណោះដែលបានទៅរៀនសូត្រ ក្រៅពីនោះគ្មាននរណាម្នាក់ចេះអានឬសរសេរឡើយ ។ យាយឲ្យដឹងថា ពីដំបូងឡើយ បងប្រុសរបស់យាយទៅរៀននៅសាលារដ្ឋដែលនៅឆ្ងាយពីភូមិ ។ ម្តាយរបស់យាយបារម្ភក្រែងបាត់កូនប្រុស គាត់ក៏យកកូនមកឲ្យបួសរៀននៅវត្តក្បែរភូមិវិញ ។ ដោយខឹងនឹងម្តាយមិនឲ្យទៅរៀន បងប្រុសរបស់យាយក៏សឹកពីបួសហើយទៅរកស៊ីនៅស្រុកឆ្ងាយបាត់ទៅ ។

ថ្វីដ្បិតតែឪពុករបស់យាយជាជំទប់ឃុំ ប៉ុន្តែក្នុងផ្ទះរបស់យាយគ្មានឈ្នួលបម្រើទេ ។ បងប្អូនរបស់យាយធ្វើការងារសព្វសារពើ បូករួមទាំងការងារស្រែចម្ការផង ។ លើសពីនេះ យាយឆ្លៀតពេលទំនេរទៅកាប់ខសនៅព្រៃយកមកលក់យកប្រាក់សម្រាប់ចាយដោយខ្លួនឯង ។ ក្នុងមួយបាច់ខសយាយលក់បានប្រាក់មួយសេន ។ ក្នុងមួយថ្ងៃយាយរកប្រាក់បានជាមធ្យមប្រាំសេន ។ (កាលនោះប្រជាជនខ្មែរចាយប្រាក់សេនពណ៌ក្រហមដែលមានចោះរន្ធនៅកណ្តាលសម្រាប់ដោតជាចង្កោម ។ ក្នុងមួយសេនអាចទិញបាននំទិញពីរមុខ ឧទាហរណ៍ប្រេងកាតនិងស្ករត្នោត) ។ យាយវ៉ាន់ បាននិយាយថា ពីជំនាន់យាយនៅក្មេងយាយរស់ដោយសប្បាយណាស់ ទោះជាមិនសូវសម្បូរហូរហៀរដូចសព្វថ្ងៃនេះក៏ដោយ ។ ការកម្សាន្តសប្បាយរបស់យាយគឺពេលមានបុណ្យទានម្តងៗដូចជា បុណ្យផ្កា បុណ្យកឋិន បុណ្យឆ្លងសាលា ភ្ជុំបិណ្ឌ ចូលឆ្នាំថ្មីជាដើម បងប្អូនរបស់យាយនាំគ្នាត្រសងទៅមើលកុន ល្ខោន ល្បែង របាំ ។ កាលណោះមធ្យោបាយធ្វើដំណើរគឺដោយថ្មើរជើងឬដោយរទេះគោ ។ ក្រុមគ្រួសារណាដែលមានជីវភាពធូរធារក៏មានកង់ជិះ ប៉ុន្តែមិនសម្បូរទេ ។ ទម្រាំទិញបានកង់មួយត្រូវសន្សំលុយយូរណាស់ ។ លុះត្រាតែអ្នកដែលមានធនធានច្រើនទើបមានលទ្ធភាពទិញកង់ ។

នៅពេលដែល យាយវ៉ាន មានអាយុ១០ឆ្នាំ ឪពុករបស់យាយបានស្លាប់ដោយជំងឺហឺត ។ មិនយូរប៉ុន្មានប្រជាជននៅទូទាំងស្រុកភូមិកើតចៃដែលចេញពីសាច់ ។ យាយចាំរឿងនេះមិនច្បាស់ទេ គ្រាន់តែដឹងថាចៃទាំងអស់នោះកើតពីក្នុងសាច់របស់មនុស្សតែម្តង ។ មិនត្រឹមតែប៉ុណ្ណោះ ប្រជាជនក្រសម្លៀកបំពាក់ថែមទៀត ។ អ្នកខ្លះដែលគ្មានសម្លៀកបំពាក់ បានយកកន្ទេលឬបាវមកស្លៀកបិទបាំងរាងកាយ អ្នកខ្លះមានតែខោអត់អាវ ។ កាលជំនាន់នោះប្រជាជនមិនស្លៀកសំពត់ដូចសព្វថ្ងៃ

នេះទេ គឺស្លៀកក្បិន ហើយក្បិនមួយៗត្រូវចំណាយក្រណាត់អស់បីម៉ែត្រ ។ យាយនិយាយទាំងអស់សំណើចថា «កំពុងតែក្រក្រណាត់ផង ហើយស្លៀកម្ដងបីម៉ែត្រ» ។ ក្រុមគ្រួសាររបស់យាយរវៃសំឡីគត្បាញជាក្រណាត់សម្រាប់ប្រើក្នុងក្រុមគ្រួសារ ។ ខ្លួនយាយផ្ទាល់មិនចូលចិត្តប្រើក្រណាត់ដែលត្បាញអំពីសំឡីគទេ ព្រោះហុយហើយឆាប់ពុកផុយ ម្យ៉ាងទៀត ទទូក្រមាត្បាញអំពីសំឡីគធ្វើឲ្យយាយមានអារម្មណ៍ហ៊ឹងត្រចៀក ។ យាយរវៃកប្បាសដែលដាំបានបន្តិចបន្តួចហើយយកទៅត្បាញប្រវាស់ជាមួយអ្នកជិតខាងបានអាវឬក្រមាយកមកប្រើខ្លួនឯង ។ ពេលដែលយាយអាយុ១៣ឬ១៤ឆ្នាំ ប្រជាជនចាប់ផ្ដើមឈប់ស្លៀកក្បិន ហើយស្លៀកសំពត់សំឡុយវិញ ។ បងប្រុសរបស់យាយដែលទៅរកស៊ីនៅស្រុកឆ្ងាយ បានទិញសារុងពុម្ពយកមកឲ្យប្អូនៗស្លៀក ប៉ុន្តែមិនសូវសម្បូរទេ ។

យាយវ៉ាន រៀបការនៅអាយុ២២ឆ្នាំ ជាមួយបុរសកសិករម្នាក់ដែលជាអ្នកនៅស្រុកភូមិជាមួយគ្នា ។ ប្ដីរបស់យាយឈ្មោះ ពុំ ប៊ុត ។ ក្រោយពេលរៀបការ យាយវ៉ាន មកនៅផ្ទះជាមួយឪពុកម្ដាយក្មេក ។ ទាំងពីរនាក់ប្ដីប្រពន្ធមានកូន៤នាក់ ប៉ុន្តែកូនម្នាក់បានស្លាប់ដោយជំងឺតាំងពីអាយុពីរ-បីខែ ។ បច្ចុប្បន្ននេះកូនទាំង៣នាក់នៅរស់ទាំងអស់ ចំណែកប្ដីរបស់យាយបានស្លាប់ដោយជំងឺខ្យល់គកាលពី១០ឆ្នាំមុន ក្នុងជន្មាយុ៨១ឆ្នាំ ។

បន្ទាប់ពីកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្ដើមបែងចែកប្រជាជនឲ្យធ្វើការងារតាមកង ប៉ុន្តែផលស្រូវដែលផលិតបានមិនមែនជារបស់ប្រជាជនខ្លួនឯងទេ គឺជារបស់អង្គការ ហើយត្រូវយកទៅដាក់ជង្រុករបស់អង្គការ ។ បន្ទាប់មកទើបអង្គការបែងចែករបបឲ្យវិញតាមចំនួនសមាជិកតិចឬច្រើនរបស់គ្រួសារនីមួយៗ ។ នៅពេលចាប់ផ្ដើមបង្កើតរោងបាយរួម ខ្មែរក្រហមបានប្រមូលទ្រព្យសម្បត្តិទាំងអស់របស់ប្រជាជនយកទៅដាក់នៅរោងបាយជាកម្មសិទ្ធិរួម សូម្បីតែចានឆ្នាំងក៏មិនទុកឲ្យដែរ គឺទុកតែកំសៀវមួយសម្រាប់ឲ្យដាំទឹកតែប៉ុណ្ណោះ ។ ពេលនេះសមាជិកគ្រួសារត្រូវបំបែកចេញពីគ្នា ។ កូនប្រុសរបស់យាយត្រូវចាត់តាំងទៅកងចល័តកុមារ កូនស្រីធំឃ្វាលក្របី កូនស្រីតូចកើបអាចម៍គោនិងរៀន ។ ប្ដីរបស់យាយត្រូវខ្មែរក្រហមចាត់ចូលក្នុងកងបង្កបង្កើនផល ។ ចំណែកខ្លួនយាយ ខ្មែរក្រហមបានចាត់តាំងឲ្យធ្វើការនៅក្នុងក្រុមចុងភៅដែលមានសមាជិក១៨នាក់ ។ ការងាររបស់យាយគឺ រៀងរាល់ព្រឹកដើរបេះបន្លែដែលដាំនៅក្នុងចម្ការរបស់សហករណ៍ឬដែលប្រជាជនដាំតាមផ្ទះ ដូចជា ឃ្លោក ត្រឡាច ល្ពៅ ននោង ត្រសក់ត្រាវ ជាដើម ទូលយកមកផ្ទះបាយ បន្ទាប់មកចិតនិងលាងបន្លែទុកសម្រាប់ស្ល ។ ការងារបន្ទាប់បន្សំគឺជួយចែករបបអាហារឲ្យប្រជាជននិងជួយសម្អាតផ្ទះបាយ ។ យាយនិយាយថា ពីដំបូងរបបអាហារគឺអង្ករមួយកំប៉ុងសម្រាប់មនុស្សម្នាក់ ។ ប្រជាជនបានទទួលរបបបាយម្នាក់មួយចាន (បាយជ្រាយដូចបបរឈ្ងោល) និងសម្លមួយចានសម្រាប់មនុស្សបួននាក់ ។ ក្រោយពីនោះមិនយូរប៉ុន្មាន ប្រជាជនលែងបានបាយសុទ្ធទទួលទានហើយ គឺបាយលាយពោត ។ យូរៗម្ដង ខ្មែរក្រហមបញ្ជាឲ្យធ្វើនំបញ្ចុកឬបង្អែមឲ្យប្រជាជនទទួលទានដែរ ។ ក្នុងឱកាសបុណ្យធំៗដូចជាបុណ្យកំណើតបក្សកុម្មុយនិស្តកម្ពុជា ឬបុណ្យខួបជ័យជម្នះ ទើបខ្មែរក្រហមបញ្ជាឲ្យចុងភៅសម្លាប់ជ្រូកគោធ្វើម្ហូបឲ្យប្រជាជនទទួលទាន ។

មិនថារបបអាហារបែបណាឬធ្វើការងារនឿយលំបាកប៉ុនណាទេ គ្មានប្រជាជនណាម្នាក់ហ៊ានរអ៊ូរទាំឬត្អូញត្អែរឡើយ ។ យាយ វ៉ាន និយាយថា *«កាលណោះគេប្រាប់ថា បងប្អូនទាំងអស់ពីថ្ងៃនេះទៅត្រូវដាំដើមគ ខ្ញុំឆ្ងល់ថាម៉េចបានជាដាំដើមគ? ដល់តែក្រោយមកទើបយល់ថាគេមិនឲ្យយើងនិយាយ ។ យប់ឡើងមានមនុស្សមកលបស្ដាប់ក្រោមផ្ទះយើង ។ បើគេឮនិយាយមិនល្អដូចជាថាស៊ីមិនឆ្អែតអីណា៎ គេចាប់យកទៅហើយ ។ ស៊ីបាយមិនឆ្អែតក៏គេមិនឲ្យនិយាយ ធ្វើស្អីក៏គេមិនឲ្យនិយាយ ។ គេឲ្យយើងនិយាយតែសរសើរគេ គេមិនឲ្យយើងនិយាយផ្ដេសផ្ដាសទេ ។ ម៉្លោះហើយស្ងាត់ឈឹង គ្មាននរណាហ៊ាននិយាយអីទេ ។ ទោះស៊ីឆ្អែតឬមិនឆ្អែតក៏មិនហ៊ាននិយាយដែរ ។ បើគេសួរថាឆ្អែតទេចេះតែឆ្លើយថាឆ្អែតៗ ប៉ុន្តែតាមពិតអត់ឆ្អែតទេ ។ ឆ្អែតអីបើបាយលាយពោតនោះ មួយៗចង់ងាប់ហើយ ស្គម ។ គ្មានអ្នកណា*

ហ៊ានឆ្លើយថាអត់ឆ្អែតទេ ។ ស្រូវញ៉ាំកៗជជ្រុកវាមិនឲ្យយើងស៊ីឆ្អែតទេ ។ ម្យ៉ាងទៀត ឧបមាថាថ្ងៃហ្នឹងគេឲ្យយើងហូបត្រីងៀតដល់ហើយយើងពោលថាស្រេកទឹកក៏អត់បានដែរ ។ ខ្ញុំចេះតែហាមកូនចៅថាកុំនិយាយអីផ្តេសផ្តាស ក្រែងគេចាប់យើងយកទៅវៃចោល គេឲ្យធ្វើអីក៏ធ្វើទៅ លើកប្រឡាយ ស្ទូងដក ក៏ដោយ កុំនិយាយអីទាំងអស់ យប់ឡើងគិតតែពីដេកទៅ ។ ពិបាកណាស់ជំនាន់ហ្នឹង មិនស្រណុកទេ» ។

យាយបាននិយាយទៀតថា នៅក្នុងរបបខ្មែរក្រហម មានប្រជាជនជាច្រើនដែលនៅជិតព្រំដែនវៀតណាម បានភៀសខ្លួនទៅក្នុងទឹកដីវៀតណាមហើយបានទទួលការអនុញ្ញាតឲ្យរស់នៅទីនោះ ។ យាយលើកឧទាហរណ៍គ្រួសារអ្នកជិតខាងម្នាក់ដែលបានបរទេះគោទៅ ហើយបានខាងវៀតណាមសង់ផ្ទះឲ្យនៅនិងអនុញ្ញាតឲ្យប្រកបរបររកស៊ីចិញ្ចឹមជីវិតតាមចិត្ត ។ យាយក៏ចង់រត់ទៅដែរ ប៉ុន្តែមិនដាច់ចិត្តទៅចោលកូនដែលរស់នៅកងកុមារ ព្រោះបើឪពុកម្តាយរត់ ខ្មែរក្រហមនឹងសម្លាប់កូនដែលនៅសល់ ។ យាយនិយាយថា កាលណោះប្រសិនបើក្រុមគ្រួសាររបស់យាយជួបជុំគ្នា យាយពិតជាភៀសខ្លួនទៅប្រទេសវៀតណាមជាមិនខាន ។

នៅឆ្នាំ១៩៧៨ ខ្មែរក្រហមមួយក្រុមទៀតដែលយាយមិនដឹងថាមកពីខាងណា បានចូលមកដល់ឃុំរបស់យាយ ហើយចាប់គណៈគ្រប់គ្រងមុនយកទៅសម្លាប់ចោលអស់ ដាក់អ្នកគ្រប់គ្រងថ្មីជំនួសវិញ ។ អ្នកគ្រប់គ្រងថ្មីនេះបានកោះហៅប្រជាជនទៅប្រជុំ ។ មានមតិនៅក្នុងអង្គប្រជុំ អ្នកគ្រប់គ្រងថ្មីបានសម្តែងក្តីអាណិតអាសូរប្រជាជន ហើយថ្កោលទោសអ្នកគ្រប់គ្រងមុនដែលបានសម្លាប់និងធ្វើទុក្ខទោសប្រជាជន ប៉ុន្តែនៅទីបំផុតក្រុមនេះក៏សម្លាប់ប្រជាជនដែរ ហើយសម្លាប់ខ្លាំងជាងអ្នកមុនទៅទៀត គឺយកទាំងគ្រួសារៗតែម្តង ។ យាយនិយាយថា ប្រជាជនស្លាប់អស់ច្រើនណាស់ ជាពិសេសអ្នក១៧មេសា ។

នៅចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីស្រុកភូមិរបស់យាយចំនួនពីរលើក ដើម្បីគេចពីការវាយប្រហាររបស់កងទ័ពវៀតណាម ។ លើកទីមួយជម្លៀសទៅត្រឹមទីរួមខេត្តស្វាយរៀងក៏ត្រឡប់មកវិញ ។ លើកទីពីរ ខ្មែរក្រហមបានយករថយន្តដឹកប្រជាជនទៅឲ្យរស់នៅឃុំកោះប្រាក់ ស្រុកល្វាឯម ខេត្តកណ្តាល ។ នៅទីនោះ យាយក្លាយជាប្រជាជនថ្មីវិញម្តង ។ ខ្មែរក្រហមចាត់តាំងឲ្យយាយយាមចម្ការល្ហុតនិងជម្រះស្មៅក្នុងចម្ការប៉េងប៉ោះ ។ យាយនិយាយថា ថ្វីដ្បិតតែយាយយាមចម្ការល្ហុត ប៉ុន្តែយាយមិនដែលហ៊ានលួចបេះផ្លែល្ហុតទាល់តែសោះ ។ សូម្បីតែពេលយាយនៅធ្វើជាចុងភៅក៏យាយមិនដែលហ៊ានលាក់ម្ហូបដែរ ។ យាយពិតជាខ្លាចខ្លាំងណាស់ ខ្លាចខ្មែរក្រហមចាប់បានយកទៅសម្លាប់ចោល ។ យាយសុខចិត្តស្រេកឃ្លាន ។ យាយលើកដៃសំពះឡើងលើ ហើយបន្ថែមថា «គេឲ្យប៉ុន្មានខ្ញុំស៊ីប៉ុណ្ណឹង ខ្ញុំមិនចេះលួចលាក់ទេ ខ្លាចគេប្រជុំកសាង ខ្លាចគេធ្វើបាប ខ្លាចគេវៃចោល ។ យើងធ្វើល្អក៏បានរស់ទៅ ។ កុំឲ្យតែគេវៃគេចាប់ចង ។ ម្ល៉ែៗខ្ញុំបន់ព្រះសំពះទេវតាពេលទៅធ្វើការលួចថ្វាយបង្គំនឹងដើមល្ហុត ឱព្រះអង្គអើយបែកឲ្យឆាប់ទៅបងប្អូនងាប់អស់ហើយ មានលោកណាមកជួយទៅឲ្យរស់រានមានជីវិតទៅស្រុកវិញ ។ ខ្ញុំថាទេវតាជួយមែន ។ ជម្រះស្មៅប៉េងប៉ោះបានតែបួនថ្ងៃបែក» ។

រស់នៅឃុំកោះប្រាក់មិនយូរប៉ុន្មាន របបខ្មែរក្រហមក៏ត្រូវផ្តួលរំលំ ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ ប្តីរបស់យាយមិនចង់វិលត្រឡប់មកស្រុកកំណើតវិញទេ គាត់ចង់ទៅរស់នៅទីក្រុងភ្នំពេញ ប៉ុន្តែយាយទាមទារវិលមកស្រុកវិញព្រោះស្តាយដីភូមិកេរពីឪពុកម្តាយ ។ ម្ល៉ោះហើយ ក្រុមគ្រួសាររបស់យាយក៏វិលត្រឡប់មករស់នៅលើដីកំណើតវិញ ប្រកបរបរធ្វើស្រែចម្ការ ។ មកដល់ភ្លាម យាយគ្មានគោក្របីឬនង្គ័លសម្រាប់ភ្ជួរស្រែទេ គឺប្រើចបកាប់ដីស្រែដើម្បីស្ទូងស្រូវ ។ បច្ចុប្បន្ននេះ កូនៗរបស់យាយមានគោ រទេះ នង្គ័ល ជីវភាពរបស់យាយនិងកូនចៅលែងជួបការលំបាកទៀតហើយ ។

ឆ្លងកាត់របបខ្មែរក្រហម បងប្រុសបង្កើតម្នាក់របស់យាយត្រូវខ្មែរក្រហមសម្លាប់នៅចុងឆ្នាំ១៩៧៨ ។ ក្រៅពីនោះ ខ្មែរក្រហមបានសម្លាប់ក្មួយៗរបស់យាយជាច្រើននាក់ទៀត ។ បច្ចុប្បន្នក្នុងចំណោមបងប្អូនរបស់យាយ នៅរស់តែយាយនិង



យាយ គុជ វ៉ាន និងចៅស្រី

ប្អូនស្រីពៅប៉ុណ្ណោះ ។ យាយរស់នៅជាមួយកូនស្រីពៅរបស់យាយ ហើយប្អូនស្រីរបស់យាយក៏រស់នៅជាមួយកូនពៅដែរ ។

ប្រជាជនកម្ពុជាមួយចំនួន ជាពិសេសអ្នកដែលមានវ័យចំណាស់ យល់ថា រឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមគឺជារឿងកម្មពៀរពីអតីតជាតិ ប៉ុន្តែចំពោះលោកយាយ គុជ វ៉ាន មិនយល់ដូច្នេះឡើយ ។ យាយនិយាយថា “អ្នកណាថាស្រលាញ់ប៉ុលពត ខ្ញុំមិនស្រលាញ់ទេ ។ ខ្ញុំខឹងណាស់ ។ រឿងរបបប៉ុលពតនេះមិនមែនជារឿងកម្មពៀរទេ គឺមកពីពួកហ្នឹងតែម្តងដែលបង្កើតឲ្យមានខ្មែរក្រហមស៊ីឈាមខ្មែរគ្នាឯង គ្មានចិនយួនឯណាគេមកស៊ីយើងទេ” ។ នៅពេលដែលខ្ញុំសួរថា តើយាយបានឮអំពីការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ? យាយឆ្លើយថា បានឮតាមវិទ្យុ ។ តើយាយយល់ឃើញយ៉ាងណា? យាយឆ្លើយថា “វាត្រូវតែទទួលទោស ព្រោះវាធ្វើបាបគេឲ្យងាប់អស់រាប់លានរាប់កោដិ ។ អ្នកណាទ្រាំទ្រវាបានបើសូម្បីតែតូចៗក៏វាយកទោសម្លាប់ដែរ ។ ខ្ញុំនិយាយតាមខ្ញុំមើលឃើញ តាមខ្ញុំដឹងខ្ញុំឮ ខ្ញុំមិននិយាយបំផ្លើសទេ ។ កាត់ទោសមេវាទៅ កាត់ធ្វើអីអាតូចកាត់តែមេវាទៅ បើអស់មេវាហើយវាអស់ហើយអ្នកដឹកនាំ ។ បើអស់ពីមេវាហើយនៅមានទៀត កាត់ទោសទៀតទៅ” ។

នៅទីបញ្ចប់យាយបញ្ជាក់ថា របបខ្មែរក្រហមកើតបានមកពីខ្មែរយើងប្រហែស ប៉ុន្តែឥឡូវនេះយាយមិនជឿថាខ្មែរក្រហមត្រឡប់មកវិញម្តងទៀតទេ ព្រោះយាយជឿជាក់ថាខ្មែរបច្ចុប្បន្នបានព្យាយាមទប់ស្កាត់មិនឲ្យរបបនេះវិលមកវិញបាន ។ “ដើម្បីកុំឲ្យរបបហ្នឹងកើតឡើងម្តងទៀតយើងគិតតែព្រួតដៃគ្នាទៅ កុំឲ្យរបបហ្នឹងមកជិះជាន់ទៀត ឲ្យនៅដូចសម័យឥឡូវហ្នឹងទៅ ឯករាជ្យចឹងទៅ ។ កុំឲ្យពិបាកទៀត ឲ្យតែបានស្រួលដូចឥឡូវហ្នឹងអរណាស់ ស្រួលដូចសព្វថ្ងៃហ្នឹងរកស៊ីអីក៏បាន ចង់ធ្វើអីក៏បាន ទៅវត្តទៅវ៉ាអីក៏បានស្រួល” ។

តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមគឺជាគំរូដ៏មានប្រសិទ្ធភាពមួយក្នុងការទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមវិលត្រឡប់មកវិញជាថ្មីទៀត ។

**សាន់ កល្យាណ**

# ជឿថាជាការពិត

គុប រី ហៅ គុប នី ភេទប្រុស គឺជាអតីតអ្នកទោសនៅមន្ទីរ ស-២១ (គុកទួលស្លែង) ។ រី ត្រូវបានបញ្ជូនមកមន្ទីរស-២១ នៅដើមឆ្នាំ១៩៧៨ ដោយសារតែ រី បានធ្វើឲ្យបែកកង់ឡាន និងប្រើប្រាស់របស់របរខ្ជះខ្ជាយ ។ ក្រោយពីជាប់ឃុំឃាំងនៅមន្ទីរស-២១មួយរយៈខ្លី រី ត្រូវបានបញ្ជូនទៅលត់ដំនៅមន្ទីរ ស-២១ឃ (មន្ទីរព្រៃស) ដែលគ្រប់គ្រងដោយ ហ៊ុយ ស្រែ ។

គុប រី បានចូលបម្រើកងទ័ពនៅឆ្នាំ១៩៧៣ នៅភូមិសាមគ្គី ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ តាមការជ្រើសរើសរបស់ប្រធានភូមិដែលប្រាប់ថា ធ្វើបដិវត្តន៍ដើម្បីទាមទារឯករាជ្យមកវិញ ។ ដោយមានទឹកចិត្តស្នេហាជាតិនិងចង់ចូលរួមចំណែកក្នុងការរំដោះប្រទេសជាតិ រី បានស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពខ្មែរក្រហមដោយមិនបានប្រាប់ឪពុកម្ដាយឲ្យដឹងឡើយ ។ ប្រវត្តិរូបមួយសន្លឹករបស់ គុប រី ដែលបន្សល់ទុកពីរបបខ្មែរក្រហម បានកត់ត្រាថា រី មានតួនាទីជានិរសារកងពលបន្ទាប់មកជាយុទ្ធជន ។ រី កើតនៅក្នុងគ្រួសារដែលមានវណ្ណៈភាពជាកសិករក្រ និងមានឪពុកឈ្មោះ គុត ម្ដាយឈ្មោះ យ៉េន ។ រី មានកំណើតនៅភូមិបារ៉ែន ឃុំក្រាំងលាវ ស្រុក៥៦ តំបន់៣៣ ។

នៅក្នុងជួរកងទ័ព រី ជាកុមារវែកបាយយកទៅសមរភូមិមុខ ។ នៅឆ្នាំ១៩៧៤ រី ធ្វើជានិរសារនៅក្នុងកងពល៤៥០ ។ គាត់បានហ្វឹកហ្វឺនបច្ចេកទេសទ័ពនៅក្នុងស្រុកភ្នំស្រួច ក្រោមការគ្រប់គ្រងរបស់ប្រធានកងឈ្មោះ មួ ។ រី បានផ្ញើដំណឹងទៅឪពុកម្ដាយរបស់គាត់តាមរយៈចាស់ៗដែលចេញចូលតំបន់រំដោះ ។ នៅពេលបានទទួលដំណឹងពីកូន ឪពុករបស់ រី ក៏ទៅសួរសុខទុក្ខ រី នៅក្នុងមន្ទីរកងទ័ពបានមួយរយៈខ្លី ។ ក្រោយមក រី មានជំងឺជាទម្ងន់ ហើយបានមកសម្រាកព្យាបាលនៅមន្ទីរពេទ្យតំបន់៣៣អស់រយៈពេល១ខែ ។ បន្ទាប់ពីជាសះស្បើយពីជំងឺ រី បានសុំអនុញ្ញាតពីប្រធានកងមកសួរសុខទុក្ខឪពុកម្ដាយនៅផ្ទះបានរយៈពេល២ថ្ងៃ (ក្រោយពីនោះមកគាត់ពុំបានមកលេងផ្ទះរហូតដល់ឆ្នាំ១៩៧៩) ។

នៅដើមឆ្នាំ១៩៧៥ គុប រី ត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅម្ដុំវត្តស្លែងខាងលិចទីក្រុងភ្នំពេញ ។ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រី បានទទួលភារកិច្ចជួសជុលផ្លូវជាតិលេខ៣ ។ នៅពេលនោះ រី បានឃើញការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញយ៉ាងតក់ក្រហល់ ។ ក្រោយមក រី ត្រូវអង្គការចាត់តាំងឲ្យមកធ្វើស្រែនៅម្ដុំវត្តស្លែងរហូតដល់ចប់រដូវទើបផ្លាស់ទៅធ្វើស្រែនៅខេត្តតាកែវវិញម្ដង ។ យប់មួយនៅចុងឆ្នាំ១៩៧៦ វេលាម៉ោង១១ ប្រធានរបស់ រី បានប្រាប់ឲ្យ រី រៀបចំអីវ៉ាន់ដើម្បីចេញដំណើរ ប៉ុន្តែមិនបានបញ្ជាក់ថាទៅទីណាឡើយ ។ ពេលធ្វើដំណើរមកដល់ចោមចៅទើបប្រធានរបស់ រី ប្រាប់ថា អង្គការឲ្យមកធ្វើការងារនៅភ្នំពេញ ។ រី ស្នាក់នៅបឹងបាយាប ដោយមានតួនាទីបើករថយន្តដឹកស្រូវនិងអង្ករទៅតាមខេត្តផ្សេងៗ ដូចជាខេត្តកំពង់ចាម តាកែវ កំពត ជាដើម ។ នៅជើងទីមួយ ដែល រី ដឹកស្រូវទៅខេត្ត គាត់ឃើញប្រជាជនហូបបាយ ។ ជើងទីពីរ គាត់ឃើញប្រជាជនហូបបបរ ។ រី មិនហ៊ានសួរដេញដោលប្រជាជនទាំងនោះទេ ហើយប្រជាជនក៏មិនហ៊ាននិយាយជាមួយ រី ដែរ ។

នៅដើមឆ្នាំ១៩៧៨ ប្រធានរបស់ រី ឈ្មោះ វិន បានហៅ រី ឡើងឡានទៅព្រៃជ្រៅ ម្ដុំតាខ្មៅ ដើម្បីដាំដំណាំ ។ មួយសប្ដាហ៍ក្រោយមក រី និងមិត្តភក្តិ៧នាក់ទៀត ត្រូវអង្គការបញ្ជូនតាមរថយន្តរ៉ឺម៉ូវែមកមន្ទីរស-២១ ។ រី មិនដឹងពីមូលហេតុដែលអង្គការបញ្ជូនគាត់មកទីនេះឡើយ ។ រី បានរំឭកសម្ដីរបស់ប្រធានកងនៅមន្ទីរស-២១ថា "មិត្តណាការពារកម្មាភិបាលមិនបាន និងប្រើប្រាស់របស់របរខ្ជះខ្ជាយ ត្រូវទទួលទោសដោយខ្លួនឯង" ។ រី បានបញ្ជាក់ថា គាត់គ្មានធ្វើអ្វីឲ្យខុសក្រៅតែពីធ្វើឲ្យបែកកង់ឡាននិងខូចរបស់ប្រើប្រាស់នៅក្នុងឡានបន្តិចបន្តួចប៉ុណ្ណោះ ។ មកដល់មន្ទីរស-២១ភ្លាម កងការពារនៅទីនោះបានហៅគ្នាគាត់ទាំង៨នាក់អង្គុយផឹកទឹកតែនិងហូបចំណីអាហារ ។ ក្រោយពីហូបអាហាររួចរាល់ហើយ កងការពារបានចាប់គាត់និងមិត្តភក្តិដាក់ខ្នោះចងភ្នែកជិត ហើយបណ្ដើរយកទៅជាន់ទី២

ដោយទាត់ធាក់ពីក្រោយផង ។

នៅអគារខាងលើមានខណ្ឌជាបន្ទប់តូចៗជាច្រើនដែលមានទទឹងប្រមាណ១ម៉ែត្រសម្រាប់ដាក់អ្នកទោសម្នាក់ៗ ។ រី និង មិត្តភក្តិទាំង៧នាក់ ត្រូវដាក់នៅក្នុងបន្ទប់ផ្សេងៗពីគ្នានិងជាប់ខ្នោះជើងទាំងពីរ ។ រី ជាប់នៅក្នុងគុកទួលស្លែងអស់រយៈពេលមួយខែ ។ មួយសប្តាហ៍ដំបូង គាត់បានទទួលរបបបាយសម្រាប់ហូប ប៉ុន្តែក្រោយៗមកទៀតគាត់បានទទួលតែបបររាវប៉ុណ្ណោះ ។ រី ត្រូវសន្តិសុខយកទៅសួរចម្លើយចំនួនពីរដង ។ នៅពេលបណ្តើរចេញពីបន្ទប់ឃុំឃាំងទៅបន្ទប់សួរចម្លើយ សន្តិសុខបានដាក់ខ្នោះដៃរបស់ រី និងចងភ្នែកគាត់ជិត ។ ទៅដល់បន្ទប់មួយទើបសន្តិសុខស្រាយក្រណាត់ចងមុខគាត់ចេញ ។ រី ឃើញមិត្តភក្តិរបស់គាត់ទាំងប្រាំពីរនាក់នៅជួបជុំគ្នានៅក្នុងបន្ទប់នោះដែរ ។ បន្ទាប់មក សន្តិសុខបានហៅអ្នកទាំងប្រាំបីចូលក្នុងបន្ទប់សួរចម្លើយម្តងម្នាក់ ។ អ្នកសួរចម្លើយបានសួរ រី ថា “មិត្តឯងធ្វើអីខុស?” រី ឆ្លើយតបទៅវិញថា “ខ្ញុំមិនដឹងរឿងអ្វីទេ” ។ “តើមិត្តឯងបានបំផ្លាញអ្វីខ្លះរបស់បក្ស?” រី ឆ្លើយទៀតថា “ខ្ញុំអត់មានបំផ្លាញអ្វីទេ ខ្ញុំដាំដំណាំធម្មតាទេ” ។ អ្នកសួរចម្លើយសួរទៀតថា “មិត្តឯងចង់ស្លាប់ឬចង់រស់?” រី ឆ្លើយថា “ឥឡូវខ្ញុំប្រគល់ខ្លួនឲ្យបក្ស បើបក្សចង់ឲ្យខ្ញុំរស់ក៏រស់ ។ បើបក្សចង់ឲ្យខ្ញុំស្លាប់ក៏ស្លាប់ ។” ពេលសួរចម្លើយ មានកម្មាភិបាលម្នាក់ជាអ្នកចាំកត់ត្រា ។ សួរចម្លើយលើកទី១ រី មិនត្រូវបានធ្វើទារុណកម្មឡើយ ។ រយៈពេលពីរសប្តាហ៍បន្ទាប់មក រី ត្រូវហៅទៅសួរចម្លើយជាលើកទី២ ។ ម្តងនេះខុសប្លែកពីការសួរនៅលើកទី១ ។ មុនពេលសួរចម្លើយ រី ត្រូវនាំទៅថតរូបសិន ។ ក្នុងពេលសួរចម្លើយ រី ត្រូវអ្នកសួរចម្លើយវាយនឹងរំពាត់ផ្តៅ ដោយសារតែគាត់មិនព្រមសារភាពតាមអ្វីដែលអ្នកសួរចម្លើយចង់បាន ។ ចំណែកមិត្តភក្តិរបស់គាត់ម្នាក់ឈ្មោះ ធី ត្រូវអ្នកសួរចម្លើយវាយរហូតដល់ហើមពេញខ្លួន ។

រី ជាប់នៅក្នុងមន្ទីរស-២១ អស់រយៈពេលមួយខែទើបត្រូវបញ្ជូនឲ្យទៅលត់ដំនៅមន្ទីរស-២១យ (មន្ទីរព្រៃស) ដែលគ្រប់គ្រងដោយ ហ៊ុយស្រែ ។ នៅមុនពេលចេញពីមន្ទីរ ស-២១ គាត់ត្រូវហៅទៅថតរូបម្តងទៀត ។ ក្នុងចំណោមគ្នារបស់គាត់ទាំង៨នាក់ មានតែ៦នាក់ប៉ុណ្ណោះដែលត្រូវបញ្ជូនទៅមន្ទីរស-២១យ ចំណែកពីរនាក់ទៀតនៅជាប់ក្នុងមន្ទីរស-២១ដដែល ។ មុនពេល រី ចេញដំណើរទៅមន្ទីរព្រៃស ឌុច បានផ្តែផ្តាំថា “ពួកអ្អែងទៅខិតខំប្រឹងប្រែងធ្វើការ បើទៅមិនខំធ្វើការប្រយ័ត្នមកម្តងទៀត” ។

មកដល់មន្ទីរព្រៃសដំបូង រី មានតួនាទីជាអ្នកបោសសម្អាតនៅក្នុងមន្ទីរ ។ រយៈពេល១០ថ្ងៃក្រោយមក រី ទទួលខុសត្រូវជាអ្នកឲ្យចំណីជ្រូក ហើយចុងក្រោយធ្វើជាចុងភៅនៅក្បែរមន្ទីររបស់ ហ៊ុយស្រែ ។ រី បាននិយាយថា គាត់បានឃើញ ហ៊ុយស្រែ តែមួយរយៈខ្លីប៉ុណ្ណោះក៏លែងឃើញមុខទៀត ។ រី បានដឹងតាមរយៈនិរសារនៅមន្ទីរព្រៃសថា ហ៊ុយស្រែ និងប្រពន្ធកូន ត្រូវអង្គការចាប់បញ្ជូនទៅមន្ទីរស-២១ ។ (នៅក្នុងបញ្ជីឈ្មោះអ្នកទោសគុកពិសេសរបស់មន្ទីរ ស-២១ បានបញ្ជាក់ថា ហ៊ុយស្រែ និងប្រពន្ធត្រូវចាប់ខ្លួនថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៨ ហើយយកទៅដាក់នៅគុកពិសេស ។ ហ៊ុយស្រែ បានបញ្ចប់ចម្លើយសារភាពនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៨ ។ សាន់ ចាន់ អតីតយុទ្ធនារីនៅមន្ទីរព្រៃស បានបញ្ជាក់ថា ហ៊ុយស្រែ ត្រូវអង្គការចាប់យកទៅសម្លាប់ចោលដោយចោទប្រកាន់ថាបានចូលដៃជាមួយយួន) ។

ក្រោយឆ្នាំ១៩៧៩ តុប រី បានវិលត្រឡប់មកភូមិកំណើតវិញ និងបានដឹងថាឪពុករបស់គាត់ស្លាប់បាត់បង់ជីវិតនៅក្នុងឆ្នាំ១៩៧៦ ដោយសារជំងឺព្រោះគ្មានថ្នាំគ្រប់គ្រាន់សម្រាប់ព្យាបាល ។ រី រៀបការនៅឆ្នាំ១៩៨០ និងមានកូន៩នាក់ ។ ជារឿយៗ រី តែងរំឭករឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមប្រាប់ប្រពន្ធកូននិងសាច់ញាតិរបស់គាត់ ប៉ុន្តែកូនប្រុសច្បងរបស់គាត់ឈ្មោះ រឿន ពុំជឿឡើយ ។ នៅពេលធំឡើង រឿន បានទៅមើលសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង (អតីតមន្ទីរស-២១) ហើយបានប្រទះឃើញរូបថតឪពុករបស់ខ្លួនដែលដាក់តាំងនៅទីនោះជាមួយរូបថតជនរងគ្រោះនិងជនដៃដល់ជាច្រើនទៀត ។ ពេលនោះទើប រឿន ជឿថាអ្វីដែលឪពុករបស់ខ្លួនបាននិយាយប្រាប់គឺជាការពិត ។

**ប៉ាង ពីរ័ន**

# ប្រឹងរស់ដើម្បីកូន

យ៉ាន់ ឈីម អាយុ៥២ឆ្នាំ ជាស្ត្រីមេម៉ាយមានកូនស្រី ៣នាក់ រស់នៅភូមិត្រពាំងស្តុក ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ប្រកបរបរធ្វើស្រែនិងត្បាញហូលជាមួយ ។ ប្តីរបស់គាត់ឈ្មោះ មាស ប៉ា ត្រូវខ្មែរក្រហមយកទៅសម្លាប់នៅក្នុងឆ្នាំ១៩៧៧ ។


យ៉ាន់ ឈីម

ស្រុកកំណើតរបស់ ឈីម បានក្លាយទៅជាតំបន់រំដោះតាំងពីឆ្នាំ១៩៧២ ។ ចាប់តាំងពីពេលនោះមក ការធ្វើដំណើរចេញចូលតំបន់នេះត្រូវខ្មែរក្រហមរឹតបន្តឹង ។ ប្រជាជនមិនមានសេរីភាពពេញលេញក្នុងការដើរហើរទេ បើចង់ទៅណាមកណាត្រូវសុំការអនុញ្ញាតពីប្រធានភូមិជាមុន ។ ម្តាយក្មេករបស់ ឈីម ឈ្មោះ ស៊ូ គី មានដុះប្រជ្រុយមួយនៅខាងក្រោមភ្នែក ។ គ្រូពេទ្យប្រាប់គាត់ថា បើមិនប្រញាប់វះកាត់ទេ ប្រជ្រុយនេះនឹងអាចក្លាយទៅជាមហារីកនៅថ្ងៃក្រោយ ។ ដោយសារពេទ្យនៅក្នុងខេត្តមិនមានជំនាញគ្រប់គ្រាន់ក្នុងការវះកាត់ប្រជ្រុយនេះ យាយគី បានសុំអនុញ្ញាតពីប្រធានភូមិដើម្បីទៅវះកាត់នៅភ្នំពេញ ។ ប្រធានភូមិបានយល់ព្រមចេញលិខិតអនុញ្ញាតឲ្យយាយទៅតែរយៈពេល១៥ថ្ងៃប៉ុណ្ណោះ ។ ពេលវះកាត់ប្រជ្រុយនៅភ្នំពេញរួចរាល់ហើយ យាយគី បានវិលត្រឡប់មកស្រុកវិញស្របពេលដែលមានយន្តហោះមកទម្លាក់គ្រាប់បែកដាក់ភូមិដែរ ។ អ្នកភូមិបានចោទប្រកាន់ យាយគី ថាជាអ្នករាយការណ៍ឲ្យខាង លន់ ណុល ទើបមានយន្តហោះមកទម្លាក់គ្រាប់បែបនេះ ។ ការចោទប្រកាន់នេះបានបញ្ចប់ទៅវិញដោយសារប្រធានភូមិដែលជឿជាក់លើភាពស្មោះត្រង់របស់ យាយគី បានអះអាងចំពោះមុខប្រជាជននៅក្នុងភូមិថា យន្តហោះមកទម្លាក់គ្រាប់បែកនេះមិនមែន យាយគី ជាអ្នករាយការណ៍ទេ ។ រឿងរ៉ាវនេះបានកើតឡើងនៅក្នុងអំឡុងឆ្នាំ១៩៧២ ។

កាលណោះ ឈីម មិនបានរស់នៅក្នុងភូមិស្រុកកំណើតជួបជុំឪពុកម្តាយបងប្អូនទេ ។ គាត់រស់នៅបឹងទំពុន ក្រុងភ្នំពេញជាមួយប្តីរបស់គាត់និងកូនស្រីពីរនាក់ ។ ប្តីរបស់ ឈីម ជាបុគ្គលិកនៅក្រុមហ៊ុនអគ្គិសនីវត្តភ្នំតាំងពីឆ្នាំ១៩៦៩ ហើយក្រុមគ្រួសារនេះមានជីវភាពសមរម្យ ។

ក្រុមគ្រួសាររបស់ ឈីម ត្រូវខ្មែរក្រហមបណ្តេញចេញពីផ្ទះសម្បែងនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ ពោលគឺមួយថ្ងៃបន្ទាប់ពីខ្មែរក្រហមដណ្តើមបានអំណាចទូទាំងប្រទេស ។ ឈីម និងក្រុមគ្រួសារ បានធ្វើដំណើរយ៉ាងលំបាកជាទីបំផុតជាមួយមនុស្សម្នាច្រើនស្អេកស្កះពាសពេញផ្លូវឆ្ពោះទៅទិសដៅខុសៗគ្នា ។ ឈីម មានបំណងចង់ទៅស្រុកកំណើតរបស់គាត់ណាស់ ប៉ុន្តែដោយពេលនោះអាកាសធាតុក្តៅហួតហែងពេក និងដោយសារគាត់មានកូនតូចៗផង គាត់បានសម្រេចចិត្តឆ្លងស្ពានព្រះមុនីវង្សទៅត្រើយខាងកើតហើយបន្តដំណើរតាមបណ្តោយទន្លេបាសាក់ដើម្បីងាយស្រួលរកទឹកប្រើ ។ ពេលធ្វើដំណើរ ឈីម បានឃើញសាកសពជាច្រើនរដូករណែលតាមដងផ្លូវ ក្នុងផ្ទះ និងតាមដងទន្លេ ។ អស់រយៈពេលបួនយប់ប្រាំថ្ងៃក្រោយមក ក្រុមគ្រួសាររបស់ ឈីម មកដល់ភូមិលេខ៩ ឃុំពោធិ៍បាន ស្រុកកោះធំ ខេត្តកណ្តាល ដែលជាស្រុកកំណើតឪពុករបស់គាត់ ។

ឈីម បានឲ្យដឹងថា កាលពីដំបូង ប្រជាជន១៧មេសា ដែលបានមកដល់ស្រុកកោះធំមានចំនួនច្រើនដែរ ប៉ុន្តែបន្ទាប់ពីស្នាក់នៅបានមួយរយៈពេលខ្លី អង្គការក៏ជម្លៀសអ្នកទាំងនោះឲ្យទៅនៅខេត្តបាត់ដំបងវិញ ។ គ្រួសាររបស់ ឈីម ក៏មានឈ្មោះត្រូវទៅបាត់ដំបងដែរ ប៉ុន្តែដោយសារពេលនោះប្អូនថ្លៃរបស់គាត់មានជំងឺគ្រុនញាក់មិនអាចធ្វើដំណើរបាន អង្គការក៏អនុញ្ញាតឲ្យ

ក្រុមគ្រួសាររបស់គាត់រស់នៅក្នុងស្រុកកោះធំដដែល ។

នៅឆ្នាំ១៩៧៥ ស្រុកកោះធំមិនទាន់បង្កើតសហករណ៍នៅឡើយទេ ប្រជាជននៅហូបបាយតាមផ្ទះរៀងៗខ្លួននៅឡើយ ។ ឈីម និយាយទៀតថា ការហូបចុករវាងអ្នកថ្មី (អ្នក១៧មេសា) និងអ្នកមូលដ្ឋានមិនស្មើគ្នាទេ ។ ប្រជាជនមូលដ្ឋានមានស្រូវអង្ករដែលជាកម្មសិទ្ធិរបស់ខ្លួនឯង ចំណែកប្រជាជនថ្មីត្រូវរង់ចាំរបបដ៏តិចតួចស្តួចស្តើងដែលអង្គការចែកឲ្យ ។

នៅឆ្នាំ១៩៧៦ រដ្ឋអំណាចស្រុកកោះធំបានចាប់ផ្តើមរៀបចំបង្កើតសហករណ៍ ។ ប្រជាជនត្រូវបែងចែកជាបីកង ។ កងទី១ ហៅថា «កងពេញសិទ្ធិ» គឺប្រជាជនដែលជាអតីតកសិករមូលដ្ឋានក្រីក្រ បាតដៃទទេ គ្មានទ្រព្យសម្បត្តិ គ្មានកម្មសិទ្ធិដីស្រែចម្ការ ។ ប្រជាជនដែលនៅក្នុងកងនេះមានតួនាទីធ្វើជាប្រធានកង ប្រធានក្រុម ក្តោបក្តាប់កងពីរផ្សេងទៀត ។ ប្រជាជនក្នុងកងនេះធ្វើតែការងារស្រាលៗដូចជាដើរបេះបន្លែ ដេញចាបជាដើម ។ កងទី២ ហៅថា «កងត្រៀម» គឺជាអតីតប្រជាជនមូលដ្ឋានដែរ ប៉ុន្តែមានជីវភាពខ្ពស់បន្តួរ មានទ្រព្យសម្បត្តិ មានកម្មសិទ្ធិដីស្រែចម្ការ ។ ចំណែកការងារមិនសូវជាលំបាកប៉ុន្មានទេ ។ កងទី៣ ហៅថា «កងផ្ញើ» ។ ប្រជាជននៅក្នុងកងផ្ញើនេះជាប្រជាជន១៧មេសាសុទ្ធសាធ ។ ក្នុងចំណោមកងទាំងបីខាងលើ កងទី៣ធ្វើការយ៉ាប់យ៉ឺនបំផុត ហើយការហូបចុកវិញក៏ខ្វះខាតបំផុតដែរ ។

ឈីម ស្ថិតនៅក្នុងកងទី៣ (កងផ្ញើ) ។ គាត់ត្រូវធ្វើការងារជាច្រើននិងគ្មានរបបហូបចុកគ្រប់គ្រាន់ បណ្តាលឲ្យរាងកាយចុះស្គម ។ ឈីម មានខោអាវតែមួយចង្កេះផ្លេះជាប់នឹងខ្លួន ពេលចុះធ្វើការទទឹកខ្លួនជោក ដល់ពេលឈប់សម្រាក គាត់ពាក់អាវទទឹកដដែលនេះរហូតដល់ស្ងួតវិញ ។

ក្នុងឆ្នាំ១៩៧៦នេះ ឈីម មានផ្ទៃពោះហើយសម្រាលបានកូនស្រីម្នាក់ ។ ប្រធានកងបានអនុញ្ញាតឲ្យ ឈីម ឈប់សម្រាករយៈពេល២០ថ្ងៃ បន្ទាប់មកត្រូវចុះទៅធ្វើការវិញ ។ មុនពេលទៅធ្វើការ ឈីម ត្រូវយកកូនតូចៗទាំង៣នាក់ទៅដាក់នៅមណ្ឌលកុមារបីកន្លែងផ្សេងៗគ្នា ។ ឆ្នាំនោះជាឆ្នាំរាំង ទឹកធំ ផ្លូវមួយចំនួនត្រូវទឹកលិចដោយអន្ទើៗ ។ ឈីម ត្រូវដើរកាត់ទឹកត្រឹមៗដើមទ្រូងទៅមកៗជាច្រើនសាដើម្បីចម្លងកូនតូចៗទាំង៣ ។ បន្ទាប់ពីយកកូនៗទៅដាក់នៅមណ្ឌលកុមារអស់ហើយ ទើប ឈីម ទៅធ្វើការនៅក្នុងអង្គភាពរបស់គាត់ដោយដើរផងរត់ផងឲ្យទាន់ពេលវេលា ។ ពេលល្ងាច អ្នកមូលដ្ឋានទៅយកកូនចៅមកផ្ទះវិញស្ងាត់ឈឹងអស់ នៅសល់តែកូនរបស់ ឈីម ដែលត្រូវមូសរោមខាំពេញខ្លួន ពីព្រោះទម្រាំគាត់ត្រឡប់មកពីធ្វើការគឺព្រលប់ទៅហើយ ។ ថ្ងៃមួយ ពេលកូនរបស់គាត់ឈឺ ឈីម បានសុំមេកងទៅមើលកូននៅឯផ្ទះ មេកងបានចំអកឲ្យគាត់វិញថា «មិត្តឯងពេទ្យឬ?» ។ ទោះបីជាមេកងចំអកឡកឡឺយឲ្យគាត់យ៉ាងណាក៏ដោយ ក៏ ឈីម នៅតែទទូចអង្វរកររហូតដល់មេកងយល់ព្រមឲ្យមកមើលកូនចន្លោះម៉ោងពេលឈប់សម្រាកថ្ងៃត្រង់ ប៉ុន្តែបានដាក់កម្រិតឲ្យគាត់ត្រឡប់ទៅធ្វើការវិញឲ្យទាន់ពេលវេលា ។ បានការអនុញ្ញាតពីមេកងហើយ ឈីម មិនរវីរវល់បាយទឹកឡើយ ។ គាត់ដើរផងរត់ផងមកផ្ទះដែលមានចម្ងាយផ្លូវប្រហែលប្រាំគីឡូម៉ែត្រ ។ នៅពេលឃើញមុខម្តាយ កូនរបស់ ឈីម ដើរឆ្វេឆ្វាចុះឡើងៗនៅលើផ្ទះដោយត្រេកអរពេក មិនបានប្រយ័ត្នក៏ធ្លាក់មកដីបែកក្បាលចេញឈាមរហូតដល់សន្លប់ ។ ឈីម រន្ធត់ជាខ្លាំងយំបណ្តើរស្រែកហៅអ្នកជិតខាងឲ្យជួយកូនបណ្តើរ ។ ភ្លាមៗនោះ អ្នកមូលដ្ឋានដែលនៅផ្ទះជិតខាងគ្នាបានយកថ្នាំមកជួយលាបរឹតរហូតកូនគាត់បានដឹងខ្លួនឡើងវិញ ។ អ្នកមូលដ្ឋានមួយចំនួនបានប្រើសម្តីចំអកឲ្យ ឈីម ថា «ហ្នឹងហើយជ្រួលជ្រើមៗមករកកូន ទាល់តែកូនធ្លាក់ពីលើផ្ទះរហូតដល់សន្លប់បែបនេះ» ។ ឈីម ឈឺចាប់ក្នុងចិត្តណាស់ ប៉ុន្តែគាត់នៅស្ងៀមមិនតបតឡើយ ។ ពេលនាំកូនទៅដាក់លើផ្ទះហើយ ឈីម រូតរះវិលត្រឡប់ទៅធ្វើការវិញឲ្យទាន់ពេលកំណត់ ។

កូនស្រីទី៣របស់ ឈីម មានជំងឺគ្រុនក្តៅ កម្មាភិបាលពេទ្យខ្មែរក្រហមបានឲ្យថ្នាំគ្រាប់ពណ៌ខ្មៅៗមកលេប ។ ឈីម រៀបរាប់ថា «ឈឺពោះក៏ឲ្យលេបថ្នាំហ្នឹង ឈឺក្បាលក៏លេបថ្នាំហ្នឹង គ្រុនចាញ់ក៏លេបថ្នាំហ្នឹងដែរ» ។ ដោយសារថ្នាំខ្មៅៗនោះមិនមានប្រសិទ្ធភាព កូនរបស់ ឈីម ក្តៅខ្លួនខ្លាំងឡើងៗរហូតប្រកាច់សរសៃបណ្តាលឲ្យខូចជើងម្ខាង ។ ពេលយប់ ឈីម និងប្តីបានលួចពកូនដើរសរសៀរតាមដងទន្លេ ទៅរកគ្រូពេទ្យម្នាក់ឈ្មោះ ប៉ូ ខេង ដែលគាត់ធ្លាប់ស្គាល់ពីមុន ឲ្យជួយព្យាបាល ។ គ្រូពេទ្យនោះ

បានយកថ្នាំដែលគាត់នៅមានសេសសល់ យកមកចាក់ឲ្យកូនស្រី ឈឹម រហូតបានជាសះស្បើយឡើងវិញ ប៉ុន្តែជើងម្ខាងនៅស្វិតបន្តិចដើរមិនដូចប្រក្រតី ។ ឈឹម បន្តទៀតថា «ពេលកូនខ្ញុំឈឺ ខ្ញុំខំដើរទៅរើសសន្ទុំពោតដែលសេសសល់ក្នុងចម្ការបាន២-៣ គីឡូក្រាម ដើម្បីដោះដូរត្រីសាច់យកមកឲ្យកូនហូប ប៉ុន្តែអ្នកមូលដ្ឋានមិនព្រមដូរឲ្យទេ ថែមទាំងស្តីឲ្យខ្ញុំថា «មិត្តឯងមកស៊ីដោយសារគេ ហេតុអីហ៊ានយកពោតទៅដូរត្រី? មិត្តឯងអីក៏ហ៊ានម្ល៉េះ? មិត្តឯងឲ្យដឹងខ្លួនខ្លះផង គេខំដោះម៉ោ» ។ ទោះបីជាត្រូវប្រមាថមើលងាយយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនដែលតបតនឹងគេវិញដែរ ចៀសវាងកុំឲ្យកើតមានរឿង» ។

នៅខែវិច្ឆិកា ឆ្នាំ១៩៧៧ ប្តីរបស់ ឈឹម ត្រូវខ្មែរក្រហមយកទៅសម្លាប់ដោយគាត់មិនបានដឹងទាល់តែសោះ ។ ឈឹម និយាយទាំងអួលណែនដើមកថា «ក្នុងឆ្នាំនោះ ប្តីរបស់ខ្ញុំត្រូវគេឲ្យទៅធ្វើការនៅកងផ្សេង ។ កងនោះគេដាក់សុទ្ធតែអ្នកថ្មី (អ្នក១៧មេសា) ។ ប្តីប្រពន្ធខ្ញុំបានឃើញមុខគ្នាតែនៅថ្ងៃដែលអង្គការរៀបចំធ្វើសន្និបាតក្នុងរវាងថ្ងៃ១០ ឬថ្ងៃ២០ម្តងប៉ុណ្ណោះ ។ ពេលធ្វើសន្និបាតម្តងៗ ប្រជាជនទាំងអស់ត្រូវអង្គការដាក់កំហិតឲ្យទៅចូលរួមប្រជុំ ។ អ្នកទៅចូលរួមប្រជុំត្រូវអង្គុយតាមក្រុមជាជួរៗ ។ អ្នកថ្មីអង្គុយមួយក្រុម អ្នកមូលដ្ឋានអង្គុយមួយក្រុម កងបុរសអង្គុយផ្សេង កងនារីអង្គុយផ្សេង ។ ប្តីខ្ញុំនៅក្នុងកងបុរស១៧មេសា ។ កងនេះតែងតែបាត់សមាជិកម្នាក់ឬពីរនាក់ជារៀងរាល់យប់ ។ រាល់ពេលប្រជុំខ្ញុំតែងលួចសម្លឹងរកមើលប្តីជានិច្ច ។ ពេលឃើញមុខប្តី ខ្ញុំលួចត្រេកអរក្នុងចិត្តថាឪប្តីអញនៅរស់ទេ ។ ដល់ខែ១១ ឆ្នាំ១៩៧៧ ប្រជាជនមូលដ្ឋានដែលអាណិតស្រឡាញ់រាប់អានខ្ញុំ បានមកប្រាប់ខ្ញុំថា «មិត្តឈឹម មិត្តឯងអត់ដឹងទេ ប្តីមិត្តឯងគេយកទៅបាត់ហើយ» ។ គ្រាន់តែឮប៉ុណ្ណឹងខ្ញុំចង់សន្លប់ ភ្លេចបាយភ្លេចទឹក អង្គុយបង្ហូរទឹកភ្នែកតែម្នាក់ឯង ។ ខ្ញុំមិនដឹងថាថ្ងៃណាដល់វេនខ្ញុំត្រូវស្លាប់ទេ ព្រោះជាធម្មតាឲ្យតែយកប្តីទៅសម្លាប់ចោលហើយ មិនយូរមិនឆាប់គេច្បាស់ជាយកប្រពន្ធទៅសម្លាប់ដែរ ។» ចាប់តាំងពីពេលនោះមក ឈឹម ខំប្រឹងប្រែងធ្វើការទ្វេឡើងទៀតដើម្បីជីវិតរស់និងដើម្បីអនាគតកូនៗ ។

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ជាថ្ងៃដែលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ឈឹម ក៏បាននាំកូនស្រីទាំងបីចាកចេញពីស្រុកកោះធំដែលជាទីកន្លែងពោរពេញទៅដោយភាពល្វីងជូរចត់ ខ្លោចផ្សា និរាសព្រាត់ប្រាស់ក្រុមគ្រួសារ វិលទៅរស់នៅភូមិកំណើតរបស់គាត់វិញ ។

**ឆេង ខ៉េង**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

## ពន្យល់ពាក្យខ្មែរក្រហម

◆ **អារម្មណ៍ៈ** គឺជាមែកធាងរបស់ចិត្តដែលនឹកឃើញអ្វីមួយ រូបិក្តី អរូបិក្តី ។

◆ **ពលករៈ** អ្នកធ្វើការដោយកម្លាំងញើសឈាម មានតែបាតដៃទទេ ។

◆ **អរិយធម៌ៈ** គឺជាទំនៀមទម្លាប់ប្រពៃណីសង្គម ស្ថាបត្យកម្មផ្សេងៗដែលមាននៅក្នុងសង្គម សិល្បៈ អក្សរ ។ល ។

◆ **ប្រវត្តិសាស្ត្រៈ** ស្នាដៃផ្សេងៗដែលមានពីបុរាណនៅក្នុងសង្គម ក៏ដូចអង្គរនិងស្នាដៃរបស់វីរបុរសតស៊ូជំនាន់មុនៗបានចងក្រងទុក ។

◆ **សុភមង្គលៈ** សប្បាយមិនខ្វល់ខ្វាយលំបាកដោយហេតុការណ៍អ្វីមួយ ។ ដូចសង្គមយើងសព្វថ្ងៃនេះហៅសង្គមមានសុភមង្គល ។

(ដកស្រង់ពីកំណត់ហេតុរបស់សមមិត្ត អ៊ីវ ពេជ្រ)

# ប្រធានាធិបតីសហរដ្ឋអាមេរិក ជីមមី ខាធ័រៈ សិទ្ធិមនុស្ស និង កម្ពុជា

**(តចប់)**

លីនឌុន ប៉ូមហ្វៀល លើកឡើងថា «មានការបើកច្រកខ្វះឲ្យចូលទៅក្នុងប្រទេសកម្ពុជា» ។ ទំនិញកំពុងតែត្រូវបានដឹកជញ្ជូនតាមច្រកទន្លេមេគង្គ ។ ជើងយន្តហោះជាច្រើនបានកើនឡើងពីមួយទៅបួនជើង ។ មន្ត្រីអន្តរជាតិក៏មានចំនួនកើនឡើងដែរ ។ ប៉ូមហ្វៀល ទទួលស្គាល់ថា បញ្ហានេះនៅតែ«អាក្រក់ខ្លាំង»ដដែល ប៉ុន្តែមានសញ្ញាបញ្ជាក់អំពីការឈានទៅមុខ ហើយ នីមមីត ក៏យល់ស្របថា ស្បៀងអាហារមួយចំនួនកំពុងត្រូវបានចែកចាយ ។ លោកមានប្រសាសន៍ថា បញ្ហាដែលកើតឡើងគឺបញ្ហាភ័ស្តុភារ និងនយោបាយ ។ ហ្សេហ្ស៊ីនគី មិនអត់ឱនដល់ភាពមិនច្បាស់លាស់ឡើយ ។ ហេតុដូចនេះហើយបានជានៅថ្ងៃទី៣ ខែធ្នូ ហ្សេហ្ស៊ីនគី បានបញ្ជាឲ្យក្រសួងការបរទេសពន្យល់អំពីអ្វីដែលខ្លួនកំពុងតែផ្សព្វផ្សាយអំពីកិច្ចខិតខំរបស់វៀតណាមក្នុងការបដិសេធមិនឲ្យស្បៀងអាហារបានដល់ដៃប្រជាជនកម្ពុជាដែលទីទ័លក្រ ។ ចំពោះបញ្ហាសេ.អ៊ី.អាវិញកាន់តែគ្រោតគ្រាតទៅទៀត ។ ភ្នាក់ងារសម្ងាត់នេះបានដាក់ទិសដៅ «ដោយយកភាពបន្ទាន់ជាមូលដ្ឋាន» ដើម្បីផ្សព្វផ្សាយឲ្យបានទូលំទូលាយតាមតែអាចធ្វើទៅបានអំពី «នយោបាយបង្អត់អាហារ» របស់វៀតណាម ។ គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេថា «សេចក្តីថ្លែងការណ៍អំពីបញ្ហាកម្ពុជា» របស់មន្ត្រីសេតវិមានដែលចេញផ្សាយនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៩ បានបង្ហាញអំពីវិធីសាស្ត្រតឹងរ៉ឹងរបស់ ហ្សេហ្ស៊ីនគី ។ សេចក្តីថ្លែងការណ៍នេះបានបញ្ជាក់ថា ការដែលវៀតណាមចូលមកក្នុងប្រទេសកម្ពុជា បាននាំមកឲ្យកម្ពុជានូវ«រលកថ្មីនៃការគាបសង្កត់ គ្រោះទុរ្ភិក្ស និងជំងឺតម្កាត់» ។ វៀតណាមនិងអាជ្ញាធរហេងសំរិនបាន «រាំងខ្ទប់ដោយចេតនា» មិនឲ្យជំនួយហូរចូលប្រទេសកម្ពុជា ។ ទាំងវៀតណាមនិងអាជ្ញាធរ ហេង សំរិន ត្រូវចោទប្រកាន់ថា មិនបានចែកចាយស្បៀងអាហារ ដាក់ពន្ធលើជំនួយសង្គ្រោះ (ដែលជាការដាក់ទម្ងន់បន្ថែមទៅលើការត្រដររស់របស់មនុស្ស) ដោយបង្វែរជំនួយនោះទៅឲ្យយោធានិងមន្ត្រីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានិងអ្នកគាំទ្ររបស់ខ្លួន ព្រមទាំងជួយដល់ការរាយដាក់គ្រាប់មីនដែលធ្វើឲ្យដីស្រែមិនអាចបង្កបង្កើនផលបាន ។

សេចក្តីថ្លែងការណ៍របស់រដ្ឋការនេះត្រូវបានតបវិញយ៉ាងឆាប់រហ័ស ។ ម៉ែរី ម៉ែកហ្គ្រូរី បានឆ្លើយតបវិញជាបន្ទាន់ថា «ប្រសិនបើរដ្ឋការប្រធានាធិបតី ជីមមី ខំប្រឹងផ្តល់ស្បៀងអាហារដល់ប្រជាជនកម្ពុជាឲ្យបានខ្លាំងដូចដែលរដ្ឋការនេះខិតខំបង្ខូចកេរ្តិ៍ឈ្មោះរដ្ឋាភិបាលកម្ពុជានោះ ម្ល៉េះសមគ្រោះទុរ្ភិក្សនឹងបញ្ចប់ក្នុងរយៈពេលតែមួយខែប៉ុណ្ណោះ» ។ ម៉ែរី សរសេរថា ប្រជាជនយល់ស្របថាការបែងចែកស្បៀងអាហារមិនគ្រប់គ្រាន់ នាំឲ្យគាត់កំពុងតែស្រេកឃ្លាន ។ ភាពខុសគ្នាគឺអាស្រ័យទៅតាមរបៀបវាយតម្លៃលើមូលហេតុនៃគ្រោះទុរ្ភិក្ស ។ ម៉ែរី បានសរសេរទៀតថា ខណៈដែលរដ្ឋការប្រធានាធិបតី ជីមមី ចោទប្រកាន់ថា សាធារណរដ្ឋប្រជាមានិតកម្ពុជាកំពុងតែ«បង្អត់អាហារប្រជាជនដោយចេតនាដោយសារហេតុផលនយោបាយ» អ្នកគ្រប់គ្រងការចែកចាយបានស្តីបន្ទោស«អ្នកចាត់ការកម្ពុជាដែលគ្មានបទពិសោធន៍ នៅក្មេង និងជ្រួលច្រាល និងកង្វះបច្ចេកវិទ្យា ទូរស័ព្ទ រថយន្ត និងខ្សែរថភ្លើង» ។

អ្នកដែលចុះធ្វើការផ្ទាល់ បានវាយតម្លៃខុសៗគ្នាទៅលើបញ្ហានៃការចែកចាយ ។ មន្ត្រីដែលធ្វើការនៅក្នុងអង្គការអក់ស្វាម យូនីសេហ្វ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ និងអង្គការផ្តល់ជំនួយសង្គ្រោះដទៃទៀត សុទ្ធតែបានយល់ស្របគ្នា គ្រាន់តែមានកម្រិតតិចឬច្រើនប៉ុណ្ណោះ អំពីការវាយតម្លៃទៅលើការគ្រប់គ្រងជំនួយសង្គ្រោះនេះ ។ អ្នកឆ្លងឆ្លើយពត៌មានញូវយ៉ក ថែម ហង់រី ខាម ដែលតែងតែងលើកឡើងជាសំខាន់ៗអំពីកង្វះខាតរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជានិងវៀតណាមបានរាយការណ៍ថា អ្នកគ្រប់គ្រងជំនួយសង្គ្រោះនៅទីក្រុងភ្នំពេញ «ពេញចិត្តចំពោះការចែកចាយនេះ» ។ សេចក្តីរាយការណ៍អំពីទឹកខ្មែងនិងការផារដាក់ស្តែងក៏សម្តែងអំពីចម្ងល់ទៅ

លើសុក្រឹតភាពដែលអាមេរិកបានអះអាងថាតាមពិតមិនមានជំនួយរបស់សូវៀតទេ ។ ដូចដែលមន្ត្រីគណៈកម្មាធិការកាកបាទក្រហមអន្តរជាតិនិងយូនីសេហ្វបានគូសបញ្ជាក់ថា រថយន្តសូវៀតជាង២០០គ្រឿងបានមកដល់នៅខែធ្នូ ហើយរថយន្តទាំងនោះនឹងជួយបង្កើនល្បឿនចែកចាយស្បៀងនិងជំនួយសង្គ្រោះដទៃទៀតជាមួយនឹងរថយន្តដែលនាំចូលថ្មីៗដោយអង្គការជំនួយអន្តរជាតិ ។

អ្នករិះគន់នានាក៏បានលើកឡើងយ៉ាងត្រឹមត្រូវថា សហរដ្ឋអាមេរិកធ្វើកិច្ចការពីរក្នុងពេលតែមួយ ពោលគឺគ្រប់គ្រងការចែកចាយសម្ភារនៅតាមព្រំដែនផងនិងនៅក្នុងប្រទេសផង ។ នៅក្នុងប្រទេសកម្ពុជា សហរដ្ឋអាមេរិកទទូចថាមិនត្រូវឲ្យជំនួយណាមួយបានទៅដល់កងទ័ពវៀតណាមទេ ហើយថា ត្រូវតែមានយន្តការត្រួតពិនិត្យទើបបាន ។ ផ្ទុយនឹងការនិយាយនេះ នៅតាមបណ្តោយព្រំដែន ជំនួយនេះត្រូវបានទុកឲ្យប្រជាជនមកយកដោយខ្លួនឯង ។ ភាគច្រើននៃជំនួយត្រូវបានយកត្រឡប់ចូលទៅក្នុងប្រទេសកម្ពុជា ដែលនៅទីនោះជំនួយអាចត្រូវយកទៅប្រើដោយកងយោធារួមទាំងកម្លាំងរបស់ប៉ុលពតផង ។ សូម្បីតែនៅពេលដែលការចែកចាយស្បៀងកាន់តែមានលក្ខណៈស្របគ្នាជាមួយនឹងគ្រឿងផ្គត់ផ្គង់ដែលចែកចាយដល់ជំរំជនភៀសខ្លួននោះ ក៏នៅទីបំផុតជំនួយបានទៅដល់ដៃមេបញ្ជាការយោធានិងកងកម្លាំងប្រដាប់អាវុធ ក្នុងនោះរាប់បញ្ចូលទាំងខ្មែរក្រហមផង ។ ការស្ទាបស្ទង់មតិមួយរបស់អង្គការយូនីសេហ្វបានបញ្ជាក់ថា ជំនួយ៨៧ភាគរយនៅភាគនីមួយៗតាមព្រំដែនត្រូវបានគេបន្លំ ។ និយាយម្យ៉ាងវិញទៀត សហរដ្ឋអាមេរិកមិនបានគ្រប់គ្រងឲ្យជិតដល់ទៅលើជំនួយដែលចែកទៅក្នុងផ្ទៃប្រទេសកម្ពុជា គឺដើម្បីយកហេតុផលក្នុងការកម្រិតជំនួយមកឲ្យកម្ពុជា ប៉ុន្តែមិនបានគិតដល់កង្វះខាតការគ្រប់គ្រងជំនួយដែលចែកចាយនៅតាមបណ្តោយព្រំដែនទេ ទោះបីជាជំនួយមួយចំនួនបានទៅដល់ដៃ ប៉ុល ពត ក៏ដោយ ។

ទោះជាមានការរិះគន់ទាំងនេះក្តី រដ្ឋការប្រធានាធិបតីជីមមី នៅតែទទូចមិនឈប់ឈរ ប្រឆាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជានិងវៀតណាមដែលជាអ្នកគាំទ្ររបបនេះទៀត ។ ទីភ្នាក់ងារទំនាក់ទំនងអន្តរជាតិដែលទទួលបន្ទុកខាងផ្សព្វផ្សាយគោលនយោបាយថ្មីរបស់រដ្ឋការនេះ ធានាថា "សេចក្តីថ្លែងការណ៍អំពីកម្ពុជា" បានទៅដល់មិត្តអ្នកស្តាប់អន្តរជាតិដ៏ទូលំទូលាយតាមរយៈវិទ្យុសំឡេងសហរដ្ឋអាមេរិក ។ ទីភ្នាក់ងារនេះក៏បានផ្សព្វផ្សាយនូវសំណេររបស់ ចេមស៍ រ៉េស្តុន នៅក្នុងទំព័រកាសែតញូវយ៉កថែម ដោយផ្អែកលើរបាយការណ៍សម្ងាត់របស់អាមេរិកដែលមានបំណងបង្ខូចដល់កិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយសង្គ្រោះអន្តរជាតិនៅក្នុងប្រទេសកម្ពុជា ដោយលើកឡើងថា តាមពិតសហភាពសូវៀតជាអ្នកខ្ទប់ជំនួយកុំឲ្យទៅដល់ប្រជាជនដែលអស់សង្ឃឹមក្នុងជីវិត ហើយបែរជាយកជំនួយនេះទៅឲ្យវៀតណាមនិងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជាទៅវិញ ។

សហរដ្ឋអាមេរិកចេះតែបន្តផ្តោតការយកចិត្តទុកដាក់លើទិដ្ឋភាពនៃជនភៀសខ្លួនកម្ពុជានៅតាមព្រំដែនដែលខ្លួនបន្ទោសថាសាធារណរដ្ឋប្រជាមានិតកម្ពុជានិងវៀតណាមជាអ្នកបង្ក ។ ហ្សេហ្ស៊ីនគី សង្ឃឹមថានឹងលើកកម្ពស់ការផ្សព្វផ្សាយនិងខិតខំប្រឹងប្រែងផ្តល់ស្បៀងអាហារឲ្យដល់តំបន់នេះ ។ មានម្តងនោះលោកគិតដល់ការទម្លាក់ស្បៀងពីលើយន្តហោះឲ្យដល់តំបន់នៅជាប់ព្រំដែន ។ បន្តិចក្រោយមកទៀត លោកក៏សុំឲ្យរដ្ឋមន្ត្រីក្រសួងការបរទេសនិងរដ្ឋមន្ត្រីក្រសួងការពារជាតិ កំណត់ភាពងាយស្រួលក្នុងការទម្លាក់អង្ករតាមជើងយន្តហោះឲ្យដល់ព្រំដែនជាមួយនឹងរទេះគោដែលប្រជាជនប្រើសម្រាប់ដឹកស្រូវអង្ករចូលទៅក្នុងប្រទេសវិញ ។ លោកនិយាយថា វាក៏អាចទៅរួចដែរដែលឲ្យរថយន្តដឹកគ្រឿងសម្ភារនានាកាត់តាមព្រំប្រទល់ និងទម្លាក់ស្បៀងអាហារនៅទីនោះ ។ លីអូ ឈើនណេ ដែលជាប្រធានគណៈកម្មការពលរដ្ឋទទួលបន្ទុកជនភៀសខ្លួនឥណ្ឌូចិន ហើយដែលតែងតែធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋការប្រធានាធិបតី ជីមមី ខាតធ័រ បានយល់ស្របក្នុងការព្យាយាមរៀបចំក្បួនរថយន្តដឹកជំនួយដែលរៀបចំឡើង ដើម្បីដាក់សម្ពាធមកលើសាធារណរដ្ឋប្រជាមានិតកម្ពុជានិងទីក្រុងហាណូយឲ្យអនុញ្ញាតឲ្យក្បួនដឹកជំនួយសង្គ្រោះចូលដល់ក្នុងប្រទេសកម្ពុជាដោយកាត់តាមព្រំដែនប្រទេសថៃ ជាជាងកាត់តាមទីក្រុងភ្នំពេញ ។

ទោះជាគ្មានអ្វីគួរមន្ទិលសង្ស័យថាមានសេចក្តីត្រូវការជា

ចាំបាច់នូវស្បៀងអាហារនៅតាមព្រំដែនក៏ដោយ ចេតនារបស់ ប៊ីនីវ ហ្សេហ្ស៊ីនគី មានលក្ខណៈនយោបាយស្មើនឹងលក្ខណៈមនុស្សធម៌ ។ ភាគច្រើនគឺលោកផ្តល់ស្បៀងអាហារដល់ប្រជាជនដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ កិច្ចខិតខំប្រឹងប្រែងក្នុងការទទួលជំនួយឲ្យចូលជ្រៅទៅក្នុងប្រទេសកម្ពុជា រួមទាំងតំបន់ដែលគ្រប់គ្រងដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា ដូចជាក្បួនដឹកស្បៀងសង្គ្រោះចេញពីប្រទេសថៃ ត្រូវបានរៀបចំឡើងជាផ្នែកមួយនៃការធ្វើឲ្យអាម៉ាស់ដល់សាធារណរដ្ឋប្រជាមានិតកម្ពុជា ។ រួមសេចក្តីមក រដ្ឋការប្រធានាធិបតី ជីមមី ខាតធ័រ បានផ្សាញ់ផ្សាលជាមួយ ហេង សំរិន និងអ្នកគាំទ្រគាត់គឺវៀតណាមនិងសូវៀត ។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៩ ប៊ីនីវ ហ្សេហ្ស៊ីនគី បានសួរទាំងសោះកក្រោះទៅ វ៉ានស៍ ថា "ចូរប្រាប់យើងឲ្យដឹងផងនូវអ្វីដែលជាវិធានការបន្ថែមដែលក្រសួងការបរទេសមានចេតនាចង់ដាក់សម្ពាធថែមទៀតទៅលើរបបភ្នំពេញរបស់ ហេង សំរិន" ។ ទោះជាធ្វើសកម្មភាពផ្តល់ជំនួយជាស្បៀងអាហារដល់ប្រជាជនកម្ពុជាដែលអត់អាហារយ៉ាងណាក៏ដោយ ក៏ការគាបសង្កត់របស់រដ្ឋការ ជីមមី មកលើសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺធ្វើឡើងដោយមូលហេតុនយោបាយ ។

ការប្រើប្រាស់វិធីសាស្ត្រក្តៅមកលើសាធារណរដ្ឋប្រជាមានិតកម្ពុជាមិនអាចធ្វើឲ្យអ្នកទិតៀនស្ងាត់មាត់បានឡើយ ។ គីរ៉ាក់ អាលីមែន ថ្លែងថា ចំពោះរដ្ឋការប្រធានាធិបតី ជីមមី យល់ថា"សង្គ្រាមវៀតណាមមិនទាន់ចប់នៅឡើយទេ" ។ អាលីមែន បន្តការរិះគន់ចំពោះការវាយប្រហាររបស់រដ្ឋការ ជីមមី ទៅលើសាធារណរដ្ឋប្រជាមានិតកម្ពុជាតាមរយៈនាទីពត៌មាន *McNeil-Lehrer News* នៃប្រព័ន្ធផ្សព្វផ្សាយពត៌មានជាសាធារណៈដ៏មានឥទ្ធិពល និងតាមរយៈលិខិតទៅកាន់សារពត៌មានញូវយ៉កថែម ។ លោកបានជំរុញឲ្យមាន"ការទូតជាលក្ខណៈស្ងប់ស្ងាត់និងប្រកបដោយន័យស្ថាបនា" ដែលអាចធ្វើឲ្យប្រសើរឡើងដល់ការបែងចែកស្បៀងអាហារនៅក្នុងប្រទេសកម្ពុជា ។ វិធីសាស្ត្រនេះផ្ទុយស្រឡះពី ប៊ីនីវ ហ្សេហ្ស៊ីនគី ដែលចង់ឲ្យមានកិច្ចខិតខំប្រឹងប្រែងខ្លាំងក្លា ដែលមានលក្ខណៈពូកែអួតក្នុងការបង្ខំឲ្យយកស្បៀងអាហារចូលទៅក្នុងប្រទេសកម្ពុជាតាមច្រកព្រំដែនថៃ ។ អ្វីដែលកាន់តែក្តៅគគុកជាងនេះទៀតនោះ បានលេចចេញពីអ្នកសរសេរកាសែត ជែក អាន់ដឺសុន ដែលចេះតែបន្តវាយប្រហារមកលើនយោបាយរបស់រដ្ឋការ ជីមមី ចំពោះកម្ពុជា ។ ឧទាហរណ៍នៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៨០ លោកបានសរសេរម្តងទៀតអំពី"អ្នកបំផ្លិចបំផ្លាញមិនចេះអៀនខ្មាស" នៅក្នុងក្រសួងការបរទេសនិង (ដែលជាការបន្ថែមទៅលើ) ក្រុមប្រឹក្សាសន្តិសុខជាតិដែលត្រូវកំណត់ឲ្យ"ប្រើសេចក្តីរន្ធត់របស់កម្ពុជា ដើម្បីឲ្យពិន្ទុដល់យុទ្ធនាការសង្គ្រាមត្រជាក់" ។ លោកបានទាញហេតុផលថា ការបែងចែកស្បៀងនិងសម្ភារប្រើប្រាស់ដ៏សំខាន់គឺនៅតាមបណ្តោយព្រំដែនថៃ ដែលនៅទីនោះ មន្ត្រីពុករលួយថៃបានបង្វែរស្បៀងចំនួន៥០ភាគរយទៅលក់យកកម្រៃខ្ពស់ ហើយ"ក្រុមកងទ័ពរបស់ប៉ុលពតដែលសប្បាយលើគំនរទុក្ខរបស់អ្នកដទៃ" បានលួចស្បៀងដែលបម្រុងទុកឲ្យជនស៊ីវិល ។

ការវាយប្រហារនេះធ្វើឲ្យមន្ត្រីរដ្ឋការ ជីមមី ក្តៅក្រហាយយ៉ាងខ្លាំង ។ ទោះជាយ៉ាងណាក៏ដោយ មន្ត្រីទាំងនោះក៏ទទួលរងផលប៉ះពាល់ខ្លះដែរ ដូចជាមន្ត្រីក្រុមប្រឹក្សាសន្តិសុខជាតិ លីនខនប្លូមហ្វៀល ទោះជាគាត់មានក្តៅក្រហាយនឹង អាលីមែន និងមាក់ផាយចំពោះ អាន់ដឺសុន ក្តី ក៏គាត់នៅតែទទួលស្គាល់ថាការផ្គត់ផ្គង់ជំនួយសង្គ្រោះនេះដែលបញ្ជូនមកដល់ទីក្រុងភ្នំពេញត្រូវបានចែកចាយ ហើយអង្គការ អក់ស្វាម និង ឆឺច វើលស៊ីវីស ជាអ្នករ៉ាប់រងការផ្គត់ផ្គង់ ។ ឥស្សរជនមួយចំនួនរបស់រដ្ឋការ ជីមមី យល់ស្របចំពោះករណីរិះគន់នេះ ។ នៅក្នុងរបាយការណ៍មួយដែលប្រើពាក្យពេចន៍ដ៏ប្រុងប្រយ័ត្នជូនប្រធានាធិបតីជីមមី គណៈកម្មការរបស់ប្រធានាធិបតីទទួលបន្ទុកគ្រោះទុរ្ភិក្សពិភពលោកបាននិយាយថា ការរៀបចំចាត់ចែងភស្តុភារសម្រាប់យកគ្រឿងផ្គត់ផ្គង់ចូលក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះគឺ"គ្រប់គ្រាន់"ហើយ ។ នៅក្នុងអ្វីដែលគេយល់ថាជាការរិះគន់ទៅលើការរិះគន់ឥតកែប្រែរបស់ ប៊ីនីវ ហ្សេហ្ស៊ីនគី មកលើសាធារណរដ្ឋប្រជាមានិតកម្ពុជានោះ គណៈកម្មការនេះថ្លែងថារឿងរ៉ាវនៃការចាត់ចែងមិនល្អបានគំរាមកំហែងកាត់បន្ថយឆន្ទៈរបស់សាធារណជនក្នុងការគាំទ្រជំនួយមកសម្រាលទុក្ខកម្ពុជា ។

បន្ថែមពីលើនេះទៀត គណៈកម្មការទទួលស្គាល់ថា អ្នកគាំទ្រ ប៉ុល ពត បានទទួលផលប្រយោជន៍ពីកម្មវិធីនេះនៅតាមព្រំដែន ។ គណៈកម្មការគិតថាវាមិនមែនជានយោបាយគិតទុកជាមុនរបស់សហរដ្ឋអាមេរិកទេ ប៉ុន្តែវាជាលទ្ធផលនៃ “ទីតាំងភូមិសាស្ត្រនិងចលនាយោធា” (ដែលប្រហែលជាគេអាចទាញហេតុផលថានយោបាយនេះមានកម្លាំងអនុវត្តស្មើគ្នាចំពោះការផ្គត់ផ្គង់ជំនួយនៅក្នុងប្រទេសកម្ពុជា) ។

វីកទ័រ ផាលមៀរី ជាអ្នកសម្របសម្រួលកិច្ចការជនភៀសខ្លួនថ្មីរបស់លោក ជីមមី ក៏មានគំនិតប្រកបដោយតុល្យភាពជាងក្រុមប្រឹក្សាសន្តិសុខជាតិឬរដ្ឋមន្ត្រីក្រសួងការបរទេសដែរ ។ ផាលមៀរី និយាយទៅកាន់អ្នកសារព័ត៌មានថា គ្រោះទុរ្ភិក្សត្រូវបានត្រួតពិនិត្យបណ្ដោះអាសន្នរួចហើយនៅក្នុងប្រទេសកម្ពុជា មួយផ្នែកដោយកម្មវិធីផ្គត់ផ្គង់ស្បៀងអាហារដោយជោគជ័យនៅតាមព្រំដែន មួយផ្នែកទៀតដោយការប្រូតកាត់ថ្មីៗ មួយផ្នែកដោយភ្នាក់ងារអន្តរជាតិដែលដំណើរការនៅក្នុងទីក្រុងភ្នំពេញ និងមួយផ្នែកទៀតដោយសាធារណរដ្ឋប្រជាមានិតកម្ពុជាខ្លួនឯងផ្ទាល់ដែលបានចែកចាយពោតសូវៀត ។ ផ្អែកលើការពិភាក្សារបស់លោកជាមួយអ្នកធ្វើការខាងជំនួយសង្គ្រោះអន្តរជាតិ ផាលមៀរី បានរាយការណ៍ថា ការចែកចាយគ្រឿងផ្គត់ផ្គង់នៅក្នុងផ្ទៃប្រទេសកម្ពុជាបានជឿនលឿនទៅមុខហើយ ។ ឆ្លើយតបនឹងសំណួរថាតើហេតុអ្វីបានជាមានការពន្យារពេលយ៉ាងដូច្នេះ ផាលមៀរី បានត្រឹមតែឆ្លើយថា មានហេតុផលច្រើនយ៉ាង ។ គ្មានការប៉ុនប៉ងណាមួយក្នុងការថ្កោលទោសសាធារណរដ្ឋប្រជាមានិតកម្ពុជាឬវៀតណាមដែលជាអ្នកគាំទ្រខ្លួនឡើយ ។ ផាលមៀរី បានសង្កេតប្រហាក់ប្រហែលគ្នានេះនៅក្នុងរបាយការណ៍ផ្លូវការមួយគោរពជូនប្រធានាធិបតី ។ សូម្បីតែឯកអគ្គរដ្ឋទូត អាប្រាម៉ូវីត ប្រចាំនៅប្រទេសថៃ ក៏មិនជឿដែរថាបញ្ហាទាក់ទងនឹងការចែកចាយគ្រឿងផ្គង់ផ្គង់នៅក្នុងប្រទេសកម្ពុជាអាចថាដោយសារការរារាំងជិតាស់ដោយចេតនា ។ ឯកអគ្គរដ្ឋទូតរាយការណ៍ជូនក្រសួងការបរទេសថា “ប្រព័ន្ធចែកចាយរបស់ក្រុងភ្នំពេញដំណើរការមិនទាន់ដល់កម្រិត” ។ “ការចែកចាយមានលក្ខណៈរយីករយាកដោយសារប្រព័ន្ធដឹកជញ្ជូនកង្វះបទពិសោធន៍និងការផ្ដល់អាទិភាពដល់វៀតណាមនិង ហេង សំរិន” ។

ក្រសួងការបរទេសនិងមន្ត្រីសន្តិសុខជាតិនៅតែបន្តរិះគន់កាន់តែខ្លាំងទៅលើស្ថានការណ៍នៅក្នុងប្រទេសកម្ពុជា ។ ដោយហេតុផលគោលនយោបាយ (តាមឯកសាររបស់ក្រសួងការបរទេសដែលរៀបចំឡើងដោយ ហេ្សហ្សិនគី) វៀតណាមនៅតែជា“ឧបសគ្គចម្បង”ដល់កិច្ចខិតខំនាំជំនួយ ហើយប្រការនេះទំនងជាចេះតែបន្តដល់អនាគតដែលអាចមើលឃើញទៀតផង ។ គេទាញហេតុផលថា មានព័ត៌មានតិចតួចណាស់ដែលអាចយកជាការបានពីប្រទេសកម្ពុជាអំពីកម្មវិធីជំនួយសង្គ្រោះ ហើយធ្វើឲ្យខូចប្រយោជន៍ដល់ការវាយតម្លៃប្រកបដោយន័យវិជ្ជមានរបស់អង្គការស្ម័គ្រចិត្តដូចជា អក់ស្វាម, ឈើច វើល សឺវីស ដោយហេតុថា “ការរែអង្គាសប្រាក់ និង/ឬ នៅក្នុងករណីខ្លះសមានចិត្តនយោបាយរបស់ខ្លួន” មានផលប៉ះពាល់ដល់ការវាយតម្លៃ ដែលនេះគឺជាការវិភាគមួយដែលមិនយុត្តិធម៌ចំពោះក្រុមទាំងនេះ ហើយធ្វើមិនដឹងមិនឮដល់លទ្ធភាពដែលការប៉ាន់ស្មានរបស់រដ្ឋាភិបាលខ្លួនត្រូវបានលាយពណ៌ “សមានចិត្តនយោបាយ” ផ្សេងៗគ្នា ។ ចំពោះអនុសាសន៍របស់ ផាលមៀរី ជូនដល់លោក ជីមមី វិញ វាហាក់ដូចជាថា ហេ្សហ្សិនគី មិនយល់ស្របឡើយ ។

មិនតែប៉ុណ្ណោះ របាយការណ៍មកពីអង្គការស្ម័គ្រចិត្ត ឯកអគ្គរដ្ឋទូត ផាលមៀរី ប្រធានគណៈកម្មការគ្រោះទុរ្ភិក្សពិភពលោករបស់ប្រធានាធិបតី និងឯកអគ្គរដ្ឋទូត អាប្រា ម៉ូវីត មិនប៉ះពាល់ដល់ជំហររបស់រដ្ឋការ ជីមមី ឡើយ ហើយហាក់ដូចជាបានធ្វើឲ្យមន្ត្រីមួយចំនួនជឿទៀតផងថាមានការរីកចម្រើនទៅមុខទាក់ទងនឹងការចែកចាយជំនួយសង្គ្រោះនៅក្នុងផ្ទៃប្រទេស ។ ហេតុដូចនេះហើយបានជានៅក្នុងសុន្ទរកថាមួយទៅកាន់ក្រុមប្រឹក្សាទំនាក់ទំនងការបរទេសនៅថ្ងៃទី២ ខែមេសា ហូលប្រ៊ុកទទួលស្គាល់ថាមានការពិភាក្សាដេញដោលគ្នាអំពីថា តើមានស្បៀងអាហារប៉ុន្មានត្រូវបានបង្វែរខុសទិសដៅហើយដល់ដៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ប៉ុន្តែលោកទទួលស្គាល់ថាទីភ្នាក់ងារអន្តរជាតិនានាកំពុងតែរាយការណ៍ថា “ឥឡូវនេះស្បៀងកំពុងតែចេញទៅដល់ទីរួមខេត្តហើយ” ។

ប្រសិនបើរដ្ឋការ ជីមមី ត្រូវបានបង្ខំឲ្យទទួលស្គាល់ថាបញ្ហា

ភ័ស្តុភារ មន្ត្រីខុទ្ទកាល័យ និងហេដ្ឋារចនាសម្ព័ន្ធខេចខាំ ដោយខ្មែរក្រហមបំផ្លិចបំផ្លាញនោះ យ៉ាងហោចណាស់មួយផ្នែក និងប្រហែលជាសំខាន់ទៀតផង ជាការទទួលខុសត្រូវចំពោះការ យឺតយ៉ាវក្នុងការចែកចាយស្បៀង ។ ប្រសិនបើរដ្ឋការ ជីមមី ត្រូវតែយល់ស្របថាស្ថានការណ៍មានការរីកចម្រើនទៅមុខប៉ុន្មាន សប្តាហ៍ថ្មីៗ នេះដោយមានស្បៀងអាហារជាច្រើនដឹកឆ្លងកាត់ ប្រការនេះក៏មិនបានផ្លាស់ប្តូរដល់ការគិតគូរផ្នែកនយោបាយ ឡើយ ។ បើទោះជាសហរដ្ឋអាមេរិកប្រហែលជាបានបញ្ជូន ជំនួយមួយចំនួនតាមទីក្រុងភ្នំពេញដោយសារភាពបន្ទាន់និងធំ មហិមានៃភយន្តរាយផ្នែកមនុស្សធម៌ក៏ដោយ ក៏សហរដ្ឋអាមេរិក នៅតែរក្សានយោបាយរបស់ខ្លួនក្នុងការបង្ខំឲ្យវៀតណាមដក កងទ័ព ព្រមទាំងរដ្ឋាភិបាលដែលខ្លួនបានរៀបចំ ចេញពីប្រទេស កម្ពុជា ។ សរុបមកវិញ រដ្ឋការ ជីមមី អាចទទួលយកនូវការលំបាក ខ្លះៗ ចេញពីទស្សនៈរបស់ខ្លួនចំពោះស្ថានភាពជំនួយសង្គ្រោះ ប៉ុន្តែរដ្ឋការនេះមិនទទួលយកសំណើដែលសុំឲ្យខ្លួនផ្លាស់ប្តូរគោល នយោបាយជាមូលដ្ឋានចំពោះតំបន់នេះឡើយ ។

ដាក់ស្តែងនៅក្នុងការថ្លែងទៅកាន់ក្រុមប្រឹក្សាទំនាក់ទំនង ការបរទេស ហូលប្រ៊ុក បានលាបពណ៌វៀតណាមយ៉ាងចាស់ដៃ បំផុត ។ ជំនួយមួយចំនួនកំពុងតែឆ្លងកាត់ ប៉ុន្តែវៀតណាម "មិនបានជួយសម្រួលដល់បញ្ហានេះឡើយ" (ការវិនិច្ឆ័យសេចក្តី ដែលផ្ទុយទៅនឹងពត៌មានខាងលើ បានមកពីទីភ្នាក់ងារជំនួយ សង្គ្រោះអន្តរជាតិដែលនិយាយថាវៀតណាមកំពុងចែកចាយយ៉ាង ហោចណាស់នូវជំនួយមួយចំនួន) ។ ហូលប្រ៊ុក និយាយថា ជនភៀសខ្លួននៅតាមព្រំដែនថៃស្អប់វៀតណាមណាស់ ទោះជា ប្រ៊ុក ទទួលស្គាល់ដោយត្រង់ៗថាជនភៀសខ្លួននិយាយអំពី ប៉ុល ពត "ដោយអារម្មណ៍ក្តុកក្តួលនិងឈឺចាប់ជាងរឿងវៀតណាម ទៅទៀត"ក៏ដោយ ។ ជនភៀសខ្លួនមួយចំនួនថែមទាំងរិះគន់ការ ទម្លាក់គ្រាប់បែកដ៏ដូរចត់របស់អាមេរិកាំងនៅកម្ពុជានៅពេល ដែល លន់ ណុល ធ្វើជានាយករដ្ឋមន្ត្រី ។ តាមសម្តីរបស់ ហូលប្រ៊ុក គោលនយោបាយអាមេរិកគឺដើម្បីបញ្ចប់ការចូលរួម ខាងយោធារបស់សូវៀតនៅក្នុងប្រទេសវៀតណាមដើម្បីបញ្ចប់ ប្រតិបត្តិការយោធានៅកម្ពុជា និងដើម្បីផ្លាស់ប្តូររបប ហេង សំរិន ជាមួយរបបមួយដែលជាឆន្ទៈរបស់ប្រជាជន ។ នេះគឺជា អ្វីដែលមិនខុសពីគោលនយោបាយដែលស្តែងចេញឲ្យឃើញ កាលពីឆ្នាំ១៩៧៧ឡើយ ។ នៅក្នុងឆ្នាំ១៩៧៧ គោលនយោបាយ អាមេរិកមិនបានលើកឡើងអំពីគ្រោះថ្នាក់នៃការវិលត្រឡប់ សាជាថ្មីនៃការដឹកនាំប្រកបដោយភេរវកម្មរបស់ខ្មែរក្រហមលើ ទឹកដីកម្ពុជាឡើយ ។

ចំណុចមួយទៀតដែលជាអាទិភាពរបស់អាមេរិកាំងគឺស្តែង ឲ្យឃើញនៅក្នុងកិច្ចខិតខំប្រឹងប្រែងដែលកំពុងតែចាប់កំណើតក្នុង ការកសាងកងកម្លាំងនយោបាយ និងប្រហែលជាយោធាផង ទប់ទល់នឹងកងទ័ពសាធារណរដ្ឋប្រជាមានិតកម្ពុជានិងកងទ័ព វៀតណាម ។ ដោយសារតែឯកសារជាច្រើនមិនត្រូវបានបញ្ចេញ ឲ្យដឹង ដូច្នេះពត៌មានលម្អិតអំពីកិច្ចខិតខំប្រឹងប្រែងនេះមិនត្រូវ បានដឹងពេញទាំងស្រុងឡើយ ។ សម្តេច សីហនុ គឺជាបញ្ហាគន្លឹះ ។ សហរដ្ឋអាមេរិកនៅតែមានការទាក់ទងឥតដាច់ជាមួយសម្តេច សីហនុ សឹងតែតាំងពីវៀតណាមរុញច្រានខ្មែរក្រហមចេញពី ទីក្រុងភ្នំពេញម្ល៉េះ ។ ឯកអគ្គរដ្ឋទូត លីអូណាត វូដខក់ បានធ្វើ ទស្សនកិច្ចជាប្រចាំជាមួយសម្តេច សីហនុ នៅទីក្រុងប៉េកាំង ហើយនៅពេលដែលសម្តេចយាងមកទីក្រុងវ៉ាស៊ីនតោន សម្តេច បានជួបមន្ត្រីមួយចំនួនមកពីក្រសួងការបរទេសសហរដ្ឋអាមេរិក ព្រមទាំងក្រុមប្រឹក្សាសន្តិសុខជាតិទៀតផង ។ នៅខែធ្នូឆ្នាំ១៩៧៩ រ៉ូបឺត អូកឡេ អតីតឧបការីរងរដ្ឋមន្ត្រីក្រសួងការបរទេស សហរដ្ឋអាមេរិកទទួលបន្ទុកកិច្ចការអាស៊ីបូព៌ា បានចូលគាល់និង ពិភាក្សាជាមួយសម្តេច សីហនុ នៅទីក្រុងប៉ារីសអស់រយៈពេល ២ម៉ោង ព្រមទាំងថ្វាយលិខិតមួយច្បាប់ពី វ៉ាន ដង ។

បន្តិចក្រោយមក ឯកអគ្គរដ្ឋទូត អាប្រាម៉ូវិត បានចូលជួប ជាមួយអនុព័ន្ធយោធាចិននៅក្នុងទីក្រុងបាងកក ។ ពត៌មានដែល អ្នកទាំងពីរបានពិភាក្សាជាមួយគ្នា មិនត្រូវបានបញ្ចេញឲ្យដឹងឡើយ ប៉ុន្តែ"ការលើកឡើងជាថ្មីម្តងទៀតថ្វាយសម្តេច សីហនុ" ដែលជា លទ្ធភាពអាចទៅរួចដែរនោះ ដាក់ស្តែងត្រូវបានលើកយកមក និយាយតាំងពីពេលនោះមក ។ យោងតាម ហ្សេហ្សីនគី ប្រធានាធិបតី ជីមមី បានសរសេរថា "យើងគួរតែធ្វើកិច្ចការ នេះ"នៅក្នុងផ្នែកមួយនៃរបាយការណ៍របស់អាប្រាម៉ូវិត ។

ទំនងជាថា ប្រធានាធិបតី ជីមមី ចង់ជំរុញឲ្យសម្តេច សីហនុ សហការជាមួយកងកម្លាំងខ្មែរក្រហមដែលនៅសេសសល់ ដាមធ្យោបាយក្នុងការតស៊ូជាមួយសាធារណរដ្ឋប្រជាមានិតកម្ពុជា និងវៀតណាម ពីព្រោះថានៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៨០ វ៉ាន បានសរសេរកំណត់ហេតុផ្ទាល់ខ្លួនទៅប្រធានាធិបតី ជីមមី ដែលក្នុងកំណត់ហេតុនោះ រដ្ឋមន្ត្រីក្រសួងការបរទេសយល់ស្របជាមួយយោបល់របស់ ជីមមី ដែលថា សម្តេច សីហនុ គួរតែយកមកប្រើជា«ចំណុចប្រមូលផ្តុំប្រជាជនខ្មែរ» ប៉ុន្តែលោកមិនគិតដូច ជីមមី ដែលថា «សហរដ្ឋអាមេរិកគួរតែជំរុញឲ្យសម្តេចសហការជាមួយរបបកម្ពុជាប្រជាធិបតេយ្យ» នោះទេ «ដរាបណា ប៉ុល ពត និងកូនចៅ នៅតែបន្តគ្រប់គ្រងរបបនោះ» ។ វ៉ាន បានកត់សម្គាល់ថា កិច្ចខិតខំប្រឹងប្រែងរបស់ចិនក្នុងការធ្វើឲ្យកម្ពុជាប្រជាធិបតេយ្យផ្លាស់ប្តូររូបភាពនោះ ជាលទ្ធផលបាននាំដល់ការផ្លាស់ប្តូរត្រឹមតែមុខមាត់ប៉ុណ្ណោះ ។ ហេតុដូចនេះប្រសិនបើសម្តេច សីហនុ ចងសម្ព័ន្ធជាមួយកម្ពុជាប្រជាធិបតេយ្យ «សម្តេចនឹងបំផ្លាញសមត្ថភាពរបស់ព្រះអង្គក្នុងការទាក់ទាញការចូលរួមពីសំណាក់មហាជនកម្ពុជា បំផ្លាញអនាគតដែលសង្ឃឹមថានឹងទទួលយកជាបន្តបន្ទាប់ពីសំណាក់វៀតណាមដែលជាជម្រើសផ្សេងពី ប៉ុល ពត និង ហេង សំរិន» ។

ទោះជាយ៉ាងណាក៏ដោយ ក៏ជាក់ស្តែងសម្តេច សីហនុ បានសុំឲ្យមានការគាំទ្រលើសពីការគាំទ្រផ្នែកនយោបាយ ។ ដូចដែល វ៉ាន លើកឡើងថា «កន្លងមកយើងមិនដែលឆ្លើយតប... ទៅនឹងសំណើរបស់សម្តេច សីហនុ ដែលសុំឲ្យយើងផ្តល់ជំនួយយោធាលាក់មុខដល់កងកម្លាំងតស៊ូរបស់កម្ពុជាដែលទទួលការដឹកនាំរបស់សម្តេច»ទេ ។ វ៉ាន ថ្លែងថា «ធ្វើដូចនេះនឹងធ្វើឲ្យយើងជំពាក់ជំពិនជាថ្មីម្តងទៀតនៅក្នុងឈុតសម្តែងនៅឥណ្ឌូចិនដែលមិនចេះចប់មិនចេះហើយ ថែមទាំងអាចបន្ថែមចំណាយក្នុងស្រុក និងអន្តរជាតិកាន់តែធ្ងន់ ហើយនៅទីបញ្ចប់វាប្រហែលជានឹងធ្វើឲ្យថយចុះឥទ្ធិពលរបស់យើងនៅក្នុងលទ្ធផលចុងក្រោយបង្អស់» ។

វ៉ាន គិតថា មិនមែនជាការឆ្លាតឡើយក្នុងការផ្តល់ជំនួយយោធាលាក់មុខដល់កងកម្លាំងសម្តេច សីហនុ (ដែលមានចំនួនដ៏តិចតួច) នោះ ប៉ុន្តែក្រុមប្រឹក្សាសន្តិសុខជាតិបើកចំហដល់លទ្ធភាពផ្តល់ជំនួយនេះ ។ នៅខែមីនា ឆ្នាំ១៩៨០ ក្រុមប្រឹក្សាសន្តិសុខជាតិបានសុំឲ្យទីភ្នាក់ងារស៊ើបការណ៍សម្ងាត់រៀបចំសិក្សាទៅលើស្ថានភាពជាក់ស្តែងនៃកងកម្លាំងរបស់កម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា ។ ទីភ្នាក់ងារស៊ើបការណ៍សម្ងាត់រៀបចំផ្តល់នូវចំនួនបុគ្គលិក ទីតាំងអង្គភាព ស្ថានភាពសុខភាពនិងស្មារតី ចំនួននិងគុណភាពអាវុធប្រើប្រាស់ និងស្បៀងអាហារ ។ល ។ បីថ្ងៃក្រោយមក ហូលប្រ៊ុក ថ្លែងទៅកាន់អនុគណៈកម្មាធិការព្រឹទ្ធសភាថា ខ្មែរក្រហមអាចទប់ទល់បាននូវការប្រយុទ្ធរដូវប្រាំង ហើយប្រហែលជា«មានកងទ័ពចំនួនពីរម៉ឺននាក់ដែលមានលទ្ធភាពបើកប្រតិបត្តិការសឹកយ៉ាងមានប្រសិទ្ធភាពនៅភាគខាងលិចប្រទេសកម្ពុជានិងទូទាំងប្រទេសគ្រាន់តែក្នុងកម្រិតខ្សោយ» ។ ដោយផ្សព្វផ្សាយបញ្ហានេះ (សក្ខីភាពរបស់ ហូលប្រ៊ុក ត្រូវបានបោះផ្សាយនិងចែកចាយជាសាធារណៈយ៉ាងឆាប់រហ័ស) រដ្ឋាភិបាលប្រហែលជាចង់បញ្ជាក់ប្រាប់វៀតណាមថាខ្លួនជួបប្រទះនូវការតស៊ូស៊ិតស្វាញមួយដែលយ៉ាងហោចណាស់ក៏សហរដ្ឋអាមេរិកកំពុងតែគាំទ្រយ៉ាងស្ងៀមស្ងាត់ដែរ ។

នៅខែឧសភា ឆ្នាំ១៩៨០ វ៉ាន ដែលធ្វើជាកម្លាំងដាស់តឿននៅក្នុងរដ្ឋការជីមមី បានលាឈប់ពីតំណែងជាការតវ៉ាទៅនឹងការប៉ុនប៉ងជួយសង្គ្រោះចំណាប់ខ្មាំងជនជាតិអាមេរិកនៅក្នុងប្រទេសអ៊ីរ៉ង់ ។ ហ្សេហ្ស៊ីនគី មានការត្រេកអរនឹងការលាលែងនេះ ។ ហ្សេហ្ស៊ីនគី និយាយប្រាប់លោកប្រធានាធិបតី ជីមមី ថា វ៉ាន មិនដែលនិយាយចេញមុខខ្លាំងៗជួសមុខឲ្យនយោបាយរបស់ ជីមមី ឡើយ ហើយ«មនុស្សប្រភេទនេះបន្តក្បត់ឥតឈប់ឈរ ទាំងធ្វើឲ្យខ្សោយដល់គោលនយោបាយរបស់លោក ឬបំភ្លៃគោលនយោបាយនោះទៅតាមអ្វីដែលជាចំណូលចិត្តផ្ទាល់ខ្លួន» ។ ហ្សេហ្ស៊ីនគី ស្នើសុំឲ្យលោក ជីមមី តែងតាំងសាឡើងវិញ ។

បន្ទាប់ពី វ៉ាន លាឈប់ពីការងារ ហ្សេហ្ស៊ីនគី កាន់តែមានឥទ្ធិពលនៅក្នុងរដ្ឋការ ជីមមី ដែលមានន័យថា កម្ពុជានឹងកាន់តែត្រូវមើលឃើញតាមដងវនយោបាយភូមិសាស្ត្រសង្គ្រាមត្រជាក់ថែមទៀត ។ សេចក្តីក្រេវក្រោធរបស់លោក ជីមមី ចំពោះការលុកលុយរបស់សូវៀតមកលើទឹកដីអាហ្វហ្គានីស្ថាននៅចុងឆ្នាំ

១៩៧៩ មិនត្រឹមតែធ្វើឲ្យ ហ្សេហ្សុីនគី កាន់តែមានអាជ្ញាសេរីក្នុងដៃមួយកម្រិតទៀតដូចជានៅកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឲ្យវិធីសាស្ត្ររបស់រដ្ឋការ ជីមមី កាន់តែខ្វាំងនិងមានទិសដៅមុតស្រួចចំពោះរាល់បញ្ហាទាំងឡាយណាដែលទាក់ទងនឹងសហភាពសូវៀត ។ វិធីសាស្ត្រ“ទន់ជាងមុន”ដូចជាការសង្កត់ធ្ងន់ទៅលើសិទ្ធិមនុស្ស ឬឆន្ទៈចង់ទទួលយកភាពមិនប្រាកដប្រជាចំពោះវៀតណាមឬកម្ពុជា កាន់តែឃ្លាតឆ្ងាយបន្តិចម្តងៗពីការគិតរបស់រដ្ឋការ ជីមមី ។ ការណ៍នេះបានបង្ហាញឲ្យឃើញបញ្ហាពីរទាក់ទិនគ្នាដែលលេចឡើងនៅរដូវក្តៅនិងរដូវស្លឹកឈើជ្រុះនាឆ្នាំ១៩៨០៖ តើអ្នកណាគួរតែតំណាងឲ្យកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិ? ហើយថាតើត្រូវផ្តល់ការគាំទ្រចំពោះឬជំរុញឲ្យអ្នកដទៃទៀតគាំទ្រយុទ្ធជនខ្មែរក្រហមដែលនៅសេសសល់និងតស៊ូជាមួយសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែរឬទេ?

នៅឆ្នាំ១៩៧៩ សហរដ្ឋអាមេរិកបានបោះឆ្នោតទាំងស្ទាក់ស្ទើរ ឲ្យកម្ពុជាប្រជាធិបតេយ្យរក្សាអាសនៈនៅអង្គការសហប្រជាជាតិ ។ ឧបការីរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិកទទួលបន្ទុកសិទ្ធិមនុស្ស ប៉ាទ្រីសា ដឺរៀន បានទាញហេតុផលដោយភាពរំជួលចិត្តប្រឆាំងនឹងការផ្តល់សំឡេងឆ្នោតមួយសន្លឹកនេះ ។ ការជំទាស់នេះធ្វើឡើងដោយ ដូណាល់ ហង់រីដែលជាអ្នកតំណាងឲ្យសហរដ្ឋអាមេរិកប្រចាំនៅអង្គការសហប្រជាជាតិនិងអ្នកដទៃទៀត ។ អ្នកដែលគាំទ្រចំពោះការផ្តល់អាសនៈនៅអង្គការសហប្រជាជាតិដល់កម្ពុជាប្រជាធិបតេយ្យបានឲ្យហេតុផលថា តម្លៃនៃការមិនគាំទ្រសមាគមប្រជាជាតិអាស៊ី-អាគ្នេយ៍និងចិននៅក្នុងបញ្ហានេះមិនអាចជម្នះបានទេ ។ វ៉ាន សរសេរថា “យើងសម្រេចចិត្តនេះគឺឲ្យស្របទៅនឹងផលប្រយោជន៍ជាតិរបស់យើងតែប៉ុណ្ណោះ” ។ ផ្ទុយទៅវិញ វាគឺជាជំហរប្រកបដោយភាពអាម៉ាស់ផ្ទុយទៅនឹងការតាំងចិត្តរបស់លោក ជីមមី ចំពោះបញ្ហាសិទ្ធិមនុស្សដែលលោកបានថ្លែងកន្លងមក ។ ដូចដែល លីនខុន ប៊្លូមហ្វៀល បានលើកឡើងថា “មូលហេតុបច្ចេកទេសសម្រាប់តួនាទីរបស់យើងបានបង្ហាញនូវការលំបាកហួសពីធម្មតាក្នុងការពន្យល់ប្រាប់ដល់មហាជនទូទៅដែលមានការពាក់ព័ន្ធ ។ គោលនយោបាយរបស់អាមេរិកចំពោះតំណាងរបស់កម្ពុជានៅអង្គការសហប្រជាជាតិ កាន់តែចម្រូងចម្រាស់នៅក្នុងនយោបាយផ្ទៃក្នុងរបស់អាមេរិក ។ ដល់ពេលនេះបញ្ហាហៀបតែនឹងកើតឡើងម្តងទៀតហើយ ។

ពេលនេះកាន់តែមានសមានចិត្តចំពោះរដ្ឋការលោក ជីមមី សុំឲ្យមានការផ្លាស់ប្តូរគោលនយោបាយ ។ នៅឯក្រសួងការបរទេសសហរដ្ឋអាមេរិក រីឆាត ហូលប្រ៊ុក ផ្តល់ប្រឹក្សាដល់រដ្ឋមន្ត្រីការបរទេសថ្មីឈ្មោះ អេដម៉ុន ម៉ាស់គី ថា វាលឿនពេកហើយក្នុងការសម្រេចចិត្តទៅលើបញ្ហាសារតាំងនេះ ។ នៅឯក្រុមប្រឹក្សាសន្តិសុខជាតិ ប៊្លូមហ្វៀល បានទាញហេតុផលយ៉ាងគំហុកទាមទារឲ្យទុកអាសនៈកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិនៅទំនេរ ដោយផ្អែកលើហេតុផលថា ទាំងសាធារណរដ្ឋប្រជាមានិតកម្ពុជានិងកម្ពុជាប្រជាធិបតេយ្យ សុទ្ធតែពុំមានសិទ្ធិពេញច្បាប់ក្នុងការធ្វើជាតំណាងឲ្យកម្ពុជាឡើយ ។ ហ្សេហ្សុីនគី សរសេរថា “វាជារឿងធំធេងពេករវាងគោលនយោបាយដោះកុន (គាំទ្រតំណាងកម្ពុជាប្រជាធិបតេយ្យ) និងជំហរក្នុងន័យសីលធម៌ដែលជាញឹកញយតែងប្រកាសឡើងជាឱឡារិកដោយប្រធានាធិបតីដែលបរិហារ ប៉ុល ពត ថាមានចរិតប្រល័យពូជសាសន៍បន្ទាប់ពីអ៊ីតែ្លរ” ។ ហ្សេហ្សុីនគី បន្តទៀតថា ប្រសិនបើ ប៉ុល ពត ពិតជាគ្រប់គ្រងប្រទេសកម្ពុជាមែន ម្ល៉េះ“យើងពិចារណាបន្តិចរួចទទួលស្គាល់នូវភាពស្របច្បាប់តាមលក្ខណៈបច្ចេកទេសទៅហើយ” ប៉ុន្តែខ្មែរក្រហមស្ទើរតែគ្មានទឹកដីកាន់កាប់ផង ហើយយោងតាមរបាយការណ៍ពីទីភ្នាក់ងារស៊ើបការណ៍សហរដ្ឋអាមេរិកបានឲ្យដឹងថា “ខ្មែរក្រហមមិនទទួលការគាំទ្រក្នុងប្រទេសឡើយ” ។ ជាងនេះទៅទៀត ការគាំទ្រខ្មែរក្រហមធ្វើឲ្យយើងពិបាកក្នុងការបន្តសកម្មភាពជំនួយសង្គ្រោះនៅក្នុងប្រទេសកម្ពុជា ។

រ៉ូហ្គើ ស៊ូលីវ៉ាន ជំនួយការមួយរូបទៀតរបស់ ហ្សេហ្សុីនគី នៅក្រុមប្រឹក្សាសន្តិសុខជាតិ មិនយល់ស្របតាមគំនិតនេះទេ ។ ដោយហេតុជំហររបស់ ហូលប្រ៊ុក ថា“មិនអាចការពារបាន” ស៊ូលីវ៉ាន ចង់ឲ្យសហរដ្ឋអាមេរិកបន្តឈរឲ្យរឹងនៅពីក្រោយសមាគមប្រជាជាតិអាស៊ី-អាគ្នេយ៍និងចិន ។ លោកនិយាយថា ឲ្យតែមានតម្រុយណាមួយបញ្ជាក់អំពីការងាករេរបស់អាមេរិកច្បាស់ជាភាគីទាំងអស់ចង្អុលដាក់ថា សហរដ្ឋអាមេរិកបានសម្រេច

ចិត្តសម្រួលជាមួយនឹងការកាន់អំណាចរបស់វៀតណាមនៅកម្ពុជាមិនខាន ។ ស៊ូលីវ៉ាន និយាយថា ការប្រកាន់ជំហរបែបណាក៏ដោយ ក៏មិនប៉ះពាល់ដល់ការចែកចាយស្បៀងសង្គ្រោះទៅក្នុងផ្ទៃប្រទេសកម្ពុជាដែរ ។ មិនមានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ ហេ្សហ្ស៊ីនគឺ (ប្រហែលជាមានការបន្ទរពី ជីមមី ផង) បានសម្រេចយកស្ថានភាពបច្ចុប្បន្ន ។ បើទោះជាការសម្រេចចិត្តជាផ្លូវការមិនទាន់ធ្វើឡើងទៅលើគោលនយោបាយអាមេរិកចំពោះអាសនៈកម្ពុជាប្រចាំអង្គការ នៅអង្គការសហប្រជាជាតិក៏ដោយ ក៏នៅមានចម្ងល់តិចតួចណាស់ដែលថាតើអាមេរិកនឹងត្រូវធ្វើអ្វីនោះ ។

នៅពេលដែលជ្រាបថាការបោះឆ្នោតនៅអង្គការសហប្រជាជាតិគ្រោងធ្វើនៅខែកញ្ញា អង្គការមនុស្សធម៌និងសាសនាសំខាន់ៗបានព្យាយាមបញ្ចុះបញ្ចូលឲ្យមានការផ្លាស់ប្តូរគោលនយោបាយសហរដ្ឋអាមេរិក ។ ក្រុមប្រឹក្សាព្រះវិហារជាតិគណៈកម្មការសហព្រះវិហារសម្រាប់អ្នកដឹកនាំសាសនា សហព្រះវិហារគ្រិស្ត សម្ព័ន្ធភាពដើម្បីការផ្លាស់ប្តូរនយោបាយការបរទេសថ្មី និងអង្គការដទៃទៀត បានផ្ញើលិខិតដែលប្រើពាក្យសម្តីធំៗចំពោះប្រធានាធិបតី ដោយដាស់តឿនឲ្យមន្ត្រីនៃរដ្ឋការប្រធានាធិបតីកុំបោះឆ្នោតគាំទ្រអាសនៈរបស់ខ្មែរក្រហម ។ អ្នកទាំងអស់បានជះត្រឡប់ដាក់លោក ជីមមី វិញនូវពាក្យខ្លាំងៗដែលលោកបានហៅរបប ប៉ុល ពត ថា“អ្នករំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនៅក្នុងពិភពលោក” ។ ពិសេសជាងនេះទៅទៀត ក្នុងន័យនយោបាយ គឺជាជំហររបស់គណៈកម្មាធិការជួយសង្គ្រោះអន្តរជាតិ ។ គណៈកម្មាធិការប្រតិបត្តិនៃគណៈកម្មាធិការជួយសង្គ្រោះអន្តរជាតិបានបោះឆ្នោតជាឯកច្ឆ័ន្ទគាំទ្រឲ្យទុកអាសនៈនេះនៅទំនេរ បើទោះជាតាមការពិតនាយកប្រតិបត្តិគណៈកម្មាធិការនេះឈ្មោះ លីអូ ឈើណេ ជាអ្នកគាំទ្រយ៉ាងពេញទំហឹងដល់រដ្ឋការប្រធានាធិបតី ជីមមី ក៏ដោយ ។

តំណាងសមាជិកសភាមួយចំនួនបានបន្ទរនូវការបង្ហាញមនោសញ្ចេតនានេះ រួមទាំង សម ញ្ញេវាន ជាអ្នកដែលលោក ជីមមី តែងតាំងឲ្យដឹកនាំក្រុមរក្សាសន្តិភាពនៅក្នុងប្រទេសផង ។ នៅនាទីចុងក្រោយ ញ្ញេវាន បានអំពាវនាវឲ្យប្រធានាធិបតីនិងរដ្ឋមន្ត្រីការបរទេស ម៉ាស់គី ពិចារណាឡើងវិញនូវសេចក្តីសម្រេចចិត្តគាំទ្រខ្មែរក្រហមនៅឯអង្គការសហប្រជាជាតិ ។ លោកបានសរសេរថា “វាជាការខុសឆ្គងជាក់ស្តែង ហើយបានត្រឹមតែធ្វើឲ្យប្រជាជនជាច្រើនដែលចាប់អារម្មណ៍នឹងបញ្ហានេះកាន់តែដកខ្លួនឆ្ងាយចំពោះភាពជាប់លាប់នៃគោលនយោបាយរបស់អាមេរិកប៉ុណ្ណោះ... ។ ការសម្រេចចិត្តបែបនេះគឺជាការសាកល្បងដ៏សំខាន់បំផុតមកលើការតាំងចិត្តរបស់យើងចំពោះសិទ្ធិមនុស្ស ។ ក្នុងន័យទូលាយជាងនេះ វាគឺជាការសាកល្បងនូវសីលធម៌និងភាពសុចរិតនៃសកម្មភាពរបស់យើងនៅក្រៅប្រទេស” ។ ក្រុមប្រឹក្សាសន្តិសុខជាតិមិនបានបញ្ជូនសំបុត្ររបស់ ញ្ញេវាន ជូនទៅប្រធានាធិបតីទេ ហើយ ហេ្សហ្ស៊ីនគី ក៏មិនបានចុះហត្ថលេខាលើលិខិតឆ្លើយតបចំពោះ ញ្ញេវាន វិញដែរ ។ ពីរបីថ្ងៃក្រោយមក សហរដ្ឋអាមេរិកចូលរួមជាមួយសមាគមប្រជាជាតិអាស៊ី-អាគ្នេយ៍និងចិន ក្នុងការបោះឆ្នោតជាថ្មីម្តងទៀត គាំទ្រអាសនៈរបស់ខ្មែរក្រហមប្រចាំនៅអង្គការសហប្រជាជាតិ ។

កាន់តែមានបញ្ហាជាងនេះទៅទៀត និងកាន់តែមានលក្ខណៈសម្ងាត់ជាងនេះទៅទៀតនោះគឺជាការយល់ស្របរបស់ ហេ្សហ្ស៊ីនគី (និងប្រហែលជារបស់ ជីមមី ដែរ) ទៅលើការគាំទ្រផ្នែកយោធារបស់ថៃនិងចិនចំពោះខ្មែរក្រហម ។ ជាការពិតណាស់ រដ្ឋការ ជីមមី បានរិះគន់យ៉ាងខ្លាំងដល់ការលុកលុយរបស់វៀតណាមចូលទឹកដីកម្ពុជា និងបានព្យាយាមដាក់គំនាបសង្កត់ឲ្យដកទ័ពវៀតណាមចេញពីកម្ពុជា ។ ដើម្បីឈានទៅដល់គោលដៅនេះ សហរដ្ឋអាមេរិកបានអំពាវនាវឲ្យមានសន្និសីទអន្តរជាតិដើម្បីដេញវៀតណាមចេញ ដោយចោទប្រកាន់ថា វៀតណាមជាអ្នកបង្អាក់កិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយសង្គ្រោះ ហើយសហរដ្ឋអាមេរិកថែមទាំងបំភ្លេចការពិតដែលថាវៀតណាមក៏បានថែទាំជនភៀសខ្លួនកម្ពុជាចំនួន៤សែននាក់នៅក្នុងប្រទេសរបស់ខ្លួនដែរ ។ វិធីម្យ៉ាងទៀតក្នុងការដាក់គំនាបសង្កត់មកលើវៀតណាមគឺត្រូវបំពាក់អាវុធដល់ក្រុមតស៊ូដើម្បីបង្ខំឲ្យវៀតណាមចាកចេញឲ្យបានឆាប់ដើម្បីធ្វើឲ្យវៀតណាមកាន់តែលំបាកក្នុងការរក្សាជំហររបស់ខ្លួននៅក្នុងប្រទេសកម្ពុជា ។

សហរដ្ឋអាមេរិកដឹងថាខ្មែរក្រហមរស់គឺដោយសារស្បៀង

ដែលទទួលបានពីសហគមន៍អន្តរជាតិ ជាពិសេសគឺជាជំនួយដែលថៃសុំឲ្យមាន ប៉ុន្តែក៏ជាជំនួយដែលអាមេរិកបានជួយឧបត្ថម្ភដែរ ។ សម្តេច សីហនុ ផ្ទាល់ព្រះអង្គក៏សោកស្តាយចំពោះបញ្ហានេះដែរ ។ នៅក្នុងលិខិតទៅកាន់ប្រធានាធិបតី ជីមមី ខាតធ័រ នៅខែមេសា ឆ្នាំ១៩៨០ សម្តេច សីហនុ មានព្រះបន្ទូលថា ប្រជាជនកម្ពុជាដែលនៅតាមបណ្តោយព្រំដែនថៃគឺជា«ទាសករដ៏អាម៉ាស់មុខ»ដោយសារតែសង្គ្រាមនៅក្នុងប្រទេសកម្ពុជា ។ ដូចដែលសម្តេច សីហនុ បានចោទប្រកាន់ ហើយប្រាកដជាមានភាពអាម៉ាស់ដល់រដ្ឋការ ជីមមី នោះ គឺការមិនចែកចាយគ្រឿងផ្គត់ផ្គង់ជំនួយនៅតាមព្រំដែនឲ្យបានស្មើភាពគ្នា ហើយត្រូវបានបង្វែរខុសទិសដៅ ពោលគឺមិនបានដល់ដៃអ្នកដែលអត់ឃ្លានពិតប្រាកដទេ ។ លិខិតរបស់សម្តេចបានរិះគន់យ៉ាងត្រឹមត្រូវទៅនឹងស្ថានភាពជាក់ស្តែងថា «ជំនួយមនុស្សធម៌ (របស់យូនីសេហ្វ កាកបាទក្រហម ។ល ។) ដែលរៀបចំតម្រង់ឲ្យជនដែលអត់ឃ្លាននោះ ត្រូវបាន«អ្នកធ្វើសង្គ្រាម» «រដ្ឋាភិបាល» និងក្រុមតស៊ូដែលគាំទ្រដោយចិននិងថៃបង្វែរយកទៅអស់មួយភាគធំ ។

កម្មវិធីឧបត្ថម្ភស្បៀងនៅតាមព្រំដែនបានប្រោសជីវិតខ្មែរក្រហមឲ្យរស់ឡើងវិញ (និងថែមទាំងជួយកសាងក្រុមតស៊ូមិនមែនកុម្មុយនិស្តទៀតផង) ដែលជាការបើកផ្លូវឲ្យមានការតស៊ូប្រដាប់អាវុធកាន់តែខ្លាំងប្រឆាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជានៅទសវត្សរ៍ឆ្នាំ១៩៨០ ។ ទស្សីករណ៍ល្អបំផុតសម្រាប់គាំទ្រចំណុចនេះគឺថា យើងមិនអាចធ្វើមិនដឹងមិនឮចំពោះជនស៊ីវិលរាប់ពាន់នាក់រួមទាំងកូនក្មេងនៅក្នុងជំរំខ្មែរក្រហមទេ ។ សហរដ្ឋអាមេរិកនិងប្រទេសដទៃទៀតប្រហែលជាបានប៉ុនប៉ងដាក់ការគាបសង្កត់លើថៃឲ្យដកអាវុធខ្មែរក្រហម ។ ឯកអគ្គរដ្ឋទូត អាប្រាម ម៉ូរីត និយាយកាលពីឆ្នាំ១៩៨០ថា «ខ្ញុំបានសួរខ្លួនឯងមួយពាន់ដងថាតើនោះគឺជាអ្វីដែលយើងគួរតែធ្វើឬ?» ។

អាប្រាម ម៉ូរីត បានផ្តល់នូវហេតុផលមួយចំនួនអំពីមូលហេតុដែលការដកអាវុធខ្មែរក្រហមមិនត្រូវយកមកអនុវត្ត រួមទាំងថៃនិងចិនដែលជាមិត្តរបស់សហរដ្ឋអាមេរិក និងដែលទទួលបានផលប្រយោជន៍ច្រើនជាងអាមេរិកនៅក្នុងអាស៊ី-អាគ្នេយ៍ ។ ប៉ុន្តែមូលហេតុចម្បងគឺថា «យើងគិតថាវៀតណាមមានការខុសឆ្គងនៅកម្ពុជា» ។ តាមពិតរដ្ឋការ ជីមមី ចង់ឲ្យខ្មែរក្រហមរស់ដើម្បីប្រឆាំងជាមួយសាធារណរដ្ឋប្រជាមានិតកម្ពុជានិងវៀតណាម ។ ហេតុដូចនេះហើយបានជាសហរដ្ឋអាមេរិកមិនត្រឹមតែបណ្តោយឲ្យសភាពការណ៍ទៅតាមដំណើរប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលួចគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ថៃនិងចិនក្នុងការផ្តល់ជំនួយផ្សេងៗទៅដល់ខ្មែរក្រហម រួមទាំងជំនួយផ្នែកយោធាដែរ ។

ចិនបានសម្រេចចិត្តកសាងខ្មែរក្រហមឡើងវិញសឹងតែចាប់តាំងពីពេលដែលខ្មែរក្រហមត្រូវបានរុញច្រានចេញពីទីក្រុងភ្នំពេញម្ល៉េះ ។ បើត្រឹមតែនិយាយអំពីពេលវេលាពិតប្រាកដថា នៅពេលណាដែលសហរដ្ឋអាមេរិកចង់គាំទ្របញ្ហានេះ វាមិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយទេ ។ នៅត្រឹមខែមិថុនា ឆ្នាំ១៩៨០ គោលនយោបាយនេះត្រូវបានអនុវត្តជាអន្ទើៗហើយ ។ នៅពេលដែលមនុស្សមួយចំនួននៅក្រសួងការបរទេសនិងនៅកន្លែងផ្សេងទៀតកំពុងតែជំរុញឲ្យសហរដ្ឋអាមេរិកបោះឆ្នោតប្រឆាំងនឹងខ្មែរក្រហមនៅអង្គការសហប្រជាជាតិ និងឲ្យដកខ្លួនពី គោលនយោបាយមកលើសមាគមប្រជាជាតិអាស៊ី-អាគ្នេយ៍និងចិនទាក់ទងនឹងបញ្ហាខ្មែរក្រហមនោះ មន្ត្រីក្រុមប្រឹក្សាសន្តិសុខជាតិ រ៉ូហ្គើ ស៊ូលីវ៉ាន ក៏បង្ហាញការភ្ញាក់ផ្អើលភ្លាម ។ ស៊ូលីវ៉ាន បានសរសេរទៅ ហ្សេហ្ស៊ីនគី ថា «មានការច្របូកច្របល់ទៅលើគោលនយោបាយរបស់យើងចំពោះប៉ុលពតនិងកម្លាំងតស៊ូរបស់ប៉ុលពត» ។ ស៊ូលីវ៉ាន គូសបញ្ជាក់ថា ហ្សេហ្ស៊ីនគី បានជំរុញជាយូរមកហើយ ឲ្យថៃនិងចិនផ្តល់ការគាំទ្រឲ្យគ្រប់គ្រាន់ចំពោះខ្មែរក្រហម ដើម្បីធ្វើឲ្យវៀតណាមនៅទាំងលំបាក ។ ស៊ូលីវ៉ាន បន្តទៀតថា ឥឡូវនេះ ក្រសួងការបរទេសសហរដ្ឋអាមេរិកហាក់ដូចជាមានទំនោរទៅលើគោលនយោបាយថ្មីមួយប្រឆាំងទៅនឹង «កម្លាំងកម្ពុជាប្រជាធិបតេយ្យ» ហើយមិនបានជំរុញឲ្យប្រទេសផ្សេងទៀតគាំទ្រខ្មែរក្រហមឡើយ ។ ជាលទ្ធផល ចិននិងថៃ «ច្របូកច្របល់និងភ្ញាក់ផ្អើល» ។ ស៊ូលីវ៉ាន សរសេរថា ប្រសិនបើសហរដ្ឋអាមេរិកមិនឃាត់ថៃ«កុំឲ្យធ្វើសហប្រតិបត្តិការជាមួយចិនក្នុងការគាំទ្រកម្លាំងប៉ុលពតទេ ពេលនោះយើងនឹងប្តូរពីល្បិចកលផ្សេងគ្នាមកជាជម្លោះផលប្រយោជន៍ធំវិញ» ។ លោកបានជំរុញឲ្យ ហ្សេហ្ស៊ីនគី ប្រាកដក្នុងចិត្តថា ម៉ាស់គី និយាយប្រាប់ចិនច្បាស់ហើយថា «យើងមិនរិះរកមធ្យោបាយបង្អាក់ថៃមិនឲ្យគាំទ្រក្រុមតស៊ូកម្ពុជាប្រជាធិបតេយ្យនោះទេ ។

ជុំយមកវិញ ដូចដែលលោកបានប្រាប់ទៅរដ្ឋមន្ត្រីក្រសួងការបរទេសថៃ (សិទ្ធិ សាវេត ស៊ីឡា) រួចហើយថា យើងមិនចង់ឲ្យវៀតណាមពង្រីកការគ្រប់គ្រងរបស់ខ្លួនបានទេ ប្រសិនបើយើងអាចការពារបាន ហើយប្រសិនបើយើងមិនអាចទប់ទល់បាន យើងចង់ឲ្យរឿងនេះក្លាយជារឿងមួយអូសបន្លាយស៊ិតស៊ាញ និងជារឿងធំសម្រាប់វៀតណាម» ។ ថ្ងៃបន្ទាប់មក ហេ្សហ្ស៊ិនគឺ, ម៉ាស់គី និងរដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រោន យល់ស្របថា សហរដ្ឋអាមេរិក«មិនប្រឆាំងនឹងជំនួយយោធារបស់ចិនមកឲ្យក្រុមខ្មាំងខ្មែរក្រហមទេ» ។

ការបង្ហាញជាក់ស្តែងដែលថាសហរដ្ឋអាមេរិកពិតជាចង់ឲ្យចិននិងថៃជួយជ្រោមជ្រែងដល់យោធាខ្មែរក្រហម ជាមធ្យោបាយមួយក្នុងការដាក់គំនាបសង្កត់ទៅលើវៀតណាម ធ្វើឲ្យមានការគាំទ្រចំពោះជនទាំងឡាយដែលចោទប្រកាន់កាលពីពេលនោះថា សហរដ្ឋអាមេរិកជាអ្នកជួយរៀបចំកិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយអន្តរជាតិទៅតាមវិធីដែលខ្លួនចង់ជួយដល់ខ្មែរក្រហមដោយចេតនា ។ អ្នកគាំទ្ររដ្ឋការ ជីមមី មិនសប្បាយចិត្តចំពោះការរិះគន់បែបនេះទេ ប៉ុន្តែរដ្ឋការលោក ជីមមី បានសម្រេចចិត្តជំរុញឲ្យចិននិងថៃគាំទ្រកម្លាំងខ្មែរក្រហមដែលនៅសេសសល់ (ហើយថែមទាំងជួយផ្តល់អាវុធយុទ្ធភណ្ឌថែមទៀតផង) ហើយជំរុញឲ្យប្រើប្រាស់កម្លាំងប៉ុលពតជាមធ្យោបាយប្រឆាំងនឹងវៀតណាមដែលបានរំដោះកម្ពុជាឲ្យផុតពីក្រញាំមច្ចុរាជ ។ ទោះបីជារដ្ឋការ ជីមមី មិនអាចធ្វើមិនដឹងមិនឮចំពោះការទាមទារភាពមនុស្សធម៌ និងបានផ្តល់ជំនួយមួយចំនួនតាមរយៈសាធារណរដ្ឋប្រជាមានិតកម្ពុជាក្តី (តាមសេចក្តីណែនាំតឹងរ៉ឹង) គោលដៅសំខាន់របស់សហរដ្ឋអាមេរិកគឺបម្រើឲ្យនយោបាយភូមិសាស្ត្រដូចដែលអ្នករិះគន់នានាបានចោទប្រកាន់ ។ សហរដ្ឋអាមេរិកមានការពាក់ព័ន្ធជាមួយការតស៊ូទូទាំងពិភពលោកប្រឆាំងនឹងសហភាពសូវៀត ដែលបានធ្វើឲ្យកាន់តែមានភាពតឹងតែងជាអន្តរជាតិចំពោះចំណុចពុះកញ្ជ្រោលនៃការចូលលុកលុយប្រទេសអាហ្វហ្កានីស្ថាន ។ ជីមមី បានឆ្លើយតបតាមរយៈពហិការមិនចូលរួមកីឡាអូឡាំពិកនៅទីក្រុងម៉ូស្គូ ។ សហភាពសូវៀតគាំទ្រវៀតណាម ចំណែកឯរដ្ឋការ ជីមមី ជាពិសេសក្រុមប្រឹក្សាសន្តិសុខជាតិ ចាត់ទុកការចូលលុកលុយរបស់វៀតណាមនៅក្នុងទឹកដីកម្ពុជាជាការពង្រីកឥទ្ធិពលរបស់សូវៀតដែលមានការប៉ះពាល់ដល់ផលប្រយោជន៍របស់សហរដ្ឋអាមេរិកនិងសម្ព័ន្ធមិត្ត ។ ដោយថ្កោលទោសយ៉ាងដាច់អហង្ការចំពោះការលុកលុយរបស់វៀតណាម ឈរលើគោលការណ៍មិនជ្រៀតជ្រែកគ្នា ចំណុចដែលមានបញ្ហាគឺកត្តានយោបាយភូមិសាស្ត្រ ។ ក្នុងអំឡុងពេលពីរបីខែនៃការចូលលុកលុយរបស់វៀតណាម សហរដ្ឋអាមេរិកបានស្វាគមន៍ចំពោះការចូលលុកលុយរបស់ប្រទេសតង់ហ្សានីមកលើប្រទេសអ៊ូហ្កាន់ដាដែលជាការផ្តួលរំលំជនផ្តាច់ការប្រល័យពូជសាសន៍ម្នាក់ទៀតគឺ អ៊ីឌី អាមីន ។

ស្នាដៃដ៏មោទកភាពបំផុតរបស់ ហ្សេហ្ស៊ិនគី គឺការធ្វើឲ្យមានប្រក្រតីភាពឡើងវិញនៃទំនាក់ទំនងជាមួយចិន និងការទោរទន់របស់អាមេរិកទៅរកទីក្រុងប៉េកាំង ។ ចិនដែលមានការតស៊ូដូរចត់ខាងមនោគមវិជ្ជាជាមួយសហភាពសូវៀត បានគាំទ្រខ្មែរក្រហម (ទោះបីជាប៉ុលពតមានគោលនយោបាយប្រល័យពូជសាសន៍ប្រឆាំងជនជាតិចិនរស់នៅប្រទេសកម្ពុជាក្តី) និងបានសោកស្តាយចំពោះការចូលលុកលុយរបស់វៀតណាម ។ ដូចជាសហរដ្ឋអាមេរិកដែរ ចិនបានចាត់ទុកការណ៍នេះថាជាការពង្រីកឥទ្ធិពលសូវៀតដែលជាការមិនអាចទទួលយកបាន ។ ដោយគ្មានលទ្ធភាពគាស់វៀតណាមឲ្យរបើកតាមរយៈការបញ្ចុះបញ្ចូលចិនបានធ្វើឲ្យខ្មែរក្រហមរស់ឡើងវិញក្នុងក្តីសង្ឃឹមថាចុងបញ្ចប់ខ្លួននឹងមានលទ្ធភាពបណ្តេញវៀតណាមចេញឲ្យខាងតែបាន ។ សហរដ្ឋអាមេរិកបានជំរុញឲ្យចិននិងថៃឲ្យជួយផ្តល់ជំនួយស្បៀងអាហារដល់ខ្មែរក្រហម ។

ជួនពេលខ្លះនិងនៅកន្លែងខ្លះ ការការពារសិទ្ធិមនុស្សគឺជាចំណុចសំខាន់នៃគោលនយោបាយការបរទេសរបស់ ជីមមី ប៉ុន្តែវាមិនមែនជាការគិតគូរពិចារណាចម្បងទេសម្រាប់ទីប្រឹក្សាសន្តិសុខជាតិ ហ្សេហ្ស៊ិនគី ហើយចំពោះការដែល ជីមមី អនុញ្ញាតឲ្យ ហ្សេហ្ស៊ិនគី បង្កើតនយោបាយការបរទេសនោះ ការការពារសិទ្ធិមនុស្សចេះតែអន់ថយទៅៗនៅពេលដែលរដ្ឋការកណ្តាលមានការព្រួយបារម្ភ ។

ឥឡូវនេះតើនៅមានកន្លែងណាទៀតដែលឃើញទិដ្ឋភាពច្បាស់ក្រឡែតដូចជានៅកម្ពុជា?

**ខេនតុន ក្លែម័រ**



# តួនាទីសិល្បៈនៅក្នុងដំណើរការផ្សះផ្សាជាតិនៅកម្ពុជា៖ ការតាំងពិព័រណ៍រូបថតនៅសារមន្ទីរទួលស្លែង

## *សេចក្តីផ្តើម*

*នៅក្នុងអំឡុងខ្មែរក្រហមកាន់អំណាច "មន្ទីរស-២១" ដែលស្គាល់ជាទូទៅថាគុកទួលស្លែង និងបង្កើតឡើងដោយមេដឹកនាំរបបខ្មែរក្រហម ដែលបានបណ្តាលឲ្យអ្នកទោសជាប្រជាជនខ្មែរនិងបរទេសប្រមាណ១ម៉ឺន៤ពាន់នាក់ ស្លាប់បាត់បង់ជីវិតដោយសារការធ្វើទារុណកម្មនិងការបញ្ជូនយកទៅសម្លាប់នៅទីពិឃាតជើងឯក ។ អ្នកទោស"អង្គការ"ដែលត្រូវចាប់បញ្ជូនមកទីនេះ តែងតែត្រូវបានថតរូបទុកជាឯកសារ ។ អ្នកទោសខ្លះបានថតរូបទាំងពេលចូលមកដល់ភ្លាម ពេលធ្វើទារុណកម្ម និងក្រោយពេលស្លាប់ ។ សព្វថ្ងៃនេះ រូបថតទាំងអស់ត្រូវបានដាក់តាំងនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដើម្បីបង្ហាញពីអំពើឃោរឃៅរបស់ខ្មែរក្រហម ។*

*នៅខែតុលា ឆ្នាំ២០០២ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសារមន្ទីរទួលស្លែងបានបើកការតាំងពិព័រណ៍រូបថតនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងក្រោមប្រធានបទ "ជនរងគ្រោះនៃប្រវត្តិសាស្ត្រៈ សំឡេងជនរងគ្រោះនិងជនដៃដល់នៃរបបខ្មែរក្រហម" ។ នេះគឺជាការដាក់តាំងពិព័រណ៍រូបថតអតីតយុទ្ធជនខ្មែរក្រហមចំនួន១៣នាក់ ។ គោលបំណងនៃការដាក់តាំងពិព័រណ៍នេះគឺដើម្បីនាំមកនូវការរំសាយកំហឹង ការផ្សះផ្សា និងផ្តល់ឳកាសដល់អតីតជនដៃដល់ប្រាប់ការពិតនៅចំពោះមុខជនរងគ្រោះ អំពីអ្វីដែលនាំឲ្យមានការកាប់សម្លាប់មនុស្សយ៉ាងរង្គាលនៅក្នុងរបបខ្មែរក្រហម ។*

*អត្ថបទនេះនឹងសិក្សាទៅលើតួនាទីសិល្បៈក្នុងការរួមចំណែកឲ្យមានការរំសាយកំហឹង ជាពិសេសផ្តោតទៅលើការតាំងពិព័រណ៍នៅសារមន្ទីរទួលស្លែងថ្មីៗនេះ ដែលនឹងនាំមកនូវការផ្សះផ្សារវាងអតីតជនដៃដល់និងជនរងគ្រោះនៃរបបខ្មែរក្រហម ។ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យដែលមនុស្សគ្រប់រូបស្គាល់ជាទូទៅថា "ខ្មែរក្រហម" ប្រជាជនស្លូតត្រង់ប្រមាណ ២លាននាក់បានស្លាប់បាត់បង់ជីវិតដោយសារការអត់ឃ្លាន ការបង្ខំឲ្យធ្វើការជាទម្ងន់ ជំងឺ និងការសម្លាប់ ។ ចាប់តាំងពីរបបខ្មែរក្រហមដួលរលំនៅខែមករា ឆ្នាំ១៩៧៩ មិនទាន់មានមេដឹកនាំណាម្នាក់នៃរបបនេះត្រូវបាននាំខ្លួនយកទៅជំនុំជម្រះក្តីនៅឡើយទេ ។ ភាពមិនចុះសម្រុងគ្នារវាងជនរងគ្រោះនិងជនដៃដល់នៃរបបខ្មែរក្រហមនៅតែកើតមាននៅឡើយ ។ អតីតជនដៃដល់ខ្មែរក្រហមថ្នាក់ក្រោមតែងតែនិយាយថា ខ្លួនជាជនរងគ្រោះនៃរបបខ្មែរក្រហមដែរ ក៏ប៉ុន្តែនៅក្នុងក្រសែភ្នែករបស់ជនរងគ្រោះរាប់លាននាក់ដែលទទួលរងការធ្វើទុកបុកម្នេញពេញអំឡុងរបបខ្មែរក្រហម នៅតែយល់ថាអ្នកទាំងនោះមិនមែនជាជនរងគ្រោះឡើយ គឺជាជនដៃដល់ដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ អំពើប្រល័យពូជសាសន៍នៅកម្ពុជាមិនត្រឹមតែជាស្នាមរបួសនៅលើរូបរាងកាយប៉ុណ្ណោះទេ ប៉ុន្តែគឺជារបួសនៅក្នុងចិត្តថែមទៀតផង ។*

*ដើម្បីពិភាក្សាអំពីតួនាទីនៃរូបថតទាំងនោះដែលអាចនឹងរួមចំណែកនៅក្នុងដំណើការផ្សះផ្សាស្នាមរបួសអតីតកាល ជាដំបូងខ្ញុំនឹងបង្ហាញអំពីប្រវត្តិរូបទាំងឡាយដែលបានបន្សល់ទុកមកពីរបបខ្មែរក្រហម ។ អត្ថបទនេះក៏នឹងសិក្សាលម្អិតអំពីមូលហេតុដែលមជ្ឈមណ្ឌលឯកសារកម្ពុជានិងសារមន្ទីរទួលស្លែងជ្រើសរើសយករូបថតអតីតយុទ្ធជនខ្មែរក្រហមទាំង១៣នាក់នោះមកដាក់តាំងពិព័រណ៍ ។ នៅផ្នែកទីពីរ ខ្ញុំនឹងលើកយកពាក្យសម្តីរបស់អតីតយុទ្ធជនខ្មែរក្រហមដែលត្រូវបានដកស្រង់យកមកដាក់តាំងពិព័រណ៍ ព្រមទាំងទស្សនៈនិងមតិប្រតិកម្មរបស់អ្នកទស្សនាការតាំងពិព័រណ៍នេះ ។ នៅផ្នែកទីបី ខ្ញុំនឹងពិភាក្សាអំពីតួនាទីនៃការតាំងពិព័រណ៍ក្នុងការនាំឲ្យមានការផ្សះផ្សារវាងជនដៃដល់និងជនរងគ្រោះនៃរបបខ្មែរក្រហម ។ អត្ថបទនេះនឹងធ្វើសេចក្តីសន្និដ្ឋាន*

ជាមួយនឹងការពិនិត្យមើលជុំវិញតម្លៃនៃការតាំងពិព័រណ៍រូបថតនៅក្នុងការអប់រំប្រជាជនកម្ពុជានិងពិភពលោកអំពីប្រវត្តិសាស្ត្រ និងអត្ថាធិប្បាយជុំវិញវិធានការនានាដើម្បីទប់ស្កាត់ការវិលត្រឡប់មកវិញនៃអំពើប្រល័យពូជសាសន៍ ។

## ១) មរតកនៃរបបខ្មែរក្រហម

ប្រជាជនកម្ពុជាតែងតែយល់ថា "បន្ទាប់ពីភ្លៀងមេឃនឹងស្រឡះ" ។ ផ្ទុយទៅវិញ បន្ទាប់ការមកដល់នៃរបបខ្មែរក្រហមនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជោគវាសនាប្រជាជនកម្ពុជាបានធ្លាក់ទៅក្នុងភាពងងឹតសូន្យសុង ។ ប្រជាជនទូទាំងប្រទេសប្រមាណពីរលាននាក់បានស្លាប់បាត់បង់ជីវិតដោយសារការជម្លៀសចេញពីទីប្រជុំជនទៅកាន់ជនបទដាច់ស្រយាល បង្ខំឲ្យធ្វើការងារហួសកម្លាំង បង្អត់អាហារ ជំងឺ និងការចាប់យកទៅសម្លាប់ជាខ្សែសង្វាក់ ។ រូបថតរាប់ពាន់សន្លឹកដែលបន្សល់ទុកនៅសារមន្ទីរទួលស្លែង គំនរឆ្អឹង និងរណ្តៅសាកសពរាប់រយកន្លែងនៅទូទាំងប្រទេស បានបង្ហាញយ៉ាងច្បាស់នូវអំពើយង់ឃ្នងនេះ ។ ចាប់តាំងពីការបង្កើតឡើងនៅឆ្នាំ១៩៩៥ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបំពេញបេសកម្មយ៉ាងចាំបាច់ក្នុងការប្រមូលចងក្រងឯកសារនិងថែរក្សាកេរដំណែលខ្មែរក្រហមសម្រាប់មនុស្សជំនាន់ក្រោយសិក្សាស្វែងយល់ ។

រហូតមកដល់បច្ចុប្បន្ននេះ តាមរយៈទិន្នន័យដែលប្រមូលបានដោយការសិក្សាស្រាវជ្រាវតាមលក្ខណៈវិទ្យាសាស្ត្រ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផែនទីវាលពិឃាតនៃរបបខ្មែរក្រហម ហើយពន្យចនូវទីតាំងសម្លាប់មនុស្សចំនួន៣៤៨កន្លែង ដែលមានរណ្តៅសាកសពចំនួន១៩.៥២១កន្លែង មន្ទីរសន្តិសុខ(គុក) ចំនួន១៩៤កន្លែង និងបូជនីយដ្ឋានតម្កល់អដ្ឋិធាតុចំនួន៨០កន្លែង ។

រយៈពេល២៥ឆ្នាំហើយបន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំចេញពីអំណាចនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប៉ុន្តែមរតកនៃរបបខ្មែរក្រហមនៅតែមានជីវិតនៅឡើយ ។ យើងអាចមើលឃើញប្រជាជនមួយចំនួនមានជំងឺផ្លូវចិត្តរ៉ាំរ៉ៃដែលបង្កឡើងដោយខ្មែរក្រហម ។ មរតកខ្មែរក្រហមកំពុងបន្តបង្កើតការសង្ស័យភាពមិនទុកចិត្តគ្នា ការចោទប្រកាន់គ្នា និងការសងសឹកមិនចេះចប់មិនចេះហើយ ។ ជាងនេះទៅទៀត មរតកខ្មែរក្រហមបានបង្កឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់អនាគតរបស់អតីតយុទ្ធជនខ្មែរក្រហមថ្នាក់ក្រោមនិងក្រុមគ្រួសាររបស់អ្នកទាំងនោះ នៅខណៈពេលជនរងគ្រោះកំពុងប្រឹងប្រែងស្ថាបនាអនាគតជាថ្មី ។ ទោះបីយ៉ាងណាក៏ដោយ នេះគឺជាភារកិច្ចរបស់ប្រជាជនកម្ពុជាដែលត្រូវមានសុឆន្ទៈរួមគ្នាក្នុងការស្វែងរកដំណោះស្រាយចំពោះប្រវត្តិសាស្ត្រនេះដើម្បីនាំមកនូវសន្តិភាព ការផ្សះផ្សា និងអភិវឌ្ឍន៍ ។

ផ្នែកខាងក្រោមនេះនឹងអធិប្បាយអំពីមន្ទីរសន្តិសុខខ្មែរក្រហមស-២១ ដែលអ្នកទោសរាប់ពាន់នាក់ត្រូវបានឃុំខ្លួន ធ្វើទារុណកម្ម រួចសម្លាប់ចោល និងជាកន្លែងដែលរក្សាទុករូបថតរាប់ម៉ឺនសន្លឹក ។

## ២) មន្ទីរសន្តិសុខស-២១

សូម្បីតែមុនពេលបានឡើងកាន់អំណាច មេដឹកនាំខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខជាច្រើនកន្លែងចាប់តាំងពីថ្នាក់ភូមិភាគ តំបន់ រហូតដល់ថ្នាក់ស្រុក ។ ប្រមាណពីរខែបន្ទាប់ពីទទួលបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានបង្កើតមន្ទីរសន្តិសុខមជ្ឈិមស-២១ ដើម្បីឃុំឃាំង សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់មនុស្សទាំងឡាយណាដែលត្រូវបានចាត់ទុកថាជា"ខ្មាំងអង្គការ" ។

នៅអំឡុងពេលប្រាំបីខែដំបូងនៃប្រតិបត្តិការ មន្ទីរសន្តិសុខស-២១បានស្ថិតនៅក្រោមការទទួលខុសត្រូវរបស់កងពលខ្មែរក្រហមលេខ៧០៣ ដែលនៅពេលនោះមានទីតាំងនៅក្នុងបរិវេណស្នងការនគរបាលជាតិត្រង់ភាគខាងត្បូងផ្សារថ្មី ។ ដោយសារចំនួនអ្នកទោសកាន់តែកើនឡើង នៅខែមីនាឬមេសា ឆ្នាំ១៩៧៦ មន្ទីរសន្តិសុខស-២១ត្រូវបានប្តូរទីតាំងមកក្នុងបរិវេណវិទ្យាល័យទួលស្វាយព្រៃក្រុងភ្នំពេញវិញ ក្នុងបរិវេណដីដែលមានបណ្តោយ ៦០០ម៉ែត្រនិងទទឹង៤០០ម៉ែត្រ ។ គ្រឹះស្ថានសិក្សាមួយនេះត្រូវបានសាងសង់ក្នុងអំឡុងឆ្នាំ១៩៦២ដោយមានឈ្មោះថា "វិទ្យាល័យពញាយ៉ាត" ។ នៅឆ្នាំ១៩៧០ក្នុងរបបសាធារណរដ្ឋខ្មែរ វិទ្យាល័យនេះបានផ្លាស់ឈ្មោះជា "វិទ្យាល័យទួលស្វាយព្រៃ" វិញ ។ នៅខាងក្រោយជាប់នឹងរបងវិទ្យាល័យមានអគារ

សិក្សាពីរខ្នងទៀតសង់អំពីឈើប្រក់ស្បឹកដែលមានឈ្មោះថា សាលាបឋមសិក្សាបឹងកេងកង ។ ក្រោយមកទៀត សាលាបឋមសិក្សាបឹងកេងកងក៏ត្រូវបានប្តូរឈ្មោះទៅជាសាលាបឋមសិក្សាទួលស្វែង ។

ដូចមន្ទីរសន្តិសុខដទៃទៀតដែរ មន្ទីរសន្តិសុខស-២១ត្រូវមេដឹកនាំខ្មែរក្រហមបង្កើតឡើងដោយសារតែយល់ឃើញថា នៅក្នុងសង្គមកម្ពុជានាពេលនោះគឺពោរពេញទៅដោយខ្មាំង ។ អ្នកទោសទាំងឡាយដែលត្រូវបញ្ជូនទៅមន្ទីរសន្តិសុខស-២១ កម្រនឹងមានវាសនារួចផុតពីការសម្លាប់ណាស់ ។ នៅក្នុងចំណោមអ្នកទោសប្រមាណ១ម៉ឺន៤ពាន់នាក់ដែលត្រូវសម្លាប់នៅមន្ទីរសន្តិសុខស-២១ មានអ្នកទោសតែ១៤នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិតពីការសម្លាប់រង្គាលដោយសារតែការដួលរលំនៃរបបនេះ ។

ជាផ្លូវការ មន្ទីរសន្តិសុខស-២១ត្រូវខ្មែរក្រហមហៅថា "មន្ទីរស-២១" ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់សេនាធិការកងទ័ពនៃរបបខ្មែរក្រហម ។ មន្ទីរស-២១បានបំពេញតួនាទីរបស់ខ្លួនជាអ្នកការពារសន្តិសុខនិងជាតុលាការនៃរបបខ្មែរក្រហម ។ ទោះបីជារដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យដែលបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ គ្រង់ជំពូក៧មាត្រា៩ចែងអំពីតុលាការថា ជា"តុលាការរបស់ប្រជាជន តំណាងយុត្តិធម៌របស់ប្រជាជន ការពារយុត្តិធម៌របស់ប្រជាជន ការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន" ក៏ដោយ ប៉ុន្តែធាតុពិត របបខ្មែរក្រហមពុំមានតុលាការសម្រាប់បំពេញតួនាទីក្នុងការផ្តល់យុត្តិធម៌ដល់មនុស្សដែលត្រូវបានចាត់ទុកថាមានទោសនិងជាខ្មាំងអង្គការដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនោះទេ ។ មេដឹកនាំខ្មែរក្រហមតែងតែបានណែនាំសមាជិករបស់ខ្លួនឲ្យជឿថា អំណាចគឺចេញមកពីប្រជាជន ។ តាមពិតអំណាចនិងការសម្រេចចិត្តទាំងអស់គឺស្ថិតនៅលើ "អង្គការ" តែប៉ុណ្ណោះ ។ អ្នកទោសទាំងអស់តែងតែត្រូវបានចាប់ខ្លួនបញ្ជូនទៅកាន់មន្ទីរឃុំឃាំង និងយកទោសម្លាប់ចោលបន្ទាប់ពីសាកសួរចម្លើយចប់សព្វគ្រប់ ។ មន្ទីរឃុំឃាំងគឺជាតុលាការកាត់ទោសខ្មាំងអង្គការ ដែលស្ថិតក្រោមការសម្រេចចិត្តពីអង្គការ"គណៈមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា" ។

អ្នកទោសដែលត្រូវបានចាប់បញ្ជូនមកមន្ទីរស-២១ដំបូងមានអ្នកទោសដែលជាអតីតមន្ត្រីរដ្ឋការនៃរបបសង្គមរាស្ត្រនិយមនិងរបបសាធារណរដ្ឋខ្មែរ ព្រមទាំងកម្មាភិបាលជាន់ខ្ពស់នៃរបបខ្មែរក្រហមផងនោះ តែងតែត្រូវថតរូបដើម្បីធ្វើប្រវត្តិរូបអ្នកទោសនៅមុនពេលបញ្ជូនទៅកាន់បន្ទប់ឃុំឃាំងតូចៗ ឬក៏ត្រូវបញ្ជូនយកទៅសួរចម្លើយនិងសម្លាប់ចោលនៅទីពិឃាតជើងឯក ។ អ្នកទោសខ្លះត្រូវបានថតរូបនៅខណៈពេលធ្វើទារុណកម្ម ហើយខ្លះទៀតត្រូវបានថតរូបបន្ទាប់ពីស្លាប់នៅមន្ទីរស-២១ ឬត្រូវបានសម្លាប់ ។ រូបថតទាំងនោះបង្ហាញពីអំពើឃោរឃៅនៃរបបខ្មែរក្រហមដែលជាលទ្ធផលនៃការដឹកនាំប្រទេសកម្ពុជារវាងពីឆ្នាំ១៩៧៥ដល់១៩៧៩ ។

ញ៉ែម អេន ត្រូវអង្គការបញ្ជូនទៅប្រទេសចិននៅក្នុងឆ្នាំ ១៩៧៦ដើម្បីទទួលការហ្វឹកហ្វឺនបច្ចេកទេសថតរូប ហើយបានត្រឡប់មកបម្រើការជាអ្នកថតរូបអ្នកទោសនៅមន្ទីរស-២១ វិញរហូតដល់ការដួលរលំនៃរបបខ្មែរក្រហម ។ នៅខណៈពេលមើលរូបថតនៅសារមន្ទីរទួលស្លែង (អតីតមន្ទីរស-២១) នៅឆ្នាំ ១៩៩៧ ញ៉ែម អេន បាននិយាយថា "ការថតរូបគឺជារឿងធម្មតាសម្រាប់មនុស្សទូទៅ ប៉ុន្តែនៅពេលយើងក្រឡេកទៅអតីតកាលក្នុងរបបខ្មែរក្រហម មនុស្សរាប់ពាន់នាក់ដែលដើរសំដៅទៅម៉ាស៊ីនថតគឺមានន័យថាដើរសំដៅទៅឋាននរក" ។

មិនត្រឹមតែអ្នកទោសទេដែលត្រូវថតរូប សូម្បីតែយុទ្ធជននៅមន្ទីរស-២១ក៏ត្រូវថតរូបដូចគ្នាដែរ ។ បន្ទាប់ពីថតរូបរួចហើយ យុទ្ធជនម្នាក់ៗត្រូវបិទរូបថតរបស់ខ្លួនទៅលើប្រវត្តិរូបមួយសន្លឹកឬច្រើនជាងនេះ រួចប្រគល់ទៅឲ្យប្រធានក្រុមរបស់ខ្លួន ។ យុទ្ធជនខ្លះបានថតរូបពីរឬបីដង ។ ដាក់ស្ដែង ញ៉ែប ហូ អតីតយុទ្ធជនកងការពារមន្ទីរស-២១ មានរូបថតចំនួនពីរសន្លឹកផ្សេងគ្នា និងមានប្រវត្តិរូបពីរដែរដែលបានធ្វើនៅក្នុងរបបខ្មែរក្រហម ។

នៅផ្នែកបន្ទាប់នឹងសិក្សាអំពីកិច្ចខិតខំប្រឹងប្រែងរបស់ប្រជាជនកម្ពុជាក្នុងការចងចាំអតីតកាលតាមរយៈរូបថត និងការរៀបចំបណ្ណសារឯកសារទាំងឡាយដែលបន្សល់ទុកពីរបបខ្មែរ

ក្រហម ។

### ៣) ពីវាលពិឃាតមកជាកន្លែងចងចាំនិងបណ្ណសារ

ក្រោយពីការដួលរលំនៃរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩ មន្ទីរស-២១ត្រូវបានរៀបចំជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលអំពើឃោរឃៅនៃរបបខ្មែរក្រហមរួមទាំងឧបករណ៍ធ្វើទារុណកម្មនិងរូបថតជនរងគ្រោះរាប់ពាន់នាក់ត្រូវបានថែរក្សានិងដាក់តាំងបង្ហាញ ។ សារមន្ទីរទួលស្លែងបានបើកទ្វារស្វាគមន៍អ្នកទេសចរណ៍នៅឆ្នាំ១៩៨០ ។ ចាប់តាំងពីពេលនោះមក សារមន្ទីរបានទទួលអ្នកទស្សនាជាតិនិងអន្តរជាតិរាប់ម៉ឺននាក់ ។ សារមន្ទីរនេះបានផ្លាស់ប្តូរការគ្រប់គ្រងយ៉ាងហោចណាស់ចំនួនបីលើក ។ នៅខណៈពេលចាប់ផ្តើមរៀបចំដំបូង សារមន្ទីរទួលស្លែងស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជារហូតដល់ពេលមានការបោះឆ្នោតនៅឆ្នាំ១៩៩៣ដែលរៀបចំដោយអង្គការសហប្រជាជាតិ ។ នៅអំឡុងពេលនោះ ឯកសារទាំងអស់នៅក្នុងបណ្ណសារត្រូវបានចុះលេខ ហើយប្រើប្រាស់ជាផ្លូវការរហូតមកដល់បច្ចុប្បន្ន ។ ក្នុងពេលជាមួយគ្នានោះដែរ សារមន្ទីរទួលស្លែងត្រូវបានប្តូរទៅជាសារមន្ទីរប្រវត្តិសាស្ត្រ ហើយឯកសារមួយចំនួនត្រូវបានថតចម្លងជាម៉ៃក្រូហ្វីលដោយសាកលវិទ្យាល័យខូណែលនៅសហរដ្ឋអាមេរិក ។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ សារមន្ទីរទួលស្លែងត្រូវបានគ្រប់គ្រងដោយរាជរដ្ឋាភិបាលចម្រុះដែលមានសម្តេចក្រុមព្រះនរោត្តម រណឫទ្ធិ និងសម្តេច ហ៊ុន សែន ជាសហនាយករដ្ឋមន្ត្រី ។ បច្ចុប្បន្ន សារមន្ទីរទួលស្លែងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

បណ្ណសារសារមន្ទីរទួលស្លែងរួមទាំងរូបថតទាំងអស់នៅទីនោះគឺជាឃ្លាំងឯកសារយ៉ាងសំខាន់សម្រាប់អ្នកសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រនិងនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ បណ្ណសារបានធ្វើឲ្យអ្នកសិក្សាស្រាវជ្រាវខ្មែរនិងបរទេសជាច្រើននាក់ស្វែងរកឃើញនូវខ្សែសង្វាក់និងយន្តការដាក់មេដឹកនាំខ្មែរក្រហមឲ្យទទួលខុសត្រូវចំពោះមុខប្រវត្តិសាស្ត្រ ។ គំហើញទាំងអស់នេះគឺបានមកពីកិច្ចសហការគ្នាក្នុងចំណោមអ្នកសិក្សាស្រាវជ្រាវទាំងអស់ដែលធ្វើការវិភាគទៅលើទិន្នន័យ រួមទាំងរូបភាពទាំងឡាយដែលបានដាក់តាំងពិព័រណ៍នៅទីនោះផង ។ សារមន្ទីរទួលស្លែងមិនត្រឹមតែជាកន្លែងដែលរំឭកនូវប្រវត្តិសាស្ត្រកម្ពុជានាពេលថ្មីៗប៉ុណ្ណោះទេ ថែមទាំងពន្យល់ឲ្យទាំងអស់គ្នាចងចាំនិងចៀសវាងការប្រព្រឹត្តជាថ្មីម្តងទៀតនូវអំពើព្រៃផ្សៃ និងការរំលោភសិទ្ធិរស់មានមានជីវិតរបស់មនុស្ស ។

ផ្នែកបន្ទាប់នេះនឹងរៀបរាប់ពិស្តារអំពីតួនាទីសិល្បៈ ពោលគឺការតាំងពិព័រណ៍រូបថតនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ក្នុងការចូលរួមចំណែកនាំមកនូវការរសាយកំហឹងនិងការផ្សះផ្សារវាងអតីតជនរងគ្រោះនិងជនដៃដល់នៃរបបខ្មែរក្រហម ។

### ៤) សំឡេងជនរងគ្រោះនៃប្រវត្តិសាស្ត្រ

នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០២ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកការតាំងពិព័រណ៍រូបថតបច្ចុប្បន្នភាពរបស់អតីតយុទ្ធជនខ្មែរក្រហមចំនួន១៣នាក់នៅសារមន្ទីរទួលស្លែង ។ ដោយប្រើប្រាស់ឯកសារដែលតម្កល់នៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ហេង ស៊ីនិត្យ អ្នកថតរូប និងក្រុមអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅមូលដ្ឋានដើម្បីធ្វើសម្ភាសន៍និងថតរូបអតីតយុទ្ធជនទាំង១៣នាក់ ដែលនៅក្នុងចំណោមនោះធ្លាប់បម្រើការជាយុទ្ធជននៅមន្ទីរស-២១ ។ រូបថតរបស់យុទ្ធជនទាំងនោះត្រូវបានដាក់តាំងនៅលើជញ្ជាំងបន្ទប់ចំនួនពីរនៅជាន់ទី១អគារ“ឃ”នៃសារមន្ទីរ ដោយមានប្រវត្តិរូបសង្ខេបនិងពាក្យសម្តីរបស់របស់អ្នកទាំងនោះដែលទទួលបានមកពីបទសម្ភាសន៍អមជាប់នោះផង ។ ពិព័រណ៍រូបថតនោះមានចំណងជើងថា “ជនរងគ្រោះនៃប្រវត្តិសាស្ត្រៈ សំឡេងនៃជនរងគ្រោះនិងជនដៃដល់នៃរបបខ្មែរក្រហម” ។ អត្ថបទដកស្រង់សម្តីរបស់យុទ្ធជនទាំង១៣នាក់ដែលបានដាក់តាំង បង្ហាញអំពីការទាមទារឲ្យមានការអធ្យាស្រ័យ ការអត់ឱន ការផ្សះផ្សា និងយុត្តិធម៌ ។ ជាមួយគ្នានឹងរូបថតបច្ចុប្បន្នដែលបង្ហាញអំពីសកម្មភាពប្រចាំថ្ងៃ ការប្រកបកិច្ចការងាររកទទួលទាន ការរស់នៅជាមួយក្រុមគ្រួសាររបស់យុទ្ធជនទាំង១៣នាក់នោះ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានដាក់តាំងដែរនូវរូបថតរបស់យុទ្ធជនទាំង១៣នាក់ដែលបានថតនៅក្នុងអំឡុងរបបខ្មែរក្រហម ដើម្បីឆ្លុះបញ្ចាំងអំពី

ជីវិតពិតរបស់អ្នកទាំងនោះដែលបានចំណាយយុវវ័យរបស់ខ្លួនដើម្បីបដិវត្តន៍ខ្មែរក្រហមនិងជីវិតបច្ចុប្បន្ន ។

ហេង ស៊ីនិត្យ អ្នកថតរូបសម្រាប់ការតាំងពិព័រណ៍និងជាជនរងគ្រោះនៃរបបខ្មែរក្រហម បាននិយាយអំពីគោលបំណងរបស់ខ្លួនក្នុងការចូលរួមតាំងពិព័រណ៍នេះថា «ខ្ញុំពិបាកនឹងបង្ហាញអំពីទំហំនៃការឈឺចាប់របស់ខ្ញុំឲ្យស្មើនឹងអ្វីដែលបានទទួលរងពីរបបខ្មែរក្រហមណាស់ ។ ទោះបីយ៉ាងណាក៏ដោយ ខ្ញុំអាចប្រើប្រាស់វិជ្ជាជីវៈជាអ្នកថតរូបដើម្បីធ្វើពិព័រណ៍បង្ហាញពិភពលោកអំពីជីវិតបច្ចុប្បន្នរបស់យុទ្ធជនទាំងនោះដែលកំពុងរស់នៅជាមួយក្រុមគ្រួសារ ។ វាជាការចាំបាច់ក្នុងការបង្ហាញអំពីការពិតដែលកើតមានទាំងចំពោះជនរងគ្រោះនិងយុទ្ធជនខ្មែរក្រហម ។ នៅក្នុងរបបខ្មែរក្រហម យុទ្ធជនទាំងនោះបានបម្រើការនៅមន្ទីរស-២១ ដែលជាមន្ទីរឃុំឃាំងយ៉ាងសាហាវព្រៃផ្សៃ ហើយឥឡូវនេះអ្នកទាំងនោះនៅតែជាសាក្សីផ្ទាល់ដែលអាចប្រាប់យើងអំពីមូលហេតុដែលនាំឲ្យកើតមានអំពើព្រៃផ្សៃបែបនោះ» ។

អ៊ីសា ឧស្មាន ដែលបាត់បង់សាច់ញាតិចំនួន១៣នាក់នៅក្នុងរបបខ្មែរក្រហម ក៏យល់ឃើញដូច ស៊ីនិត្យ ដែរ ។ ឧស្មាន និយាយអំពីគោលបំណងដែលចូលរួមរៀបចំការតាំងពិព័រណ៍ថា «ខ្ញុំចង់ឲ្យអ្នកទស្សនាទាំងអស់ដឹងអំពីជីវិតរបស់យុទ្ធជនខ្មែរក្រហម ក្រុមគ្រួសាររបស់អ្នកទាំងនោះ និងទំនាក់ទំនងរបស់អ្នកទាំងនោះជាមួយអ្នកស្រុក ។ ទោះបីជាអ្នកទាំងនោះធ្លាប់បម្រើការនៅកន្លែងសម្លាប់មនុស្សស-២១ក៏ដោយ ក៏យើងមិនត្រូវទម្លាក់កំហុស ស្តីបន្ទោស ឬស្អប់អ្នកទាំងនោះដែរ ។ អ្នកទស្សនាក៏ដូចជាជនរងគ្រោះអាចឮសម្តីរបស់អ្នកទាំងនោះដែលត្រូវបានដកស្រង់មកថា កិច្ចការទាំងអស់គឺធ្វើឡើងក្រោមបញ្ជារបស់មេដឹកនាំខ្មែរក្រហមនិងដើម្បីការរស់រានមានជីវិតតែប៉ុណ្ណោះ» ។

ឧស្មាន បានបញ្ជាក់ថា «ការតាំងពិព័រណ៍នេះមិនមែនជាការសងសឹកឬការគុំកួនមិនចេះចប់នោះទេ ។ នេះគឺជាមធ្យោបាយមួយក្នុងការរួមចំណែកស្វែងរកការពិតអំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ យើងគួរតែអត់ឱនដល់អ្នកទាំងឡាយណាដែលទទួលស្គាល់ឬសារភាពកំហុសជាជាងការសងសឹកដែលមិនមានទីបញ្ចប់ ។ នេះគឺជាអ្វីដែលព្រះពុទ្ធបានថែងថា «ពៀររំងាប់ដោយការមិនចងពៀរ» ។

ជាមួយនឹងការរៀបចំការតាំងពិព័រណ៍នេះ អ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើដំណើរទូទាំងប្រទេសជាច្រើនឆ្នាំមកហើយ ដើម្បីធ្វើសម្ភាសន៍អតីតយុទ្ធជនខ្មែរក្រហមដែលនៅរស់រានមានជីវិតរហូតមកទល់បច្ចុប្បន្ន ។ យុទ្ធជនខ្មែរក្រហមទាំងនោះមានលក្ខណៈធម្មតាដូចមនុស្សទូទៅដែរ ។ ដោយសារតែអ្នកស្រាវជ្រាវជាប្រជាជនខ្មែរដូចគ្នា យុទ្ធជនទាំងនោះតែងតែនិយាយប្រាប់អំពីជីវិតនិងសកម្មភាពរបស់ខ្លួននៅក្នុងរបបខ្មែរក្រហមដោយគ្មានការលាក់លៀម ។

ឧស្មាន បានរំឭកអំពីបទពិសោធន៍របស់ខ្លួននៅក្នុងការជួបសម្ភាសន៍ជាមួយ ប្រាក់ ខន អតីតអ្នកសួរចម្លើយអ្នកទោសនៅមន្ទីរស-២១ថា «នៅមុនពេលខ្ញុំទៅជួប ខន ខ្ញុំគិតថា ខន គឺជាមនុស្សសាហាវ មានភ្នែកក្រហម និងមានបាតដៃប្រឡាក់ឈាម ។ ខ្ញុំមិនជឿថា ខន លះបង់ចោលចរិតឃោរឃៅឡើយ ។ ផ្ទុយទៅវិញ ខន គឺជាមនុស្សរួសរាយរាក់ទាក់ ។ ខន រស់នៅដោយរីករាយជាមួយប្រពន្ធកូននិងក្នុងចំណោមអ្នកស្រុក ។ ជាការពិត ខ្ញុំជឿថា ខន ត្រូវមេដឹកនាំខ្មែរក្រហមបោកប្រាស់» ។

នៅក្នុងចំណោមអតីតយុទ្ធជនដែលបានផ្តល់បទសម្ភាសន៍ ទុយ គិន ជាអតីតយុទ្ធនារីខ្មែរក្រហមម្នាក់ដែលត្រូវជាប់ឃុំឃាំងអស់រយៈពេល១៨ខែនៅឆ្នាំ១៩៨៤ ដោយសារតែរូបថតរបស់គាត់មួយសន្លឹកដែលបានថតនៅក្នុងរបបខ្មែរក្រហមត្រូវបានដាក់តាំងនៅសារមន្ទីរទួលស្លែង ។ ដោយសារតែរូបថតនោះ គិន ត្រូវបានចោទប្រកាន់ពីអាជ្ញាធរខេត្តកណ្តាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ពីបទជាប់ទាក់ទិននឹងរបបខ្មែរក្រហមនិងការសម្លាប់មនុស្សចំនួន៣០០នាក់នៅមន្ទីរស-២១ ។ គិន បានបដិសេធពាក្យចោទប្រកាន់ទាំងនោះនិងបញ្ជាក់ថា គាត់មិនដែលសម្លាប់អ្នកណាម្នាក់ឡើយ ។

គិន បាននិយាយថា «សព្វថ្ងៃខ្ញុំតែងតែលើកដៃសំបូងសង្រួងថា ប្រសិនបើខ្ញុំប្រាកដជាបានសម្លាប់បងប្អូនណាម្នាក់ ឬក៏បាតដៃរបស់ខ្ញុំមានប្រឡាក់ឈាមបងប្អូនណាម្នាក់នោះ សូមឲ្យទេវតាបរាមុខខ្ញុំទៅចុះ» ។ ទោះបីយ៉ាងណាក៏ដោយ គិន បានជាប់ឃុំឃាំងរួចទៅហើយ ហើយសព្វថ្ងៃនេះ គាត់កំពុង

រស់នៅក្នុងភាពមន្ទិលសង្ស័យពីសំណាក់ញាតិជិតខាងចំពោះអតីតភាពរបស់គាត់ដែលជិតដាមមកពីរបបខ្មែរក្រហម ។

វាមិនមែនជាការងាយស្រួលក្នុងការប្រាប់ជនរងគ្រោះឲ្យផ្សះផ្សាជាមួយអ្នកដែលបានធ្វើទារុណកម្មនិងសម្លាប់ឪពុកម្តាយបងប្អូននិងសាច់ញាតិរបស់ខ្លួននោះឡើយ ។ វាក៏ជាការសំខាន់ដែលយើងមិនបំភ្លេចអតីតកាលនៅខណៈដែលមានមនុស្សមួយចំនួនព្យាយាម"ជីកកប់ប្រវត្តិសាស្ត្រ" ។ ប៊ូ ម៉េង អតីតអ្នកទោសនៅមន្ទីរស-២១ដែលរស់នៅមិនឆ្ងាយប៉ុន្មានពីផ្ទះរបស់អតីតយុទ្ធជនខ្មែរក្រហមម្នាក់ឈ្មោះ ហ៊ឹម ហ៊ុយ បាននិយាយថារាល់ពេលដែលគាត់ឃើញ ហ៊ុយ ដើរកាត់មុខផ្ទះរបស់គាត់ គាត់ចង់តែស្ទុះទៅសម្លាប់ ហ៊ុយ ដើម្បីសងសឹកចំពោះការបានហៅខ្ញុំថាមេអាពត ។ ខ្ញុំមិនខឹងនឹងគេទេពីព្រោះខ្ញុំពិតជាបានបម្រើការឲ្យរបបប៉ុលពតមែន ។ អ្នកភូមិភាគច្រើនបានដឹងថាខ្ញុំធ្លាប់ធ្វើការនៅកន្លែងសម្លាប់មនុស្សមន្ទីរស-២១ ។ ក៏ប៉ុន្តែខ្ញុំអាណិតប្រពន្ធនិងកូនរបស់ខ្ញុំ" ។ ដោយសារតែអតីតកាលរបស់ ហូ ជិតដាមពីរបបខ្មែរក្រហម ជីវិតប្រពន្ធនិងកូនរបស់ ហូ ក៏កំពុងរស់នៅជាមួយនឹងវិប្បដិសារីនេះដែរ ។

ហ៊ឹម ហ៊ុយ អតីតអនុប្រធានកងការពារអ្នកទោសនៅមន្ទីរស-២១ដែលទទួលខុសត្រូវទាំងការចាប់ចងនិងបញ្ជូនអ្នកទោសទៅទីពិឃាតជើងឯកដែរនោះ បានត្រឡប់មករស់នៅក្នុងភូមិកំណើតវិញបន្ទាប់ពីការដួលរលំរបបខ្មែរក្រហម ។ នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ អតីតយុទ្ធជនមន្ទីរស-២១


ញ៉ៀប ហូ ក្នុងរបបខ្មែរក្រហម


ញ៉ៀប ហូ និងក្រុមគ្រួសារ បច្ចុប្បន្ន

ឈឺចាប់ទាំងឡាយដែលគាត់បានទទួលរងនៅក្នុងរបបខ្មែរក្រហម ។

ទោះបីយ៉ាងណាក៏ដោយ វាជាការចាំបាច់ណាស់ដែលយើងត្រូវព្យាយាមជួយជនរងគ្រោះនិងយុទ្ធជនទាំងនោះឲ្យរសាយកំហឹង និងនាំមកនូវការផ្សះផ្សាគ្នាវិញ ។ អស់រយៈពេលជាច្រើនឆ្នាំមកហើយដែលអតីតយុទ្ធជនខ្មែរក្រហមទាំង ១៣នាក់ បានរស់នៅក្នុងភាពមន្ទិលសង្ស័យនិងការគុំគួនពីសំណាក់អ្នកស្រុក ។ ញ៉ៀប ហូ បានបម្រើការជាយុទ្ធជនកងការពារអ្នកទោសនៅមន្ទីរស-២១អស់រយៈពេលជាងពីរឆ្នាំ ។ រំឭកដល់ការរស់នៅរបស់គាត់នៅក្នុងភូមិ ហូ បាននិយាយថា "អ្នកភូមិភាគច្រើនត្រូវបានអាជ្ញាធរកោះហៅឲ្យទៅរៀនសូត្រនយោបាយ និងមួយចំនួនទៀតត្រូវបានចាប់បញ្ជូនទៅមន្ទីរឃុំឃាំង ។ ដោយសារតែធ្លាប់បម្រើការនៅក្នុងរបបខ្មែរក្រហម ហ៊ុយ ក៏ត្រូវបានអាជ្ញាធរខេត្តកណ្តាលចាប់ខ្លួនបញ្ជូនទៅមន្ទីរឃុំឃាំងអស់រយៈពេលជាងពីរឆ្នាំ ។ ទោះបីជា ហ៊ុយ ត្រូវបានដោះលែងឲ្យមានសេរីភាពវិញក៏ដោយ ក៏ ហ៊ុយ នៅតែបន្តរស់នៅក្នុងសភាពមន្ទិលសង្ស័យពីអ្នកស្រុកនៅឡើយ ជាពិសេសពីសំណាក់ ប៊ូ ម៉េង ដែលជាអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោស ១៨នាក់ដែលរស់រានមានជីវិតពីការសម្លាប់រង្គាលនៅមន្ទីរ

ស-២១ ។

ឆ្លើយតបចំពោះការសុំទោសរបស់ ប៊ូ ម៉េង និងដើម្បីបង្ហាញអំពីការពិត ហ៊ឹម ហ៊ុយ បាននិយាយថា "ខ្ញុំសូមសម្តែងការពិតអស់ពីចិត្តថា ខ្ញុំមិនចង់ធ្វើការនៅមន្ទីរស-២១នោះទេ។ ខ្ញុំបានសុំ សុន សេន រដ្ឋមន្ត្រីក្រសួងការពារប្រទេសនៃរបបខ្មែរក្រហម ដើម្បីចាកចេញពីកន្លែងនោះទៅសមរភូមិមុខ ប៉ុន្តែ សុន សេន បានបដិសេធ។ សព្វថ្ងៃអ្នកស្រុកនៅតែហៅខ្ញុំថាពួកខ្មែរក្រហម ។ ខ្ញុំមិនចង់ធ្វើដូច្នេះទេ ប៉ុន្តែ ឌុច ប្រធានគុក និង ហ៊ី អនុប្រធានគុក បានបញ្ជាខ្ញុំឲ្យធ្វើ។ បើខ្ញុំមិនធ្វើតាម ពួកគេនឹងសម្លាប់ខ្ញុំចោល" ។

នៅឆ្នាំ១៩៨១ សួស ធី ដែលធ្លាប់បានបម្រើការជាប្រពន្ធរបស់គាត់នៅខេត្តកណ្តាល ស្ថិតនៅប្រមាណ៦០គីឡូម៉ែត្រភាគខាងត្បូងទីក្រុងភ្នំពេញ ចំណែកឯកូនប្រុសស្រីទាំងអស់របស់គាត់កំពុងសិក្សានិងបម្រើការងារក្នុងរោងចក្រនៅទីក្រុងភ្នំពេញ ។ ធី បានអះអាងអំពីមូលហេតុដែលគាត់សម្រេចចិត្តបញ្ជូនកូនរបស់គាត់មកទីក្រុងថា នេះមិនមែនដោយសារតែបារម្ភខ្លាចក្រែងអ្នកភូមិស្អប់កូនរបស់គាត់ឡើយ ប៉ុន្តែដើម្បីអនាគតកូនរបស់គាត់ ។

ការដកស្រង់សង្ខេបសម្តីយុទ្ធជនទាំង១៣នាក់សម្រាប់ការតាំងពិព័រណ៌ ពិតជាបានជួយបង្ហាញពីរឿងរ៉ាវនិងបរិបទពិតនៅក្នុងរបបខ្មែរក្រហម ។ យើងសង្ឃឹមថា ពិព័រណ៌នេះជួយដល់ជនរងគ្រោះនិងជនដៃដល់នៃរបបខ្មែរក្រហមស្វែងយល់ទៅ


ហ៊ឹម ហ៊ុយ ក្នុងរបបខ្មែរក្រហម


ហ៊ឹម ហ៊ុយ និងក្រុមគ្រួសារ បច្ចុប្បន្ន

យុទ្ធជនផ្នែកឯកសារនៅមន្ទីរស-២១ ក៏ត្រូវជាប់ឃុំឃាំងនៅគុកតេ-៣ក្នុងទីក្រុងភ្នំពេញអស់រយៈពេលជាង៣ឆ្នាំដែរ ។ ធី បាន និយាយថា បន្ទាប់ពីគាត់ត្រូវបានដោះលែងពីមន្ទីរឃុំឃាំង គាត់បានប្រឹងប្រែងធ្វើស្រែចម្ការ ចិញ្ចឹមជ្រូកគោ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ។ ដោយសារតែគាត់មានតួនាទីនៅក្នុងរបបខ្មែរក្រហម ប្រពន្ធនិងកូនរបស់គាត់ត្រូវរស់នៅដោយឯកោនិងឈឺចាប់ចំពោះអតីតកាល ។ ធី ជឿថា អ្នកភូមិមួយចំនួននៅតែស្អប់គាត់និងក្រុមគ្រួសាររបស់គាត់ ទោះជាការស្អប់នោះមិនបានសម្តែងឲ្យឃើញក៏ដោយ ។ សព្វថ្ងៃ ធី រស់នៅជាមួយ

វិញទៅមក អំពីទស្សនៈនិងព្រឹត្តិការណ៍ទាំងឡាយដែលបានកើតមានកន្លងមកនៅក្នុងសង្គមកម្ពុជា ។ ប្រសិនបើគ្មានភាពយល់គ្នាទៅវិញទៅមក ឬក៏មិនបានស្វែងយល់សូម្បីតែការតាំងពិព័រណ៌នេះ ជនរងគ្រោះក៏ដូចជាអ្នកទស្សនាមួយចំនួននឹងមិនអាចរកឃើញនូវដំណោះស្រាយសមស្របចំពោះប្រវត្តិសាស្ត្រនេះឡើយ ។ ជុំ ម៉ី និង វ៉ាន់ ណាត អតីតអ្នកទោសពីរនាក់ក្នុងចំណោមអ្នកទោសនៅមន្ទីរស-២១ចំនួន១៨នាក់ដែលនៅរស់រានមានជីវិត បានសម្តែងភាពងឿងឆ្ងល់នៅពេលដែលពួកយុទ្ធជនខ្មែរក្រហមនិយាយថាខ្លួនជាជនស្លូតត្រង់និងជាជនរងគ្រោះដែរ ។

ម៉ី និង ណាត បាននិយាយដូចគ្នា "ប្រសិនបើជាគេជាជនរងគ្រោះនោះ យើងមិនដឹងថាយើងដែលអ្នកទទួលរងទារុណកម្មជាអ្វីនោះទេ" ។

វាមិនមែនជាការងាយស្រួលក្នុងការធ្វើឲ្យសម្រេចបាននូវការផ្សះផ្សារវាងជនរងគ្រោះនិងជនដៃដល់ក្នុងរយៈពេលដ៏ខ្លី ហើយក៏មិនមានវិធីណាមួយដែលអាចផ្លាស់ប្តូរទស្សនៈនិងការគិតរបស់ប្រជាជនកម្ពុជាចំពោះខ្លួនឯងនិងអ្នកដទៃបានក្នុងមួយពព្រិចភ្នែកនោះដែរ ។ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា មានប្រសាសន៍ថា "វាមិនមែនជាការត្រឹមត្រូវទេក្នុងការទម្លាក់កំហុសទាំងអស់ចំពោះខ្មែរក្រហម ។ ប៉ុន្តែវាក៏មិនមែនជាការត្រឹមត្រូវដែរក្នុងការជំរុញឲ្យជនរងគ្រោះអត់ទិនដល់ជនដៃដល់ ខណៈពេលជនដៃដល់ទាំងនោះដើរហើរដោយសេរីនៅចំពោះមុខជនរងគ្រោះ" ។ ឆាំង យុ បានផ្តល់ជាអនុសាសន៍ថា "អ្វីដែលយើងអាចធ្វើបាននាពេលបច្ចុប្បន្នគឺជួយជាយុទ្ធសាស្ត្រដល់ប្រជាជនកម្ពុជា ក្នុងការស្វែងរកយុត្តិធម៌ចំពោះអតីតកាលដែលជាមធ្យោបាយនាំមកនូវការពិត ការរសាយចិត្ត និងការអធ្យាស្រ័យ" ។

ការតាំងពិព័រណ៍នេះពិតជាផ្តល់នូវការរសាយចិត្តនិងជីវិតថ្មីមួយដល់អតីតយុទ្ធជនខ្មែរក្រហមទាំង១៣នាក់ព្រមទាំងក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ វាក៏បាននាំមកនូវការយល់ឃើញមួយទៀតដល់អ្នកភូមិនិងប្រជាជនកម្ពុជាចំពោះអតីតកាលរបស់យុទ្ធជនខ្មែរក្រហម ។ ប្រហែលជាមានសំណួរលើកឡើងថាតើក្រៅអំពីយុទ្ធជនទាំង១៣នាក់នេះនៅមានយុទ្ធជនប៉ុន្មាននាក់ទៀតដែលកំពុងបន្តរស់នៅជាមួយនឹងភាពមិនចុះសម្រុងនៅក្នុងសហគមន៍របស់ខ្លួន? អ្នកទស្សនាភាគច្រើនរួមទាំងប្រជាជនកម្ពុជានិងបរទេស មានឱកាសច្រើនក្នុងការស្វែងយល់អំពីប្រវត្តិសាស្ត្រខ្មែរក្រហម ។

ព្រះសាមណេរ ប៊ុត វុទ្ធី មកពីវត្តនិរោធរង្សីដែលបាននិមន្តមកទស្សនាពិព័រណ៍នៅសារមន្ទីរទួលស្លែង បានមានថេរដីកាថា "អាត្មាធ្លាប់បានឮញោមប្រាប់ពីអំពើឃោរឃៅរបស់ខ្មែរក្រហមជារឿយៗ ប៉ុន្តែកាលនោះអាត្មាដូចជាមិនជឿជាក់ទាំងស្រុងនោះទេ ។ ឥឡូវនេះបន្ទាប់ពីបានឃើញរូបភាពនៅសារមន្ទីរទួលស្លែង ទើបអាត្មាបានដឹងពីសភាពជាក់ស្តែងដែលកើតមាននៅក្នុងរបបខ្មែរក្រហម" ។ ព្រះសាមណេរក៏បានបួងសួងសុំឲ្យមានសន្តិភាពដល់ប្រទេសកម្ពុជា ។

ទោះបីថាអំពើប្រល័យពូជសាសន៍ខ្មែរក្រហមបានកើតមាននៅប្រទេសកម្ពុជា ប៉ុន្តែនេះគឺជាផ្នែកមួយនៃបទពិសោធន៍និងបញ្ហារបស់មនុស្សជាតិ ហើយយើងត្រូវតែទប់ស្កាត់កុំឲ្យកើតមានសាជាថ្មីម្តងទៀត ។ ខាល ជនជាតិអូស្ត្រាលី បានសរសេរនៅក្នុងសៀវភៅ "មតិអ្នកទស្សនា" ដែលបានដាក់នៅក្នុងបន្ទប់តាំងពិព័រណ៍ថា "ទឹកមុខមនុស្សនៅក្នុងរូបថតទាំងនេះបានបង្ហាញនូវការពិតចំពោះអ្វីដែលបានកើតឡើង ។ ខ្ញុំមានការតក់ស្លុតយ៉ាងខ្លាំង ហើយសង្ឃឹមថាអំពើឃោរឃៅបែបនេះនឹងមិនកើតមានទៀតឡើយ ។ ខ្ញុំនឹងប្រាប់គ្រប់គ្នាអំពីរឿងរ៉ាវនេះ" ។

ឡែន លីន ជនជាតិប៊្រុយណេ បានសម្តែងនូវការសោកស្តាយថា "ខ្ញុំពិតជាមានការអាណិតអាសូរដល់អ្នកទាំងឡាយដែលបានស្លាប់នៅក្នុងរបបកន្លងទៅ មិនត្រឹមតែនៅទីនេះទេ ពេលគឺនៅគ្រប់ទីកន្លែង ។ យើងទាំងអស់គ្នាត្រូវតែព្យាយាមបញ្ឈប់សង្គ្រាមនិងការរំលោភសិទ្ធិមនុស្សដែលកំពុងកើតមាននៅលើពិភពលោក" ។

ការផ្តល់ឱកាសឲ្យជនរងគ្រោះនិងជនដៃដល់នៃរបបខ្មែរក្រហមបញ្ចេញទស្សនៈនិងប្រាប់ការពិតទៅវិញទៅមក គឺអាចជួយឲ្យមានការធូរស្បើយនូវភាពតានតឹង ។ ភាពស្ងៀមស្ងាត់មិនអាចជួយឲ្យយើងស្រុះស្រួលគ្នានិងស្វែងរកការពិតឃើញឡើយ ។ ចាប់តាំងពីអតីតកាលរបស់អ្នកទាំងនោះត្រូវបានលាតត្រដាង យុទ្ធជនទាំង១៣នាក់មានការរសាយចិត្តច្រើនជាងពេលមុន ។ អ្នកទាំងនោះថែមទាំងបានអះអាងថា ខ្លួននឹងមិនរួញរាក្នុងការឡើងធ្វើជាសាក្សីនិងបញ្ជាក់ឲ្យច្បាស់អំពីសកម្មភាពទាំងឡាយដែលកើតមាននៅមន្ទីរស-២១ នៅចំពោះមុខសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនាពេលខាងមុខឡើយប្រសិនបើតុលាការត្រូវការរូបគេដើម្បីបំភ្លឺ ។

ការអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនិងអំពើប្រល័យពូជសាសន៍ដែលត្រូវតែជំនុំជម្រះក្តី គឺចាំបាច់បំផុតសម្រាប់មនុស្សជំនាន់ក្រោយ ។ ផ្នែកបន្ទាប់នេះនឹងរៀបរាប់អំពីទស្សនៈថាតើមនុស្សនិងយុវជនជំនាន់ក្រោយអាចទទួលបានផលប្រយោជន៍

និងចូលរួមយ៉ាងដូចម្តេចដើម្បីទប់ស្កាត់ការវិលត្រឡប់ជាថ្មីនូវអំពើប្រល័យពូជសាសន៍ ។

## ៩) ការចូលរួមចំណែករបស់មនុស្សជំនាន់ក្រោយ

យុវជនតែងតែងាយនឹងធ្លាក់ចូលទៅក្នុងការអូសទាញដោយមនោគមវិជ្ជា ។ ជាងនេះទៅទៀត យុវជនក៏ឆាប់ទទួលរងនូវការភ័យខ្លាច តក់ស្លុត និងបាក់ស្បាតដែរ ។ រឿងរ៉ាវរបស់យុវជនទាំង១៣នាក់ដែលបានរៀបរាប់នៅក្នុងពិព័រណ៍គួរតែត្រូវបានពិចារណាសម្រាប់ជាឧទាហរណ៍ ។ អ្នកទាំងនោះបានចូលរួមបម្រើបដិវត្តន៍ខ្មែរក្រហមតាំងពីនៅក្មេង ហើយលះបង់យុវវ័យរបស់ខ្លួននិងទំនាក់ទំនងក្នុងសង្គមទាំងអស់ដើម្បីបដិវត្តន៍ ។

បច្ចុប្បន្ននេះ សិស្សនិស្សិតនៅតាមវិទ្យាល័យនិងមហាវិទ្យាល័យភាគច្រើននៅប្រទេសកម្ពុជា មិនបានយល់ដឹងស៊ីជម្រៅអំពីប្រវត្តិសាស្ត្រខ្មែរក្រហមទេ ។ ជាក់ស្តែង នៅអំឡុងពេលយុទ្ធនាការឃោសនាបោះឆ្នោតនាខែកក្កដាឆ្នាំ២០០៣ ទស្សនៈរបស់សិស្សនៅតាមវិទ្យាល័យជាច្រើនត្រូវបានដកស្រង់ចុះផ្សាយក្នុងទំព័រសារព័ត៌មានក្នុងស្រុក ។ ការបញ្ចេញមតិរបស់សិស្សានុសិស្សគឺជុំវិញចរិតលក្ខណៈរបស់អ្នកដឹកនាំប្រទេសដែលគេចង់បានសម្រាប់ការបោះឆ្នោតនាពេលនោះ ។ កុមារាម្នាក់អាយុ១៥ឆ្នាំរៀននៅវិទ្យាល័យស៊ីសុវត្ថិ បាននិយាយថា "ខ្ញុំចង់មានមេដឹកនាំដែលស្រឡាញ់ជាតិដូចអ៊ីត្លែរ ម៉ឺងមាត់ដូចស្តាលីន រូសរាយរាក់ទាក់ដូចឈីចឈីល គោរពឧត្តមគតិដូចអាប្រាហាំលីនកុន និងក្លាហានដូចណាប៉ូឡេអុង" ។ នេះគឺជាសញ្ញាណដែលអាចមើលឃើញថា អំពើប្រល័យពូជសាសន៍នៅតែមានសក្តានុពលក្នុងការកើតឡើងជាថ្មីទៀតនៅប្រទេសកម្ពុជាទៅអនាគត ប្រសិនបើយើងខកខានមិនបានអប់រំយុវជនជំនាន់ក្រោយពីអំពើប្រល័យពូជសាសន៍ជាទូទៅនិងប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យច្បាស់លាស់ទេនោះ ។

ការប្រើប្រាស់រូបថតជាមធ្យោបាយក្នុងការបង្រៀនគឺមានប្រសិទ្ធភាពខ្ពស់សម្រាប់ប្រទេសកម្ពុជា ។ ការឆ្លើយតបជាសាធារណៈពីសំណាក់អ្នកទស្សនាពិព័រណ៍នៅសារមន្ទីរទួលស្លែង បានបង្ហាញមិនត្រឹមតែចំណុចវិជ្ជមានប៉ុណ្ណោះទេ ថែមទាំងរៀបរាប់អំពីព័ត៌មានដ៏កម្រនិងមានតម្លៃដល់សាធារណៈអំពីប្រវត្តិសាស្ត្រខ្មែរក្រហមទេ ។ ជាក់ស្តែង សិស្សមួយក្រុមមកពីវិទ្យាល័យសន្ធរម៉ុក បានសរសេរនៅក្នុងសៀវភៅ"មតិរបស់អ្នកទស្សនា" ថា "យើងទាំងអស់គ្នាមានការរន្ធត់យ៉ាងខ្លាំងនៅពេលដែលមើលរូបថតទាំងនេះ ។ យើងមានសំណាងណាស់ដែលមិនបានកើតនៅក្នុងសម័យខ្មែរក្រហម ។ យើងសង្ឃឹមថា អំពើឃោរឃៅបែបនេះនឹងមិនកើតឡើងទៀតឡើយ" ។

អាន់ខ្វូ ជាជនជាតិអង់គ្លេសនិងជាអ្នកទស្សនាម្នាក់នៅក្នុងចំណោមអ្នកទស្សនាសារមន្ទីរទួលស្លែង បានសរសេរថា "ខ្ញុំស្ទើរតែមិនជឿថាអំពើឃោរឃៅបែបនេះកើតឡើងនាពេលថ្មីៗសោះ ។ នេះគឺជារឿងរ៉ាវដែលត្រូវតែសិក្សារៀនសូត្រនិងអប់រំ ។ សារមន្ទីរនេះគឺជាចំណុចចាប់ផ្តើមនៃការស្វែងយល់ពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហមសម្រាប់ប្រជាជនកម្ពុជានិងជនទាំងឡាយដែលបានធ្វើដំណើរមកដល់ប្រទេសនេះ ។ យើងត្រូវតែនាំមេដឹកនាំខ្មែរក្រហមឡើងសាលាក្តី ដើម្បីបង្ហាញជាគំរូនិងអប់រំជាសាធារណៈដល់ពិភពលោក ។ ខ្ញុំសង្ឃឹមថា នៅក្នុងលក្ខណៈណាមួយ ឬនៅកន្លែងណាមួយទៀត អំពើសម្លាប់មនុស្សបែបនេះនឹងមិនបន្តកើតមានឡើយ" ។

នៅក្នុងប្រទេសកម្ពុជាដែលមានប្រជាជនចំនួនពីរភាគបីមិនចេះអានឬសរសេរ និងពិបាកក្នុងការទទួលព័ត៌មានស្តីពីអំពើប្រល័យពូជសាសន៍ខ្មែរក្រហម ពិព័រណ៍រូបថតបានដើរតួនាទីដ៏សំខាន់ក្នុងការអប់រំប្រជាជនកម្ពុជាអំពីប្រវត្តិសាស្ត្រនេះ ។ នៅអនាគតដ៏ឆាប់ខាងមុខនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងបោះពុម្ពសៀវភៅស្តីអំពីរូបថតនៅក្នុងរបបខ្មែរក្រហម ដើម្បីចែកផ្សាយទូទាំងប្រទេស ។ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានមានប្រសាសន៍ថា "នេះគឺជាគោលបំណងរបស់មជ្ឈមណ្ឌលក្នុងការបោះពុម្ពសៀវភៅទាំងនេះ ។ ការមើលសៀវភៅរូបថតនេះនឹងបង្កើនឲ្យមានការជជែកពិភាក្សាអំពីបញ្ហាខ្មែរក្រហម រួមចំណែកការចងចាំអំពីប្រវត្តិសាស្ត្រ និងជំរុញឲ្យទាំងអស់គ្នាចូលរួមទប់ស្កាត់អំពើប្រល័យពូជសាសន៍" ។

ផ្នែកបន្ទាប់នេះនឹងរៀបរាប់អំពីតួនាទីមជ្ឈមណ្ឌលឯកសារកម្ពុជានិងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលនឹងបន្តបំពេញភារកិច្ចដើម្បីជួយជនរងគ្រោះនៃរបបខ្មែរ

ក្រហមតទៅទៀត ។

## ៦) ការថែរក្សាប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យនៅមានជីវិត

ចាប់តាំងពីបដិសន្ធិនៅឆ្នាំ១៩៩៥ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបំពេញតួនាទីជាចម្បងក្នុងការ ១) ផ្តល់ព័ត៌មានជាអចិន្ត្រៃយ៍ដល់សាធារណជនដើម្បីសិក្សាស្វែងយល់កាន់តែច្បាស់អំពីរបបខ្មែរក្រហម និង ២) ទប់ស្កាត់ការវិលត្រឡប់មកវិញនូវអំពើប្រល័យពូជសាសន៍តាមរយៈផ្លូវច្បាប់និងមធ្យោបាយសន្តិភាព ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបំពេញកិច្ចការយ៉ាងសកម្មក្នុងការប្រមូលចងក្រងឯកសារដែលទាក់ទងនឹងរបបខ្មែរក្រហម ។ រហូតមកទល់បច្ចុប្បន្ននេះ មជ្ឈមណ្ឌលឯកសារកម្ពុជាប្រមែប្រមូលនិងរៀបចំទុកដាក់យ៉ាងត្រឹមត្រូវនូវឯកសារចំនួន៦សែនទំព័រ រូបថតដែលបន្សល់ទុកពីរបបខ្មែរក្រហមប្រមាណ៣ម៉ឺន៩ពាន់សន្លឹក និងភស្តុតាងជាសក្ខីភាពស្តីអំពីបទឧក្រិដ្ឋនៅក្នុងរបបខ្មែរហ្រាមជាច្រើនទៀត ។

ជាមួយគ្នានឹងឯកសារទាំងនោះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយនូវសៀវភៅប្រវត្តិសាស្ត្រជាច្រើនក្បាល និងទស្សនាវដ្តីប្រចាំខែដែលមានចំណងជើងថា "ស្វែងរកការពិត" ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកនិងផ្សព្វផ្សាយឯកសារទាំងនោះដល់សាធារណជន ប្រធានភូមិ ប្រធានឃុំ រហូតដល់មន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល គណបក្សនយោបាយ សាលារៀន និងបណ្ណាល័យ នៅទូទាំងប្រទេស ។ ឯកសារទាំងនោះបានដើរតួនាទីដ៏មានសារប្រយោជន៍ដល់ប្រជាជននិងសិស្សានុសិស្ស សិក្សារៀនសូត្រនិងថែរក្សាប្រវត្តិសាស្ត្រខ្មែរក្រហម ។

ជាងនេះទៅទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតគម្រោងការងារជាច្រើនដើម្បីរួមចំណែកជំរុញឲ្យមានការផ្សះផ្សារវាងជនជនរងគ្រោះនិងជនដៃដល់ដែលកំពុងរស់នៅក្នុងសហគមន៍ជាមួយគ្នា និងឈានទៅដល់ការផ្សះផ្សាថ្នាក់ជាតិ ។ ក្នុងពេលជាមួយគ្នានេះ សារមន្ទីរទួលស្លែងក៏បានបំពេញភារកិច្ចយ៉ាងសកម្មដើម្បីបង្ហាញដល់ពិភពលោកនូវវិនាសកម្មក្រោមរបបខ្មែរក្រហម និងថែរក្សាមរតកព្រៃផ្សៃទាំងនេះទុកសម្រាប់មនុស្សជំនាន់ក្រោយសិក្សារៀនសូត្រ ។ វាជាការចាំបាច់ណាស់ដែលមនុស្សជំនាន់ក្រោយត្រូវចងចាំអំពីអតីតកាលនិងរៀនសូត្រដើម្បីអនាគតកាល ។

នៅអនាគតដ៏ឆាប់នេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងដាក់តាំងពិព័រណ៍រូបថតមេដឹកនាំខ្មែរក្រហមដែលស្លាប់បាត់បង់ជីវិត និងនៅរស់ ព្រមទាំងលាដ៍សាកសពជនរងគ្រោះនៅសារមន្ទីរទួលស្លែង ដើម្បីឲ្យអ្នកទស្សនាសិក្សាស្វែងយល់បន្ថែមអំពីគោលប្រវត្តិរបស់មេដឹកនាំម្នាក់ៗ និងអំពីទិដ្ឋភាពរងគ្រោះក្រោមរបបខ្មែរក្រហម ។

លើសពីគោលការណ៍និងសកម្មភាពខាងលើនេះនិងសម្រាប់បរិបទនៃសង្គមកម្ពុជា វាជាការចាំបាច់ណាស់ដែលយើងត្រូវតែកសាងនូវមូលដ្ឋានច្បាប់ (នីតិរដ្ឋ) ។ ផ្នែកចុងក្រោយនេះនឹងពិភាក្សាអំពីតួនាទីតុលាការខ្មែរក្រហមក្នុងការនាំឲ្យមាននូវបម្លាស់ប្តូរវិជ្ជមានឲ្យកត់សម្គាល់ ។ យើងជឿជាក់ថា តុលាការខ្មែរក្រហមនឹងរួមចំណែកយ៉ាងសំខាន់ចំពោះដំណើរការផ្សះផ្សាជាតិនៅកម្ពុជា ។

## ៧) ការកសាងមូលដ្ឋានច្បាប់

*"គ្មានអ្វីដែលអាចជាសំណងដល់ជនរងគ្រោះនៃរបបខ្មែរក្រហមបានទេ ។ ដូច្នេះការទាមទារឲ្យមានត្រឹមតែតុលាការមួយនោះគឺតិចតួចណាស់"* ។ ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។

អស់រយៈពេលជាច្រើនឆ្នាំមកហើយដែលប្រជាជនកម្ពុជាទន្ទឹងរង់ចាំយុត្តិធម៌ដែលជាសំណងចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តដោយរបបខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ អំពើឃោរឃៅនៃរបបខ្មែរក្រហមបានផុតរលត់ទៅជាង២៥ឆ្នាំមកហើយ ប៉ុន្តែវានៅតាមលងអារម្មណ៍និងអនាគតប្រជាជនកម្ពុជាដូចស្រមោលដែលអន្ទោលតាមប្រាណ និងធ្វើឲ្យរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា ។ ដោយសារតែដំណើរការបង្កើតសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមបានប្រព្រឹត្តទៅដោយសភាពយឺតយ៉ាវ រួមជាមួយនឹងហេតុការណ៍ដែលមិនអាចរំពឹងទុកជាមុន ជនរងគ្រោះវ័យចំណាស់ដែលបានទទួលរងការឈឺចាប់ទាំងផ្លូវចិត្ត ជីវភាពរស់នៅ និងការទន្ទឹងរង់ចាំយុត្តិធម៌ ព្រមទាំងមេដឹកនាំខ្មែរក្រហមមួយចំនួន បាន

ស្លាប់បាត់បង់ជីវិតជាបន្តបន្ទាប់នៅមុនពេលទទួលបានយុត្តិធម៌និងវិនិច្ឆ័យក្តី ។

ឆាំង យុ មានប្រសាសន៍ថា «យើងត្រូវចាំថា រយៈពេលជាង២៥ឆ្នាំហើយចាប់តាំងពីរបបខ្មែរក្រហមដួលរលំ កម្ពុជាមិនទាន់សម្រេចបាននូវបំណងក្នុងការបង្កើតសាលាក្តីមួយដែលគួរឲ្យជឿទុកចិត្តដើម្បីជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនៅឡើយទេ» ។ ជាការពិត ប្រជាជនកម្ពុជាមិនគួរបន្តនៅជាចំណាប់ខ្មាំងនៃប្រវត្តិសាស្ត្រខ្មែរក្រហមដូច្នេះឡើយ ។

ថ្មីៗនេះ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងដើម្បីបង្កើតតុលាការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម ។ នេះគឺជាដំណើរការមួយនៅលើកំណាត់ផ្លូវដ៏វែងឆ្ងាយនិងប្រកបដោយភាពលំបាកលំបិនក្នុងការស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះរាប់លាននាក់ ។ នេះគឺជាជំហានមួយដ៏សំខាន់បំផុតក៏ប៉ុន្តែនៅមិនទាន់មានប្រសិទ្ធភាពនៅឡើយដែរ ។ ទាក់ទិននឹងមរតកនៃរបបខ្មែរក្រហម វាគឺជាដំណើរការមួយដ៏យូរអង្វែងសម្រាប់កម្ពុជា ។ ជាមួយគ្នានេះ កម្ពុជាត្រូវកសាងសេដ្ឋកិច្ច ពង្រឹងមូលដ្ឋានប្រជាធិបតេយ្យ និងអប់រំបណ្តុះបណ្តាលមនុស្សជំនាន់ក្រោយ ។ វាក៏តម្រូវឲ្យមាននូវកម្មវិធីជាជំនួយដល់ការរសាយចិត្តនិងការអធ្យាស្រ័យអត់ឱនចំពោះអតីតកាលរវាងប្រជាជននៅក្នុងសហគមន៍ដែរ ។ តុលាការខ្មែរក្រហមនឹងជួយគាំទ្រដល់ដំណើរការទាំងអស់នេះ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏វានឹងមិនអាចលុបបំបាត់នូវសេចក្តីត្រូវការទាំងស្រុងរបស់កម្ពុជានោះឡើយ ។ សម្រាប់បរិបទកម្ពុជា តុលាការខ្មែរក្រហមនឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សាសន្តិភាព ប្រជាធិបតេយ្យ និងអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា ។

ជនរងគ្រោះមួយចំនួនទទូចឲ្យមានការជំនុំជម្រះទាំងអតីតសមាជិកនៃរបបខ្មែរក្រហម ប៉ុន្តែនៅក្នុងបទបញ្ញត្តិទូទៅនៃច្បាប់ស្តីពី«ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ» បានចែងថា «ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម...» តែប៉ុណ្ណោះ ។

ទោះបីជានៅមានភាពងឿងឆ្ងល់ចំពោះបទឧក្រិដ្ឋនេះក៏ដោយ ក៏មិនទាន់មានមេដឹកនាំខ្មែរក្រហមណាម្នាក់ត្រូវបាននាំទៅកាន់សាលាក្តី និងប្រឈមមុខចំពោះការចោទប្រកាន់តាមផ្លូវច្បាប់នៅឡើយដែរ ។ ផ្ទុយទៅវិញ អ្នកទាំងនោះមានសិទ្ធិដើរហើរយ៉ាងសេរីនៅចំពោះមុខជនរងគ្រោះ ។ សកម្មភាពបែបនេះគឺជាគំរូដ៏អាក្រក់សម្រាប់យុវជនជំនាន់ក្រោយ ព្រមទាំងមេដឹកនាំបច្ចុប្បន្ននិងទៅអនាគត ។

### សន្និដ្ឋាន

ដើម្បីអនាគតកម្ពុជា វាជាការចាំបាច់ណាស់ក្នុងការផ្លាស់ប្តូរនូវភាពគានតឹងនិងការឈឺចាប់ពីអតីតកាល និងនាំមកនូវការផ្សះផ្សាជាតិ ។ ការតាំងពិព័រណ៍គឺជាជំហានមួយក្នុងការរួមចំណែកក្នុងការផ្សះផ្សាជាតិ ។ មិនតែប៉ុណ្ណោះ ពិព័រណ៍នេះគឺជាសំឡេងជំរុញកាន់តែខ្លាំងក្នុងការនាំខ្លួនមេដឹកនាំខ្មែរក្រហមឡើងសាលាក្តីឲ្យកាន់តែឆាប់ ដើម្បីបញ្ចប់នូវវប្បធម៌គ្មានទោសពៃរ៍ ព្រមទាំងជួយថែរក្សាសន្តិភាពនិងការផ្សះផ្សាជាតិនៅកម្ពុជា ។ លើសពីនេះទៀត នៅក្នុងប្រទេសកម្ពុជាដែលអត្រាអនក្ខរជនមានចំនួនច្រើននិងពិបាកក្នុងការស្វែងយល់នូវព័ត៌មានស្តីពីអំពើប្រល័យពូជសាសន៍តាមរយៈទូរទស្សន៍និងកាសែត ដូច្នេះរូបថតទាំងនេះបានផ្តល់នូវចំណេះដឹងប្រវត្តិសាស្ត្រដែលមិនអាចកាត់ថ្លៃបានដល់ប្រជាជនកម្ពុជា ព្រមទាំងជួយឲ្យប្រជាជនកម្ពុជាយល់កាន់តែច្បាស់អំពីតួនាទីរបស់ខ្លួននៅក្នុងការស្តាបនា ការថែរក្សាប្រវត្តិសាស្ត្រ និងនៅក្នុងដំណើរការប្រជាធិបតេយ្យ ។

**ហ៊ុយ វណ្ណៈ**

## ពន្យល់ពាក្យខ្មែរក្រហម

◆ ***ការបដិវត្តន៍:*** *ការបំបះបំបោរឡើងដើម្បីផ្លាស់របៀបចាស់ទៅជាថ្មី ។*

◆ ***ឯកភាព:*** *ការបង្រួបបង្រួមបញ្ចូលគ្នាធ្វើតែមួយ ។*

*(ដកស្រង់ពីកំណត់ហេតុរបស់សមមិត្ត ប៊ុនធឿន)*

# ឧក្រិដ្ឋកម្មសង្គ្រាមនិងការរំលោភសិទ្ធិមនុស្សនៅឆេចឆ្នី

*របាយការណ៍ផ្ទាល់មាត់ដោយ អូឡិក អូឡុហ្*
*ប្រធានកម្មវិធីស្រាវជ្រាវនិងវិពុកដល់សង្គ្រាមនៅឆេចឆ្នី*
*ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០០*

អស់រយៈពេលជាច្រើនឆ្នាំមកហើយ អង្គការរបស់ខ្ញុំបាន និងកំពុងធ្វើបេសកកម្មនៅក្នុងតំបន់ កូខេសឹស ជាពិសេសនៅផ្នែកខាងជើង ។ យើងបានសង្កេតទៅលើការគោរពសិទ្ធិមនុស្សនៅក្នុងតំបន់នេះតាំងតែពីដើមទសវត្សរ៍ឆ្នាំ១៩៩០មកម្ល៉េះ ។

នៅក្នុងដំណាក់កាលនៃសង្គ្រាមទីមួយ យើងបានរៀបចំបេសកកម្មសង្កេតការសិទ្ធិមនុស្សមួយនៅក្នុងតំបន់ដែលមានជម្លោះ ។ នៅចន្លោះពេលសង្គ្រាម យើងបានបញ្ជូនមនុស្សជាច្រើនក្រុមទៅកាន់តំបន់ឆេចឆ្នីនិងតំបន់នៅជុំវិញជាច្រើនលើកច្រើនសា ។ បេសកកម្មរបស់យើងកន្លងមកគឺធ្វើនៅក្នុងតំបន់អ៊ិងហ្គុស្សេទៀ តាំងតែពីពេលចាប់ផ្ដើមនៃសង្គ្រាមទីពីរបច្ចុប្បន្ន ។

តំណាងអង្គការសិទ្ធិមនុស្សពុំអាចធ្វើដំណើរទៅតំបន់ឆេចឆ្នីបានទេ ដោយសារមានឧបសគ្គជាច្រើនបង្កឡើងដោយអាជ្ញាធររុស្ស៊ី ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលិកនៅតាមតំបន់របស់យើងបានប្រមែប្រមូលពត៌មាននៅកន្លែងកើតហេតុ ហើយជួនកាលនៅក្នុងតំបន់ឆេចឆ្នីនោះតែម្ដង ។

ខ្ញុំនឹងចាប់ផ្ដើមដោយការបរិយាយអំពីចំណុចទូទៅនៃគោលជំហររបស់អង្គភាពខ្ញុំចំពោះជម្លោះ ។ ទីមួយខ្ញុំត្រូវតែទទួលស្គាល់ថាយើងបានកាន់កាប់នូវឯកសារមួយចំនួនដែលអាចឲ្យយើងឈានសន្និដ្ឋានថា នៅក្នុងអំឡុងពេលពីឆ្នាំ១៩៩៦ដល់១៩៩៩ របនាសម្ព័ន្ធនៃការកាន់កាប់អំណាចនៅក្នុងសាធារណរដ្ឋឆេចឆ្និនបានបង្ហាញអំពីកង្វះសមត្ថភាពទាំងស្រុងក្នុងការការពារអាយុជីវិតនិងធានាឲ្យបាននូវសន្តិសុខនិងសិទ្ធិជាជនស៊ីវិលនៃប្រជាជនរស់នៅក្នុងតំបន់ឆេចឆ្នី ។ លើសពីនេះ រដ្ឋដែលកំពុងស្ថិតនៅក្រោមការកកើត បានបង្ហាញខ្លួនដោយមិនខ្វាយខ្វល់អំពីបញ្ហាផ្សេងៗទាក់ទងទៅនឹងការគោរពសិទ្ធិមនុស្ស ។ ឧទាហរណ៍ ខ្ញុំមានអត្ថបទថតចម្លងមួយនៃអ្វីដែលហៅថា “ក្រមព្រហ្មទណ្ឌនៃសាធារណរដ្ឋ ឆេចឆ្និន អ៊ិកកេរៀ” ។ មនុស្សគ្រប់រូបដែលដឹងច្បាស់អំពីច្បាប់នេះ នឹងកត់សម្គាល់ឃើញថា ច្បាប់នេះរំលោភយ៉ាងធ្ងន់ធ្ងរទៅលើបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ។ ម្យ៉ាងទៀត ខ្ញុំគួរចង្អុលបង្ហាញថា របនាសម្ព័ន្ធនៃអំណាចរបស់សាធារណរដ្ឋឆេចឆ្និន អ៊ិកកេរៀ បានបរាជ័យក្នុងការដោះស្រាយបញ្ហាវាយប្រហារពីក្រុមចោរព្រៃ ការចាប់ពង្រត់ និងការរំលោភបំពានផ្នែកព្រហ្មទណ្ឌផ្សេងទៀត ដែលលេចចេញពីសាធារណរដ្ឋនេះខ្លួនឯង ហើយរាលដាលទៅក្នុងតំបន់ជិតខាងនៅក្នុងប្រទេសរុស្ស៊ី ។ តាមរយៈការបូកសរុបនៃកត្តាទាំងនេះ យើងឈានសន្និដ្ឋានថា សំណួរនៃការផ្ដល់ដល់តំបន់ឆេចឆ្នីនូវឋានៈជារដ្ឋឯករាជ្យមួយមិនអាចក្លាយជារបៀបវារៈនៃការពិភាក្សាណាមួយនៅក្នុងពេលបច្ចុប្បន្នបានទេ ។ គ្រោះថ្នាក់ដែលឆេចឆ្និនអាចបង្កឲ្យមានចំពោះប្រទេសឬតំបន់ជិតខាង គឺត្រូវបានបង្ហាញយ៉ាងច្បាស់នៅក្នុងការវាយប្រហារពីក្រុមប្រដាប់អាវុធដែលបានអនុវត្តចេញពីតំបន់ឆេចឆ្នីនៅចុងរដូវក្ដៅនិងដើមរដូវស្លឹកឈើជ្រុះកាលពីឆ្នាំមុន ។ ក្នុងពេលនោះ ខ្ញុំកំពុងតែនៅក្នុងតំបន់ ដាជេស្ដាន់ ហើយបានឃើញព្រឹត្តិការណ៍ទាំងនោះដោយផ្ទាល់ភ្នែក ។

ការវាយប្រហារទៅលើតំបន់ ដាជេស្ដាន់ បានបង្ខំឲ្យរដ្ឋាភិបាលប្រទេសរុស្ស៊ីអនុវត្តនូវវិធានការធ្ងន់ធ្ងរដើម្បីជួយសង្គ្រោះអាយុជីវិតនិងសិទ្ធិជនស៊ីវិលនៃប្រជាជនរុស្ស៊ីក៏ដូចជាប្រជាជនឆេចឆ្នី ។ ដើម្បីសម្រេចបាននូវគោលដៅទាំងនេះ ការប្រើប្រាស់កម្លាំងទ័ពគឺអាចទទួលយកបាន ប៉ុន្តែគួរត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់ ជ្រើសរើសគោលដៅច្បាស់លាស់ និងទៅតាមទំហំនៃការគំរាមកំហែងដែលមាន ។ មេដឹកនាំរបស់ប្រទេសរុស្ស៊ីបានបើកបេសកកម្មវាយប្រហារមួយដែលមិនសមស្របទៅនឹងទំហំនៃការគំរាមកំហែង ។

បេសកកម្មរបស់កងទ័ពរុស្ស៊ីនៅក្នុងតំបន់កូខេសីសប៉ែកខាងជើង គឺរំលោភទៅលើច្បាប់និងរដ្ឋធម្មនុញ្ញរបស់សហព័ន្ធរុស្ស៊ី ។ សិទ្ធិរដ្ឋធម្មនុញ្ញជាច្រើនត្រូវបានបន្ថយឬដកហូត ដូចជាសិទ្ធិទាក់ទងទៅនឹងសេរីភាពក្នុងការដើរហើរនិងការជ្រើសរើសទីស្នាក់អាស្រ័យ ។ល ។ ច្បាប់របស់ប្រទេសរុស្ស៊ីអនុញ្ញាតឲ្យមានការចាត់វិធានការបែបនោះនៅក្នុងព្រឹត្តិការណ៍នៃការប្រកាសអាសន្ន ប៉ុន្តែការប្រកាសអាសន្នមិនត្រូវបានធ្វើឡើងទេ ។ យើងជឿជាក់ថា មធ្យោបាយបែបហិង្សាដែលបានប្រើប្រាស់ដោយកងកម្លាំងសហព័ន្ធប្រទេសរុស្ស៊ីនិងអាជ្ញាធរនៅក្នុងតំបន់ឆេចឆ្នីបានធ្វើឲ្យសង្គ្រាមនេះក្លាយទៅជាបទឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរនិងគួរឲ្យភ័យខ្លាច ។ ខ្ញុំសូមនិយាយម្តងទៀតថា វិធីនៃការប្រើប្រាស់ទ័ពរបស់ប្រទេសរុស្ស៊ីគឺជាអំពើឧក្រិដ្ឋ ។

ច្បាប់សិទ្ធិមនុស្សនិងច្បាប់មនុស្សជាតិត្រូវបានរំលោភយ៉ាងធ្ងន់ធ្ងរដោយភាគីទាំងពីរ ប៉ុន្តែចំនួននៃជនរងគ្រោះជាជនស៊ីវិលនិងវិសាលភាពនៃការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិជនស៊ីវិលដែលបង្កឡើងដោយសកម្មភាពរបស់កងកម្លាំងសហព័ន្ធរបស់ប្រទេសរុស្ស៊ី គឺមានកម្រិតខ្ពស់ជាង ។ លើសពីនេះ ខ្ញុំត្រូវតែសង្កត់ធ្ងន់ថាប្រតិបត្តិការរបស់ទាហាននិងនគរបាលរុស្ស៊ីគឺជាប្រតិបត្តិការនៃកងកម្លាំងនៅក្រោមការដឹកនាំរដ្ឋរុស្ស៊ី ដែលតាមរយៈការចុះហត្ថលេខាទៅលើសន្ធិសញ្ញាអន្តរជាតិជាច្រើនមានកាតព្វកិច្ចសង្កេតអំពីការគោរពសិទ្ធិមនុស្ស ។ ការពិតនេះបានបញ្ជាក់អំពីភាពធ្ងន់ធ្ងរនៃការរំលោភសិទ្ធិមនុស្សរបស់កងកម្លាំងប្រដាប់អាវុធរុស្ស៊ី ។

សង្គ្រាមបានប្រព្រឹត្តទៅនៅពីក្រោយការបំផ្លើសជាច្រើនដង ។ អាជ្ញាធររបស់ប្រទេសរុស្ស៊ីបានបង្កើតឃ្លោងឃ្លានិងពាក្យពេចន៍ថ្មីជាច្រើនដូចជា “បេសកកម្មប្រឆាំងភេរវកម្ម” “ការវាយប្រហារចំៗ” “ច្រកទ្វារមនុស្សធម៌សម្រាប់ឲ្យប្រជាជនចេញ” និង “តំបន់មានសុវត្ថិភាព” ។ល ។ ហើយថែមទាំងចាប់ផ្តើមជឿថា ឃ្លាសម្រាប់សម្រាលន័យទាំងនេះសំដៅទៅលើព្រឹត្តិការណ៍ដែលកើតមានជាក់ស្តែង ។ ប្រសិនបើមានការពិតជាក់ស្តែងនៅពីក្រោយឃ្លាទាំងនេះមែននោះ វាជាការពិតមួយដែលមិនទាក់ទងទៅនឹងអភិវឌ្ឍន៍ជាក់ស្តែងនៅក្នុងតំបន់ឆេចឆ្នី ។

មិនមានហេតុផលណាដែលត្រូវហៅសង្គ្រាមបច្ចុប្បន្ននៅក្នុងតំបន់ឆេចឆ្នីថាជាសង្គ្រាមប្រឆាំងភេរវកម្មទេ ។ ជាក់ស្តែងវាមិនមែនជាជម្លោះ“អន្តរជាតិ”នោះទេដែលឋិតនៅក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ ពិសេសនៅក្នុងមាត្រាទី៣នៃសន្ធិសញ្ញានេះនិងសន្ធិសញ្ញាដែលបានធ្វើវិសោធនកម្មលើកទីពីរ ។ ជម្លោះនៅតំបន់ឆេចឆ្នីបានបំពេញរាល់លក្ខខណ្ឌនៃជម្លោះមួយដែលមិនមានលក្ខណៈអន្តរជាតិ ដូចដែលបានរៀបរាប់នៅក្នុងសន្ធិសញ្ញាកែប្រែបន្ថែមលើកទីពីរនៃសន្ធិសញ្ញាទីក្រុងហ្សឺណែវ ។ យើងអាចឃើញបេសកកម្មទ្រង់ទ្រាយធំដោយមានការប្រើប្រាស់ទ័ពអាកាសការបាញ់ប្រហារព្រមគ្នានឹងរ៉ុក្កែតយុទ្ធសាស្ត្រ ។ តំបន់ដែលមានប្រជាជនរស់នៅត្រូវបានវាយប្រហារ ហើយទទួលរងការខូចខាតស្ទើរតែទាំងស្រុង ។ ប្រធានាធិបតី ពូទីន បានហៅការវាយប្រហារបែបនេះថាជាបេសកកម្មប្រឆាំងភេរវកម្ម ។ បេសកកម្មនេះមិនអាចចាត់ទុកថាប្រឆាំងភេរវកម្មបានទេ ទោះជានៅក្រោមនីតិប្រឆាំងភេរវកម្មរបស់ប្រទេសរុស្ស៊ីក៏ដោយ ដែលជាថ្មីម្តងទៀតវាបញ្ជាក់អំពីការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់របស់ប្រទេសរុស្ស៊ីខ្លួនឯង ។

ខ្ញុំសូមអនុញ្ញាតប្តូរប្រធានបទនៃការពិភាក្សាបន្តិចដើម្បីកែតម្រូវការយល់ច្រឡំមួយចំនួនដែលធ្វើឲ្យមានការខ្វែងគំនិតគ្នា ។ អ្នកខ្លះពោលថា “ប្រតិបត្តិការទ័ពត្រូវបានប្រើប្រាស់មែន ប៉ុន្តែសន្តិភាពកំពុងតែឈានចូលមកដល់ ហើយការប្រើប្រាស់ទ័ពនៅក្នុងជម្លោះនៅកូខេសីសខាងជើងត្រូវបានបញ្ចប់ហើយ” ។ គួរឲ្យសោកស្តាយណាស់ ការនិយាយបែបនេះមិនពិតទេ ។ នេះគឺជាការយល់ខុសដែលប្រទេសរុស្ស៊ីបានឃោសនាជាផ្លូវការដោយចេតនា ។ វាផ្ទុយទាំងស្រុងទៅនឹងតួលេខដែលបានផ្តល់ឲ្យដោយតំណាងផ្លូវការរបស់រុស្ស៊ីខ្លួនឯង ។ ឧទាហរណ៍ ពីថ្ងៃទី២៧ ខែមេសាដល់ថ្ងៃទី៤ ខែឧសភា កងកម្លាំងសហព័ន្ធរុស្ស៊ីនៅក្នុងតំបន់ឆេចឆ្នីបានស្លាប់៣២នាក់និងរងរបួស១០៧នាក់ ។ នៅក្នុងសប្តាហ៍ទីពីរនៃខែឧសភា ការខូចខាតរបស់កងកម្លាំងសហព័ន្ធរុស្ស៊ីបានកើនឡើងដល់៩១នាក់និងរងរបួស៧០នាក់បន្ថែមទៀត ។ រឿងនេះបានកើតឡើងនៅពេលដែលរុស្ស៊ីកំពុងតែប្រកាសថាមិនមានប្រតិបត្តិការធំដុំកំពុងត្រូវអនុវត្តទេ ។ ទាហានរុស្ស៊ី

ជាច្រើននាក់បានស្លាប់បាត់បង់ជីវិតរៀងរាល់សប្តាហ៍ ។

នៅថ្ងៃទី៣០ ខែមេសា ការពិភាក្សាវែកញែកមួយត្រូវបានធ្វើឡើងអំពីការប្រើប្រាស់យន្តហោះទម្លាក់គ្រាប់បែកចម្ងាយឆ្ងាយ និងការបង្កើនបរិមាណគ្រាប់បែកសម្រាប់ទម្លាក់ទៅលើតំបន់ជួរភ្នំនៅឆេចឆ្នី ។ ចំនួនជើងហោះហើរទម្លាក់គ្រាប់បែកទៅលើតំបន់ទាំងនេះ ត្រូវបានបង្កើនដោយកម្រិតជាក់លាក់មួយនៅក្នុងខែឧសភា ។ នេះបង្ហាញថាសង្គ្រាមមិនទាន់បញ្ចប់ទេ ។ សង្គ្រាមកំពុងតែបន្ត ហើយគ្មានសញ្ញាណាមួយបញ្ជាក់ថាវានឹងចប់នោះដែរ ។ ពត៌មានចេញពីតំបន់ភ្នំឥឡូវនេះមានកម្រិតកំណត់និងមិនពិស្តារដោយមូលហេតុការដាក់កំហិតពីអាជ្ញាធររុស្ស៊ី ។

ខ្ញុំសូមវិលត្រឡប់ទៅរកការវាយតម្លៃទៅលើជម្លោះ ។ ខ្ញុំគួរនិយាយថា ប្រសិនបើប្រតិបត្តិការរបស់រុស្ស៊ីជាសកម្មភាពប្រឆាំងនឹងអំពើភេរវកម្ម វាច្បាស់ជាមានទម្រង់មួយច្បាស់គឺការកំណត់គោលដៅ ។ ប្រតិបត្តិការប្រឆាំងអំពើភេរវកម្មគួរមានគោលបំណងៈ ទីមួយការពារជនស៊ីវិលតាមរយៈការបំបែកនិងបំផ្លាញបណ្តាញភេរវកម្ម ។ តើតាមការពិតយើងបានឃើញអ្វីខ្លះ? អ្វីដែលឃើញគឺវាផ្ទុយទាំងស្រុង ។ តាំងតែពីដើមទីនៃសង្គ្រាមប្រតិបត្តិការដែលអនុវត្តឡើងដោយកងកម្លាំងប្រដាប់អាវុធរុស្ស៊ីនៅក្នុងតំបន់ឆេចឆ្នីមានលក្ខណៈមិនចំពោះ ។

ខ្ញុំសូមលើកឧទាហរណ៍ខ្លះៗអំពីដំណាក់កាលផ្សេងៗគ្នានៃជម្លោះ ។ នៅក្នុងដំណាក់កាលដំបូងនៃជម្លោះនៅថ្ងៃទី២៧ ខែតុលា សារពត៌មានរុស្ស៊ីបានប្រកាសថា គេហដ្ឋានរបស់ ហ្សាមិល បាសាយិហ្វ បានទទួលរងការវាយប្រហារដោយគ្រាប់រ៉ុក្កែត ។ សារពត៌មាននោះបានប្រកាសទៀតថា គេហដ្ឋានត្រូវបានកម្ទេចទាំងស្រុង ប៉ុន្តែ ស្សាមិល បាសាយិហ្វ នៅរស់នៅឡើយ ទោះបីជាអង្គរក្សនិងមនុស្សនៅជុំវិញខ្លួនគាត់បានស្លាប់ក៏ដោយ ។ ការវាយប្រហារនេះត្រូវបានផ្សាយតាមរបៀបមួយដើម្បីបង្ហាញថាជាប្រតិបត្តិការដ៏ជោគជ័យមួយរបស់កងទ័ពរុស្ស៊ី ប៉ុន្តែសារពត៌មានដដែលនោះមិនបានប្រកាសថាគ្រាប់រ៉ុក្កែតនិងការទម្លាប់គ្រាប់បែកបានបំផ្លិចបំផ្លាញផ្ទះសម្បែងរបស់ប្រជាជននៅជិតខាងផងទេ ។ យ៉ាងហោចណាស់ក៏មានផ្ទះល្វែងជាច្រើនខ្នងត្រូវបំផ្លាញ រួមជាមួយផ្ទះមួយខ្នងដែលមានកម្ពស់ប្រាំជាន់ ផ្ទះមួយជាន់ជាច្រើនខ្នង ផ្សារមួយ ចំណតរថយន្តតាក់ស៊ីមួយដែលមានរថយន្ត អ្នកបើកបរ និងអ្នកដំណើរ នៅទីនោះ ។ ក្នុងពេលនោះ យើងមិនទាន់ដឹងថាតើមានប្រជាជនស្លូតត្រង់ប៉ុន្មាននាក់បានស្លាប់នៅក្នុងហេតុការណ៍កម្ទេចអង្គរក្សនិងអ្នកគាំទ្រ ស្សាមិល បាសាយិហ្វ តែប៉ុន្មាននាក់ប៉ុណ្ណោះ ហើយយើងនឹងមិនអាចដឹងជារៀងរហូត ។

នៅក្នុងដំណើរការនៃសង្គ្រាម មានជនស៊ីវិលជាច្រើននាក់ត្រូវសម្លាប់ដោយរដ្ឋាភិបាលរុស្ស៊ីនៅក្នុងការព្យាយាមសម្លាប់ជនសង្ស័យជាភេរវករ ។ យើងមិនអាចសន្និដ្ឋានថាមានជនស៊ីវិលប៉ុន្មាននាក់បានស្លាប់នោះទេ ប៉ុន្តែអាចមានរហូតដល់រាប់ពាន់នាក់ ។ ច្រើនយ៉ាងនេះហើយអាជ្ញាធររុស្ស៊ីនៅតែហៅការវាយប្រហារទៅលើ ស្សាមិល បាសាយិហ្វ ថាជាការវាយប្រហារចំៗគោលដៅថែមទៀត ។ មានការវាយប្រហារស្រដៀងគ្នានេះជាច្រើននៅក្នុងតំបន់ហ្គ្រូសនី ។ ដូចដែលសាធារណជនបានដឹងហើយថា ហ្គ្រូសនីស្ទើរតែក្លាយទៅជាគំនរដេះ ។

នេះជាឧទាហរណ៍មួយទៀតស្រង់ចេញពីដំណាក់កាលបន្ទាប់នៃជម្លោះដែលបង្ហាញថាភាគីទាំងសងខាងមិនបានអើពើចំពោះផលប្រយោជន៍របស់ជនស៊ីវិលឡើយ÷

ស្សាលី គឺជាទីប្រជុំជនដ៏ធំមួយក្តោបក្តាប់ដោយកងទ័ពសហព័ន្ធរុស្ស៊ីនៅចុងឆ្នាំ១៩៩៩ដោយគ្មានការផ្ទុះអាវុធ ។ មេបញ្ជាការរបស់ទ័ពសហព័ន្ធបានហៅតំបន់នេះថាជាតំបន់មានសុវត្ថិភាព ។ នេះជាពាក្យដែលគួរឲ្យចាប់អារម្មណ៍មួយទៀត "តំបន់សុវត្ថិភាព" ។ អាជ្ញាធររបស់រុស្ស៊ីបានជំរុញឲ្យជនភៀសខ្លួនវិលត្រឡប់មកផ្ទះសម្បែងវិញ ហើយមនុស្សជាច្រើនក៏ចាប់ផ្តើមវិលមកវិញ ។ ជីវិតនៅក្នុងតំបន់សុវត្ថិភាពគឺមិនបានសុខទេ ។ ប្រជាជនជាច្រើននាក់បានទទួលរងការធ្វើទុក្ខបុកម្នេញពីប៉ូលិសរុស្ស៊ីដែលបញ្ជូនពីភូមិភាគផ្សេងៗនៃប្រទេសរុស្ស៊ីទៅកាន់តំបន់ឆេចឆ្នី ។ យើងបានចងក្រងជាឯកសារយ៉ាងហោចណាស់ក៏បទឧក្រិដ្ឋមួយករណីដូចជា ការរំលោភហើយសម្លាប់ស្ត្រីម្នាក់នៅក្នុងទីប្រជុំជន ស្សាលី នៅក្នុងដំណាក់កាលដែលរុស្ស៊ីកាន់កាប់ ។ នៅក្នុងករណីមួយទៀត អាជ្ញាធរបានចែកប្រាក់

បៀវត្សរ៍ទៅឲ្យប្រជាជនដែលគ្មានបៀវត្សរ៍ជាយូរមកហើយ ។ បៀវត្សរ៍ត្រូវបានចែកចាយលើកទីមួយនៅថ្ងៃទី៨ខែកុម្ភៈ ហើយនៅថ្ងៃទី៩ ប្រជាជនជាច្រើនបានប្រមូលផ្តុំគ្នានៅកណ្តាលទីប្រជុំជន សូរ៉ាលី ដើម្បីចាំបើកប្រាក់ ។ គ្មាននរណាដឹងថា យុទ្ធជនឆេចឆ្នីមួយក្រុមតូចបានលួចចូល សូរ៉ាលី នៅពេលនោះទេ ។ ក្រុមនេះបានឡោមព័ទ្ធទីបញ្ជាការយោធា ។ ប្រជាជនមិនដឹងអ្វីសោះអំពីបញ្ហានេះ ហើយភ្ញាក់ផ្អើលយ៉ាងខ្លាំងដែលបានឃើញជនប្រដាប់អាវុធទាំងនោះនៅក្បែរខ្លួន ។ ក្នុងពេលនោះ កាំជ្រួចយុទ្ធសាស្ត្ររបស់រុស្ស៊ីមួយគ្រាប់បានផ្ទុះឡើងចំពីលើក្រុមមនុស្ស ។ វាគឺជាការតបតរបស់បញ្ជាការរុស្ស៊ីក្រោយពីដឹងថា មានពួកខ្មាំងនៅក្នុងភូមិ ។ កាំជ្រួចនោះត្រូវបានសន្និដ្ឋានថាបានសម្លាប់ជនស៊ីវិលយ៉ាងហោចណាស់១៥០នាក់ ។ បន្ទាប់មក មានការ វាយប្រហារពីឧទ្ធម្ភាគចក្រប្រយុទ្ធដែលបណ្តាលឲ្យមានការបាត់បង់ជីវិតជនស៊ីវិលបន្ថែមទៀត ។ ពួកខ្មាំងឆេចឆ្នីបានភៀសខ្លួនចេញពី សូរ៉ាលី ដោយបាត់បង់សមាជិកតែប៉ុន្មាននាក់ប៉ុណ្ណោះ ។ ដូច្នេះយើងអាចសន្និដ្ឋានបានថា ដើម្បីសម្លាប់សត្រូវតែប៉ុន្មាននាក់ ទ័ពរុស្ស៊ីសម្លាប់ជនស៊ីវិលរាប់រយនាក់ ។

នេះជាឧទាហរណ៍មួយផ្សេងទៀតដែលបង្ហាញអំពីការទទួលខុសត្រូវដោយផ្ទាល់របស់បញ្ជាការយោធាចំពោះការប្រើប្រាស់កម្លាំងទ័ពដែលបណ្តាលឲ្យមានការស្លាប់បាត់បង់ជីវិតជនស៊ីវិល ។ នៅក្នុងខែកុម្ភៈ ឆ្នាំ២០០០ តំបន់ហ្គូសនីឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រុមប្រដាប់អាវុធឆេចឆិន ។ តំបន់ដែលនៅក្បែរៗនោះបានស្ថិតក្រោមការគ្រប់គ្រងរបស់ទ័ពរុស្ស៊ី ហើយ"តំបន់សុវត្ថិភាព" នឹងត្រូវប្រកាសនៅក្នុងតំបន់ទាំងនេះដែរ ។ ភូមិដ៏ធំមួយឈ្មោះ កាធៀយុត ត្រូវបានប្រកាសថាជាតំបន់សុវត្ថិភាព ។ ជនភៀសខ្លួនត្រូវបានលើកទឹកចិត្តឲ្យត្រឡប់មកភូមិស្រុកវិញ ។ ដោយសារតំបន់នេះជាតំបន់សុវត្ថិភាព ប្រជាជនដែលមិនធ្លាប់រស់នៅក្នុងភូមិនេះក៏ចូលមកដែរ ។ ឧត្តមសេនីយ៍រុស្ស៊ីបានចុះហត្ថលេខាលើសេចក្តីប្រកាសថាតំបន់នេះជាតំបន់សុវត្ថភាព ។

ក្រោយមកទៀតយើងបានរកឃើញថា ឧត្តមសេនីយ៍ដដែលនោះកំពុងតែរៀបចំប្រតិបត្តិការប្រយុទ្ធដ៏ស្មុគស្មាញមួយក្នុងពេលជាមួយគ្នា ក្នុងគោលបំណងទាក់ទាញកងកម្លាំងខ្មាំងឆេចឆ្នីឲ្យចាកចេញពីតំបន់ហ្គូសនី ។ ពត៌មានក្លែងក្លាយបានផ្សាយថា មេបញ្ជាការរុស្ស៊ីមួយចំនួនត្រូវបានចោទប្រកាន់ថាមានបំណងផ្តល់ដល់ពួកខ្មាំងឆេចឆិននូវច្រកភ្នំមួយសម្រាប់ចេញ ជាថ្នូរនឹងប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់ ។ ពួកខ្មាំងឆេចឆិនក៏ជឿហើយបានប្រគល់ប្រាក់មួយចំនួន រួចក៏ចេញដំណើរទៅតាមច្រកភ្នំដែលបញ្ជាការរុស្ស៊ីបានផ្តល់ឲ្យ ។ នៅក្នុងច្រកភ្នំនោះ ពួកខ្មាំងឆេចឆិនបានឆ្លងកាត់ចម្ការមីន ការបាញ់ផ្លោងដោយកាំភ្លើងត្បាល់ និងការវាយប្រហារពីអាកាស ហើយខូចខាតយ៉ាងដំណំ ប៉ុន្តែបានគេចខ្លួនទៅលើជួរភ្នំ ។

កងទ័ពរុស្ស៊ីបានចាត់ទុកថានេះជាប្រតិបត្តិការដ៏ជោគជ័យ និងឈ្លាសវៃមួយ ។ ឧត្តមសេនីយ៍រុស្ស៊ីបានថ្លែងដោយចំហនៅក្នុងទូរទស្សន៍អំពីការពិតដែលខ្លួនបានរៀបចំអន្ទាក់នេះ ប៉ុន្តែមិនបាននិយាយអំពីចំណុចដែលថា នៅតាមច្រកភ្នំមានតំបន់សុវត្ថិភាពដូចជាភូមិ កាធៀយុត តាំងនៅផងទេ ។ ដូច្នេះ បន្ទាប់ពីអ្នកតស៊ូឆេចឆិនបានចាកចេញពីតំបន់ហ្គូសនី ហើយបានចូលក្នុងភូមិ មួយរំពេចនោះភូមិបានឋិតក្រោមការបាញ់ផ្តក់ពីកាំភ្លើងត្បាល់រុស្ស៊ី ។ រឿងរ៉ាវបែបនេះបានកើតនៅក្នុងភូមិ អាល់ខាន់កាឡា, ហ្សាខាន់យុត, ស្សារាមីយុត និង កាធៀយុត ។ នៅក្នុងភូមិកាធៀយុត ប្រជាជនប្រមាណ២០០នាក់បានស្លាប់បាត់បង់ជីវិត ។

ភូមិមួយឈ្មោះ ហ្គេឃីឈូ ដែលមានទីតាំងនៅក្បែរជួរភ្នំ នៅតែទទួលរងការបាញ់ផ្លោងយ៉ាងធ្ងន់ធ្ងរបន្ទាប់ពីក្រុមខ្មាំងបានចាកចេញផុត ។ ទូរទស្សន៍រុស្ស៊ីបានថតព្រឹត្តិការណ៍នេះ ។ ទូរទស្សន៍បានបង្ហាញអំពីការប្រើប្រាស់ជាតិផ្ទុះស្រូបនៅក្នុងភូមិមួយដែលមានប្រជាជនរស់នៅកកកុញ ។ ខ្ញុំយល់ថា ទូរទស្សន៍នេះមិនដឹងថាខ្លួនកំពុងតែចាក់ផ្សាយអំពីអ្វីផងទេ ។ បន្ទាប់មក ព្រឹត្តិការណ៍ដែលថតដោយអ្នកសារពត៌មានបរទេសនៅថ្ងៃបន្ទាប់ត្រូវបានចាក់ផ្សាយ ដែលក្នុងនេះបង្ហាញអំពីស្ត្រីនិងកុមារត្រូវសម្លាប់នៅក្នុងភូមិ ។

ការបាញ់ផ្លោងចូលភូមិបានបន្តដោយប្រតិបត្តិការបោសសម្អាតផ្សេងៗទៀត ។ នេះជាពាក្យដែលគួរឲ្យខ្លាចមួយទៀត "ប្រតិបត្តិការបោសសម្អាត" ដែលបានបង្កើតចេញពីពាក្យដែល

តែងតែប្រើប្រាស់ដោយប៉ូលិស មានន័យថា ការត្រួតពិនិត្យទូទៅទៅលើប្រជាជននិងផ្ទះសម្បែងនៅក្នុងក្រុងឬភូមិ ។ រឿងហេតុអាក្រក់តែងតែកើតមាននៅក្នុងប្រតិបត្តិការប្រភេទនេះ ដូចជាការប្រហារជីវិត ការលួចទ្រព្យសម្បត្តិ អំពើហិង្សា... ។ យើងមានភ័ស្តុតាងបញ្ជាក់ថា យ៉ាងហោចណាស់មានប្រជាជនបីនាក់នៅក្នុងភូមិហ្គោយីឈូត្រូវបាញ់សម្លាប់ ។

ដូច្នេះ នេះគឺជាប្រតិបត្តិការយោធាមួយក្នុងចំណោមប្រតិបត្តិការយោធាជាច្រើន ដែលខុសប្លែកត្រង់ថា ការទទួលខុសត្រូវផ្ទាល់ពីថ្នាក់លើ គឺឧត្តមសេនីយ៍ ត្រូវបានកត់ត្រាទុក ។ នៅក្នុងគំនិតរបស់ខ្ញុំ បញ្ហាការយោធារបស់រុស្ស៊ីមិនបានយល់ថាខ្លួនត្រូវពិចារណាអំពីសុវត្ថិភាពប្រជាជនស៊ីវិលផងទេ ហើយមិនរវល់អំពីការពិតនេះទាល់តែសោះ ។

ការឃុំឃាំងនៅក្នុងភូមិដែលបានរៀបរាប់ខាងលើ (កាធៀយុត) គឺមិនរើសមុខ ។ ស្រដៀងគ្នាទៅនឹងការបាញ់ផ្លោងមិនចំពោះ កងទ័ពរុស្ស៊ីបានអនុវត្តការចាប់ខ្លួនដោយមិនចំពោះរួចបញ្ជូនមនុស្សទៅកាន់"ជំរំសម្រាប់ជម្រុះ" និងរំលោភបំពានទៅលើជនជាប់ឃុំឃាំង ។

ពាក្យជំរំសម្រាប់ជម្រុះមានន័យដូចម្តេច? ពាក្យនេះត្រូវប្រើមិនសូវចំន័យប៉ុន្មានទេ ។ នៅក្នុងសង្គ្រាមមុនៗ ជំរំជម្រុះគឺជាកន្លែងដែលប្រើប្រាស់សម្រាប់ឃុំខ្លួនអ្នកដែលត្រូវចាប់ខ្លួន ។ ជំរំប្រភេទនេះគ្មាននៅក្នុងច្បាប់របស់ប្រទេសរុស្ស៊ីទេ ។ ដូច្នេះជំរំទាំងនេះជាកន្លែងល្មើសច្បាប់ដែលដកហូតយកសេរីភាពរបស់ប្រជាពលរដ្ឋរុស្ស៊ី ។ ឥឡូវនេះ តួនាទីជាផ្លូវការត្រូវបានដាក់ឲ្យជំរំទាំងនេះ ។

ឧទាហរណ៍ ជំរំសម្រាប់ជម្រុះដ៏ល្បីឈ្មោះមួយនៅឆេនូកូហ្សូរ៉ូ មានតួនាទីជាផ្លូវការមួយ គឺកន្លែងឃុំឃាំងជនជាប់ចោទមុនពេលឡើងតុលាការ ។ មានជំរំផ្សេងទៀតដែលនៅតែរក្សាឈ្មោះចាស់ដដែល និងហៅជាផ្លូវការថា អគារឃុំឃាំងបណ្តោះអាសន្ន ។ ជំរំទាំងនេះត្រូវបានបង្កើតឡើងនៅឯនាយកដ្ឋានថ្នាក់ស្រុកនៃកម្លាំងមហាផ្ទៃនៅតាមកន្លែងជាច្រើននៅក្នុងតំបន់ឆេចឆ្នី ។ វាមានតួនាទីជាផ្លូវការ ហើយអ្នកគ្រប់គ្រងត្រូវបានជ្រើសចេញពីកម្លាំងមហាផ្ទៃ ឬអ្វីដែលហៅថា "ស្ពិកណាហ្ស" នៃក្រសួងយុត្តិធម៌របស់ប្រទេសរុស្ស៊ី ។ ស្ពិកណាហ្ស ល្បីឈ្មោះពេញប្រទេសរុស្ស៊ីខាងអំពើឃោរឃៅ ។ វាត្រូវបានប្រើប្រាស់ដើម្បីទប់ទល់នឹងការបះបោរនៅក្នុងគុក ។ យើងអាចយល់បានថាអំឡុងពេលសង្គ្រាមនៅឆេចឆ្នី ការរួចទោសបានបណ្តាលឲ្យភាពឃោរឃៅរបស់ ស្ពិកណាហ្ស កាន់តែកើនឡើង ។

ជំរំនៅ ឆេនូកូហ្សូរ៉ូ បានទាក់ទាញការចាប់អារម្មណ៍ពីសាធារណជន ហើយគណៈកម្មាធិការសម្រាប់ការពារមិនឲ្យមានទារុណកម្មរបស់ក្រុមប្រឹក្សាអឺរ៉ុប បានទៅធ្វើទស្សនកិច្ច ។ ក្រោយមក លក្ខខណ្ឌរស់នៅក្នុងជំរំបានកើនឡើង ។ បុគ្គលិកនៅក្នុងជំរំឆេនូកូហ្សូរ៉ូ ត្រូវបានផ្លាស់ប្តូរ របបអាហារត្រូវបានបង្កើន ហើយទារុណកម្មត្រូវបញ្ឈប់ ។ ជនជាប់ឃុំមួយភាគធំត្រូវបានបញ្ជូនទៅតំបន់ ស្តាវរ៉ូប៉ូល ។ ក្នុងពេលជាមួយគ្នានេះ អំពើឃោរឃៅនិងទារុណកម្មនៅតែមាននៅក្នុងជំរំផ្សេងទៀតនៅឡើយ ដូចជានៅ យូរុស ម៉ាតាន់ ជាដើម ។

នេះជាសក្ខីកម្មមួយដែលយើងបានទទួលពីភូមិ យូរុស ម៉ាតាន់ ។ វាជាសក្ខីកម្មរបស់បុរសម្នាក់ដែលសុំមិនបញ្ចេញឈ្មោះ ។ "ស្ទើរតែពេញមួយយប់ទល់ភ្លឺ ពួកវាបានវាយយើង ហើយឲ្យអ្នកទោសស្រែកតាមពួកវាបន្ទាប់ ។ អ្នកដែលមិនស្រែកត្រូវពួកវាវាយធ្វើបាបយ៉ាងអាណោចអាធ័ម ។ មានអ្នកទោសយ៉ាងហោចណាស់ក៏៣០នាក់នៅក្នុងបន្ទប់មួយដែលមានបណ្តោយ៣ម៉ែត្រនិងទទឹង២ម៉ែត្រ ។ ខ្ញុំរកកន្លែងអង្គុយឬទម្រេតខ្លួនមិនបានទេ ។ អ្នកទោស៤នាក់មិនអាចដើរបានជារៀងរហូត... ។ ខ្ញុំត្រូវបានហៅទៅសួរចម្លើយចំនួនប្រាំដង ។ ពួកវាបានសួរខ្ញុំអំពីទីកន្លែងដែលក្រុមឧទ្ទាមលាក់ខ្លួន អ្នកណាជាអ្នកឧបត្ថម្ភ ។ ពួកវាបានវាយខ្ញុំនឹងដំបងប៉ូលិស ស្នូកកាំភ្លើង ឬស្បែកជើង ។ វាបានបង្ខំឲ្យខ្ញុំចុះហត្ថលេខាលើក្រដាសមួយសន្លឹកដែលនិយាយថាខ្ញុំគឺជាអ្នកតស៊ូប្រឆាំង ។ មានអ្នកតស៊ូចំនួន១៨នាក់ទៀតនៅក្នុងឃុំដែលភាគច្រើនមានរបួស ។ អ្នកខ្លះត្រូវគេចងរហូតដល់ស្លាក់ឈាម ហើយមិនមាននរណាមកស្រាយចំណងឲ្យទេ ។ នៅពេលចេញពីគុក ពួកវាបានបង្ខំឲ្យខ្ញុំចុះហត្ថលេខាទទួលស្គាល់ថាខ្ញុំមិនបានទទួលរងការធ្វើទារុណកម្ម" ។ បុរសរូបនេះត្រូវដោះលែង ។ នេះមានន័យថាគាត់ជាជនគ្មានកំហុស ។ ក្រៅអំពី

មន្ទីរឃុំឃាំងស្របច្បាប់ មានមន្ទីរឃុំឃាំងជាច្រើនដែលគ្មានច្បាប់ ។ មន្ទីរទាំងនេះស្ថិតនៅក្រោមការគ្រប់គ្រងដោយកងទ័ព ឬនៅតាមប៉ុស្តិ៍ត្រួតពិនិត្យតាមផ្លូវ ។ ដូចនៅក្នុងសង្គ្រាមពីមុន ជនជាប់ឃុំត្រូវបានដឹកទៅដាក់នៅ ខាន់កាឡា ដែលជាជំរំកងទ័ពដ៏ធំមួយនៅក្បែរហ្គ្រូសនី ។ ការដឹកជញ្ជូននេះធ្វើឡើងដោយចំហ ទោះជា ខាន់កាឡា មិនមែនជាមន្ទីរឃុំឃាំងស្របច្បាប់ក៏ដោយ ។

ប្រជាជនដែលត្រូវបានដឹកទៅជំរំកងទ័ព ត្រូវបានឃុំខ្លួននៅក្នុងរូងក្រោមដីឬនៅក្នុងរថយន្តសម្រាប់ដឹកអ្នកទោស ។ នៅ ខាន់កាឡា ទូរថភ្លើងសម្រាប់ដឹកអ្នកទោសបានលេចឡើង ។ តើទូរថភ្លើងទាំងនេះលេចចេញមកពីណា? យើងមានការសង្ស័យមួយ ។ នៅដើមឆ្នាំ២០០០ មន្ទីរឃុំឃាំងបណ្តោះអាសន្នមួយត្រូវបានបង្កើតឡើងនៅទីប្រសព្វផ្លូវរថភ្លើងមួយនៅឆេលីយ៉ូណាយ៉ា ។ មន្ទីរនេះត្រូវបង្កើតតាមរយៈការតទូរថភ្លើងច្រើនចូលគ្នា រួចដាក់ឈ្មោះឲ្យវាថា មន្ទីរឃុំឃាំងបណ្តោះអាសន្ន ហើយចាប់មនុស្សមកឃុំឃាំងតែម្តង ។ គណៈកម្មាធិការសម្រាប់ការពារមិនឲ្យមានទារុណកម្មនៃក្រុមប្រឹក្សាទ្វីបអឺរ៉ុប បានទៅទស្សនាទីកន្លែងនោះ ហើយបានវាយតម្លៃថាវាមិនស័ក្តិសមជាមន្ទីរឃុំឃាំងទាល់តែសោះ និងបានទាមទារឲ្យបញ្ឈប់ដំណើរការ ។ រយៈពេលពីរខែក្រោយមក គណៈកម្មាធិការបានទៅទស្សនាទីនោះម្តងទៀត ។ មន្ទីរឃុំឃាំងនោះបានបិទទ្វារ ហើយទូរថភ្លើងទាំងប៉ុន្មានត្រូវបានរើទៅកន្លែងផ្សេង ។ យើងបានរកឃើញទូរថភ្លើងនោះនៅខាន់កាឡា ។ បើនិយាយឲ្យខ្លីទៅ មន្ទីរឃុំឃាំងបណ្តោះអាសន្ននោះត្រូវរំសាយចោលមែន ប៉ុន្តែទូរថភ្លើងត្រូវគេយកទៅដាក់នៅខាន់កាឡា ជាកន្លែងដែលឃុំមនុស្សមិនស្របច្បាប់ ។

ឆ្នាំគុកនៅ ខាន់កាឡា ឃោរឃៅជាងនៅកន្លែងផ្សេង ។ ហេតុផលគឺថា មនុស្សដែលជាប់ឃុំនៅក្នុងមន្ទីរឃុំឃាំងមិនផ្លូវការ មិនមានឈ្មោះនៅក្នុងបញ្ជីទេ ។ នៅក្នុងមន្ទីរឃុំឃាំងផ្លូវការ



ការបញ្ជូនអ្នកទោសចេញពីមន្ទីរ ស-២១
វិចិត្រករៈ វ៉ាន់ ណាត (អតីតអ្នកទោសនៅមន្ទីរ ស-២១)

ដូចនៅឆេនទូកូហ្សូវ៉ូ ឆ្មាំនិងបុគ្គលិកគុកជាអ្នករក្សាបញ្ជីឈ្មោះអ្នកទោស និងទទួលខុសត្រូវចំពោះអ្នកទោសទាំងនោះ ។ នៅមន្ទីរឃុំឃាំងមិនផ្លូវការ វិធីសាស្ត្រសួរចម្លើយកាន់តែឃោរឃៅ ពីព្រោះគ្មានអ្នកទទួលខុសត្រូវទេប្រសិនបើមានអ្វីធ្ងន់ធ្ងរកើតឡើង ។ ជនជាប់ឃុំ«អាចបាត់ខ្លួន»នៅកន្លែងបែបនោះដោយងាយ ។

ខ្ញុំសូមលើកឧទាហរណ៍មួយទៀតដែលមនុស្សបានបាត់ខ្លួននៅក្នុងមន្ទីរឃុំឃាំងមិនផ្លូវការ ។ យើងបានប្រមូលភ័ស្តុតាងមកពីកន្លែងត្រួតពិនិត្យមួយនៅក្បែរភូមិឌុបបាយុត ។ នេះគ្រាន់តែជាកន្លែងត្រួតពិនិត្យមួយទេ ។ ពីខែមករាដល់ខែមីនា មានករណីបាត់ខ្លួនយ៉ាងហោចណាស់ប្រាំ ។ ករណីទីមួយបានកើតឡើងនៅថ្ងៃទី១៣ខែមករា នៅពេលដែលបុរសបួននាក់ត្រូវឃុំខ្លួនដោយមូលហេតុឆែកឆេរឯកសារ ។ ក្រោយមក បុរសទាំងបួនក៏បាត់ដំណឹងឈឹង ។ នៅថ្ងៃទី១០ ខែឧសភា ប្រជាជននៅក្នុងភូមិតាំងជីឈូបានរកឃើញសាកសពបីក្នុងចំណោមបុរសទាំងបួន ។ បុរសទីបួនមិនទាន់រកឃើញនៅឡើយទេ ។

ករណីទីពីរបានកើតឡើងនៅថ្ងៃទី១៨ ខែកុម្ភៈ ក្នុងនោះបុរសពីរនាក់បានបាត់ខ្លួន ។ ញាតិមិត្តរបស់បុរសទាំងពីរបានខិតខំស្វែងរក ហើយបានរកឃើញរថយន្តរបស់បុរសទាំងពីរដែលកប់មិនជិតនៅក្នុងដី ។ រថយន្តទាំងពីរត្រូវកិនកម្ទេចដោយរថក្រោះឬរថយន្តចម្បាំងធំៗ ។ មិនមាននរណាដឹងថាបុរសទាំងពីរនៅទីណាទេ ។

ករណីទីបីបានកើតឡើងនៅក្នុងខែមីនា ។ មនុស្សដប់ពីរនាក់ត្រូវបានឃុំខ្លួន ក្នុងចំណោមនោះស្ត្រីប្រាំនាក់ត្រូវបានដោះលែង ។ ប្រជាជនទាំង១២រូបនេះបានធ្វើដំណើរមកពីភូមិមួយនៅតំបន់ភ្នំឈ្មោះ យូលុសខឺត ជាមួយនឹងទាហានឆ័ត្រយោងរុស្ស៊ីមួយរូប ។ មុនពេលចេញដំណើរ ទាហានឆ័ត្រយោងមួយក្រុមបានចូលក្នុងភូមិ ហើយប្រាប់អ្នកភូមិថា "ក្រុមផ្សេងទៀតកំពុងតែមកពីក្រោយយើង ពួកនេះកាចសាហាវណាស់ ។ អ្នកទាំងអស់គ្នាគួរចាកចេញពីភូមិឥឡូវនេះភ្លាម" ។ ទាហានឆ័ត្រយោងមួយរូបបានស្ម័គ្រចិត្តអមដំណើរអ្នកភូមិទៅកាន់វាលទំនាប ។ នៅពេលដែលអ្នកទាំងអស់ធ្វើដំណើរទៅដល់ប៉ុស្តិ៍ត្រួតពិនិត្យឌុបបាយុត ទាហាននៅទីនោះបានចាប់ទាហានឆ័ត្រយោងដែលអមដំណើររួចវាយធ្វើបាបដោយចោទប្រកាន់ថាគាត់បានលក់ខ្លួនទៅឲ្យពួកឧទ្ទាមឆេចឆិន ហើយសួរគាត់ថាតើពួកឆេចឆិនបានសូកលុយគាត់ប៉ុន្មាន ។ បន្ទាប់មក គាត់ត្រូវនាំយកទៅកន្លែងផ្សេង ។ អ្នកភូមិភេទប្រុសត្រូវចាប់ខ្លួន ឯភេទស្រីត្រូវដោះលែង ។ រហូតមកដល់ពេលនេះ យើងមិនទាន់បានទទួលពត៌មានអំពីបុរសទាំងនោះទេ ទោះជាញាតិសន្តានរបស់អ្នកបាត់ខ្លួន អង្គការសិទ្ធិមនុស្ស និងសមាជិកសភា បានទាមទារពត៌មានពីរដ្ឋាភិបាលរុស្ស៊ីក៏ដោយ ។ មិនទាន់មានចម្លើយច្បាស់ការណាមួយទេ ។

យើងសង្ឃឹមថា ដំណើរការស្រាវជ្រាវឧក្រិដ្ឋកម្មនឹងចាប់ផ្តើម ពីព្រោះយើងបានដឹងយ៉ាងហោចណាស់ពីរករណីដែលកន្លែងត្រួតពិនិត្យស្ថិតនៅក្រោមបញ្ជាការរបស់មេទាហានតែមួយរូបដែលប្រជាជនអាចចង្អុលបង្ហាញមុខបាន ។ មិនមាននរណាម្នាក់ស្គាល់នាមត្រកូលរបស់នាយទាហានរូបនោះទេ ពីព្រោះថា ជាទូទៅ នាយទាហាននៅតាមប៉ុស្តិ៍ត្រួតពិនិត្យមិនបានប្រើប្រាស់ឈ្មោះពិតប្រាកដឡើយ ។ ករណីខាងលើគ្រាន់តែជាឧទាហរណ៍ខ្លះនៃការបាត់ខ្លួនជាច្រើនដែលបានកើតឡើង ។

ទោះបីជាមានរឿងរ៉ាវគួរឲ្យភ័យខ្លាចទាំងនេះក្តី ក៏តាមពិតទាហានទាំងអស់មិនមានភាពឃោរឃៅដូចគ្នាទេ ។ ពោលគឺតែងតែមានចំណុចខុសគ្នា ហើយអ្វីៗទាំងអស់គឺអាស្រ័យលើមេបញ្ជាការ ។ ឧទាហរណ៍ ឧត្តមសេនីយ៍ ស្សាម៉ាណុហ្វ ត្រូវបានស្គាល់ថាជាបុរសដែលមានភាពឃោរឃៅនៅក្នុងកងរបស់គាត់ ។ ឧត្តមសេនីយ៍ ត្រូស្សេហ្វ ខុសពី ស្សាម៉ាណុហ្វ បន្តិច ទោះជាគាត់ក៏ត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋសង្គ្រាមក៏ដោយ ។ យើងថែមទាំងបានដឹងថា នាយទាហានក្មេងៗបានប្រព្រឹត្តផ្សេង ។ ប្រជាជននៅរស់នៅក្នុងតំបន់ឆេចឆ្និបានសង្កេតឃើញភាពខុសគ្នាដ៏ធំរវាងទាហានក្មេងៗដែលត្រូវចាប់បង្ខំនិងទាហានដែលចុះកិច្ចសន្យាដោយខ្លួនឯង ដែលមកឆេចឆ្នីដើម្បីរកចំណូល ។ ទាហានក្នុងក្រុមទីពីរប្រព្រឹត្តបទឧក្រិដ្ឋភាគច្រើន ។ សាក្សីខ្លះបាននិយាយថា ជួនកាលទាហានវ័យក្មេងនៅក្នុងក្រុមទីមួយបានជួយការពារជនស៊ីវិលពីការធ្វើបាបរបស់ទាហានក្រុមទីពីរ ។

បញ្ហាដែលអាក្រក់បំផុតនោះគឺថា ឧក្រិដ្ឋកម្មធំៗត្រូវបាន

ប្រព្រឹត្តឡើងដោយសមាជិកនៃអង្គភាពនីតិប្រតិបត្តិ ដូចជាអង្គភាពប៉ូលិសពិសេសដែលបានបញ្ជូនពីតំបន់ជាច្រើននៅក្នុងប្រទេសរុស្ស៊ីទៅឆេចឈ្នី ។ រឿងនេះគួរឲ្យភ័យខ្លាចខ្លាំងណាស់ដោយសារមូលហេតុច្រើនយ៉ាង ។ ក្រោយពីបានភ្លក្សឈាមនៅឆេចឈ្នីហើយ តើប៉ូលិសទាំងនេះទៅរក្សាច្បាប់ទម្លាប់នៅរុស្ស៊ីយ៉ាងដូចម្តេចនៅពេលត្រឡប់ទៅវិញ?

មានចំណុចខុសគ្នាជាច្រើនដែលត្រូវរៀបរាប់ ។ ឧទាហរណ៍នៅថ្ងៃទី២៨ខែមេសា ឧបទ្ទវហេតុមួយបានកើតឡើងនៅក្នុងភូមិតូចមួយមានឈ្មោះថា ណូវ៉ាយ៉ា ហ្ស៊ីន ជាផ្នែកមួយនៃតំបន់ ហ្គិលដាជិន ។ មុនពេលកើតហេតុ ពួកឧទ្ទាមឆេចឈិនបានវាយប្រហារទៅលើក្បួនទ័ពរបស់រុស្ស៊ីនៅក្បែរភូមិ ស៊ីរហ្សិនយុត ហើយបានសម្លាប់ទាហានរុស្ស៊ីខ្លះ ។ ទ័ពអូម៉ុន (កម្លាំងប៉ូលិសពិសេស) បានចាប់ផ្តើម“បោសសម្អាត”ភូមិនិងទីប្រជុំជនជាច្រើន ។ ទ័ពអូម៉ុនបានចាប់ប្រជាជននៅក្នុងភូមិស្សាលីយុំយ៉ាងដោយមិនរើសមុខ ហើយវាយយ៉ាងដំណំ ។ កងកម្លាំងប៉ូលិសមួយក្រុមមកពីយូរ៉ាល់បានចូលមកដល់ភូមិ ណូវ៉ាយ៉ា ហ្ស៊ីន ហើយបានចាប់ផ្តើមចាប់មនុស្សយុំនិងវាយធ្វើបាប ។ ក្រុមនេះបានវាយទាំងស្ត្រី ដែលរួមមានស្ត្រីមានផ្ទៃពោះម្នាក់ បណ្តាលឲ្យគាត់រលូតកូន ។ ប៉ុន្តែមានកងកម្លាំងប៉ូលិសពិសេសមួយក្រុមទៀតនៅក្នុងភូមិដដែល ជាក្រុមរបស់កម្លាំងប៉ូលិសអូម៉ុនដែលមានប្រភពមកពីតំបន់ ម៉ូដូវៀ នៅក្នុងប្រទេសរុស្ស៊ី ។ មានការយល់យោគគ្នាខ្លះរវាងក្រុមនេះនិងអ្នកភូមិ ។ ក្រុមក្រោយនេះបានព្យាយាមបញ្ឈប់អំពើរំលោភបំពានដែលប្រព្រឹត្តដោយក្រុមផ្សេង ហេតុនេះការប្រយុទ្ធតូចមួយបានកើតឡើងរវាងក្រុមទាំងពីរ ។ ក្រុមដែលមកពី ម៉ូដូវៀ បានចាញ់ ទទួលការវាយដំ ហើយត្រូវក្រុមម្ខាងទៀតដកហូតម៉ាស៊ីនថតវីដេអូដែលខ្លួនបានប្រើប្រាស់សម្រាប់ថតអំពើហិង្សា ។ បន្ទាប់មក ក្រុមដែលឈ្នះបានវាយប្រជាជនក្នុងភូមិបន្តទៀត រួចចាប់បុរសចំនួន១១រូបយកទៅបន្ទាយរបស់ខ្លួនដើម្បីធ្វើទារុណកម្ម ។ ក្រោយមក ក្រុមទាហានបានដឹកជញ្ជូនបុរសទាំងអស់នេះតាមឧទ្ធម្ភាគចក្រទៅខាន់កាឡា ។ នៅទីនោះ បុរសទាំងអស់ត្រូវដាក់ក្នុងទូរថភ្លើងដើម្បីដឹកបន្តទៅកន្លែងផ្សេង ។

ពេលនោះ មានរឿងហេតុមិនប្រក្រតីមួយកើតឡើង ។ នៅពេលដែលអ្នកយកពត៌មានទៅដល់កន្លែងកើតហេតុ ក្រុមទាហានបានឧទ្ទេសនាមអ្នកទោសទាំងអស់ថាជាក្រុមឧទ្ទាមឆេចឈិន ។ ទោះជាយ៉ាងនេះក្តី ក្រុមទាហានបានអនុញ្ញាតឲ្យអ្នកទោសនិយាយជាមួយអ្នកយកពត៌មាន ។ បុរសម្នាក់បានឆក់ឱកាសនេះនិយាយថា “ខ្ញុំមិនមែនជាឧទ្ទាមទេ ខ្ញុំមកពីណូវ៉ាយ៉ាហ្ស៊ីន ។ ខ្ញុំមិនបានប្រព្រឹត្តបទល្មើសទេ” ។ បន្ទាប់ពីនោះ អ្នកសារពត៌មានបានសម្ភាសន៍ឧត្តមសេនីយ៍ ត្រូស្សិហ្វ ដែលបានឆ្លើយតបដោយគ្មានភ្ញាក់ផ្អើលថា “ទេ! ពួកនេះពិតជាឧទ្ទាមមែន!” ។ ត្រូស្សិហ្វ បានចោទប្រកាន់អ្នកទោសទាំងនោះថាបានចូលរួមក្នុងការវាយប្រយុទ្ធផ្សេងៗ ។ រឿងរ៉ាវនេះត្រូវបានចាក់ផ្សាយតាមទូរទស្សន៍ ។ នៅក្នុងថ្ងៃដដែល ប្រជាជននៅក្នុងភូមិ ណូវ៉ាយ៉ាហ្ស៊ីន បានដឹងថាមនុស្សមកពីភូមិរបស់ខ្លួនត្រូវចាប់ខ្លួន និងចោទប្រកាន់ថាជាឧទ្ទាម ។ ប្រជាជននៅក្នុងភូមិបានប្រមូលគ្នាហើយធ្វើបាតុកម្មទាមទារឲ្យដោះលែងបុរសទាំងនោះវិញ ។ ដូច្នេះបន្ថែមទៅលើរឿងអាស្រូវទាក់ទងទៅនឹងការប្រយុទ្ធគ្នារវាងក្រុមពីរនៃកម្លាំងប៉ូលិសពិសេសអូម៉ុន ការភ័ន្តច្រឡំមួយទៀតបានកើតឡើងទាក់ទងនឹងការចាប់អ្នកភូមិ ណូវ៉ាយ៉ាហ្ស៊ីន ។ នៅទីបញ្ចប់ទាហានបានដោះលែងអ្នកភូមិដោយគ្មានការចោទប្រកាន់ ។ បុរសទាំង១១រូបមានសេរីភាពវិញក្រោយពីត្រូវវាយធ្វើបាបយ៉ាងធ្ងន់ធ្ងរ ។ គ្មានការសុំអភ័យទោសទេ ។

ដំណើរការស៊ើបអង្កេតបទឧក្រិដ្ឋបានធ្វើទៅលើក្រុមប៉ូលិសពិសេសដែលមកពីតំបន់យូរ៉ាល់ ដោយការកាត់ទោសអ្នកគាំទ្រពួកឆេចឈិននៅទីក្រុងមូស្គូ ។ ទោះជាយ៉ាងណាខ្ញុំមិនជឿថា វាមិនមានប្រយោជន៍អ្វីធំដុំទេ ពីព្រោះថាការកាត់ទោសថ្នាក់ជាតិដោយអង្គច្បាប់នៃប្រទេសរុស្ស៊ីគឺមិនមានប្រសិទ្ធភាពឡើយ ។

អំពើហិង្សាដែលបានកើតឡើងនៅក្នុងអំឡុងប្រតិបត្តិការកងទ័ពគឺជាបញ្ហាដ៏ធំសម្រាប់ឆេចឈ្នី ។ អ្វីដែលសំខាន់មួយទៀតនោះគឺសកម្មភាពរបស់អង្គនីតិប្រតិបត្តិរុស្ស៊ីនៅក្នុងតំបន់រំដោះ ។ វាមានសារសំខាន់ណាស់ក្នុងការធានាថាជនល្មើសត្រូវបានកាត់ទោសតាមច្បាប់ ។

# ដំណោះស្រាយក្រោយជម្លោះនៅប្រទេសសេរ៉ាឡេអូន

**(តចប់)**

## ៥) តុលាការពិសេស និង គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សា

ការចោទប្រកាន់របស់តុលាការនេះចាប់ផ្តើមនៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០០៣ ដោយមានដីកាចោទប្រកាន់បណ្តោះអាសន្នចំនួនប្រាំពីរ ។ ដីកាបួនសម្រាប់អតីតខុទ្ទាមរណសិរ្សរួបរួមបដិវត្តន៍ (មានឈ្មោះ ហ្វូដេ សាបានា សាន់កុស, សាម បូការី, អ៊ីសា ហាសាន់ និង អាឡិច តាមបា ប្រ៊ីម៉ា ហៅ "ហ្គូលីត") សមាជិកពីររូបនៃរបបយោធា AFRC (មានឈ្មោះ ចននី ដូល កូរ៉ូម៉ា និង ម៉ូរីស កាលូន ហៅ "ប៊ីឡៃ ការីម") ព្រមទាំង សាម ហ៊ិនហ្គានរមែន ដែលជាមន្ត្រីជាន់ខ្ពស់នៅក្នុងចំណោមអ្នកដែលត្រូវបានចោទប្រកាន់ទាំងនេះ ។ ជនដែលត្រូវចោទប្រកាន់ចំនួនប្រាំរូបត្រូវជាប់ឃុំឃាំង ហើយមានដីកាតាមចាប់ខ្លួនពីរនាក់ទៀត ម្នាក់ជាសមាជិកសភា និងម្នាក់ទៀតជាអតីតមេដឹកនាំយោធានិយម ចូនី ដូល កូរ៉ូម៉ា និងអតីតមេបញ្ជាការសមរភូមិ RUF សាម "ម៉ូស្គីតូ" បូការី ។

ឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ រួមមាន ឃាតកម្ម ការរំលោភ អំពើភេរវកម្ម អំពើទាសភាព ការលួចប្លន់ ដុតផ្ទះ និងបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ទាសភាពខាងផ្លូវភេទ ការកេណ្ឌកុមារឲ្យធ្វើទាហាននិងកងកម្លាំងប្រដាប់អាវុធ ព្រមទាំងការវាយប្រហារមកលើកងកម្លាំងថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនិងបុគ្គលិកធ្វើការខាងមនុស្សធម៌ និងមានអ្នកផ្សេងទៀត ។ ចននី ដូល កូរ៉ូម៉ា ក៏កំពុងតែត្រូវបានស្វែងរកចាប់ខ្លួនពីសំណាក់អាជ្ញាធរសេរ៉ាឡេអូន ពីបទជាប់ពាក់ព័ន្ធជាមួយនឹងការប៉ុនប៉ងធ្វើរដ្ឋប្រហារនៅខែមករា ។ ចននី ដូល បានរត់គេចពីការចាប់ខ្លួននៅអំឡុងពេលដែលនគរបាលព័ទ្ធចាប់នៅលំនៅឋានរបស់លោកនៅភាគខាងលិចទីក្រុងហ្វ្រីថោន ប៉ុន្តែនគរបាលរកមិនឃើញកន្លែងលាក់ខ្លួន ។ សាម បូការី រត់ទៅលីបេរីយ៉ាក្រោយពីផ្តាច់ខ្លួនចេញពី ហ្វូដេ សានកុស នៅខែធ្នូឆ្នាំ១៩៩៩ ។

តុលាការពិសេសនឹងមិនត្រឹមតែបន្តតាមចាប់ កូរ៉ូម៉ា និង សាម បូការី ប៉ុណ្ណោះទេ តែថែមទាំងតាមចាប់ខ្លួនអ្នកដែលមានការទទួលខុសត្រូវខ្លាំងបំផុត (ទោះជានៅក្នុងឬក្រៅប្រទេសក្តី) ពីបទឧក្រិដ្ឋសង្គ្រាមដែលប្រព្រឹត្តឡើងនៅប្រទេសសេរ៉ាឡេអូន ។ ដូចដែល ដេវីដ ក្រេន ព្រះរាជអាជ្ញាតុលាការពិសេស បានកត់សម្គាល់ថា ករណីនេះវាធំជាងសេរ៉ាឡេអូនច្រើនណាស់ ។ មានភ័ស្តុតាងច្បាស់បញ្ជាក់អំពីការចូលរួមថ្នាក់តំបន់និងថ្នាក់អន្តរជាតិខាងផ្នែកហិរញ្ញវត្ថុ នយោបាយ និងការគាំទ្រផ្នែកយោធា ។ លោកបានសង្កត់ធ្ងន់ថា "ល្អិតណាវាស្ថិតនៅក្នុងអាណត្តិរបស់តុលាការ...ខ្ញុំអាចទៅគ្រប់ទីកន្លែង ទៅរកអ្នកទាំងនោះឲ្យទាល់តែឃើញ" ។ លោកនិយាយបែបនេះនៅពេលដែលជនរងគ្រោះមើលឃើញអ្នកខ្លះដាក់ខ្លួនចំពោះមុខច្បាប់ ។ នេះហើយជាយុត្តិធម៌ ។

ប្រជាជនសេរ៉ាឡេអូនជាច្រើនមានទឹកចិត្តរីករាយណាស់ដែលបានឃើញជនទាំងឡាយដែលមានការទទួលខុសត្រូវខ្ពស់ចំពោះអំពើឃោរឃៅមកឲ្យតុលាការកាត់ទោស ។ ប្រាហ៊ីម ម៉ាចាឡោះ គឺជាឆ្នាំសន្តិសុខនិងជាអ្នកដែលមានវាសនារួចផុតពីជម្លោះ ។ លោកកត់សម្គាល់ថា ការកាត់ក្តីធ្វើឲ្យមនុស្សភាគច្រើនសប្បាយចិត្ត ។ ចាឡោះ ជឿថា ការជំនុំជម្រះក្តីមិនត្រឹមតែនាំមកនូវយុត្តិធម៌ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឲ្យរាងចាលមិនហ៊ានប្រព្រឹត្តឧក្រិដ្ឋកម្មនៅប្រទេសរបស់ខ្លួននៅពេលខាងមុខទៀតផង ។ "ខ្ញុំគិតថា ការចាប់ខ្លួននិងការជំនុំជម្រះក្តីនឹងធ្វើឲ្យមនុស្សឈប់សម្លាប់និងប្រព្រឹត្តបទឧក្រិដ្ឋស្រេចតែទំនើងចិត្ត ។ ខ្ញុំចង់និយាយថា គ្មានអ្នកណាចេះតែលើកកាំភ្លើងបាញ់និងបំភិតបំភ័យអ្នកដទៃដោយគ្មានទទួលទោសឡើយ" ។ អ្នកបើកបរតាក់ស៊ីឈ្មោះ អាប់ឌុលឡៃ ក៏យល់ស្របជាមួយ ចាឡោះ ដែរ ។ អាប់ឌុលឡៃ និយាយថា ការជំនុំជម្រះក្តីនឹងបំបាត់មនុស្សអាក្រក់ ហើយទប់ស្កាត់មិនឲ្យមានអំពើអាក្រក់កើតឡើងនៅពេលអនាគត ។ គាត់និយាយ

ថា «ឲ្យគេចាប់ពួកវាទាំងអស់ទៅ ។ កុំទុកអ្នកណាម្នាក់ឲ្យសោះ» ។

បើទោះជាតុលាការពិសេសគឺជាយុទ្ធសាស្ត្រចម្បងដើម្បីដោះស្រាយបញ្ហានៃការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរក៏ដោយ ចំណុចខ្សោយគឺថា វាអាចបង្កអសន្តិសុខនៅក្នុងប្រទេស ។ អតីតយុទ្ធជនមានការភ័យខ្លាចតុលាការ ។ អ្នកស្រុកអ្នកភូមិមួយចំនួនយល់ឃើញថា ការកាត់សេចក្តីគឺជាការគំរាមកំហែងដែលប្រហែលជាអាចនាំដល់អំពើឃោរឃៅ នាំដល់ការវាយប្រយុទ្ធសាជាថ្មី ឬមានសង្គ្រាមស៊ីវិលក៏អាចថាបាន ។ កង្វល់មួយគឺថា សកម្មភាពរបស់តុលាការអាចបង្កការភ័យខ្លាចនៅក្នុងចំណោមពួកខ្មាំង ។ ការភ័យខ្លាចនេះទំនងជាមានទំហំធំជាងនៅពេលដែលអតីតខ្មាំងមួយចំនួននិងអ្នកស្រុកអ្នកភូមិមួយចំនួនមិនដឹងច្បាស់អំពីថាតើតុលាការនេះជាអ្វី ហើយមានអាណត្តិបែបណានោះ ។ ការប្រថុយគ្រោះថ្នាក់អសន្តិសុខចេះតែកើនឡើង នៅពេលដែលអតីតយុទ្ធជនមួយចំនួនសោកស្តាយចំពោះមេដឹកនាំរបស់ខ្លួនដែលត្រូវនាំមកកាត់ទោសចំពោះមុខតុលាការ ហើយយកទៅដាក់គុកដោយអយុត្តិធម៌ ។ ឧទាហរណ៍ ការចាប់ខ្លួន សាម ហ៊ីងហ្គា នរមែន ដោយតុលាការពិសេស មិនត្រឹមតែធ្វើឲ្យប្រជាជនស៊ីវិលសេរ៉ាឡេអូនភ្ញាក់ផ្អើលទេ សូម្បីតែកងជីវពលស៊ីវិលក៏មានការភ្ញាក់ផ្អើលនិងមិនសប្បាយចិត្តដែរ ។ នរមែន ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តឡើងដោយកងជីវពលគាំទ្ររដ្ឋាភិបាលដែលគាត់បានដឹកនាំនៅអំឡុងសង្គ្រាមស៊ីវិល ។ ប៉ុន្តែចំពោះមនុស្សជាច្រើនទៀតយល់ថា នរមែន គឺជាវីរបុរសដែលរៀបចំអង្គការចាត់តាំងប្រឆាំងទប់ទល់នឹងខ្មាំងរណសិរ្សរួបរួមបដិវត្តន៍ ។ អ្នកគាំទ្រ នរមែន បានសុំឲ្យប្រធានាធិបតីប្រាប់ឲ្យតុលាការដោះលែងរូបគាត់ឲ្យមានសេរីភាព ។ អតីតមេបញ្ជាការកងជីវពលស៊ីវិលឈ្មោះ កាសេឡា បញ្ជាក់ថា ក្រុមរបស់ខ្លួនមិនសប្បាយចិត្តដែលឃើញមេដឹកនាំរបស់ខ្លួនត្រូវចាប់ខ្លួននិងធ្វើឲ្យអាម៉ាស់មុខបែបនេះ ។ គាត់និយាយថា «យើងមិនសប្បាយចិត្ត ។ យើងប្រយុទ្ធដើម្បីប្រជាធិបតេយ្យនៅក្នុងប្រទេសនេះ ។ លោកប្រធាន នរមែន មិនមែនជាឧក្រិដ្ឋជនទេ ។ គាត់ជាវីរបុរសតស៊ូដើម្បីសន្តិភាពនិងរំដោះប្រជាជន ។» ដេវីដ ក្រេន ក៏ទទួលស្គាល់ដែរថាមានភាព រំជើបរំជួលពីសំណាក់អ្នកគាំទ្រទៅលើបុគ្គលមួយចំនួនដែលត្រូវបានតុលាការចោទប្រកាន់ ។ គាត់និយាយថា «មានការឈឺចាប់បន្តិចបន្តួច ។ វាហាក់ដូចជាការវះរបួសប៉ុណ្ណោះ ។ នៅពេលដែលយើងបកវាចេញ រំពេចនោះវាឈឺចាប់ដូចឃ្មុំទិច ប៉ុន្តែវាក៏ចាប់ផ្តើមជាសះបន្តិចម្តងៗទៅវិញដែរ» ។

យុទ្ធសាស្ត្រមួយទៀតក្នុងការនាំមកនូវសន្តិភាពនិងការផ្សះផ្សាដែលប្រកាន់យកដោយរដ្ឋាភិបាលសេរ៉ាឡេអូនគឺ គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សា ។ គណៈកម្មការនេះបង្កើតឡើងដោយច្បាប់ដែលអនុម័តដោយសភាជាតិនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០០០ ។ គោលបំណងនៃគណៈកម្មការនេះគឺចងក្រងឯកសារប្រវត្តិសាស្ត្រមួយផ្អែកស្តីអំពីការរំលោភនិងការបំពានមកលើច្បាប់សិទ្ធិមនុស្សនិងច្បាប់មនុស្សធម៌អន្តរជាតិ ដោះស្រាយបញ្ហានិទណ្ឌភាព ឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ជនរងគ្រោះ ជំរុញឲ្យមានការសះជានឹងគ្នានិងការផ្សះផ្សា ព្រមទាំងទប់ស្កាត់មិនឲ្យមានការរំលោភបំពានកើតឡើងសាជាថ្មី ។ អាណត្តិរបស់គណៈកម្មការមានរយៈពេលគិតចាប់ពីឆ្នាំ១៩៩១ រហូតដល់ថ្ងៃចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងឡូមឆ្នាំ១៩៩៩ ។

ខណៈដែលតុលាការពិសេសសេរ៉ាឡេអូនបានបញ្ជាក់អំពីគោលបំណងរបស់ខ្លួនមិនចង់រៀបចំការជំនុំជម្រះក្តីទៅលើយុទ្ធជនវ័យក្មេងនោះ គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាអះអាងថានឹងធ្វើការជាមួយឧក្រិដ្ឋជននៅថ្នាក់ក្រោម ជាពិសេសកម្មាភិបាលវ័យក្មេង និងអ្នកនៅជិតកន្លែងព្រឹត្តិការណ៍មួយកើតឡើង ។

«គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាមិនមែនជាតុលាការ ហើយការបើកសវនាការមិននាំដល់ការដាក់ពន្ធនាគារឡើយ ។ គណៈកម្មការស្វែងរកការពិតគឺសម្រាប់មនុស្សគ្រប់រូប ជនរងគ្រោះ ក្រុមគ្រួសារ សាក្សី ជនដៃដល់ ។ ចំណែកឯតុលាការពិសេសកាត់ទោសតែជនទាំងឡាយណាដែលមានការ

ទទួលខុសត្រូវខ្ពស់បំផុតប៉ុណ្ណោះ ។»

លោក អូសេហ្វ ហាំភើ ប្រធានគណៈកម្មការបានពន្យល់ថា មួយទសវត្សរ៍កន្លងទៅនេះ ភាពខ្មៅងងឹតបានគ្របដណ្តប់មកលើប្រទេសសេរ៉ាឡេអូន ដែលនៅទីនោះ បងវាយជាមួយប្អូន ក្រុមគ្រួសារបែកបាក់ហើយវាយប្រហារគ្នាទៅវិញទៅមក ភូមិករនិងសហគមន៍នានាក្លាយទៅជាឆាកប្រព្រឹត្តអំពើឃោរឃៅ និងសាហាវយង់ឃ្នង ។ នៅពេលដែលឈាមរបស់ជនស្លូតត្រង់ហូរ ជនជាតិសេរ៉ាឡេអូននៅតែមិនជឿទុកចិត្តគ្នា ហើយមានការរន្ធត់ចិត្តយ៉ាងខ្លាំង ។ មានសំណួរច្រើនណាស់ដែលត្រូវសួរ ។ តើមានអ្វីកើតឡើង? តើវាកើតឡើងចំពោះប្រទេសសេរ៉ាឡេអូនដោយរបៀបណា?

គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សានឹងឆ្លើយសំណួរទាំងនេះ ហើយនាំមកនូវសន្តិភាពសម្រាប់ប្រជាជនសេរ៉ាឡេអូន ។ ហាំភើ អះអាងថា ដើម្បីនាំមកនូវសន្តិភាព គណៈកម្មការនឹងមិនចែករំលែកការស្តីបន្ទោសឬការសងសឹកឡើយ ប៉ុន្តែទទួលស្គាល់បទពិសោធន៍របស់អ្នកដែលទទួលរងគ្រោះ ហើយគិតគូរដល់ជនដែលបានចូលរួមនៅក្នុងការប្រព្រឹត្តអំពើឃោរឃៅ ។ ធ្វើដូចនេះគឺដើម្បីឲ្យប្រជាជនដឹងនូវអ្វីដែលបានកើតឡើង និងការពារមិនឲ្យអំពើនេះកើតឡើងសាជាថ្មី ។ ចម្លើយនេះនឹងជួយកសាងជាផែនទីបង្ហាញផ្លូវសម្រាប់ប្រទេសសេរ៉ាឡេអូនថ្មីកសាងវប្បធម៌សន្តិភាព ការអត់ឱន ការគោរពទៅវិញទៅមក លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ។

ចំពោះអ្នកដែលរស់រានមានជីវិតនិងជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្សដែលកើតមានក្នុងអំឡុងពេលមានជម្លោះ គណៈកម្មការដែលរ៉ាប់រងដោយរដ្ឋាភិបាលផ្តល់នូវឱកាសរំដោះអ្នកទាំងនោះចេញពីភាពជាជនរងគ្រោះនៃអតីតកាល តាមរយៈការផ្តល់នូវការពិត ការផ្សះរបួសផ្លូវចិត្ត និងសំណងការខូចខាត ។ ហាំភើ អះអាងថា គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាជារបស់ប្រជាជនសេរ៉ាឡេអូនគ្រប់ៗរូប ។ ទាំងអស់នេះគឺជាកត្តាសំខាន់សម្រាប់សន្តិភាព ។ សន្តិភាពនឹងធ្វើឲ្យសេរ៉ាឡេអូនមានការអភិវឌ្ឍន៍ ។ តាំបា ហ៊ីនណោះ ដែលដៃស្តាំរបស់គាត់ត្រូវបានយុទ្ធជនវ័យក្មេងកាប់ដាច់នោះ គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សជាច្រើនដែលបាននិយាយអំពីរឿងរ៉ាវរបស់គាត់នៅចំពោះមុខគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សានៅថ្ងៃទី១៤ ខែមេសា ឆ្នាំ២០០៣ ។ តាំបា ហ៊ីនណោះ ពេញចិត្តចំពោះកិច្ចការរបស់គណៈកម្មការនេះ ហើយព្រមអត់ឱនដល់យុទ្ធជនវ័យក្មេងដែលបានកាប់ដៃរបស់គាត់ ។ គាត់និយាយថា «ខ្ញុំបានបំភ្លេចវាចោលហើយរៀបចំខ្លួនដើម្បីអត់ឱន... ខ្ញុំជឿថាកុមារតូចៗត្រូវបានពួកឧទ្ទាមបញ្ឆោត ហើយក្មេងទាំងនោះពូកែធ្វើត្រាប់តាមមនុស្សចាស់ណាស់» ។ ដេវីដ ក្រេន គាំទ្រគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាយ៉ាងពេញទំហឹង ។ គាត់និយាយថា គណៈកម្មការនេះអាចធ្វើសមាហរណកម្មអតីតយុទ្ធជននិងផ្សះផ្សាជាមួយអតីតបច្ចាមិត្តរបស់ខ្លួន ដើម្បីឲ្យភាគីទាំងពីររស់នៅជាមួយគ្នាក្នុងសន្តិភាព ។ គាត់បន្ថែមថា «ខ្ញុំមិនអត់ទោសឲ្យជនដែលប្រព្រឹត្តអំពើឧក្រិដ្ឋទេ ប៉ុន្តែយើងត្រូវតែឲ្យអ្នកទាំងនោះវិលមករួមរស់ក្នុងសង្គមជាតិវិញ ។ ប្រសិនបើយើងនៅតែយាយីពួកគេមិនចេះចប់មិនចេះហើយ នោះគេនឹងវិលត្រឡប់ចូលព្រៃវិញមិនខាន» ។

តាមការស្ទាបស្ទង់មតិមហាជនពីសំណាក់ក្រុមសង្គមស៊ីវិលដែលមានទីស្នាក់ការនៅទីក្រុងហ្វ្រីថោន ដែលធ្វើយុទ្ធនាការលើវិស័យអភិបាលកិច្ចល្អ បានរាយការណ៍ថា ប្រជាជនជាច្រើនមិនច្បាស់ក្នុងចិត្តអំពីតុលាការ ពិសេសគណៈកម្មការស្វែងរកការពិត ថែមទាំងមិនច្បាស់ថាតើកិច្ចការរបស់ស្ថាប័នទាំងពីរមានលក្ខណៈខុសគ្នាយ៉ាងដូចម្តេចដែរទេ ។ ការស្ទង់មតិមហាជនធ្វើឡើងនៅក្នុងឃុំចំនួន១២៨០ ក្នុងស្រុកចំនួន១៤ និងឃុំ២០០ នៅក្នុងតំបន់ខាងលិច ។ ទន្ទឹមពេលគ្នានេះដែរ ការស្ទង់មតិបង្ហាញអំពីការគាំទ្រចំពោះអាណត្តិរបស់តុលាការដើម្បីកាត់សេចក្តីត្រឹមតែជនទាំងឡាយ«ដែលមានការទទួលខុសត្រូវខ្ពស់បំផុតអំពីឧក្រិដ្ឋកម្មសង្គ្រាមតែប៉ុណ្ណោះ» ។ មានប្រជាជនតែ២ភាគ៣ប៉ុណ្ណោះដែលដឹងថាយុត្តាធិការតុលាការមានតែទៅលើ

ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្រោយថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៦ ។ ការភ័ន្តច្រឡំគ្នាកើតមានកាន់តែខ្លាំងទៅលើគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សា ។ មានតែ១៧ភាគរយនៃអ្នកដែលឆ្លើយនឹងសំណួរស្ទង់មតិប៉ុណ្ណោះដែលបាននិយាយថាខ្លួនយល់ច្បាស់អំពីតួនាទីរបស់គណៈកម្មការស្វែងរកការពិតនិងផ្សះផ្សា ។ ៨៣ភាគរយឆ្លើយថាយល់ខ្លះៗ ឬមិនយល់ទាល់តែសោះ ។

ខ្ញុំបាននិយាយទៅជាមួយ ស៊ូ ខាត់ធើ ដែលធ្លាប់ធ្វើការអស់រយៈពេល៩ឆ្នាំនៅក្នុងប្រទេសសេរ៉ាឡេអូន ហើយដែលនៅតែមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយបុគ្គលិកអង្គការក្រៅរដ្ឋាភិបាលព្រមទាំងមិត្តភក្តិនៅក្នុងប្រទេសសេរ៉ាឡេអូន ។ កិច្ចសម្ភាសន៍ជាមួយ ស៊ូ ក៏បង្ហាញអំពីកង្វះខាតការយល់ដឹងអំពីតុលាការពិសេសនិងគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សា ។ ប្រជាជនរស់នៅតាមភូមិមិនសូវមានការចូលរួមនិងមិនសូវយល់ដឹងដូចប្រជាជនរស់នៅតាមទីក្រុងទេ ជាពិសេសទីក្រុងហ្វ្រីថោនតែម្តង ។ អ្នកស្រុកអ្នកភូមិបកស្រាយដំណើរការនេះថាមាន «កម្រិតជាតិ» «ចំណាយពេលនិងចំណាយលុយឥតប្រយោជន៍» ជា«គំនិតបរទេស» និង«មិនមានការពាក់ព័ន្ធ»ឡើយ ។ ចំពោះ ស៊ូ យល់ថា សន្តិភាពនិងការផ្សះផ្សានៅប្រទេសសេរ៉ាឡេអូនមានដំណើរវែងឆ្ងាយណាស់ ហើយមានកិច្ចការជាច្រើនដែលត្រូវធ្វើ ។ តំបន់ផ្សេងៗនៅក្នុងប្រទេសត្រូវការចាំបាច់នូវការចូលរួមក្នុងដំណើរការនេះ យុវជនត្រូវតែមានអារម្មណ៍ថាខ្លួនមានចំណែកនៅក្នុងនេះដែរ តំបន់ជីកត្បូងត្រូវតែដាក់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាល ហើយត្រូវបង្កើតឲ្យមានឱកាសជាច្រើនក្នុងការធ្វើសមាហរណកម្មអតីតយុទ្ធជនចូលក្នុងសង្គមជាតិវិញ ។ រដ្ឋាភិបាលមិនមែនទទួលខុសត្រូវតែម្នាក់ឯងចំពោះសន្តិភាពនិងការផ្សះផ្សាទេ ។ ក្រុមសង្គមស៊ីវិលត្រូវតែចូលរួមនៅក្នុងដំណើរការនេះ ហើយបង្កើតជាដំណោះស្រាយចំពោះបញ្ហានេះ ។ ស៊ូ បន្ថែមថា ដំណោះស្រាយចំពោះបញ្ហានេះមានលក្ខណៈស្មុគស្មាញ ហើយតម្រូវឲ្យមានពេលវេលាច្រើន ធនធាននិងសកម្មភាពដែលរាប់តាំងពីការបង្កើនគូប្រកួតប្រជែងសេដ្ឋកិច្ចនិងការអប់រំរហូតដល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ។

នៅក្នុងបរិបទប្រទេសសេរ៉ាឡេអូន ក្រុមសង្គមស៊ីវិលក៏ត្រូវចូលរួមនៅក្នុងការជំរឿនសន្តិភាពនិងការផ្សះផ្សានៅថ្នាក់មូលដ្ឋានដែរ ។ ព្រះវិហាររ៉ូម៉ាំងកាតូលិកនិងវិសាលវិហារសេនផូល និងគណៈកម្មការដើម្បីសាមគ្គីភាពនិងសន្តិភាពជាពិសេស ។ នៅឯសិក្ខាសាលាមួយស្តីអំពីសន្តិភាពនិងការផ្សះផ្សាដែលរៀបចំឡើងដោយគណៈកម្មការដើម្បីសាមគ្គីភាពនិងសន្តិភាពនៅក្នុងប្រទេសសេរ៉ាឡេអូន ក្រុមសង្គមស៊ីវិលនិងអ្នកដទៃទៀតបានឈានដល់ការមូលមតិគ្នាថា បទបញ្ញត្តិមួយចំនួននៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងវ៉ូម ចាំបាច់ត្រូវការឲ្យមានការពិនិត្យសារឡើងវិញ ជាពិសេសបទបញ្ញត្តិទាំងឡាយដែលទាក់ទងដល់ស្ថានការណ៍នយោបាយរបស់រណសិរ្សរួបរួមបដិវត្តន៍និងមេដឹកនាំសាន់កុស ។ ទាំងអស់គ្នាក៏បានព្រមព្រៀងគ្នាទៀតថា កិច្ចព្រមព្រៀងនេះតំណាងឲ្យក្របខណ្ឌល្អមួយសម្រាប់ស្វែងរកសន្តិភាព ។ ក្របខណ្ឌនេះរួមមានការប្រឹក្សាយោបល់ ការថែទាំសុខភាពនិងកម្មវិធីផ្សេងៗដែលលើកកម្ពស់សន្តិភាពនិងសុខដុមរមនាប្រកបដោយនិរន្តរភាពនៅថ្នាក់មូលដ្ឋាន ។

ក្រោយពីវិលត្រឡប់មករួមរស់នៅក្នុងសង្គមជាតិវិញ អតីតយុទ្ធជនមិនត្រឹមតែបានស្វាគមន៍យ៉ាងកក់ក្តៅពីសំណាក់ក្រុមគ្រួសាររបស់ខ្លួនទេ សូម្បីតែអ្នកជិតខាងក៏ស្វាគមន៍ដែរ ។ ស៊ូ បានបញ្ជាក់អំពីស្ថានការណ៍នេះ ។ នាងបានពន្យល់ថា ការផ្សះផ្សានៅថ្នាក់សហគមន៍ត្រូវបានលើកកម្ពស់ដោយអង្គការសង្គមស៊ីវិល ។ នាងបានកត់សម្គាល់ទៅលើគម្រោងមួយរបស់កម្មវិធី វិសាលវិហារសេនផូល ដែលប្រើចម្រៀងដើម្បីជំរុញឲ្យមានការផ្សះផ្សានៅក្នុងសហគមន៍ ។ គ្រប់ចម្រៀងទាំងអស់និយាយតែអំពីសន្តិភាពនិងការអត់ឱន ព្រមទាំងលើកទឹកចិត្តឲ្យប្រជាជនរស់នៅជាមួយគ្នានៅក្នុងសហគមន៍មួយដែលពោរពេញទៅដោយសន្តិភាព ។ ស៊ូ បានគូសបញ្ជាក់ថា ឃ្លាមួយដែលថា «យើងត្រូវតែអត់ឱន» ត្រូវបានច្រៀងបន្ទរជាច្រើនលើកច្រើន

សា ។ ចម្រៀងក៏ទាំងនេះក៏សុំឲ្យព្រះជាម្ចាស់អត់ឱនឲ្យប្រជាជនសេរ៉ាឡេអូនចំពោះអំពើឃោរឃៅដែលកើតឡើងនៅក្នុងប្រទេសមួយដែលព្រះបានបង្កើតឡើង ។ ស៊ូ មានសេចក្តីសង្ឃឹមថា ប្រជាជនសេរ៉ាឡេអូននឹងរស់នៅជាមួយគ្នាដោយសន្តិភាពនៅពេលដែលទាំងអស់គ្នាចែករំលែកការទទួលខុសត្រូវជាបណ្តើរៗ ជាជាងស្តីបន្ទោសគ្នាទៅវិញទៅមក ។

នៅខែតុលា ឆ្នាំ២០០២ រីឆាត ដូដិន និយាយអំពីជនពិការចំនួន២៥០នាក់ថា គ្មានអ្នកណាម្នាក់ចង់បានសំណងមកវិញទេ ។ ចំពោះ រីឆាត យល់ថា ប្រការនេះ“ជាការអត់ឱនហួសពីសមត្ថភាពរបស់មនុស្សទៅទៀត” ។ បុគ្គលិកសិទ្ធិមនុស្សសេរ៉ាឡេអូនបញ្ជាក់ថា ការអត់ឱនកំពុងតែចាប់ដំណើរការហើយ ។ លោកមានប្រសាសន៍ថា “វាជាការពិបាក ប៉ុន្តែយើងត្រូវតែអត់ឱន” ។

### សេចក្តីសន្និដ្ឋាន

យុទ្ធសាស្ត្រដែលរបបក្រោយជម្លោះទទួលយកដើម្បីដោះស្រាយជាមួយនឹងសំណល់ដែលបន្សល់ទុកដោយការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរដែលប្រព្រឹត្តឡើងនៅអំឡុងពេលមានជម្លោះនោះតែងតែបង្កើតនូវភាពតានតឹងរវាងយុទ្ធសាស្ត្រមួយទៅយុទ្ធសាស្ត្រមួយ ។ ប្រទេសសេរ៉ាឡេអូនគឺជាករណីពិសេស ។ ដើម្បីសម្របសម្រួលប្រយោជន៍ ដើម្បីសន្តិភាពនិងស្ថិរភាព រដ្ឋាភិបាលបានផ្តល់ការលើកលែងទោសដល់កម្មាភិបាលថ្នាក់ក្រោម ព្រមទាំងចារីបទល្មើសសិទ្ធិមនុស្សធ្ងន់ធ្ងរ ។

ជនរងគ្រោះនិងអ្នកដែលរស់រានមានជីវិត ព្រមទាំងជនទាំងឡាយដែលត្រូវបានសម្លាប់ឬទទួលរងនូវការឈឺចាប់មិនអាចរស់បាន មានអារម្មណ៍យ៉ាងណាកាលបើឃើញជនដែលមានការទទួលខុសត្រូវចំពោះការស្លាប់ ពិការភាព និងការឈឺចាប់នៅតែដើរហើរដោយសេរីជាមួយនឹងនិទណ្ឌភាព ។ ចំពោះមនុស្សជាច្រើន និទណ្ឌភាពបានបដិសេធមិនឲ្យជនរងគ្រោះទទួលបាននូវយុត្តិធម៌ឬការជួសជុលឡើយ ។ ប៉ុន្តែការផ្សះផ្សាតម្រូវឲ្យមានការសម្របសម្រួលនិងការអត់ឱនក្នុងកម្រិតមួយធំណាស់ទើបបាន ។

លីដីវ៉ាច យល់ថា សន្តិភាពនិងការផ្សះផ្សាមិនត្រឹមតែជាលទ្ធផលនោះទេ ប៉ុន្តែថែមទាំងជាដំណើរការមួយដែលត្រូវការពេលវេលា ការតាំងចិត្ត និងកិច្ចសហការ ។ ដើម្បីឲ្យមាននិរន្តរភាព សន្តិភាព និងការផ្សះផ្សា ដែលរដ្ឋាភិបាលសេរ៉ាឡេអូនបានចំណាយពេលអស់៣ឆ្នាំហើយនោះ កិច្ចសហការនិងការគាំទ្រពីសហគមន៍អន្តរជាតិនិងប្រទេសនៅក្នុងតំបន់គឺត្រូវការចាំបាច់ណាស់ ។ តម្រូវការសំខាន់មួយគឺបញ្ចប់ជម្លោះនៅលីបេរីយ៉ា ហើយនិងបញ្ចប់ការជួញដូរអាវុធនៅក្នុងតំបន់ ។

អស្ថិរភាពនិងការប្រយុទ្ធគ្នានៅប្រទេសលីបេរីយ៉ាកំពុងតែបន្តឲ្យមានជនភៀសសឹកយ៉ាងច្រើនហូរចូលទៅក្នុងប្រទេសសេរ៉ាឡេអូន ។ ការហូរចូលនេះនឹងធ្វើឲ្យរដ្ឋាភិបាលស្ថិតក្រោមសម្ពាធដែលមិនត្រឹមតែត្រូវផ្តល់ជំនួយមនុស្សធម៌ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធានាដល់សន្តិសុខទៀតផង ។ ជម្លោះនៅលីបេរីយ៉ានឹងបន្តឲ្យមានអសន្តិសុខនៅតាមព្រំដែន ហើយនឹងរាលដាលដូចកាលពីឆ្នាំ១៩៩១ដែរ ។ វាជាគ្រោះថ្នាក់ដែលអតីតយុទ្ធជនសេរ៉ាឡេអូននឹងចូលរួមក្នុងជម្លោះដើម្បីឆ្លៀតយកចំណេញពីសង្គ្រាម ។ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានទទួលស្គាល់ថា កិច្ចសហប្រតិបត្តិការនិងការគាំទ្រពីសំណាក់ប្រទេសជិតខាងនិងសហគមន៍អន្តរជាតិមានសារសំខាន់សម្រាប់និរន្តរភាពនៃសន្តិភាពនៅប្រទេសសេរ៉ាឡេអូន ។ ទាក់ទងនឹងបញ្ហានេះ លោកអគ្គលេខាធិការបានអំពាវនាវឲ្យមានជំនួយពីអន្តរជាតិដើម្បីបញ្ចប់ជម្លោះនៅលីបេរីយ៉ា ។

បញ្ហាមួយទៀតដែលគំរាមកំហែងដល់សន្តិភាពនិងការផ្សះផ្សាជាតិនៅប្រទេសសេរ៉ាឡេអូន គឺការជួញដូរអាវុធនៅក្នុងតំបន់ ។ ប្រវត្តិនៃជម្លោះនៅប្រទេសសេរ៉ាឡេអូនបានបង្ហាញថា ការដែលមានអាវុធហូរហៀរបាននាំដល់ការកើនឡើងនូវសកម្មភាពទាហានស៊ីឈ្នួលកាន់តែច្រើន ។ យុទ្ធជនក្រៅក្របខ័ណ្ឌបានធ្វើដំណើរពីប្រទេសមួយទៅប្រទេសមួយ គិតតែចង់ប្រយុទ្ធដើម្បីអ្នកណាក៏ដោយឲ្យតែបានប្រាក់ឈ្នួល ។ លោក កូហ្វី

អាណាន់ មានប្រសាសន៍ថា សង្គ្រាមនៅប្រទេសសេរ៉ាឡេអូន ត្រូវបានបញ្ឆេះកាន់តែសន្ធោសន្ធៅដោយសារតែពាណិជ្ជកម្មអាវុធធុនតូចដែលគ្មានច្បាប់ហាមប្រាមហ្មត់ចត់ ដែលគេយកលុយបានមកពីអាជីវកម្មធនធានធម្មជាតិទៅចំណាយ ។ ដើម្បីដោះស្រាយបញ្ហានេះ លោក កូហ្វី អាណាន់ បានអំពាវនាវដល់មេដឹកនាំអាហ្វ្រិកខាងកើតឲ្យផ្តោតសំខាន់ទៅលើ"ការគំរាមកំហែងយ៉ាងជាក់ស្តែងដល់សន្តិភាពដែលបណ្តាលមកពីការសាយភាយអាវុធធុនតូចនៅក្នុងតំបន់ ។ លោកបានពន្យល់ថា ការរីកសាយភាយអាវុធដោយគ្មានការគ្រប់គ្រងច្បាស់លាស់និងការប្រើទាហានដែលចេះតែឆក់ឱកាសធ្វើឲ្យជម្លោះបន្តកើតមានបានបង្កឲ្យអំពើហិង្សាកាន់តែតានតឹង បញ្ឆេះឲ្យមានឧក្រិដ្ឋកម្មនិងភេរវកម្មកាន់តែច្រើន ជំរុញឲ្យមានអំពើហិង្សារំលោភច្បាប់មនុស្សធម៌អន្តរជាតិនិងរាំងស្ទះដល់ការអភិវឌ្ឍន៍ ។ បញ្ហានេះ "មានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការខកខានមិនបានធ្វើហិរញ្ញប្បទានគ្រប់គ្រាន់ និងការខកខានមិនបានអនុវត្តការដកអាវុធ ការរំសាយទ័ព និងសមាហរណកម្មកងកម្លាំងរបស់ខ្លួនដែលជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាពក្រោយពេលមានជម្លោះ ។

ជម្លោះនៅលីបេរីយ៉ានិងការជួញដូរអាវុធនៅក្នុងតំបន់គឺជាកត្តាចម្បងបំផុតដែលអាចធ្វើឲ្យខូចដល់ដំណើរការសន្តិភាពនិងការផ្សះផ្សានៅក្នុងប្រទេសសេរ៉ាឡេអូន ។ ប្រសិនបើគ្មានកិច្ចសហប្រតិបត្តិការនិងការគាំទ្រពីសហគមន៍អន្តរជាតិនិងប្រទេសនៅក្នុងតំបន់ដើម្បីបញ្ចប់ជម្លោះនៅលីបេរីយ៉ានិងការជួញដូរអាវុធនៅក្នុងតំបន់ទេនោះ ដំណើរការសន្តិភាពរបស់ប្រទេសសេរ៉ាឡេអូននឹងដួលរលំ ។ គ្រប់កិច្ចសហប្រតិបត្តិការនិងការគាំទ្រមិនត្រឹមតែធ្វើឲ្យមាននិរន្តរភាពដល់សន្តិភាពនិងការផ្សះផ្សាប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងនាំមកនូវសន្តិភាពសម្រាប់តំបន់ទាំងមូលផង ពីព្រោះថា អស្ថិរភាពនៅក្នុងប្រទេសសេរ៉ា-ឡេអូន ក៏មានផលប៉ះពាល់ដល់សន្តិសុខក្នុងតំបន់ដែរ ។

**អៀ ម៉េងទ្រី**

## សេចក្តីជូនដំណឹងរបស់សមាគមអ្នកនិពន្ធខ្មែរ

សមាគមអ្នកនិពន្ធខ្មែរសូមជម្រាបដល់ប្រជាជនកម្ពុជាគ្រប់រូបថា សមាគមបានរៀបចំ "**វេទិកាថែរក្សាប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ**" ក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ វេទិកានេះមានគោលបំណងសំខាន់ៗដូចជា÷

- រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។
- ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍សេចក្តីទុក្ខ ការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។
- ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។
- ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

សមាគមអ្នកនិពន្ធខ្មែរសូមអំពាវនាវដល់ប្រជាជនកម្ពុជាចូលរួមសរសេរអត្ថបទទាំងឡាយអំពី÷ ១) រឿងរ៉ាវផ្ទាល់ខ្លួន ២) ព្រឹត្តិការណ៍ដែលលោកអ្នកធ្លាប់បានជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ៣) ផ្តល់ដំណោះស្រាយចំពោះបញ្ហាប្រវត្តិសាស្ត្រនេះ ។ ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។

សមាគមអ្នកនិពន្ធខ្មែរនិងមជ្ឈមណ្ឌលឯកសារកម្ពុជានឹងមានកិត្តិយសដោយចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តី "*ស្វែងរកការពិត*" ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ ការចូលរួមរបស់លោកអ្នកគឺជាការរួមចំណែកលើកស្ទួយតម្លៃនៃការសរសេរនិងចំណេះដឹង ។

សូមផ្ញើអត្ថបទរបស់លោកអ្នកមកសមាគមអ្នកនិពន្ធខ្មែរទីស្នាក់ការៈ វត្តបទុមវតី ភ្នំពេញ ឬទាក់ទងតាមទូរស័ព្ទលេខ ០១២ ៨៨៣ ០៧២ ចាប់ពីពេលផ្សាយដំណឹងនេះរហូតដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ។

**យូ ប៊ុ**

**ប្រធានសមាគមអ្នកនិពន្ធខ្មែរ**

# លិខិតផ្ញើជូន ខៀវ សំផន

តើខ្មែរក្រហមសម្លាប់រង្គាលឬសម្លាប់ផ្តាច់ពូជ? ថ្ងៃ ១៧ មេសា ១៩៧៥ គេថាភ្នំពេញត្រូវបានរំដោះ កាលនោះខ្ញុំទើបមានអាយុប្រហែល១១ឆ្នាំប៉ុណ្ណោះ ។ កន្លះខែក្រោយថ្ងៃរំដោះ ខ្ញុំបានឃើញអ្នកភ្នំពេញបានមកដល់ភូមិខ្ញុំជាបន្តបន្ទាប់យ៉ាងច្រើនកុះករ ។ ខ្ញុំនិងក្មេងៗដទៃទៀតបានឈរចាំមើលដោយមិនយល់នូវហេតុការណ៍អ្វីឡើយ ដោយខ្លះរុញស៊ីក្លូ ម៉ូតូ និងកូនឡានតូចៗ ។ យើងមិនឃើញមានឥវ៉ាន់ច្រើនប៉ុន្មានទេ ខ្លះទៀតទូលបង្វេចតូចៗ ដឹកដៃកូនចៅដោយក្តីលំបាកលំបិន ។ អ្នកដែលមានញាតិមិត្តបងប្អូនក្នុងភូមិក៏ឆៀងចូលទៅរកផ្ទះដែលខ្លួនធ្លាប់ស្គាល់ រីឯអ្នកដែលគ្មានបងប្អូនក៏នាំគ្នាសម្រាកក្រោមដើមឈើតាមចិញ្ចើមថ្នល់និងក្នុងវត្ត ។ ត្បិតតែអ្នកជម្លៀសទាំងនោះមានរូបរាងនិងសម្លៀកបំពាក់ស្អាតៗ ប៉ុន្តែខ្ញុំដឹងថាពួកគាត់មានសភាពហេវហត់ណាស់ ពិសេសគឺក្មេងៗតូច ។ មិនទាន់ទាំងមានកន្លែងស្នាក់ត្រឹមត្រូវផង ខ្ញុំឃើញកងឈ្លបនិងប្រធានភូមិខ្ញុំបាននាំគ្នាសុំឆែកឆេររុះរើអីវ៉ាន់យ៉ាងប្រញាប់ប្រញាល់ ។ គេថាឆែករកគ្រាប់រំសេវ ហើយនិងសាកសួរអំពីការងារមុខតំណែងក្នុងរបបលន់ ណុល ។

កាលណោះ ថ្ងៃជិតលិចទៅហើយ អ្នកខ្លះគ្មានអង្ករដាំបាយហូបទេ ។ គាត់បានយកខោអាវ មាសពេជ្រ និងរបស់របរដទៃទៀត ដើម្បីដូរយកអង្ករអ្នកភូមិ ព្រោះពេលនោះគេឈប់ចាយលុយហើយ ។ ទោះបីពួកគេមានការលំបាកលំបិន តែកាលនោះខ្ញុំដឹងថាខ្លួនខ្ញុំមិនបានអាណិតអាសូរដល់ពួកគេទេ ហើយហាក់មានអារម្មណ៍ស្អប់និងខឹងទៅវិញ ព្រោះធ្លាប់តែឮគេនិយាយរាល់ថ្ងៃថា អ្នកមានជិះជាន់អ្នកក្រ អ្នកក្រុងមើលងាយអ្នកស្រែ...។ ប្រហែលជាមកពីមូលហេតុបែបនេះហើយបានជាអ្នកមូលដ្ឋានមិនសូវយកចិត្តទុកដាក់នឹងអ្នកថ្មីទាំងនោះទេ ។ ពីរបីថ្ងៃក្រោយមកទើបអង្គការចាត់ឲ្យពួកគាត់ទៅស្នាក់នៅតាមផ្ទះអ្នកភូមិ ផ្ទះណាធំក៏ទទួលពីរឬបីគ្រួសារ ។

និយាយអំពីអ្នកភ្នំពេញ ខ្ញុំធ្លាប់បានឮជីតាខ្ញុំដំណាលថា គាត់មានកូនពៅម្នាក់ទៅធ្វើការនៅភ្នំពេញ ហេតុនេះហើយបានជាតាខ្ញុំ អ៊ុំខ្ញុំ ឪពុកខ្ញុំ និងមីងខ្ញុំ គាត់ទាំងអស់គ្នាទន្ទឹងរង់ចាំពូខ្ញុំយ៉ាងអន្ទះសា តែខ្ញុំមិនដែលបានស្គាល់ពូទេ ។ ១៨ថ្ងៃក្រោយរំដោះ ខ្ញុំឃើញស៊ីក្លូមួយអមដោយសមាជិក៦នាក់ បានរុញសំដៅមកផ្ទះខ្ញុំ ។ ពេលនោះបងប្អូនទាំងអស់គ្នារីករាយណាស់ ។ ឪពុកខ្ញុំប្រាប់ខ្ញុំថា នេះជាពូរបស់ឯង ។ សេចក្តីរីករាយមិនបានប៉ុន្មានផងបរិយាកាសក៏ប្រែជាអាប់អួទៅវិញ ព្រោះពេលនោះឈ្លបភូមិក៏បានមកដល់ដែរ ។ ពូខ្ញុំប្រែទឹកមុខស្រងូតស្រងាត់ ។ កងឈ្លបនិងមេភូមិបានសាកសួរអំពីការងារដែលពូខ្ញុំធ្លាប់បានធ្វើកាលនៅភ្នំពេញ ។ គាត់មានការស្ទាក់ស្ទើរមិនចង់ឆ្លើយទេ តែដោយសារការស្មោះត្រង់របស់អ៊ំនិងឪពុកខ្ញុំផងចំពោះអង្គការ គាត់ប្រាប់ពូខ្ញុំថា សូមប្អូនឆ្លើយឲ្យត្រង់ទៅ អង្គការមិនយកទោសពៃរ៍ទេ ។ ខ្ញុំឃើញពូខ្ញុំរលីងរលោងទឹកភ្នែកមិនឈប់ទេ ។ ប្រហែលជាគាត់ជ្រាបពីហេតុការណ៍អ្វីហើយ តែនៅទីបំផុតគាត់ក៏ព្រមឆ្លើយសារភាពត្រង់ៗថាគាត់ធ្វើគិញ ។

តាំងពីមកដល់ភូមិកំណើត ខ្ញុំសង្កេតឃើញថាពូមិនពិសាបាយទឹកទេ ។ គាត់សម្រាន្តលើអង្រឹងទទូក្រមាជិតមិននិយាយស្តីអ្វីទាំងអស់ ។ បីថ្ងៃក្រោយមក គេក៏មកហៅពូខ្ញុំឲ្យទៅរៀនសូត្រ ។ ខ្ញុំឮពុកនិងអ៊ំបានផ្តែផ្តាំពូថា សូមប្អូនខំប្រឹងលត់ដំខ្លួនតាមអង្គការ កុំអាឡោះអាល័យរបបចាស់អី ។ តាំងពីពេលនោះមកដល់សព្វថ្ងៃគឺ២៧ឆ្នាំឰាយហើយ មិនទាន់ឃើញពូខ្ញុំត្រឡប់មកពីរៀនសូត្រវិញទេ ។ ជីតានិងអ៊ំរបស់ខ្ញុំគាត់ស្លាប់បាត់អស់ហើយ ។ ឪពុកខ្ញុំក៏ដូចជាបងប្អូនទាំងអស់ដែរ គឺបានឃើញមុខពូខ្ញុំតែ៣ថ្ងៃគត់ ។ ខ្ញុំចេះតែស្រមៃថាពូខ្ញុំនឹងវិលត្រឡប់មកវិញ ព្រោះខ្ញុំនៅចាំបានថា អង្គការយកគាត់ទៅរៀនតែបីថ្ងៃទេ ។ តើអង្គការយកពូខ្ញុំទៅរៀននៅឯណា? សូមលោក ខៀវ សំផន ប្រាប់ខ្ញុំផង ។

ក្នុងឆ្នាំ១៩៧៦ អង្គការតម្រូវឲ្យប្រជាជនធ្វើរួមហូបរួមក្នុងសហករណ៍ ។ មីងថ្លៃខ្ញុំក៏ដូចជាអ្នកភូមិទាំងអស់ដែរ គឺយើងបានហូបបាយតែបីថ្ងៃប៉ុណ្ណោះ ក្រៅពីនោះគឺបបរជាមួយសម្លព្រលិតជិតបីឆ្នាំ ព្រោះអង្គការថាខ្វះខាត ហូបសន្សំសំចៃ តែការងារ

ត្រូវគេបង្ខំឲ្យធ្វើការទាំងយប់ទាំងថ្ងៃ អ្នកណាឈឺត្រូវគេថាគ្រុនទន្សាយឬឈឺសតិអារម្មណ៍ ។ កាលនោះខ្ញុំនៅចាំបានថា អ្នកដែលមានអាយុ១៨ឆ្នាំឡើងហើយមិនទាន់មានគ្រួសារ ត្រូវបញ្ជូនឲ្យទៅធ្វើកងចល័ត ឯក្មេងៗត្រូវអង្គការប្រមូលឲ្យទៅនៅតាមកងកុមារបង្ខំឲ្យធ្វើការគ្មានឈប់ ។ រូបខ្ញុំក៏ដូចជាមិត្តភក្តិដទៃទៀតដែរ ត្រូវអត់បាយហូបជាញឹកញាប់ព្រោះតែលួចរត់ចេញពីកងមកលេងម្តាយ ។

បួនប្រាំខែក្រោយពីបានទៅនៅកងចល័ត បងខ្ញុំពីរនាក់និងបងជីដូនមួយម្នាក់ដែលជាកូនរបស់ពូខ្ញុំ បានត្រឡប់មកលេងផ្ទះម្តង ។ ខ្ញុំឃើញរូបគាត់ស្គមស្គាំងប្រៀបដូចអ្នកកើតអេដស៍សម័យនេះអ៊ីចឹង ។ ប្រហែលជាមួយឆ្នាំក្រោយមក ខ្ញុំឃើញគាត់លួចរត់មកផ្ទះជាញឹកញាប់ ប៉ុន្តែប្រធានសហករណ៍មិនឲ្យបាយគាត់ហូបទេ គេថាគ្មានរបបអង្ករ ។ កាលនោះខ្ញុំនៅចាំបានថា រដូវស្រូវចេញផ្លែ បងជីដូនមួយខ្ញុំនៅពួនក្នុងស្រែពីរបីយប់ មេកងក៏តាមមកចាប់យកទៅវិញដោយវាយធ្វើបាបគួរឲ្យអាណិតណាស់ព្រោះគាត់រឹងទទឹងមិនព្រមទៅតាមគេ ។ ទោះបីឃើញគេធ្វើបាបកូនក្មួយនៅចំពោះមុខក៏គ្មាននរណាហ៊ានជួយដែរ ព្រោះគេថាក្បាលនរណាសក់អ្នកហ្នឹង ។ ទោះបីត្រូវគេវាយធ្វើបាបមិនបានហូបបាយនៅសហករណ៍ក៏ដោយ តែខ្ញុំនៅតែឃើញបងជីដូនមួយខ្ញុំលួចរត់មកភូមិដដែលៗ ។ ក្រោយមកគាត់ក៏បាត់ខ្លួនរហូតដល់សព្វថ្ងៃនេះ ។ ប្រហែលជារបបនោះយកគាត់ទៅរៀនសូត្រទៀតហើយ ។

និយាយអំពីក្នុងភូមិឯណេះវិញ ស្ទើរតែរាល់ថ្ងៃ ខ្ញុំឃើញគេចាប់មនុស្សហើយចងស្លាបសេកយ៉ាងតឹង បណ្តើរយកទៅរៀនសូត្រ ។ បុរសៗដែលជាអ្នក១៧មេសា ដោយយើងមិនបានឃើញគាត់ធ្វើអ្វីខុសឡើយ តែអង្គការថាពួកគាត់ក្បត់ជាតិ... ។ សម័យនោះបើគេហៅទៅសែងម៉ាស៊ីនឬទៅរែកកណ្តាប់ពេលយប់ គឺច្បាស់ជាបាត់ខ្លួនហើយ មិនឃើញត្រឡប់មកវិញទេ ។

ឆ្នាំ១៩៧៧ មីងថ្លៃខ្ញុំ កូនគាត់៣នាក់ដែលនៅសល់ និងអ្នក១៧មេសាប្រមាណ៥០គ្រួសារ សរុបសមាជិកប្រហែល ២៥០នាក់ ត្រូវអង្គការបញ្ជូនឲ្យទៅនៅភូមិថ្មី ។

តើភូមិថ្មីនោះនៅឯណា? ឆ្ងាយឬជិត? ហេតុអ្វីមនុស្សជាង២៥០នាក់មិនដែលឃើញមកលេងភូមិចាស់ម្នាក់សោះ? តើលោក ខៀវ សំផន ដឹងឬទេ? ចំណែកភូមិចាស់របស់ពួកគាត់ គឺភូមិក្រាំងដូង ឃុំសំរោង ស្រុកបន្ទាយមាស ខេត្តកំពត ។ បើលោកជាប្រមុខរដ្ឋសម័យនោះមិនដឹងទេ តើនរណាជាអ្នកដឹងទៅវិញ?

ខ្ញុំសូមប្រាប់ទៅចុះ អ្នកដែលបញ្ជូនប្រជាជនទៅនៅភូមិថ្មីគឺគាត់ឈ្មោះ ពូអ៊ិក ជាប្រធានភូមិក្រាំងដូងសម័យប៉ុលពត ។ កាលនោះគាត់សាហាវណាស់ សព្វថ្ងៃនេះគាត់រស់នៅយ៉ាងសុខសប្បាយក្នុងភូមិសំរោងក្រោម ស្រុកបន្ទាយមាសនេះឯង ។

បីឆ្នាំប្រាំបីខែ មនុស្សក្នុងភូមិខ្ញុំត្រូវគេសម្លាប់លើសពី ៣០០នាក់ ។ នេះមិនបានគិតដល់អ្នកដែលស្លាប់ដោយធ្វើការបាក់កម្លាំង ហូបមិនឆ្អែត និងឈឺគ្មានថ្នាំព្យាបាលផងទេ ។

អន្ទង់សាកសពមនុស្សក្មេងចាស់ប្រុសស្រីទាំង២៥០នាក់ជាងនោះ លោកប្រហែលជាអាចបានដឹងបើទៅសួរឈ្មោះ ពូកុន ពូវ៉ន បងសេក... ព្រោះគាត់ជាអ្នកដឹកខសឲ្យសហករណ៍សម័យនោះ ។ ខ្ញុំធ្លាប់ឮគាត់និយាយថា ធ្លាប់បានដើរជួបកន្លែងគេសម្លាប់រួមមួយនៅអូរកណ្តាល ។

ពូខ្ញុំ មីងថ្លៃខ្ញុំ ជីដូនមួយខ្ញុំ៤នាក់ ក្នុងនោះមានប្អូនស្រីអាយុ៥ឆ្នាំម្នាក់ផង ត្រូវគេសម្លាប់ដោយវាយនឹងដំបងគួរឲ្យខ្លោចផ្សាណាស់ ។ គ្រួសារពូខ្ញុំត្រូវស្លាប់ផុតពូជ ស្លាប់ដោយគ្មានកំហុសអយុត្តិធម៌ណាស់! តើគេសម្លាប់ពួកគាត់ធ្វើអ្វីលោក ខៀវ សំផន? ប្រាប់ខ្ញុំមក!

ខ្ញុំសរសេរអត្ថបទនេះព្រោះចង់ឲ្យរឿងរ៉ាវពិតដែលកើតមាននៅភូមិខ្ញុំជាប់នៅក្នុងប្រវត្តិសាស្ត្រប៉ុណ្ណោះ ។ ខ្ញុំជឿថាមានមនុស្សតិចណាស់ដែលស្ម័គ្រចិត្តសរសេររឿងហេតុសម័យប៉ុលពតឲ្យមនុស្សជំនាន់ក្រោយបានអាន គឺគេគ្រាន់តែនិយាយប្រាប់កូនចៅដោយមាត់ទទេតៗគ្នា ។ ជាការជាក់ស្តែង នៅក្នុងភូមិកំណើតខ្ញុំ បើមិនសរសេរទេ ជនរងគ្រោះជាង៣០០នាក់ ក្មេងជំនាន់ក្រោយពិតជាមិនដឹងព្រឹត្តិការណ៍ដ៏ឃោរឃៅបានកើតឡើងក្នុងភូមិរបស់គេទេ ។

ទីបញ្ចប់ សូមឲ្យព្រះធម៌របស់ព្រះពុទ្ធដែលជាធម៌អហិង្សាមិនបៀតបៀន គឺជាមេត្តាករុណាធម៌ មាននៅក្នុងសន្តានចិត្តរបស់មនុស្សជាតិទូទៅ ។

**ប្រាក់ ឧន្នី**

**សរសេរនៅត្រពាំងរូង កោះកុង**

# ក្មួន អត់ ឪ

ខ្ញុំកើតនៅខែកញ្ញា ឆ្នាំ១៩៧៥ នៅស្រុកសូទ្រនិគម (ដំដែក) ខេត្តសៀមរាប ។ ឆ្នាំ១៩៨១ ក្រុមគ្រួសាររបស់ខ្ញុំបានប្តូរទីលំនៅមករស់នៅខេត្តស្ទឹងត្រែង ។ រយៈពេលជាងប្រាំឆ្នាំដែលខ្ញុំរស់នៅខេត្តសៀមរាប រឿងមួយដែលធ្វើឲ្យខ្ញុំចាំមិនភ្លេចនោះគឺរឿងប៉ាខ្ញុំ ។ ប៉ាបានបាត់ខ្លួននៅទីនោះយ៉ាងអាណោចអាធ័មបំផុត សូម្បីរូបខ្ញុំផ្ទាល់ក៏មិនចាំមុខប៉ាច្បាស់ដែរ ។ ម៉ាក់តែងតែដំណាលរឿងនេះប្រាប់កូនៗជារឿយៗរាល់ពេលយើងជួបជុំគ្នា ។ ម៉ាក់និយាយអំពីប៉ា អំពីការរស់នៅក្នុងសង្គមរាស្ត្រនិយម របបសាធារណរដ្ឋខ្មែរ និងរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្វីដែលធ្វើឲ្យខ្ញុំក្រៀមក្រំចិត្តបំផុតនោះគឺការរស់នៅរបស់គ្រួសារខ្ញុំក្នុងសម័យប៉ុលពតនេះតែម្តង ។ ម៉ាក់ប្រាប់ថា ប៉ានិងម៉ាក់ជាគ្រូបង្រៀននៅសម័យសង្គមរាស្ត្រនិយម ជីវភាពគ្រួសាររស់នៅសមរម្យ ប៉ុន្តែដោយសារសង្គ្រាមទើបធ្វើឲ្យគ្រួសារយើងលំបាកវេទនាបែកបាក់គ្នាអស់ ។

ក្រោយពីប៉ាម៉ាក់ប្តូរប៉ុស្តិ៍ការងារទៅបង្រៀននិងរស់នៅក្នុងទីរួមខេត្តសៀមរាបនាសម័យ លន់ ណុល បានមួយរយៈ ប្រទេសជាតិក៏ធ្លាក់ក្នុងកណ្តាប់ដៃខ្មែរក្រហម គ្រួសារខ្ញុំត្រូវពួកអាវខ្មៅនេះជម្លៀសឲ្យទៅរស់នៅភូមិរលួស ឃុំដំដែក ស្រុកសូទ្រនិគម ខេត្តសៀមរាប ។ យើងរស់នៅទីនោះក្នុងនាមជាអ្នក១៧មេសា ។ អស់លោកដែលធ្លាប់ឆ្លងកាត់របបប៉ុលពតអាចដឹងបានថាតើអ្នក១៧មេសាលំបាកប៉ុនណា? គ្រួសារខ្ញុំរស់នៅក្រោមការគាបសង្កត់ មើលងាយ បន្ទិតបន្ទំ ធ្វើបាប ពីអ្នកមូលដ្ឋាននិងទាហានអាវខ្មៅរាល់ថ្ងៃ ពេលខ្លះយើងជួបការគំរាមកំហែងដោយសារខ្មែរក្រហមសង្ស័យថាគ្រួសារខ្ញុំជាគ្រូបង្រៀនជាបញ្ញាជន ជានាយទុន ទោះជាប៉ាប្រាប់ថាគ្រួសារយើងគ្រាន់តែជាអ្នកលក់ប្រហុកនៅក្នុងផ្សារសៀមរាបក៏ដោយ ក៏អ្នកទាំងនោះនៅតែសង្ស័យទៅលើប៉ាម៉ាក់ជានិច្ច ។ យើងធ្វើការច្រើនតែបានរបបហូបតិច ម៉ាក់មានការលំបាកច្រើនព្រោះពេលនោះម៉ាក់ពពោះរូបខ្ញុំផង ។

ម៉ាក់និយាយថា ពេលខ្ញុំកើតមកក្មាមមានសុខភាពល្អទេ ប៉ុន្តែដោយសារកង្វះចំណីអាហារបានធ្វើឲ្យសុខភាពខ្ញុំចុះខ្សោយជាលំដាប់ រហូតដល់ក្លាយជាទារកដែលខ្វះជីវជាតិ ក្បាលធំជាងខ្លួនរាងកាយស្គមតែឆ្អឹង ។ ខ្ញុំស្គមឆ្អឹងជំនីររាប់បាន ដើងខ្ញុំទាំងសងខាងមើលឃើញតែក្បាលជង្គង់ប៉ុណ្ណោះ ។ ម៉ាក់បន្ថែមទៀតថា ខ្ញុំយំអត់ឮសំឡេងទេ ។ ដោយសារខ្វះអាហារ ម៉ាក់គ្មានទឹកដោះឲ្យខ្ញុំបៅ រូបរាងកាយរបស់ម៉ាក់ក៏ស្គមណាស់ដែរ ហើយម្យ៉ាងទៀតម៉ាក់ត្រូវទៅធ្វើការនៅឆ្ងាយពីកូនៗទៀត ។

ខ្ញុំអាចរស់នៅរហូតមកដល់ថ្ងៃនេះក៏ដោយសារម៉ាក់យករបស់មានតម្លៃដែលគាត់លាក់ទុកបានបន្តិចបន្តួច ទៅដូរទឹកត្នោតក្រូចពោធិ៍សាត់ ឬអង្ករ ដែលមានតម្លៃកប់ពពក មកឲ្យខ្ញុំហូប ។ ក្រុមគ្រួសារយើងបែកបាក់គ្នាទាំងអស់ ។ បងស្រីទីមួយនិងទីពីររបស់ខ្ញុំត្រូវទៅរស់នៅកងចល័តមិនបាននៅផ្ទះជួបជុំគ្នាទេ ។ បងស្រីខ្ញុំប្រាប់ថា ពេលគាត់នឹកម៉ាក់ឬចង់មកលេងផ្ទះគឺត្រូវលួចមកនៅពេលយប់ ។ បងប្រាប់ថា ម្តងនោះ ព្រោះតែងងឹតខ្លាំងពេក គាត់បានវង្វេងផ្លូវនៅក្នុងព្រៃទៅចំកន្លែងដែលខ្មែរក្រហមសម្លាប់មនុស្ស ។ ពេលនោះគាត់ទាំងពីរនាក់ភ័យខ្លាំងណាស់គិតតែពីអង្គុយយំរហូតដល់ជិតភ្លឺ ។ បងស្រីទីពីរមានសម្លាកនៅលើថ្ងាសរហូតដល់សព្វថ្ងៃដោយសារគាត់យកគល់ចេកមួយដុំទៅដុតនៅចង្ក្រានបាយរបស់ចុងភៅ ហើយត្រូវកម្មាភិបាលខ្មែរក្រហមដឹងក៏ធ្វើបាបរករឿងសម្លាប់គាត់ចោល ។ បងនិយាយថា ដោយសារតែគាត់ស្រេកឃ្លានពេកទើបគាត់ហ៊ានធ្វើយ៉ាងនេះ ។ នៅសម័យនោះបងធ្លាប់ប្រាប់ម៉ាក់ថាបើបងបានហូបឆ្អែតតែមួយពេល ទោះជាឲ្យបងស្លាប់ក៏បងព្រមដែរ ។ នៅចំពោះមុខស្ថានភាពបែបនេះ ម៉ាក់បានត្រឹមតែសម្រក់ទឹកភ្នែកប៉ុណ្ណោះ ។ បងប្រុសទីបីរបស់ខ្ញុំដែលពេលនោះរស់នៅក្នុងកងកុមារ មានរាងកាយស្គមស្គាំង ។ អង្គការចាត់តាំងឲ្យគាត់ឃ្វាលគោនិងរើសអាចម៍គោ ។ បើគាត់បំពេញមិនបានតាមការកំណត់ទេ ត្រូវទទួលពិន័យដោយកាត់របបអាហារដែល

ជាធម្មតាគឺបបរមួយវែក ។ គាត់ត្រូវទៅឃ្វាលគោនៅទីឆ្ងាយៗ កាត់ភ្លៀងកាត់ខ្យល់ ។ ពេលរងាខ្លាំង បងចុះត្រាំក្នុងទឹកដើម្បីកុំឲ្យត្រូវខ្យល់រងា ។ ការរស់នៅក្នុងសភាពបែបនេះយូរធ្វើឲ្យគាត់ធ្លាក់ខ្លួនមានជំងឺជាប្រចាំ ហើយរហូតដល់សព្វថ្ងៃនេះសុខភាពរបស់គាត់តែងតែចុះខ្សោយជានិច្ចនិងមិនអាចធ្វើអ្វីធ្ងន់បានឡើយ ។ ប៉ាពុំបានរស់នៅជួបជុំកូនៗនិងម៉ាក់ទេ ព្រោះគាត់ត្រូវទៅធ្វើការឆ្ងាយ ។ យូរៗប៉ាលួចមកជួបម៉ាក់និងកូនៗម្តង ។ ម៉ាក់និយាយថាប៉ាក៏ស្គមណាស់ដែរ ប៉ាដើរស្ទើតែដួល ។ ប៉ាហូបមិនគ្រប់គ្រាន់ ប៉ុន្តែធ្វើការហួសកម្លាំង ។ ប៉ាជាមនុស្សគិតច្រើន ពេលប៉ាមកជួបម៉ាក់ គាត់តែងតែលួចនិយាយពីរឿងប្រទេសជាតិ ពីការលិចលង់នៃជាតិខ្មែរ ពីការយល់ខុសរបស់អ្នកដឹកនាំ ជាពិសេសប៉ាព្រួយបារម្ភអំពីអនាគតក្មេងជំនាន់ក្រោយ អំពីអនាគតរបស់កូនៗដែលពុំបានរៀនសូត្រនិងបាត់ឱកាសចូលសាលា ។

នៅឆ្នាំ១៩៧៩ នៅពេលដែលខ្មែរក្រហមដួលរលំ ប៉ាក៏បាត់ខ្លួនដែរ គឺបាត់ពេលយើងកំពុងចលាចល ។ ម៉ាក់និយាយថាគាត់ពុំហ៊ានទៅតាមរកប៉ាទេព្រោះគ្មានអ្នកណាមើលកូនៗ ម៉ាក់ខ្លាចដូចនាងបដាចា បើទៅរកប៉ាហើយបែរជាមិនឃើញ ពេលត្រលប់មកវិញបាត់កូនៗទៀតនោះ ម៉ាក់ពិតជាវិកលចរិតពុំខាន ។

តាំងពីពេលនោះមក ប៉ាបានបែកពីយើងរហូត ហើយខ្ញុំក៏មិនចាំមុខរបស់ប៉ាដែរ ។ ខ្ញុំតែងតែសង្ឃឹមថាប៉ានៅរស់ហើយត្រឡប់មកជួបកូនៗវិញ ប៉ុន្តែរហូតមកដល់ពេលនេះខ្ញុំមិនបានជួបប៉ាទេ ។ ខ្ញុំមានរូបថតរបស់ប៉ាតែមួយសន្លឹកគត់ដែលអាចឲ្យខ្ញុំចំណាំមុខប៉ាបាន ។ តើឈើចាប់ប៉ុនណាក្នុងការរស់នៅជាក្មេងកំព្រា? ពេលយើងមកដល់ស្រុកកំណើតរបស់ម៉ាក់នៅខេត្តស្ទឹងត្រែងវិញ ទើបយើងដឹងថា សាច់ញាតិរបស់យើងជាច្រើនបានស្លាប់ ខ្លះដោយសារអត់អាហារនិងខ្លះទៀតដោយសារអង្គការយកទៅសម្លាប់ចោលដោយចោទថាជាខ្មាំងរបស់អង្គការជាជនក្បត់ ជាសេ.អ៊ី.អា ជាកា.ហ្សេ.បេ ។ ក្រុមគ្រួសាររបស់ប៉ាក៏ស្លាប់ស្ទើរអស់រួមទាំងប៉ាផង ។

របប ប៉ុល ពត បានធ្វើឲ្យខ្ញុំបែកបាក់ក្រុមគ្រួសារ ។ របប ប៉ុល ពត បានធ្វើឲ្យប៉ាខ្ញុំស្លាប់ ។ របបនេះហើយដែលធ្វើឲ្យគ្រួសារខ្មែរនិងកូនខ្មែរជាច្រើនបែកបាក់សាច់ញាតិ ជីវិតគ្រួសារត្រូវបានផ្លាស់ប្តូរយ៉ាងគំហុកមករកភាពវេទនាក្រលំបាកអស់ជាច្រើនទសវត្សរ៍ស្ទើរតែថ្លែងពុំបាន ។ វិបត្តិផ្លូវចិត្ត ទុក្ខសោកក្រៀមក្រំ ការឈឺចាប់ដោយសារត្រូវរស់នៅជាក្មេងកំព្រាតាំងតែពេលដឹងក្តីមក បានដិតដាមក្នុងអារម្មណ៍របស់ខ្ញុំរហូតមក វាមិនអាចលុបបាត់ពីខួរក្បាលខ្ញុំទេ ។ ដូចអ្វីដែលប៉ាបារម្ភមែន បងៗទាំងបីនាក់របស់ខ្ញុំពុំបានរៀនសូត្រច្រើននោះទេដោយសារជីវភាពក្រោយថ្ងៃរំដោះយើងជួបការលំបាកច្រើន បងៗត្រូវចេញទៅធ្វើការដើម្បីជួយម៉ាក់ទប់ទល់ជីវភាពដែលបានមួយថ្ងៃរស់មួយថ្ងៃ ។ តើនេះជាកម្មពៀរដែលយើងបានសាងពីអតីតជាតិឬ? តើកូនខ្មែរទាំងអស់ដែលនៅរស់រានមានជីវិតសព្វថ្ងៃនេះសុទ្ធតែមានកម្មពៀរឬ? យើងមានកំហុសអ្វីទើបធ្វើឲ្យយើងបែកបាក់គ្រួសារយ៉ាងនេះ?

រដ្ឋាភិបាលថ្មីដែលកើតចេញពីឆន្ទៈប្រជារាស្ត្រត្រូវតែរកយុត្តិធម៌ដល់ប្រជារាស្ត្រផង ពុំគួរទុកឲ្យពេលវេលាកន្លងទៅយ៉ាងយូរ ដោយទុកឲ្យជនដៃដល់រស់នៅដោយភាពសុខស្រួលលើគំនរឈាមប្រជារាស្ត្រយ៉ាងអយុត្តិធម៌បែបនេះទេ ។ យុត្តិធម៌អាចធ្វើឲ្យខ្ញុំ គ្រួសារខ្ញុំ និងប្រជារាស្ត្រខ្មែរដែលជាជនរងគ្រោះជាច្រើន បានស្ងប់អារម្មណ៍ខ្លះ ។ វាពុំមែនជាការសងសឹកទេ ប៉ុន្តែវាជាលទ្ធផលដែលមេដឹកនាំខ្មែរក្រហមបានសាងតែប៉ុណ្ណោះ ។ អ្វីដែលអ្នកបានសាង អ្នកត្រូវតែទទួល ហើយវាក៏ជាគំរូមួយកុំឲ្យមនុស្សជំនាន់ក្រោយយកទង្វើដ៏ឈឺចាប់នេះមកប្រើទៀត ។

**ហឿ សេធុល**

# ស្តាប់ប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣ៈ៣០-៣ៈ៤៥នាទី តាមរយៈវិទ្យុ ១០២ MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា ។

ផាត រចនា និង លី សុផល

# ភ្លើងគំនុំដែលមិនអាចបំភ្លេចបាន

ទោះបីជាពេលវេលាវិវឌ្ឍទៅមុខជិត៣០ឆ្នាំក៏ពិតមែន តែរឿងដែលធ្វើឲ្យប្រជាពលរដ្ឋខ្មែរទទួលរងការឈឺចាប់នោះពិតជាគ្មានថ្ងៃបំភ្លេចបានឡើយ ។ គ្មាននរណាម្នាក់យល់បានឬក៏ដឹងជាមុនថាប្រទេសកម្ពុជានឹងក្លាយទៅជាប្រទេសដែលគ្រប់គ្រងទៅដោយចោរព្រៃខ្មែរក្រហមនៅក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ឡើយ ។ ខ្មែរគ្រប់គ្នាក៏បានយល់ក្រោយពេលដែលរបបសេរីនិយមរបស់លោក លន់ ណុល ដួលរលំ តែអ្វីៗសុទ្ធតែជារឿងប្រែប្រួលធ្វើឲ្យខកចិត្តទាំងអស់ ។ រយៈពេលពីឆ្នាំ១៩៧០-៧៥ សង្គ្រាមរវាងខ្មែរក្នុងស្រុកនិងខ្មែរនៅព្រៃមានសកម្មភាពនិងវិវឌ្ឍឥតឈប់ឈរ រហូតធ្វើឲ្យប្រជាពលរដ្ឋនៅតាមស្រុកស្រែចម្ការទីជនបទឆ្ងាយៗខ្លះត្រូវបោះបង់ចោលទីកន្លែងរស់នៅរបស់ខ្លួនរត់ចូលមកជ្រកក្នុងទីក្រុងដោយនឹកស្មានថានឹងបានរួចផុតពីការស្លាប់ដោយគ្រាប់កាំភ្លើង ។

ក្នុងពេលដែលពួកខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា សកម្មភាពប្រយុទ្ធគ្នាបានចុះថយបន្តិច ប៉ុន្តែអាយុជីវិតរបស់ប្រជាពលរដ្ឋខ្មែរកាន់តែត្រូវសម្លាប់យ៉ាងរង្គាលតាមរយៈការបង្អត់បាយ ការបង្ខំឲ្យធ្វើការធ្ងន់ហួសកម្លាំងនិងគ្មានពេលសម្រាកមិនថាយប់ឬថ្ងៃ ថែមទាំងវាយដំលើរាងកាយដោយឥតមូលហេតុក៏មាន ។ ចំពោះរូបនាងខ្ញុំផ្ទាល់ ខ្ញុំនៅចងចាំជាប់ជានិច្ចនូវសោកនាដកម្មដែលក្រុមគ្រួសារនាងខ្ញុំបានទទួល ។ ឪពុកម្តាយនាងខ្ញុំត្រូវស្លាប់ដោយការបង្អត់អាហារ បងប្អូនប្រុសស្រីត្រូវស្លាប់ដោយសារធ្វើការហួសកម្លាំងគ្មានអ្វីបរិភោគគ្រប់គ្រាន់ ។ នៅពេលចុងក្រោយគឺនៅឆ្នាំ៧៩ នាងខ្ញុំដឹងថានៅមានក្មួយស្រីម្នាក់ទៀតនៅរស់ តែរហូតមកទល់ពេលនេះនៅតែមិនឮដំណឹងអ្វីដដែល ។ ខ្ញុំសន្មតថាបើក្មួយខ្ញុំនៅរស់ នាងប្រាកដជាមករកខ្ញុំហើយ ។ ពេលចាកចេញពីក្រុងភ្នំពេញ ក្រុមគ្រួសារនាងខ្ញុំមានសមាជិកជាង២០នាក់ តែពេលត្រឡប់មកស្រុកវិញនៅឆ្នាំ៧៩ នៅសល់តែពីរនាក់ប៉ុណ្ណោះ ។ ការលំបាកវេទនាគ្រប់បែបយ៉ាងដែលនាងខ្ញុំបានជួប រាប់ចាប់តាំងពីពេលរែកពុនអីវ៉ាន់ចេញពីផ្ទះរហូតទៅដល់ព្រៃមួយក្នុងខេត្តបាត់ដំបង ដែលនៅទីនោះសមាជិកក្រុមគ្រួសារខ្ញុំត្រូវស្លាប់ជាបន្តបន្ទាប់ ។ នាងខ្ញុំគិតថាការរស់នៅម្នាក់ឯងគឺត្រូវប្រឈមមុខចំពោះហេតុការណ៍គ្រប់បែបយ៉ាង ហើយត្រូវប្រឹងប្រែងតស៊ូទើបអាចជួយខ្លួនឯងបាន ។ ការសោកស្តាយរបស់នាងខ្ញុំគឺក្រុមគ្រួសារដែលធ្លាប់រស់នៅជួបជុំគ្នា តែពេលនេះអ្វីៗត្រូវប្រែប្រួលទាំងអស់ ។ នាងខ្ញុំគិតហើយគិតទៀតថា បើគ្មានរបបខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជាក្នុងរយៈពេលជាងបីឆ្នាំនោះ ក៏ខ្ញុំមិនបាត់បង់ក្រុមគ្រួសារខ្ញុំដែរ ថ្វីដ្បិតតែថាបើទុកជាឪពុកម្តាយខ្ញុំនៅរស់ក៏មិនអាចរស់ដល់សព្វថ្ងៃពិតមែនក្តី ក៏ខ្ញុំមានបងៗរបស់ខ្ញុំអាចនៅមានជីវិតសេសសល់ខ្លះដែរ ។

ដោយសារតែព្រឹត្តិការណ៍នេះហើយទើបនាងខ្ញុំហ៊ាននិយាយថា “ជាប់ខាតត្រូវតែកាត់ទោស” ខ្មែរក្រហមដែលនៅរស់ទាំងប៉ុន្មាន រួមទាំងដៃជើងរបស់ពួកនោះផងដើម្បីឲ្យស័ក្តិសមនឹងអំពើដែលគេបានធ្វើ ជាប់ខាតមិនត្រូវលើកលែងសោះឡើយ ទោះបីជាត្រូវអូសបន្លាយពេលយូរតទៅទៀតក្តី ។ ទាំងរូបគេទាំងរូបខ្ញុំ ចង់ឃើញការកាត់ទោសនេះខ្លាំងណាស់ ទោះបីជាខ្ញុំដឹងថាព្រះមិនឲ្យសងសឹកទល់នឹងមនុស្សអាក្រក់បែបនេះក៏ដោយ ប៉ុន្តែការស្តាយស្រណោះអាឡោះអាល័យ ការខ្លោចផ្សារចិត្តចេះតែធ្វើឲ្យអារម្មណ៍របស់ខ្ញុំនឹកឃើញពីការធ្វើទារុណកម្មមកលើមនុស្សដែលមានឈាមជ័រដូចគ្នា ។ ខ្ញុំមិនចង់យកកំហឹងទៅទល់នឹងកំហល់នោះទេ ប៉ុន្តែខ្ញុំគ្មានផ្លូវសម្រាប់ជ្រើសរើសឬវិធីផ្សេងទៀតសោះឡើយ ។ កំហឹងរឹតតែកើនឡើងថែមទៀតចំពោះការសម្លាប់នៅតាមមន្ទីរឃុំឃាំងនីមួយៗមានជាអាទិ៍គឺគុកទួលស្លែងនេះឯងដែលខ្ញុំបានទៅទស្សនាក្រោយឆ្នាំ៧៩ ។ គ្រប់រូបភាពដែលនៅក្នុងគុកនោះរឹតតែសង្កត់ធ្ងន់ថែមទៀតលើកំហឹងក្រេវក្រោធរបស់ខ្ញុំ ព្រោះតែអ្នកស្លាប់នៅក្នុងគុកនោះគឺស្លាប់ដោយគេបង្ខំមិនថាចាស់ឬក្មេង ។ តើនៅមានអ្វីទៀតដែលត្រូវឲ្យយើងលើកលែងនោះ?

ទោះបីជាតុលាការកាត់ទោសមេខ្មែរក្រហមជាតុលាការជាតិក្តី អន្តរជាតិក្តី ជាប់ខាតគឺត្រូវតែមាន ដើម្បីបើកការសម្រេច

ក្តីនេះ ដើម្បីឲ្យប្រជាពលរដ្ឋខ្មែរដែលនៅរស់មានទឹកចិត្តនិងមានសង្ឃឹមឡើងវិញ ។ ខ្មែរក្រហមបានបំផ្លាញសេចក្តីសុខរបស់ពលរដ្ឋខ្មែរ រួមទាំងសេចក្តីសុខរបស់ក្រុមគ្រួសារខ្ញុំផង ដែលមិនអាចឲ្យខ្ញុំនិយាយចេញមកនូវពាក្យថាអត់ឱនបានសោះឡើយ ។ ខ្ញុំត្រូវការឲ្យវិញ្ញាណក្ខន្ធក្រុមគ្រួសារខ្ញុំបានទៅកាន់សុគតិភព ។ ខ្ញុំមិនត្រឹមតែចាំទុកនោះទេ ខ្ញុំថែមទាំងនិយាយរឿងប្រវត្តិសាស្ត្រនេះឲ្យកូនចៅខ្ញុំស្តាប់ថែមទៀត ព្រោះខ្ញុំមិនចង់ឲ្យកូនចៅខ្ញុំជួបប្រទះហេតុការណ៍អាក្រក់បែបនេះដូចជំនាន់ខ្ញុំទេ ។ ការបណ្តេញប្រជាពលរដ្ឋខ្មែរឲ្យចេញពីទីក្រុងទៅកាន់ទីជនបទរបស់ក្រុមខ្មែរក្រហមនោះ គឺជារឿងគំនុំគុំកួនរបស់បុគ្គលច្រើនជាងរឿងអ្វីទាំងអស់ ។ ដូច្នេះសរុបសេចក្តីទៅ ការឲ្យគេឈប់គិតពីរឿងកាត់ទោសពិតជាមិនអាចទៅរួចឡើយ ។ ទាំងពលរដ្ឋខ្មែរទាំងរូបខ្ញុំ មិនមានអ្វីដែលត្រូវធ្វើសម្បទានដួងចិត្តឲ្យដល់ពួកខ្មែរក្រហមនោះទេ ។ ថ្វីដ្បិតតែខ្មែរក្រហមជាខ្មែរដូចខ្ញុំក៏ដោយ ប៉ុន្តែផ្នត់គំនិតមានលក្ខណៈខុសគ្នាឆ្ងាយណាស់ ។ ខ្មែរក្រហមជាក្រុមដែលស្រលាញ់អំណាច បុណ្យស័ក្តិ ជាការចង់បានតាមរបៀបឆ្កួតលេលាដែលប្រវត្តិសាស្ត្រពិភពលោកគ្មានអ្នកណាដែលជួបប្រទះសោះ ។ បដិវត្តន៍របស់ខ្មែរក្រហមគឺកាត់បន្ថយអ្នកមានតែបង្កើនអ្នកក្រទៅវិញ ។ នេះហើយជាភ្លើងគំនុំចាស់ដែលមិនអាចបំភ្លេច មិនអាចផ្សះផ្សា មិនអាចលើកលែង ដូច្នេះយើងត្រូវសងវិញនូវតុលាការមួយសម្រាប់ជម្រះក្តីមេដឹកនាំខ្មែរក្រហម ដើម្បីកុំឲ្យអ្នកដឹកនាំជំនាន់ក្រោយធ្វើដូចខ្មែរក្រហមទៀត ។ **គីម សុផានី**

# សេចក្តីប្រកាសរកឪពុកម្តាយ


សន គីណាល់ បច្ចុប្បន្ន

ខ្ញុំបាទឈ្មោះ សន គីណាល់ (ឈ្មោះដើម ស្រេង គីណាល់) កើតនៅឆ្នាំ១៩៧២ សព្វថ្ងៃជាបុគ្គលិកមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ។ ខ្ញុំបាទសូមសួររកឪពុកឈ្មោះ ហុក ឆាយស្រេង និងម្តាយឈ្មោះ ឈួន លាងវួច ដែលបានបាត់ដំណឹងតាំងពីរបបខ្មែរក្រហម មិនដឹងជាលោកទាំងពីរស្លាប់ឬរស់ ។

មុនរបបខ្មែរក្រហម ឪពុករបស់ខ្ញុំជា PM អាវុធហត្ថប្រចាំការនៅប៉ុស្តិ៍អណ្តូងចេញ ខេត្តបាត់ដំបង ។ ម្តាយរបស់ខ្ញុំជាសាស្ត្រាចារ្យនៅវិទ្យាល័យស្វាយប៉ោ (បច្ចុប្បន្នវិទ្យាល័យនេតយ៉ង់) ។ ផ្ទះរបស់គាត់នៅជាប់នឹងរោងកុនប្រាសាទមាស ផ្លូវលេខ១កន្លះ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។ ខ្ញុំបាទជាកូនទោល ។

នៅខែមេសា ឆ្នាំ១៩៧៥ ឪពុករបស់ខ្ញុំបានទៅទទួលសម្តេចនៅភ្នំធិបដេ (ភ្នំធិបតី) ក្នុងខេត្តបាត់ដំបង តាមការអំពាវនាវរបស់ខ្មែរក្រហម ហើយគាត់ក៏បាត់ខ្លួនតាំងពីពេលនោះមក ។ ចាស់ៗបាននិយាយប្រាប់ខ្ញុំថា ឪពុករបស់ខ្ញុំត្រូវខ្មែរក្រហមសម្លាប់នៅភ្នំធិបដេទៅហើយ ។ ចំណែកម្តាយខ្ញុំនិងខ្ញុំត្រូវខ្មែរក្រហមជម្លៀសទៅនៅភូមិស្រះកែវ ស្រុកសង្កែ ខេត្តបាត់ដំបង ។ អំឡុងឆ្នាំ១៩៧៧ ក្រោយពីស៊ើបដឹងថាម្តាយរបស់ខ្ញុំជាអតីតសាស្ត្រាចារ្យ ខ្មែរក្រហមក៏ស្វែងរកចាប់ម្តាយខ្ញុំយកទៅសម្លាប់ ។ ម្តាយខ្ញុំភ័យរន្ធត់ជាខ្លាំង ។ គាត់បានយកខ្ញុំទៅផ្ញើនឹងពេទ្យឆ្មបម្នាក់ឈ្មោះ សន យ៉ែន ហើយគាត់បានរត់គេចខ្លួនទៅតាមភ្នំចាក់អង្រ្កាម បាត់ដំណឹងរហូតដល់សព្វថ្ងៃ ។ ចាប់ពីពេលនោះមក ខ្ញុំរស់នៅជាមួយបងធម៌ឈ្មោះ សន យ៉ែន និងម្តាយធម៌ឈ្មោះ គេះ យ៉ុង រហូតដល់បច្ចុប្បន្ន នៅភូមិក្បាលថ្នល់ ឃុំរាំងកេសី ស្រុកសង្កែ ខេត្តបាត់ដំបង ។


ឪពុកម្តាយរបស់ សន គីណាល់ ក្នុងថ្ងៃរៀបការ

ប្រសិនបើលោក-លោកស្រីបានទទួលពត៌មានដែលទាក់ទងដល់ឪពុកម្តាយរបស់ខ្ញុំបាទ សូមមេត្តាផ្តល់ដំណឹងមកខ្ញុំបាទតាមរយៈមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ផ្ទះលេខ ១៩ ផ្លូវលេខ៥៧ សង្កាត់បឹងកេងកង រាជធានីភ្នំពេញ ឬតាមទូរស័ព្ទលេខ ០១៦ ៩៧៥ ៣៧៤ ឬ ០១២ ៨៤២ ២១៥ ។ សូមអរគុណ ។




ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់តម្លៃ ៧០០០រៀល


*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។*
*ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 50, February 2004.**
**Funded by Germany, Norway, Sweden, the Netherlands, and USA.**